**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economies**

**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងបរិស្ថាន

ស្រាវជ្រាវពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **ភាព មូផា**

កញ្ញា **ជ័រ ស្រីណយ**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត ឈុន ណារ៉ែត**

ថ្នាក់បរិញ្ញាបត្រ រដ្ឋបាលសាធារណៈ

ជំនាន់ទី១៥

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

ជាបឋម យើងខ្ញុំទាំងពីរឈ្មោះ **ភាព មុន្នី** និង **ជ័រ ស្រីណាយ** ជានិស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែករដ្ឋបាលសាធារណៈ ឆ្នាំទី៤ ឆមាសទី២ជំនាន់ទី១៥ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមលំឱនកាយក្រាបថ្វាយបង្គំដោយកិច្ចប្រណិប័តន៍សម្តែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតចំពោះ លោកឪពុក **ហ៊ិន សុភាព** អ្នកម្តាយ **ម៉េង សាំ** និងលោកឪពុក **សែម ផល្លី** និងអ្នកម្តាយ **ឃុត នាង** ដែលបានផ្តល់កំណើតចិញ្ចឹមបីបាច់ ថែរក្សា អប់រំ ទូន្មាន ប្រៀនប្រដៅ ណែនាំ និងការឧបត្ថម្ភទំនុកបម្រុងគ្រប់បែបយ៉ាងទាំងធនធានថវិកា និងសម្ភារៈ ព្រមទាំងបណ្តុះនូវស្មារតី តស៊ូ អំណត់ព្យាយាម ក្នុងការសិក្សារៀនសូត្រ រហូតដល់កូនមានឱកាសបានសិក្សាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ដោយលោកខិតខំ ពុះពារ ជំនះរាល់គ្រប់ឧបសគ្គដោយមិនខ្លាចនឿយហត់ដើម្បីឱ្យកូនបានសិក្សារៀនសូត្រ មានចំណេះដឹងខ្ពង់ខ្ពស់ ដើម្បីក្លាយជាទំពាំងស្នងឫស្សីដ៏ល្អសម្រាប់សង្គមជាតិ។ បន្ថែមពីនេះ ក៏សូមថ្លែងអំណរគុណដល់ លោក លោកស្រី និងសាស្ត្រាចារ្យទាំងអស់ដែលបានខិតខំផ្ទេរនូវចំណេះដឹង ដោយមិនខ្លាចនឿយហត់ និងជួយសម្របសម្រួលផ្នែកឯកសារ ទិន្នន័យ ស្មារតី សម្ភារៈផ្សេងៗ ដែលជាការរួមចំណែកមួយយ៉ាងសំខាន់ដល់យើងខ្ញុំក្នុងការបន្តការសិក្សា និងឈានដល់សរសេរសារណាប្រកបដោយជោគជ័យ សូមថ្លែងអំណរគុណចំពោះ ៖

- ឯកឧត្តម **លុយ ចន្ណា** ជាសាកលវិទ្យាធិការ រួមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង គណៈគ្រប់គ្រងទាំងអស់ដែលបានសម្របសម្រួលរាល់តម្រូវការនៃការសិក្សារបស់និស្សិតគ្រប់ជំនាន់
- លោកសាស្ត្រាចារ្យបណ្ឌិត **ឈុន ណារ៉េត** ជាសាស្ត្រាចារ្យណែនាំក្នុងដំណើរការនៃការសរសេរសារណាដែលបានចំណាយពេលវេលាដ៏មានតម្លៃបង្ហាត់បង្ហាញ អប់រំ ណែនាំ ផ្តល់ឯកសារ និងត្រួតពិនិត្យនូវរាល់ចំណុចខ្វះខាតព្រមទាំងកែលម្អយ៉ាងយកចិត្តទុកដាក់
- ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន រួមទាំងថ្នាក់ដឹកនាំចំណុះអគ្គនាយកដ្ឋាននានា ព្រមទាំងថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ទាំងអស់ដែលបានអនុញ្ញាត និងផ្តល់ឱកាសដល់យើងខ្ញុំបានចុះស្រាវជ្រាវឯកសារដើម្បីទទួលបាននូវចំណេះដឹង និងការអនុវត្តជាក់ស្តែង រួមទាំងផ្តល់នូវឯកសារជាជំនួយដល់ការស្រាវជ្រាវរបស់យើងខ្ញុំ
- លោក **ខឹម សុវណ្ណា** ប្រធាននាយកដ្ឋានធនធានមនុស្ស ដែលផ្តល់ការអនុញ្ញាតដល់យើងខ្ញុំទាំងពីរ
- លោក **រស់ សុវណ្ណ** អនុប្រធាននាយកដ្ឋានធនធានមនុស្ស រួមទាំងមន្ត្រីក្របខណ្ឌ និងមន្ត្រីជាប់កិច្ចសន្យាទាំងអស់ដែលស្ថិតនៅក្រោមនាយកដ្ឋានធនធានមនុស្សផងដែរ។

ជាចុងក្រោយយើងខ្ញុំសូមថ្លែងអំណរគុណ និងគោរពជូនពរលោកអ្នកទាំងអស់មានសុខភាពល្អ ព្រមទាំងសម្រេចនូវគ្រប់ភារកិច្ច និងជួបតែសេចក្តីសុខចម្រើន ជានិច្ចនិរន្ត។

# អារម្ភកថា

ប្រទេសកម្ពុជាទទួលបានសុខសន្តិភាពពេញលេញ និងរក្សាបានបូរណភាពទឹកដី សាមគ្គីភាពជាតិ ស្ថិរភាពនយោបាយ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមតាមរយៈនយោបាយឈ្នះ-ឈ្នះ។ ការអនុវត្តកម្មវិធីកំណែទម្រង់ស៊ីជម្រៅបានធ្វើឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈមានការផ្លាស់ប្តូរកាន់តែល្អប្រសើរ និងសមិទ្ធផលជាច្រើនត្រូវសម្រេចបានក្នុងរយៈពេលដ៏ខ្លី។ ដោយមានការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការកសាង ដឹកនាំប្រទេសលើគ្រប់វិស័យ បានជំរុញឱ្យសេដ្ឋកិច្ចកម្ពុជាមានការរីកចម្រើន។

អាស្រ័យហេតុនេះហើយ យើងខ្ញុំបានជ្រើសរើសសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រក្រោមប្រធានបទស្តីពី **ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងបរិស្ថាន**។ ដោយសារតែក្រសួងបរិស្ថាន ជាស្ថាប័នមួយដែលជាសេនាធិការដ៏សំខាន់របស់រាជរដ្ឋាភិបាល ក្នុងការរួមចំណែកកសាង ស្តារ និងធ្វើឱ្យប្រទេសជាតិឆ្ពោះទៅរកភាពស្រស់បំព្រង ភូមិ ឃុំ សហគមន៍ ទីជនបទមានការរីកចម្រើននឹងអភិវឌ្ឍន៍តាមរយៈការទៅចូលរួមកំសាន្តពីគ្រប់មជ្ឈដ្ឋាន។ វាពិតជាសំខាន់ណាស់ ដែលប្រជាជនគ្រប់រូបត្រូវគិតអំពីបញ្ហាបរិស្ថានទាំងការចូលរួមថែរក្សា ការការពារ អភិរក្ស គ្រប់គ្រង ទុកដាក់ ធ្វើយ៉ាងណាឱ្យមានភាពល្អប្រសើ ដើម្បីឆ្លើយតបទៅនឹងការអភិវឌ្ឍន៍តាមបែបសេដ្ឋកិច្ចបៃតង។ ហេតុនេះ រាជរដ្ឋាភិបាល ក៏ដូចជាថ្នាក់ដឹកនាំ បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រនានាព្រមទាំងបង្កើតឱ្យមានច្បាប់ជាច្រើនពាក់ព័ន្ធទៅនឹងវិស័យបរិស្ថាន ដែលជាការរួមចំណែកក្នុងការធ្វើឱ្យប្រជាជនគ្រប់រូបយល់ដឹងកាន់តែច្បាស់អំពីបរិស្ថាន។

ទន្ទឹមនឹងនេះ ទោះបីជាយើងខ្ញុំខិតខំពិនិត្យឡើងវិញនូវខ្លឹមសារ និងពាក្យពេចន៍ច្រើនដងហើយក៏ពិតមែនប៉ុន្តែចំណុចខ្វះខាត ខ្វះចន្លោះក៏នៅតែកើតមានចំពោះឯកសារមួយនេះដោយជៀសមិនរួច និងមិនទាន់គ្រប់ជ្រុងជ្រោយពេញលក្ខណៈនៅឡើយទេ អាស្រ័យហេតុនេះយើងខ្ញុំសូមអភ័យទោសផងដែរ រាល់កំហុសឆ្គងឬភាពខ្វះខាតទាំងឡាយដែលកើតមានដោយអចេតនានៅក្នុងសារណានេះ សូមសាស្ត្រាចារ្យ មិត្តនិស្សិតនិងមិត្តអ្នកអានទាំងអស់មេត្តាអធ្យាស្រ័យយើងខ្ញុំត្រៀមទទួលយកការិះគន់ទាំងឡាយក្នុងន័យកែលម្អ និងស្ថាបនាដើម្បីឱ្យយើងខ្ញុំអាចកែប្រែកំហុសទាំងអស់នោះសម្រាប់ឱ្យការស្រាវជ្រាវកាន់តែមានភាពល្អប្រសើរឡើង។

ជាចុងក្រោយយើងខ្ញុំសង្ឃឹមនិងជឿជាក់យ៉ាងមុតមាំថាប្រធានបទសារណាស្តីពី**ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងបរិស្ថាន** នេះនឹងក្លាយជាឯកសារស្រាវជ្រាវដ៏មានតម្លៃដល់មជ្ឈដ្ឋានអ្នកស្រាវជ្រាវក៏ដូចជាសិស្សនិស្សិតមិត្តអ្នកអានទាំងអស់គ្នាជាក់ជាមិនខានឡើយ។

# មាតិកា

**ទំព័រ**

បញ្ជីរូបភាព..................................................iv

## សេចក្តីផ្តើម

១. លំនាំបញ្ហា ..................................................១
២. ចំណោទបញ្ហា ..................................................២
៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ..................................................៣
៤. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ..................................................៣
៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ..................................................៤
៦. វិធីសាស្រ្តនៃការសិក្សាស្រាវជ្រាវ ..................................................៥
៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ ..................................................៦

## ជំពូកទី១
## រំលឹកទ្រឹស្តី

១.១ រំលឹកទ្រឹស្តី ..................................................៨
១.២ ប្រវត្តិរបស់ក្រសួងបរិស្ថាន ..................................................៨
១.២.១ ប្រវត្តិនៃការកកើតរបស់ក្រសួងបរិស្ថាន..................................................៨
១.២.២ ទីតាំងរបស់ក្រសួងបរិស្ថាន..................................................៩
១.២.៣ ស្លាកសញ្ញា និងអត្ថន័យនៃក្រសួងបរិស្ថាន ..................................................៩
១.២.៤ ចក្ខុវិស័យ គោលបំណង និងវប្បធម៌ការងារ របស់ក្រសួងបរិស្ថាន ..................................................៩
១.២.៤.១ ចក្ខុវិស័យរបស់ក្រសួងបរិស្ថាន..................................................៩
១.២.៤.២ គោលបំណងរបស់ក្រសួងបរិស្ថាន .................................................. ១០
១.២.៤.៣ វប្បធម៌ការងារ.................................................. ១០
១.៣ បេសកកម្មរបស់ក្រសួងបរិស្ថាន .................................................. ១០
១.៤ តួនាទី និងភារកិច្ច របស់ក្រសួងបរិស្ថាន.................................................. ១០
១.៥ រចនាសម្ព័ន្ធរបស់ក្រសួងបរិស្ថាន.................................................. ១២

## ជំពូកទី២

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

២.១ អង្គភាពថ្នាក់ជាតិ ........ ១៤

២.១.១ ខុទ្ទកាល័យរដ្ឋមន្ត្រី ........ ១៤

២.១.២ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ........ ១៥

២.១.៣ អគ្គនាយកដ្ឋានគោលនយោបាយ និងយុទ្ធសាស្ត្រ ........ ១៨

២.១.៤ អគ្គនាយកដ្ឋានគាំពារបរិស្ថាន ........ ២១

២.១.៥ អគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិ ........ ២៥

២.១.៦ អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន ........ ២៨

២.១.៧ អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ........ ៣០

២.១.៨ អគ្គាធិការដ្ឋាន ........ ៣២

២.១.៩ នាយកដ្ឋានសវនកម្មផ្ទៃក្នុង ........ ៣៣

២.១.១០ នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ........ ៣៣

២.២ អង្គភាពថ្នាក់ក្រោមជាតិ ........ ៣៤

២.៣ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ ........ ៣៤

## ជំពូកទី៣

## សមិទ្ធផល បញ្ហាប្រឈម ដំណោះស្រាយ

៣.១ សមិទ្ធផល ........ ៣៥

៣.១.១ លទ្ធផលការងារសម្រេចបាន ........ ៣៥

៣.១.១.១ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ........ ៣៥

៣.១.១.២ អគ្គនាយកដ្ឋានគោលនយោបាយនិងយុទ្ធសាស្ត្រ ........ ៣៦

៣.១.១.៣ អគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិ ........ ៣៧

៣.១.១.៤ អគ្គនាយកដ្ឋានគាំពារបរិស្ថាន ........ ៣៨

៣.១.១.៥ អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន ........ ៣៨

៣.១.១.៦ អគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន ........ ៣៩

៣.១.២ ការពង្រឹងអភិបាលកិច្ចល្អ និងកិច្ចគាំពារមន្ត្រីរាជការ ........ ៤០

៣.១.៣ ទិសដៅការងារ២០២២ ........ ៤១

៣.២ បញ្ហាប្រឈម ..... ៤៥
៣.២.១ កិច្ចគាំពារបរិស្ថាន ..... ៤៥
៣.២.២ ការងារគ្រប់គ្រងនិងអភិរក្សធនធានធម្មជាតិ ..... ៤៥
៣.២.៣ ការងារគ្រប់គ្រងដោយចីរភាព ..... ៤៦
៣.២.៤ ការងារការគ្រប់គ្រងចំណេះដឹងនិងព័ត៌មានបរិស្ថាន ..... ៤៦
៣.២.៥ សេវាគាំទ្របរិស្ថាន និងធនធានធម្មជាតិ ..... ៤៦
៣.៣ ដំណោះស្រាយ ..... ៤៦
៣.៣.១ វិធានការច្បាប់ ..... ៤៦
៣.៣.២ ពង្រឹង និងពង្រីកការផ្សព្វផ្សាយ ..... ៤៧
៣.៣.៣ ការផ្តល់ជាមធ្យោបាយ ..... ៤៧
៣.៣.៤ ការបញ្ជ្រាបចំណេះដឹង ..... ៤៧
៣.៣.៥ វិធានការការពារ និងទប់ស្កាត់ ..... ៤៨
**សេចក្តីសន្និដ្ឋាន** ..... ៥០
**អនុសាសន៍** ..... ៥២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីរូបភាព

រូបភាពទី១ រចនាសម្ព័ន្ធរបស់ក្រសួងបរិស្ថាន ............................................................................ ១២
រូបភាពទី២ អង្គការលេខរបស់អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង...................................................... ៣៣

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ប្រទេសកម្ពុជា ជាប្រទេសមួយដែលបានឆ្លងកាត់ភ្លើងសង្គ្រាមស៊ីវិលអស់រយៈពេលជាងបីទសវត្សរ៍មកហើយ ព្រមទាំងស្ថិតនៅក្រោមអាណានិគមរបស់ប្រទេសមហាអំណាចមួយចំនួនផងដែរ។ មិនត្រឹមតែប៉ុណ្ណោះ ធ្វើឱ្យប្រទេសកម្ពុជា ស្ទើរតែបាត់បង់ទាំងស្រុងនូវ ហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្ស ប្រព័ន្ធនយោបាយ វប្បធម៌ ប្រពៃណីនិងទំនៀមទំលាប់ការសិក្សាអប់រំ ដែលទាំងអស់នេះសុទ្ធសឹងតែជាចលករដ៏សំខាន់និងជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ។ ក្នុងន័យនេះ សង្គ្រាមក៏បានបំផ្លិចបំផ្លាញនូវ ធនធានធម្មជាតិ វត្ថុធាតុដើម ជីវៈចម្រុះ បញ្ហាបរិស្ថាន បរិយាកាស អាកាសធាតុ និងព្រៃឈើដែលជាជម្រកដ៏សំខាន់សម្រាប់មនុស្ស សត្វ និងរុក្ខជាតិ ដែលជាក់ស្តែងពីដើមឡើយធនធានធម្មជាតិ និងព្រៃឈើកកើតឡើងដោយធម្មជាតិយ៉ាងច្រើនពេញផ្ទៃប្រទេស ដោយបានផ្តល់សារៈសំខាន់ជាច្រើនដល់សង្គមមនុស្សនិងពិភពលោក។ ក្រោយមកដោយសារតែការបំផ្លិចបំផ្លាញយ៉ាងអាណាធិបតេយ្យ គ្មានការគ្រប់គ្រង គ្មានច្បាប់រឹតបណ្តឹង ជាហេតុធ្វើឱ្យព្រៃឈើនិងធនធានធម្មជាតិបាត់បង់បន្តិចម្តងៗ វិវត្តន៍ទៅរកភាពសឹករេចរឹល បង្កផលប៉ះពាល់ភពផែនដីទាំងមូល មនុស្សរស់នៅប្រឈមនឹងបញ្ហាគ្រោះធម្មជាតិ កើនឡើងកម្តៅផែនដី បរិស្ថានគ្មានសណ្តាប់ធ្នាប់របៀបរៀបរយ ប៉ះពាល់សុខភាពសាធារណៈ ប្រជាជនមិនគិតគូរអំពីបញ្ហាបរិស្ថាន ប្រទេសជាតិគ្មានការអភិវឌ្ឍន៍។

រហូតមកដល់ពេលដែលប្រទេសជាតិទទួលបានសុខសន្តិភាពពេញលេញឆ្នាំ១៩៩៨ រាជរដ្ឋាភិបាលក៏ដូចជាថ្នាក់ដឹកនាំបានរៀបចំហេដ្ឋារចនាសម្ព័ន្ធលិខិតបទដ្ឋានគតិយុត្ត ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល សេវាសាធារណៈ ព្រមទាំងបង្កើតឱ្យមានក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការដឹកនាំប្រទេសឆ្ពោះទៅរកភាពរីកចម្រើនជានិរន្តរភាព។ មកដល់ថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ក្រសួងបរិស្ថានត្រូវបានបង្កើតឡើងដោយច្បាប់ ក្រោយមកនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ អនុក្រឹត្យលេខ២០ អនក្រ.បក ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន ត្រូវបានបង្កើតឡើង។ ការបង្កើតអនុក្រឹត្យនេះឡើងក្នុងគោលបំណងកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាននិងបណ្តាអង្គភាពក្រោមឱវាទ។ ក្រោយពីក្រសួងបរិស្ថានបង្កើតឡើងរួចរាល់ ក្រសួងបានដាក់ចេញនូវសសរស្តម្ភចំនួនបួនក្នុងការគ្រប់គ្រងដឹកនាំក្នុងនោះមាន ១. ការធ្វើទំនើបកម្មស្ថាប័ន ២.កិច្ចគាំពារបរិស្ថាន ៣.ការអភិរក្សធនធានធម្មជាតិ និងជីវៈចម្រុះ ៤.ការរស់នៅប្រកបដោយចីរភាព លើសពីនេះ ដើម្បីគ្រប់គ្រងការពារ ថែរក្សាអភិរក្ស ព្រៃឈើ ធនធានធម្មជាតិ ថែរក្សាបរិស្ថាន ក្រសួងបានដាក់ចេញនូវផែនការ វិធានការនានា ព្រមទាំងបង្កើតតំបន់ការពារធម្មជាតិជាច្រើន គោលបំណងធានាការពារព្រៃឈើ ធនធានធម្មជាតិ សត្វព្រៃ ជីវៈចម្រុះ រុក្ខជាតិនានា ក្រៅពីការការពារធនធាន

ធម្មជាតិទាំងអស់នេះ ថែមទាំងបង្កើតយុទ្ធនាការផ្សេងៗ ក្នុងន័យបញ្ជ្រាបការយល់ដឹងពីសារៈសំខាន់ និងផលប៉ះពាល់ដល់សាធារណៈជន ដោយសហការជាមួយអង្គការដៃគូពាក់ព័ន្ធនានាដើម្បីលើកស្ទួយវិស័យបរិស្ថាន។

ទន្ទឹមនឹងការសម្រេចបាននូវលទ្ធផលនានារបស់ក្រសួងបរិស្ថានក៏ជួបនូវផលលំបាកផងដែរ ក្នុងនោះប្រជាជនមិនសូវគិតគូរយកចិត្តទុកដាក់លើបញ្ហាបរិស្ថាន ប្រជាជនមិនសូវសហការគាំទ្រ ការប្រព្រឹត្តល្មើសនឹងច្បាប់ ការមិនសហការពីមន្ត្រីខិលខូចមួយចំនួន សម្បូរទៅដោយប្រភពបំពុល បំពុលទឹក បំពុលបរិយាកាស ដោយការមិនយកចិត្តទុកដាក់ពីសំណាក់ម្ចាស់អាជីវកម្ម ឧស្សាហកម្ម រួមទាំងការយល់ដឹងរបស់ប្រជាជននៅមានកម្រិត ម៉្យាងវិញទៀត ការអភិវឌ្ឍន៍ ក៏ជាកត្តាធ្វើឱ្យប៉ះពាល់ទៅដល់បរិស្ថានផងដែរ។

## ២. ចំណោទបញ្ហា

នៅក្នុងដំណើរការនៃការអភិវឌ្ឍប្រទេស ស្ថាប័នរដ្ឋ ស្ថាប័នឯកជន ព្រមទាំងបណ្តាដៃគូពាក់ព័ន្ធផ្សេងទៀតបានដើរតួយ៉ាងសំខាន់ ក្នុងការជំរុញសេដ្ឋកិច្ចជាតិឱ្យមានភាពរីកចម្រើន។ តួយ៉ាងបរិស្ថាន ពិតជាមានសារៈសំខាន់ណាស់សម្រាប់ការរស់នៅរបស់ប្រជាពលរដ្ឋទាំងអស់ តាមរយៈការធ្វើកសិកម្ម ការកែច្នៃធនធានដែលមានស្រាប់ ការចិញ្ចឹមសត្វ ការបង្កើនមុខរបរផ្សេងៗរបស់ប្រជាពលរដ្ឋកាត់បន្ថយការចំណាកស្រុក ថែមទាំងលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន ហេតុនេះទើបរាជរដ្ឋាភិបាលសម្រេចបង្កើតក្រសួងបរិស្ថានដើម្បីជំរុញបន្ថែមនូវការគ្រប់គ្រងបរិស្ថានឱ្យកាន់តែល្អប្រសើរ។ លើសពីនេះគោលបំណងសំខាន់ចង់បញ្ជ្រាបឱ្យសាធារណជនបានយល់ពីសារៈសំខាន់នៃបរិស្ថាន គឺដើម្បីការពារ និងលើកកម្ពស់គុណភាពបរិស្ថាននិងសុខភាពសាធារណៈ តាមរយៈការការពារ ទប់ស្កាត់ និងគ្រប់គ្រងការបំពុលដើម្បីធ្វើឱ្យមានការវាយតម្លៃលើបរិស្ថានមុនពេលចេញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលើគម្រោងដែលបានគ្រោងទុកទាំងអស់ដើម្បីធានា និងគ្រប់គ្រងការប្រើប្រាស់ធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងលើកទឹកចិត្តនិងផ្តល់លទ្ធភាពដល់សាធារណជនចូលរួមក្នុងការការពារបរិស្ថាន ដើម្បីកម្ពុជាឆ្ពោះទៅរកសេដ្ឋកិច្ចបៃតង។ ដោយឡែក បញ្ហាបរិស្ថាននៅតែជាបញ្ហាចោទយ៉ាងសំខាន់ដែលត្រូវដោះស្រាយ ហេតុនេះទើបក្រុមយើងខ្ញុំសិក្សាស្រាវជ្រាវអំពីក្រសួងបរិស្ថាន ដោយបានចោទឡើងនូវសំណួរដូចខាងក្រោម៖

- តើសារតនៃការបង្កើតក្រសួងបរិស្ថានមានដូចម្តេចខ្លះ? និងបំពេញបេសកកម្មអ្វីខ្លះ?
- តើក្រសួងបរិស្ថាន មានរចនាសម្ព័ន្ធដូចម្តេច? និងធ្វើការបែងចែកតួនាទីនឹងភារកិច្ចទៅឱ្យអង្គភាពនានាក្រោមចំណុះបែបណាខ្លះ?
- តើក្រសួងបរិស្ថានបានសម្រេចនូវសមិទ្ធផលអ្វីខ្លះ?ហើយជួបប្រទះនូវបញ្ហាប្រឈមអ្វីខ្លះក្នុងការបំពេញបេសកកម្ម?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានសារណារនេះ គឺដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់និងស៊ីជម្រៅទាក់ទងទៅនឹងក្រសួងបរិស្ថាន តាំងពីមុនកកើតក្រសួងបរិស្ថាន រហូតដល់ពេលក្រសួងបរិស្ថានត្រូវបានដំណើរការ ថាតើមានសកម្មភាព ក៏ដូចជាដំណើរការបែបណាខ្លះក្នុងការគ្រប់គ្រងដឹកនាំវិស័យបរិស្ថានឱ្យឆ្ពោះទៅរកភាពជោគជ័យ និងរីកចម្រើន។ លើសពីនេះដើម្បីស្វែងយល់អំពីការបែងចែកតួនាទី ភារកិច្ច របស់ក្រសួងបរិស្ថានទៅឱ្យអង្គភាពចំណុះនានា ក្នុងការគ្រប់គ្រងដឹកនាំប្រកបដោយប្រសិទ្ធភាពនៃការគ្រប់គ្រងបរិស្ថានកម្ពុជា បញ្ហាប្រឈមទាំងឡាយដែលកើតមានក្នុងសកម្មភាពនៃការគ្រប់គ្រងបរិស្ថាន និងការផ្ដល់ជូននូវដំណោះស្រាយសមស្របណាមួយដែលអាចជាយោបល់ ឬអនុសាសន៍ ក៏ដូចជាការរៀបចំសេវាសាធារណៈ និងដំណើរការនៃការដឹកនាំការកសាងប្រទេស ភាពរីកចម្រើននៃប្រទេសជាតិ ការយល់ដឹងរបស់ប្រជាពលរដ្ឋទាក់ទងនឹងបរិស្ថាន ភាពខុសប្លែកគ្នានៃការវិវត្តពីមួយឆ្នាំទៅមួយឆ្នាំ និងដើម្បីស្វែងយល់រាល់ផែនការសកម្មភាពដែលក្រសួងសម្រេចបានក្នុងការគ្រប់គ្រងបរិស្ថាន ធ្វើយ៉ាងណាដើម្បីសម្រេចបានផែនការដែលបានដាក់ចេញ មានសូចនាករបែបណាខ្លះដើម្បីសម្រេចបានលទ្ធផល ជាមួយគ្នានឹងការសម្រេចបានលទ្ធផល ក្រសួងបរិស្ថានជួបផលលំបាកអ្វីខ្លះមុនទទួលបានជោគជ័យ។ មិនតែប៉ុណ្ណោះ គោលបំណងសំខាន់ដើម្បីបញ្ជ្រាបចំណេះដឹងបរិស្ថាន សារៈប្រយោជន៍បរិស្ថានធម្មជាតិ ក៏ដូចជាផលប៉ះពាល់បរិស្ថាន ទៅដល់សាធារណៈជនជាការស្វែងយល់បន្ថែម ព្រមទាំងជួយលើកស្ទួយនិងថែរក្សាបរិស្ថាន។ តួយ៉ាង យោងតាមប្រសាសន៍ណែនាំរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា** ជំរុញឱ្យពង្រឹងនិងពង្រីក **ទេសចរណ៍ផ្សាភ្ជាប់នឹងទឹកដី និងទេសចរណ៍ផ្ទៃក្នុង** ដែលបាននឹងកំពុងជំរុញការអភិវឌ្ឍន៍ជីវភាពសហគមន៍មូលដ្ឋាន និងការអភិរក្សធនធានធម្មជាតិទាក់ទាញចិត្តប្រជាជនឱ្យស្រលាញ់បរិស្ថាន និងចូលរួមថែរក្សាបរិស្ថាន។

## ៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

នៅក្នុងសារណាបញ្ចប់ការសិក្សានេះ យើងខ្ញុំទាំងពីរសិក្សាទៅលើប្រធានបទស្ដីពី ការរៀបចំនិងការប្រព្រឹត្តិទៅនៃក្រសួងបរិស្ថាន ពោលគឺសិក្សាស្រាវជ្រាវផ្ដោតសំខាន់ទៅលើតែសកម្មភាពរបស់ក្រសួងបរិស្ថានតែប៉ុណ្ណោះ ដោយមិនបានសិក្សាលំអិតទៅលើសកម្មភាពបរិស្ថាននានាដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាននោះទេ ព្រោះថាបើយើងនិយាយពីបរិស្ថានគឺពិតជាទូលំទូលាយធំធេងណាស់ មានច្រើនជាអនេក។ ដូចដែលបានរៀបរាប់មកនេះ ទើបយើងខ្ញុំសិក្សាផ្ដោតទៅលើសាវតា និងបេសកម្មរបស់ក្រសួង បន្ថែមពីនេះក៏សិក្សាទៅលើរចនាសម្ព័ន្ធ តួនាទីភារកិច្ចនៃអង្គភាពចំណុះឱ្យក្រសួង សមិទ្ធផលសំខាន់ៗដែលក្រសួងបរិស្ថានសម្រេចបាន បញ្ហាប្រឈម និងអនុសាសន៍។ ចំពោះដែនកំណត់នៃការស្រាវជ្រាវទៅលើប្រធានបទសារណាមួយនេះគឺនៅត្រឹមឆ្នាំ**២០២១** តែប៉ុណ្ណោះ។ ម៉្យាងដោយក្នុងអំឡុងពេលប្រទេសជាតិជួបប្រទះនឹងបញ្ហាជំងឺ

កូវីដ-១៩ បណ្តាលឱ្យមានផលលំបាកច្រើន រាប់តាំងពីការចុះទៅស្រាវជ្រាវឯកសារ ឬការទៅជួបជុំផ្សេងៗ ដោយមានការយកចិត្តទុកដាក់ខ្ពស់ពីរាជរដ្ឋាភិបាល ក្នុងការផ្តល់ជូននូវវ៉ាក់សាំងគ្រប់គ្រាន់ចាក់ជូនដល់ប្រជាពលរដ្ឋ និងគិតគូរចំពោះប្រជាពលរដ្ឋទាំងអស់ដោយស្មើភាព និងខិតខំស្តារប្រទេសទោះស្ថិតក្នុងបរិបទនៃជំងឺកូវីដ-១៩យ៉ាងណាក៏ដោយនោះ ក៏នៅតែបន្តការខិតខំមិនបោះបង់មិនតក់ស្លុតខំប្រឹងជម្នះ និងបានដាក់ចេញនូវវិធានការ ៣កុំ ៣ការពារ ដើម្បីសុខុមាលភាពប្រជាពលរដ្ឋទូទាំងប្រទេស និងគ្រប់គ្រងប្រទេសបានយ៉ាងល្អ។

## ៥.សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវមួយនេះពិតជាមានសារៈសំខាន់ខ្លាំងណាស់ ព្រោះថាមិនត្រឹមតែផ្តល់ជាប្រយោជន៍ដល់ពួកខ្ញុំទាំងពីរប៉ុណ្ណោះទេ តែការសិក្សាស្រាវជ្រាវមួយនេះក៏បានផ្តល់ជាឧត្តមប្រយោជន៍ដល់អ្នកសិក្សាស្រាវជ្រាវគ្រប់ៗជំនាន់ ជាពិសេសដល់សង្គមជាតិ ប្រទេសជាតិដូចខាងក្រោមៈ

ទីមួយ ការសិក្សាស្រាវជ្រាវមួយនេះ បានជួយឱ្យយើងខ្ញុំទាំងពីរដែលជាអ្នកសិក្សាស្រាវជ្រាវទទួលបានចំណេះដឹងបន្ថែមពាក់ព័ន្ធនឹងវិស័យបរិស្ថាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងអនុញ្ញាតឱ្យយើងខ្ញុំបានយល់ដឹង និងអាចផ្សារភ្ជាប់ពីការសិក្សាទ្រឹស្តី និងការអនុវត្តការងារជាក់ស្តែងរាល់ដំណើរការសកម្មភាពរបស់ក្រសួងបរិស្ថានផ្ទាល់ ដែលមានដូចជាសកម្មភាពគ្រប់គ្រងបរិស្ថាន ការងារសហការជាមួយដៃគូរពាក់ព័ន្ធរួមគ្នាថែរក្សាបរិស្ថាន ការដាក់ចេញនូវផែនការផ្សេងៗ ការទំនាក់ទំនងជាមួយថ្នាក់ក្រោមជាតិជាដើម។

ទីពីរ ការសិក្សាស្រាវជ្រាវមួយនេះ និងក្លាយជាឯកសារជំនួយស្មារតីបន្ថែមដែលនឹងអាចក្លាយជាមូលដ្ឋានមួយរួមចំណែកជួយសម្រួលដល់ការសិក្សាស្រាវជ្រាវបន្តបន្ទាប់ដល់អ្នកសិក្សាស្រាវជ្រាវគ្រប់ជំនាន់ដែលមានបំណងចង់ធ្វើការសិក្សាស្រាវជ្រាវ សិក្សាស្វែងយល់ពីចំណេះដឹងពាក់ព័ន្ធលើប្រធានបទដែលទាក់ទងនឹងវិស័យបរិស្ថាន ក៏ដូចជាសកម្មភាពនានាដែលក្រសួងបរិស្ថានបានអនុវត្តដើម្បីសម្រេចបានលទ្ធផល ជាងនេះទៅទៀតក៏ជាការយល់ដឹង និងជួយថែរក្សាការពារ អភិរក្ស ធនធានធម្មជាតិ បរិស្ថានប្រទេសជាតិយើង។

ចុងក្រោយ ការសិក្សាស្រាវជ្រាវនេះ និងរួមចំណែកជាសារវន្តដល់សង្គមជាតិ ជាពិសេសរួមចំណែកដល់សុខុមាលភាពសាធារណៈតាមរយៈការធ្វើអនាម័យ ការរស់នៅស្អាត ការទុកដាក់សំរាមបានត្រឹមត្រូវ ការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ការកែច្នៃឡើងវិញ បន្ថែមពីនេះជំរុញវិស័យទេសចរណ៍ បង្កើនសេដ្ឋកិច្ចជាតិ ជីវភាពសហគមន៍មូលដ្ឋានកាន់តែមានភាពរីកចម្រើន និងប្រសើរឡើងប្រទេសជាតិរីកចម្រើន។

# ៦.វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

## ៦.១ ការប្រមូលទិន្នន័យ

ដើម្បីជួយឱ្យការចងក្រងឯកសារនេះ បានល្អប្រសើរឡើងយើងខ្ញុំបានរៀបចំបែងចែកជា ៣ជំហានសំខាន់ៗសម្រាប់ធ្វើការប្រមូលទិន្នន័យអោយគ្រប់គ្រាន់ ដើម្បីជាមូលដ្ឋានក្នុងការវិភាគអោយបានល្អ និងគ្រប់ជ្រុងជ្រោយផងដែរ។ ជំហានសំខាន់ៗទាំងនោះរួមមានៈ

ជំហានទី១ ស្វែងរក និងឈ្វេងយល់រិះរកគ្រប់វិធីសាស្ត្រក្នុងការប្រមូលព័ត៌មានឯកសារ និងទិន្នន័យនានាជាពិសេសលើលិខិតបទដ្ឋានគតិយុត្ត(ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរ ប្រកាស)យុទ្ធសាស្ត្រ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ឯកសារជំនួយស្មារតីដែលបានសិក្សាកន្លងមកពីសាស្ត្រចារ្យនៅសាលា ឯកសារដែលបានទទួលបានតាមរយៈប្រព័ន្ធអេឡិចត្រូនិច(INTERNET)និងឯកសារមួយចំនួនផ្សេងទៀតដែលពាក់ព័ន្ធ។

ជំហានទី២ ការចុះស្រាវជ្រាវឯកសារដោយផ្ទាល់នៅនាយកដ្ឋានធនធានមនុស្ស របស់អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងបរិស្ថាន ដើម្បីធ្វើការអង្កេតនិងស្ទាបស្ទង់លើការអនុវត្តការងារជាក់ស្តែងរបស់អង្គភាពដែលទទួលបន្ទុកអនុវត្តរាល់លិខិតបទដ្ឋានគតិយុត្ត និងសារាចរណែនាំនានា។ ក្នុងកំឡុងពេលនៃកម្មសិក្សានេះដែរ យើងខ្ញុំក៏បានប្រមូលទិន្នន័យបន្ថែម តាមរយៈការសម្ភាសន៍សួរនាំផ្ទាល់ និងសុំឯកសារបន្ថែមពីសំណាក់មន្ត្រីកំពុងបម្រើការងារផ្ទាល់នៅក្នុងនាយកដ្ឋានធនធានមនុស្សផងដែរ។ ឯកសារទាំងនោះរួមមានៈ អនុក្រឹត្យលេខ ២៣៤ អនក្រ បក ចុះថ្ងៃទី១៧ ខែវិច្ឆកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន, របាយការណ៍បូកសរុបការងារបរិស្ថាន, របាយការណ៍សន្និបាតបូកសរុបលទ្ធផលការងារបរិស្ថានឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០, របាយការណ៍ស្ថានភាពបរិស្ថានលើកទី៤, ព្រមទាំងផែនការយុទ្ធសាស្ត្រ៣ឆ្នាំរំកិល២០២២-២០២៤ ដើម្បីបំពេញភាពខ្វះខាតលើផ្នែកខ្លឹមសាររបស់របាយការណ៍បញ្ចប់ការសិក្សាមួយនេះឱ្យកាន់តែមានលក្ខណៈពេញលេញ និងមានភាពស៊ីជម្រៅបន្ថែមទៀត។

ជំហានទី៣ គឺជាការបូកសរុបលទ្ធផលនៃការចុះកម្មសិក្សារបស់យើងខ្ញុំ ពីសំណាក់លោកអនុប្រធាននាយកដ្ឋានធនធានមនុស្ស។ តាមរយៈនេះ យើងខ្ញុំទទួលបាននូវឱកាសក្នុងការសាកសួរ និងការណែនាំលម្អិតបន្ថែមលើចំណុចមួយចំនួនទៀតដែលមិនទាន់បានច្បាស់ ដើម្បីឱ្យខ្លឹមសារនៃអត្ថបទនេះកាន់តែមានទម្ងន់និងភាពច្បាស់លាស់អាចយកមកប្រើជាឧត្តមប្រយោជន៍សម្រាប់អ្នកសិក្សាស្រាវជ្រាវក្រោយៗទៀត។

## ៦.២ វិធីសាស្ត្រក្នុងការវិភាគទិន្នន័យ

បន្ទាប់ពីទទួលបានទិន្នន័យគ្រប់គ្រាន់តាមរយៈការធ្វើកម្មសិក្សារួចមក យើងបានយកទិន្នន័យដែលទទួលបានទាំងនោះមកពីការប្រៀបធៀបរវាងទ្រឹស្តីជាមួយនឹងការអនុវត្តជាក់ស្តែង ដើម្បីវិភាគរកភាពខ្លាំង ភាពខ្សោយ បញ្ហាប្រឈម និងកាលានុវត្តភាពក្នុងការអនុវត្តការងាររបស់ក្រសួងបរិស្ថាន ដើម្បីឈានឆ្ពោះទៅរកការសន្និដ្ឋាន

ជារួម និងលើកជាអនុសាសន៍ ក្នុងការចូលរួមចំណែកកែលម្អ នូវចំណុចខ្វះខាតមួយចំនួនឱ្យកាន់តែមានភាពប្រសើរថែមមួយកម្រិតទៀត។

## ៧.រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

ដើម្បីឱ្យការសិក្សាស្រាវជ្រាវទទួលបានជោគជ័យល្អប្រសើរ និងប្រកបដោយប្រសិទ្ធភាព គុណភាពខ្ពស់ គឺចាំបាច់ណាស់ក្នុងការកំណត់នូវរចនាសម្ព័ន្ធដ៏ពិតប្រាកដមួយដើម្បីអាចបំពេញតាមលក្ខណៈវិធីសាស្ត្រស្រាវជ្រាវត្រឹមត្រូវរបស់សាកលវិទ្យាល័យ។

រចនាសម្ព័ន្ធស្រាវជ្រាវក្រោមប្រធានបទ "**ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងបរិស្ថាន**" នេះត្រូវបានចងក្រងចែកចេញតាមប្លង់ដូចតទៅនេះ **សេចក្តីថ្លែងអំណរគុណ** និយាយអំពីការគោរព ការដឹងគុណ និងការថ្លែងអំណរគុណចំពោះលោកអ្នកមានគុណទាំងពីរ លោកគ្រូអ្នកគ្រូសាស្ត្រាចារ្យទាំងអស់ឯកឧត្តមសាកលវិទ្យាធិការ ឯកឧត្តមរដ្ឋមន្ត្រីព្រមទាំងមិត្តភក្តិទាំងអស់ដែលបានជំរុញនិងលើកទឹកចិត្តឱ្យយើងខ្ញុំទាំងពីរបានបញ្ចប់ការសិក្សាដោយជោគជ័យ។ ចំពោះ **អារម្ភកថា** គឺនិយាយរៀបរាប់ពីអារម្មណ៍និងការយល់ឃើញចំពោះប្រធានបទដែលយើងខ្ញុំទាំងពីរបានខិតខំស្រាវជ្រាវចងក្រងឡើង ព្រមទាំងរំលេចនូវសារៈសំខាន់ដែលមានចំពោះប្រធានបទសារណាស្រាវជ្រាវ។ ចំណែកឯ **សេចក្តីផ្តើម** និយាយទាក់ទងទៅនឹងបញ្ហានានាដែលជាបញ្ហាចោទកើតឡើងចំពោះប្រធានបទសារៈសំខាន់នៃប្រធានបទ លំនាំនៃការកកើតក្រសួង ស្ថាប័ន ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការដឹកនាំប្រទេស។ចំណោទបញ្ហាដែលបានចោទសួរឡើងសុទ្ធសឹងតែជាចំណោទបញ្ហាសំខាន់ទាក់ទងទៅនឹងការគ្រប់គ្រងរបស់ក្រសួងស្ថាប័នសាមីទាំងការដាក់ចេញនូវផែនការយុទ្ធសាស្ត្រការរៀបចំសេវាសាធារណៈបញ្ហាប្រឈមនិងដំណោះស្រាយចំពោះបញ្ហាផ្សេងៗ គោលបំណងនៃការស្រាវជ្រាវចំពោះអត្ថបទទាំងមូល ទំហំនិងដែនកំណត់នៃការស្រាវជ្រាវគឺក្រុមរបស់យើងខ្ញុំកំណត់យកត្រឹមឆ្នាំ២០២១ តែប៉ុណ្ណោះ សារៈសំខាន់នៃការស្រាវជ្រាវមិនត្រឹមតែមានសារៈសំខាន់ ចំពោះក្រុមយើងខ្ញុំនោះទេ លើសពីនេះពិតជាមានសារៈសំខាន់សម្រាប់អ្នកសិក្សាស្រាវជ្រាវគ្រប់រូប ព្រមទាំងនិស្សិតសាកលវិទ្យាល័យ សាធារណជននិងប្រទេសជាតិរួមទាំងមានវិធីសាស្ត្រស្រាវជ្រាវដែលបង្ហាញពីវិធីសាស្ត្រក្នុងការប្រមូលចងក្រងនូវរាល់ព័ត៌មានទិន្នន័យ ព្រមទាំងឯកសារនានាដែលពាក់ព័ន្ធជាមួយក្រសួងស្ថាប័នសាមីរួមទាំងស្រាវជ្រាវពីប្រព័ន្ធផ្សព្វផ្សាយផ្សេងៗដោយច្បិចយកនូវចំណុចសំខាន់ៗដើម្បីចងក្រងជាឯកសារនេះឡើង។ ដោយឡែកការស្រាវជ្រាវឯកសារនេះចែកជាបីជំពូកដែល**ជំពូកទី១ រំលឹកទ្រឹស្តី** ជាជំពូកដំបូង នៃការចាប់ផ្តើមចំពោះប្រធានបទ ដែលបង្ហាញពីស្ថានភាពទូទៅពាក់ព័ន្ធនឹងប្រធានបទដែលមានដូចជាប្រវត្តិនៃការកកើតក្រសួងបរិស្ថាន ចក្ខុវិស័យ គោលបំណង បេសកម្ម តួនាទី ភារកិច្ច រចនាសម្ព័ន្ធ របស់ក្រសួង លិខិតបទដ្ឋានគតិយុទ្ធពាក់ព័ន្ធ ការវិវត្តរបស់ក្រសួង និងផែនការយុទ្ធសាស្ត្ររបស់ក្រសួងបរិស្ថាន។ មួយវិញទៀតចំពោះ**ជំពូកទី២ ការរៀបចំ និងការព្រឹត្តទៅរបស់ក្រសួងបរិស្ថាន** ជំពូកនេះបង្ហាញអំពី ការរៀបចំ

និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថានដោយមានអង្គភាពថ្នាក់ជាតិ អង្គភាពថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ ជំពូកទី២ជាជំពូកមួយដែលរៀបរាប់ពីគ្រោងឆ្អឹងទាំងស្រុងរបស់ក្រសួង។ **ជំពូកទី៣ សមិទ្ធផល បញ្ហាប្រឈម និងដំណោះស្រាយ** ជំពូកនេះនិយាយអំពី សមិទ្ធផល លទ្ធផលដែលសម្រេចបាន បញ្ហាប្រឈម និងដំណោះស្រាយ ចំពោះប្រធានបទ។ **សេចក្តីសន្និដ្ឋាន** នេះផ្នែកចុងក្រោយរបស់ប្រធាបទសារណាដែលក្រុមយើងខ្ញុំបានលើកឡើងដោយក្តោបរួមចំពោះប្រធានបទទាំងមូលសង្ខេបនូវរាល់លទ្ធផលទាំងអស់ដែលទទួលបានពីការស្រាវជ្រាវ រួមទាំងអនុសាសន៍មួយចំនួនទៀតផង។

# ជំពូកទី១
# រំលឹកទ្រឹស្តី

## ១.១ រំលឹកទ្រឹស្តី

ក្រសួងបរិស្ថាន ត្រូវបានបង្កើតឡើងដោយយោងតាមព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីការង្កើតក្រសួងបរិស្ថាន ក្រសួងត្រូវផ្តល់នូវសមត្ថកិច្ចគ្រប់គ្រង និងដឹកនាំលើវិស័យបរិស្ថាន នៃព្រះរាជាណាចក្រកម្ពុជា។ លិខិតបទដ្ឋានគតិយុត្តទាក់ទងនិងការវិវត្តរបស់ក្រសួងបរិស្ថានរួមមានៈ

- អនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- អនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- ព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤០៣ ចុះថ្ងៃទី០៩ ឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិ អភិវឌ្ឍន៍ដោយចីរភាព
- អនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- អនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- អនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន។

## ១.២ ប្រវត្តិរបស់ក្រសួងបរិស្ថាន

### ១.២.១ ប្រវត្តិនៃការកកើតរបស់ក្រសួងបរិស្ថាន

មុននឹងកកើតមានក្រសួងបរិស្ថានសព្វថ្ងៃស្ថាប័នមួយនេះត្រូវបានវិវត្តជាបីដំណាក់កាលរួចមកហើយ បើយោងទៅតាមប្រកាសទទួលស្គាល់របស់ **បណ្ឌិត ម៉ុក ម៉ារ៉េត** ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៣ ស្តីពីការទទួលស្គាល់មន្ត្រីរាជការបម្រើការងារនៅក្រសួងបរិដ្ឋាន នៃរដ្ឋាភិបាលបណ្តោះអាសន្ន បានបង្ហាញថាក្រសួងនេះមានអាយុកាលតាំងពីឆ្នាំ១៩៩៣មកម្ល៉េះ។ បន្ទាប់ពីបោះឆ្នោតឆ្នាំ១៩៩៣បានបង្កើតទៅជារដ្ឋាភិបាលបណ្តោះអាសន្ន ក្រសួងបរិដ្ឋាន លុះក្រោយមកទើបបង្កើតទៅជារដ្ឋលេខាធិការដ្ឋានបរិដ្ឋាន។ បន្ទាប់ពីនោះ ក្រសួងបរិស្ថានត្រូវបានបង្កើតឡើងដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស

ឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងបរិស្ថាន។[1] នៅក្នុងច្បាប់ដដែលនេះ បានកំណត់បេសកម្មរបស់ក្រសួងបរិស្ថាន គឺគ្រប់គ្រងដឹកនាំលើវិស័យបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា។

### ១.២.២ ទីតាំងរបស់ក្រសួងបរិស្ថាន

ក្រសួងបរិស្ថាន មានទីតាំងស្ថិតនៅ អគារមរតកតេជោ ដីឡូលេខ៥០៣ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។( **សូមមើលឧបសម្ព័ន្ធរូបភាពទី១** )

### ១.២.៣ ស្លាកសញ្ញា និងអត្ថន័យនៃក្រសួងបរិស្ថាន

( **សូមមើលឧបសម្ព័ន្ធរូបភាពទី២** )

❖ **និយមន័យស្លាកសញ្ញានៃក្រសួងបរិស្ថាន**

- អក្សរបរិស្ថានពណ៌លឿង តំណាងឱ្យក្រសួងទទួលបន្ទុកបរិស្ថានដែលត្រូវមាន ទំនាក់ទំនង ជាមួយបណ្តាក្រសួងដទៃទៀត
- រង្វង់មូលព័ទ្ធជុំវិញដែលមានពណ៌លឿង ក្រហម និងខៀវ តំណាងឱ្យប្រព័ន្ធអេកូឡូស៊ី ដែលមានការប្រទាក់ប្រទង់គ្នាក្នុងជីវិតរស់នៅ និងបរិស្ថាន
- រូបផ្ទៃមេឃខាងលើ ដែលមានពណ៌ស និងខៀវខ្ចី តំណាងឱ្យបរិយាកាសដែលគ្មានការបំពុល
- រូបប្រាសាទអង្គរវត្ត ដែលមានពណ៌បៃតងចាស់ ក្រម៉ៅតំណាងឱ្យបរិស្ថាននិងវប្បធម៌ដ៏រឹងមាំ
- ផ្នែកខាងក្រោមប្រាសាទអង្គរវត្តពណ៌បៃតងខ្ចី និង ពណ៌បៃតងចាស់តំណាងឱ្យធនធានធម្មជាតិ ដី ព្រៃឈើ និងជីវៈចម្រុះ
- ពណ៌ខៀវខាងក្រោម តំណាងឱ្យទឹកស្អាត ដែលគ្មានការបំពុល។

### ១.២.៤ ចក្ខុវិស័យ គោលបំណង និងវប្បធម៌ការងារ របស់ក្រសួងបរិស្ថាន

#### ១.២.៤.១ ចក្ខុវិស័យរបស់ក្រសួងបរិស្ថាន

ក្រសួងបរិស្ថាន គឺបានលើកស្ទួយការការពារបរិស្ថាន និងអភិរក្សធនធានធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីរួមចំណែកកែលម្អគុណភាពបរិស្ថានទ្រទ្រង់សុខភាពសាធារណៈវប្បធម៌ និងសេដ្ឋកិច្ចជាតិ។ ក្រសួងបរិស្ថានជាអ្នកសម្របសម្រួលដល់ការរៀបចំ និងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ផែនការបរិស្ថាន និងវិធានច្បាប់នានាដើម្បីជំរុញនិងធានាឱ្យមានការប្រើប្រាស់ និងគ្រប់គ្រងធនធានធម្មជាតិដោយសមហេតុសមផលប្រកបដោយនិរន្តរភាព។ ទន្ទឹមនឹងនេះ មានការលើកទឹកចិត្តនិងគាំទ្រពីសំណាក់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់ធនធានធម្មជាតិដោយសមធម៌។ ជំរុញកិច្ចសហការជាមួយក្រសួងផ្សេងៗក្នុងរាជរដ្ឋាភិបាលព្រមទាំង

[1] ប្រកាសស្តីពីការទទួលស្គាល់មន្ត្រីរាជការបំពីការងារនៅក្រសួងបរិដ្ឋាន ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៣

ស្ថាប័ននានា អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជននិងប្រជាពលរដ្ឋក្នុងការបំពេញបេសកកម្មរបស់ខ្លួន។[2]

**១.២.៤.២ គោលបំណងរបស់ក្រសួងបរិស្ថាន**

គោលបំណងរបស់ក្រសួងបរិស្ថាន គឺធានាគាំពារបរិស្ថាន និងការអភិរក្សធនធានធម្មជាតិក្នុងលក្ខណៈរក្សាឱ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាព ធ្វើឱ្យកើនឡើងគុណភាពបរិស្ថាននិងសុខភាពមនុស្សតាមរយៈការធ្វើសមាហរណកម្មផែនការយុទ្ធសាស្ត្រ នឹងទស្សនៈវិស័យបរិស្ថានសម្រាប់ការអនុវត្តក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមការសម្រេចចិត្តនានា និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។[3]

**១.១.៤.៣ វប្បធម៌ការងារ**

វប្បធម៌ការងារនៅក្នុងក្រសួងបរិស្ថាន គឺបុគ្គលិកមានការខិតខំធ្វើការងារដោយមានភាពពេញចិត្តជាមួយការងារ អាកប្បកិរិយាសុភាពរាបសារ គ្មានការរើសអើង មិនមានការប្រកាន់បក្សពួកនិយមមានការប្រកាន់យកភាពសកម្មសាមគ្គីផ្ទៃក្នុង គ្មានការពុករលួយ គ្មានអំពើស៊ីសំណូកសូកប៉ាន់ជាពិសេសមានភាពជាម្ចាស់ការលើការងាររបស់ខ្លួនថែមទៀតផង។

## ១.៣ បេសកកម្មរបស់ក្រសួងបរិស្ថាន

ក្រសួងបរិស្ថាន ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រគល់បេសកកម្មឱ្យដឹកនាំ និងគ្រប់គ្រង កិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប និងមាននិរន្តរភាព និងការរស់នៅដោយចីរភាព សម្រាប់ជាឧត្តមប្រយោជន៍យូរអង្វែងរបស់ប្រជាជនកម្ពុជាគ្រប់រូប និងគ្រប់ជំនាន់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ដូចនេះក្រសួងបានខិតខំស្វែងរកដំណោះស្រាយជាច្រើនដើម្បីការពារដូចជា៖

- ការរៀបចំ និងការអនុវត្តវិធានច្បាប់បរិស្ថាននានា
- អង្កេតពិនិត្យ និងផ្តល់ហេតុប៉ះពាល់បរិស្ថាន
- ប្តេជ្ញាចិត្ត ពង្រឹងទំនាក់ទំនងអន្តរជាតិ
- ផ្តល់យោបល់ និងគាំទ្រវាល់សកម្មភាពអភិរក្សការពារបរិស្ថាន
- ជម្រុញការការពារបរិស្ថានពីសំណាក់ជនរួមជាតិ និងបរទេស។

[2] គឹម ចន្ទ្រានិងហុង អេងលី ស្តីពី «ការគ្រប់គ្រងធនធានមនុស្សរបស់ក្រសួងបរិស្ថាន» ឆ្នាំ២០១៩ ត្រង់ទំព័រទី៣១

[3] គឹម ចន្ទ្រានិងហុង អេងលី ស្តីពី «ការគ្រប់គ្រងធនធានមនុស្សរបស់ក្រសួងបរិស្ថាន» ឆ្នាំ២០១៩ ត្រង់ទំព័រទី៣២

## ១.៤ តួនាទី និងភារកិច្ច របស់ក្រសួងបរិស្ថាន

ក្រសួងបរិស្ថានត្រូវបានរាជរដ្ឋាភិបាលប្រគល់បេសកកម្មឱ្យដឹកនាំនិងគ្រប់គ្រងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព និងការរស់នៅដោយចីរភាព សម្រាប់ជាឧត្តមប្រយោជន៍យូរអង្វែងរបស់ប្រជាជនកម្ពុជាគ្រប់រូប និងគ្រប់ជំនាន់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្រសួងបរិស្ថានជាសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជាមានមុខងារ និងភារកិច្ចដូចខាងក្រោម៖

- ធ្វើការរៀបចំ និងអនុវត្តលិខិតបទដ្ឋានគតិយុត្តដែលទាក់ទង នឹងវិស័យបរិស្ថាននិងធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងគ្រប់គ្រង និងអនុវត្តនូវគោលនយោបាយយុត្តិសាស្ត្រ និងការអភិវឌ្ឍក្នុងវិស័យនេះ
- គ្រប់គ្រងទិន្នន័យបរិស្ថាន និងដឹកនាំសម្របសម្រួលការងារអប់រំលើកកម្ពស់ការយល់ដឹងជាសាធារណៈ អំពីកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប និងមាននិរន្តរភាពតាមរយៈការផ្សព្វផ្សាយព័ត៌មាន
- លើកទឹកចិត្តឱ្យមានការចូលរួមជាសាធារណៈក្នុងកិច្ចគាំពារបរិស្ថានការអភិរក្សជីវៈចម្រុះការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប និងមាននិរន្តរភាពតាមរយៈការពិគ្រោះយោបល់ជាសាធារណៈនៅក្នុងដំណើរការធ្វើសេចក្ដីសម្រេចនានា
- គ្រប់គ្រង និងសម្របសម្រួលកិច្ចគាំពារបរិស្ថានរួមមាន ការគ្រប់គ្រងគុណភាពទឹក ខ្យល់ និងដី ការគ្រប់គ្រងសម្លេង និងរំញ័រ និងការគ្រប់គ្រងការបំភាយកាំរស្មី វិទ្យុសកម្ម ការងារការពារនិងអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិឱ្យបានសមស្រប និងមាននិរន្តរភាព និងការពិនិត្យវាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់គម្រោងវិនិយោគសាធារណៈ និងគម្រោងវិនិយោគឯកជន
- កៀងគរ និងគ្រប់គ្រងធនធានសម្រាប់កិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានឱ្យបានសមស្របនិងនិរន្តរភាព និងការរស់នៅដោយចីរភាព និងសហការជាមួយបណ្ដាប្រទេសនៅក្នុងតំបន់ និងពិភពលោក អង្គការអន្តរជាតិ និងសហគមន៍មូលដ្ឋានលើវិស័យបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ។[4]

ក្រៅពីតួនាទី និងភារកិច្ចចម្បងដូចបានរៀបរាប់ខាងលើនេះ ក្រសួងបរិស្ថានមានភារកិច្ចបំពេញកិច្ចការងារផ្សេងៗទៀត ដែលមានកំណត់នៅក្នុងអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថានដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី២។

[4] មាត្រា ២ នៃអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

## ១.៥ រចនាសម្ព័ន្ធរបស់ក្រសួងបរិស្ថាន

ក្រសួងបរិស្ថានត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រគល់បេសកកម្មឱ្យដឹកនាំ និងគ្រប់គ្រងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប និងមាននិរន្តរភាពនិងការរស់នៅដោយចីរភាព សម្រាប់ជាឧត្តមប្រយោជន៍យូរអង្វែងរបស់ប្រជាជនកម្ពុជាគ្រប់រូបនិងគ្រប់ជំនាន់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ដូចមានចែងក្នុងអនុក្រឹត្យលេខ២៣៤ អនក្រ.បកចុះថ្ងៃទី១៧ ខែវិច្ឆកា ឆ្នាំ២០២១ក្រសួងបរិស្ថានមាន អគ្គនាយកដ្ឋានចំណុះទីស្ដីការក្រសួងចំនួនបួន អគ្គាធិការដ្ឋានមួយ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពចំនួនមួយ និងដែលមានចំនួន៣៥ នាយកដ្ឋានជំនាញ។

**រចនាសម្ព័ន្ធរបស់ក្រសួងបរិស្ថាន**

រូបភាព ១.៥ រចនាសម្ព័ន្ធរបស់ក្រសួងបរិស្ថាន




ការបែងចែក និងប្រគល់ភារកិច្ច និងរបៀបរបបការងាររបស់ថ្នាក់ដឹកនាំនៃក្រសួងបរិស្ថាន៖

- រដ្ឋមន្ត្រី៖ ជាថ្នាក់ដឹកនាំក្រសួងមានភារកិច្ចដឹកនាំការងារទាំងអស់របស់ថ្នាក់ក្រោមមានដូចជាអគ្គនាយកដ្ឋាន ព្រមទាំងការងារទាំងឡាយដែលពាក់ព័ន្ធ។
- រដ្ឋលេខាធិការ ៖ ជាប្រធានស្ថាប័ននៃរដ្ឋលេខាធិការដ្ឋានស្វ័យជួយសម្របសម្រួលដល់រដ្ឋមន្ត្រីក្រសួង។

- អនុរដ្ឋលេខាធិការ ៖មិនមែនជាសមាជិកក្នុងរដ្ឋាភិបាលទេគឺជាជំនួយការជួយក្រសួងសម្របសម្រួលនិងភ្ជាប់ទំនាក់ទំនងការងាររវាងថ្នាក់លើរបស់ខ្លួន និងថ្នាក់ក្រោម។
- ខុទ្ទកាល័យប្រឹក្សា៖មានភារកិច្ចត្រួតពិនិត្យរាល់លិខិតស្នាមនានាដែលធ្វើការទំនាក់ទំនងជាមួយភ្ញៀវនិងសម្របសម្រួលការងារពាក់ព័ន្ធ។
- អគ្គធិការដ្ឋាន ៖មានតួនាទី និងភារកិច្ចដូចជា
  - ចាត់តាំងមន្ត្រីដឹកនាំអគ្គធិការដ្ឋាន និងមន្ត្រីជំនាញចុះតាមសកម្មភាពនិងពង្រឹងពីររបៀបធ្វើការងារព្រមទាំងផ្សព្វផ្សាយពីសេចក្តីប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅអគ្គធិការដ្ឋានខេត្ត រាជធានី។
  - សហការជាមួយក្រសួងឧស្សាហកម្ម រុក្ខាប្រមាញ់ និងនេសាទចុះស្រាវជ្រាវ និងពិនិត្យសត្វស្វានៅភ្នំក្រវាញភូមិសាស្ត្រ ខេត្តពោធិ៍សាត់។
  - សហការជាមួយការិយាល័យសត្វព្រៃចុះពិនិត្យ និងស្រង់ស្ថិតិសត្វក្រៀលខេត្តកំពត។
  - សហការជាមួយនាយកដ្ឋានសវនការផ្ទៃក្នុង ចុះដោះស្រាយទំនាស់រដ្ឋបាលមន្ទីរបរិស្ថានខេត្តពោធិ៍សាត់។
  - សហការជាមួយរដ្ឋបាលការពារ និងអភិរក្សធម្មជាតិដោះស្រាយទំនាស់នៅស្នាក់ការយ៉ាកដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់។
  - នាយកដ្ឋានសវនកម្មផ្ទៃក្នុង ដើម្បីបង្កើតប្រសិទ្ធិភាព និងលទ្ធផលការងារនៅតាមបណ្តាអង្គភាពក្រោមឱវាទបរិស្ថាននិង ដើម្បីរួមចំណែកជានាបានជោគជ័យក្នុងការអនុវត្តន៍ក្នុងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ ក្នុងការអនុវត្តយុទ្ធសាស្ត្រ។ ប៉ុន្តែទន្ទឹមនិងនេះដែរក្នុងការអនុវត្តយុទ្ធសាស្ត្រក៏នៅមានចំណុចខ្វះខាតដែលជះឥទ្ធិពលមិនល្អដល់ការគ្រប់គ្រងចំណូល ចំណាយថវិការជាតិ ការគ្រប់គ្រងទ្រព្យសម្បត្តិមួយចំនួនតូចត្រូវកែលម្អ។
  - សវនកម្មមានប្រសិទ្ធភាពការងារ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ពុំមានផែនការសកម្មភាពការងារការិយាល័យច្បាស់លាស់សមត្ថភាពមន្ត្រីនៅមានកម្រិតលើការងារ។
  - ការងារអនុវត្តការិយាល័យថ្នាក់កណ្តាលមួយចំនួនធ្វើឡើងតាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំ។ ខ្វះមន្ត្រីបម្រើក្នុងការិយាល័យបរិស្ថានក្នុងស្រុកការចាត់តាំងមន្ត្រីគោរពតាមឋានានុក្រមការងារ។
  - ការគ្រប់គ្រង និងការប្រើប្រាស់ថវិកា ការប្រើប្រាស់ថវិកាតាមគម្រោងនិងមិនមានបញ្ជី ឬវិក័យបត្រច្បាស់លាស់។

# ជំពូកទី២

# ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

## ២.១ អត្តភាពថ្នាក់ជាតិ

ការរៀបចំមានរចនាសម្ព័ន្ធ ដើម្បីគ្រប់គ្រង និងដឹកនាំជាលក្ខខណ្ឌចាំបាច់ណាស់សម្រាប់ឱ្យដំណើរការ ការងារក្រសួងស្ថាប័នមានលក្ខណៈងាយស្រួល ពិសេសគឺការបែងចែកឋានានុក្រម មុខងារតួនាទីរបស់ប្រធានស្ថាប័ន ថ្នាក់ដឹកនាំទៅតាមសមត្ថភាព បទពិសោធន៍ និងអតីតភាពការងារ។ ជាក់ស្តែងក្រសួងបរិស្ថាន ត្រូវបានដឹកនាំ ដោយរដ្ឋមន្ត្រី០១រូប ដែលអមដោយរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការតាមការចាំបាច់។ បច្ចុប្បន្ននេះ ឯកឧត្តម **សាយ សំអាល់** ជារដ្ឋមន្ត្រីក្រសួងបរិស្ថានអមដោយដោយរដ្ឋលេខាធិការចំនួន ១២ រូប និងអនុរដ្ឋលេខាធិការចំនួន ១២រូប ។[5]

ក្រសួងបរិស្ថានមានអង្គភាពចំណុះក្រសួងចំនួន ១០ រួមមាន៖

១. ខុទ្ទកាល័យរដ្ឋមន្ត្រី

២. អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

៣. អគ្គនាយកដ្ឋានគោលនយោបាយ និងយុទ្ធសាស្ត្រ

៤. អគ្គនាយកដ្ឋានគាំពារបរិស្ថាន

៥. អគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិ

៦. អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន

៧. អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន

៨. អគ្គាធិការដ្ឋាន

៩. នាយកដ្ឋានសវនកម្មផ្ទៃក្នុង

១០. នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

### ២.១.១ ខុទ្ទកាល័យរដ្ឋមន្ត្រី

ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងបរិស្ថានទទួលបន្ទុកបេសកកម្មទាំងឡាយដែលបានកំណត់ក្នុងអនុក្រឹត្យលេខ ១១ អនក្រ.បកចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន។[6]

[5] សំ សុផល ស្តីពី «ការបោះត្រាលើលិខិតចូល នៅនាយកដ្ឋានរដ្ឋបាលនៃក្រសួងបរិស្ថាន» ត្រង់ទំព័រទី២

[6] មាត្រា ៧ នៃអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

### ២.១.២ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ជាសេនាធិការឱ្យក្រសួងបរិស្ថានក្នុងការដឹកនាំគ្រប់គ្រងនិងសម្របសម្រួលកិច្ចការរដ្ឋបាលទូទៅ បុគ្គលិក ហិរញ្ញវត្ថុ សហប្រតិបត្តិការ ទ្រព្យសម្បត្តិរដ្ឋនិងការកសាងផែនការថវិកា ហើយមានតួនាទី និងភារកិច្ចដូចខាងក្រោម៖[7]

- គ្រប់គ្រង និងសម្របសម្រួលរាល់សកម្មភាពរដ្ឋបាលរបស់ក្រសួងនៅថ្នាក់ជាតិនិងរវាងអង្គភាពថ្នាក់ជាតិ និងអង្គភាពថ្នាក់ក្រោមជាតិ
- សម្របសម្រួលការងារហិរញ្ញវត្ថុ នៃអគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទទាំងអស់របស់ក្រសួង
- សម្របសម្រួលការរៀបចំសេចក្តីព្រាងនិងចងក្រងរក្សាទុកលិខិតបទដ្ឋានគតិយុត្តនានាជាអាទិ៍ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ប្រកាសអន្តរក្រសួង សេចក្តីសម្រេចនិងកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងបរិស្ថាន
- សម្របសម្រួលការអនុវត្តគោលនយោបាយកំណែទម្រង់របស់រាជរដ្ឋាភិបាលជាអាទិ៍ការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- សម្របសម្រួលជាមួយអគ្គនាយកដ្ឋាន និងអង្គភាពដទៃទៀតក្រោមឱវាទក្រសួងជាប្រចាំ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងាររបស់ក្រសួង

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុមាននាយកដ្ឋានចំណុះដូចខាងក្រោម៖

- នាយកដ្ឋានរដ្ឋបាល
- នាយកដ្ឋានធនធានមនុស្ស
- នាយកដ្ឋានផែនការ ថវិកា និងសហប្រតិបត្តិការ
- នាយកដ្ឋានគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- នាយកដ្ឋានហិរញ្ញវត្ថុ និងគណនេយ្យ។

#### ២.១.២.១ នាយកដ្ឋានរដ្ឋបាល

នាយកដ្ឋានរដ្ឋបាល មានតួនាទី និងភារកិច្ចដូចតទៅ៖ គ្រប់គ្រង និងសម្របសម្រួលកិច្ចការរដ្ឋបាលនៅថ្នាក់ជាតិ និងរវាងអង្គភាពថ្នាក់ជាតិជាមួយអង្គភាពថ្នាក់ក្រោមជាតិ គ្រប់គ្រង និងចារចរឯកសាររដ្ឋបាលផ្សេងៗ រៀបចំពិនិត្យ និងកែសម្រួលលិខិតរដ្ឋបាលទូទៅ គ្រប់គ្រងការងារនីតិកម្ម សម្របសម្រួលការរៀបចំសេចក្តីព្រាង និងចងក្រងរក្សាទុកលិខិតបទដ្ឋានគតិយុត្តនានាជាអាទិ៍ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ប្រកាសអន្តរក្រសួង

[7] មាត្រា ៨ នៃអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

សេចក្តីសម្រេច និងកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងបរិស្ថាន សម្របសម្រួល និងសហការជាមួយអង្គភាពពាក់ព័ន្ធក្នុងការរៀបចំផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានាដែលកំពុងមានជាធរមាន គ្រប់គ្រងការងារពិធីការរបស់ក្រសួង គ្រប់គ្រងបណ្ណសាររបស់ក្រសួងធ្វើកំណត់ហេតុ និងរបាយការណ៍ប្រជុំរបស់ក្រសួង រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។[8]

**២.១.២.២ នាយកដ្ឋានធនធានមនុស្ស**

នាយកដ្ឋានធនធានមនុស្សមានតួនាទី និងភារកិច្ចដូចតទៅ៖ គ្រប់គ្រងមន្ត្រីរាជការ និងបុគ្គលិកទាំងក្នុងក្របខ័ណ្ឌ និងក្រៅក្របខ័ណ្ឌ រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការ និងបុគ្គលិកទាំងក្នុងក្របខ័ណ្ឌ និងក្រៅក្របខ័ណ្ឌ រួមមានការជ្រើសរើស ការបញ្ឈប់ពីការងារ ការដាក់ឱ្យនៅទំនេរដោយគ្មានបៀវត្ស ការចូលនិវត្តន៍ ការដំឡើងឋានន្តរស័ក្តិ ការដំឡើងថ្នាក់ ការរៀបចំបៀវត្ស ការផ្តល់រង្វាន់ ការផ្តល់គ្រឿងឥស្សរិយយស ការដាក់វិន័យ ការផ្ទេរភារកិច្ចនិងកិច្ចការដទៃទៀតសម្របសម្រួលការអនុវត្តគោលនយោបាយកំណែទម្រង់រដ្ឋបាល សាធារណៈរបស់រាជរដ្ឋាភិបាល រៀបចំ និងគ្រប់គ្រងព័ត៌មាន ទិន្នន័យ និងស្ថិតិពាក់ព័ន្ធនឹងមន្ត្រីរាជការ និងបុគ្គលិកទាំងក្នុងក្របខ័ណ្ឌ និងក្រៅក្របខ័ណ្ឌ ដោយបច្ចុប្បន្នភាពជាប្រចាំសម្របសម្រួលនិងរៀបចំធ្វើប័ណ្ណសម្គាល់មន្ត្រីរាជការជូនបុគ្គលិក ទាំងក្នុងក្របខ័ណ្ឌ និងក្រៅក្របខ័ណ្ឌ ដោយធ្វើការវាយតម្លៃអំពីតម្រូវការសម្រាប់បណ្តុះបណ្តាលរយៈពេលខ្លីនិងវែងឱ្យបានទៀងទាត់និងហ្មត់ចត់ ព្រមទាំងការធ្វើកម្មសិក្សានានាសម្របសម្រួល និងសហការអនុវត្តនីតិវិធីនៃការជ្រើសរើស កាបញ្ឈប់ពីការងារ ការដាក់ឱ្យនៅទំនេរដោយគ្មានបៀវត្ស ការចូលនិវត្តន៍ ការដំឡើងឋានន្តរស័ក្តិ ការដំឡើងថ្នាក់ ការរៀបចំបៀវត្ស ការផ្តល់រង្វាន់ ការផ្តល់គ្រឿងឥស្សរិយយស ការដាក់វិន័យ ការផ្ទេរភារកិច្ចមន្ត្រីរាជការដែលកំពុងបំពេញការងារនៅថ្នាក់ក្រោមជាតិនិងចាត់ចែងកិច្ចគាំពារសង្គមសម្រាប់មន្ត្រីរាជការ និងបុគ្គលិកទាំងក្នុងក្របខ័ណ្ឌ និងក្រៅក្របខ័ណ្ឌរបស់អគ្គនាយកដ្ឋានរបស់ខ្លួន និងក្រសួងត្រួតពិនិត្យ និងវាយតម្លៃគុណផលមន្ត្រីរាជការនិងបុគ្គលិកទាំងក្នុងក្របខ័ណ្ឌនិងក្រៅក្របខ័ណ្ឌ។[9]

**២.១.២.៣ នាយកដ្ឋានផែនការ ថវិកា និងសហប្រតិបត្តិការ**

នាយកដ្ឋានផែនការ ថវិកានិងសហប្រតិបត្តិការមានតួនាទី និងភារកិច្ចដូចតទៅ៖ ដឹកនាំសម្របសម្រួលជាមួយបណ្តាអង្គភាពក្រោមឱវាទក្រសួងក្នុងការរៀបចំគម្រោង ផែនការយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិល និងផែនការថវិកាប្រចាំឆ្នាំផ្សព្វផ្សាយឯកសារសម្រាប់ដំណើរការកសាងផែនការយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិល និងផែនការថវិកាប្រចាំឆ្នាំដល់បណ្តាអង្គភាពក្រោមឱវាទក្រសួង សម្របសម្រួលជាមួយអង្គភាពជំនាញ ដើម្បីផ្តល់យោបល់ជូន

[8] មាត្រា ១០ នៃអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

[9] ដ.ឯ.ម មាត្រា១១ នៃអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១

ថ្នាក់ដឹកនាំពាក់ព័ន្ធនឹងការចូលជាភាគីនៃសន្ធិសញ្ញា អនុសញ្ញា ពិធីសារ កិច្ចព្រមព្រៀង និងអនុស្សរណៈនៃការយោគយល់គ្នា មុននិងការស្នើសុំការសម្រេចដើម្បីអង្គភាពជំនាញចាត់ចែងបន្តប្រមូលចងក្រង និងរក្សាទុកនូវរាល់ឯកសារពាក់ព័ន្ធនិងកិច្ចព្រមព្រៀងនិងលិខិតូបរណ៍អន្តរជាតិពាក់ព័ន្ធវិស័យបរិស្ថានប្រមូលរក្សានិងធ្វើបច្ចុប្បន្នភាពបញ្ជីគម្រោង និងកម្មវិធីនានាដែលបាននិងកំពុងអនុវត្តដោយអង្គភាពក្រោមឱវាទក្រសួង ប្រមូលនិងរៀបចំឯកសារពាក់ព័ន្ធនឹងគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និងផែនការថវិកាពីបណ្តាអង្គភាពក្រោមឱវាទក្រសួង តាមដានសុពលភាព ប្រសិទ្ធភាព និងការអនុវត្តសន្ធិសញ្ញា អនុសញ្ញា ពិធីសារ កិច្ចព្រមព្រៀង និងអនុស្សរណៈនៃការយោគយល់គ្នា និងការងារផ្សេងៗទៀតដែលស្ថិតក្រោមក្របខ័ណ្ឌសហប្រតិបត្តិការ ឬជំនួយទ្វេភាគី និងពហុភាគីសម្របសម្រួលការអនុវត្តគោលនយោបាយនៃការកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។[10]

### ២.១.២.៤ នាយកដ្ឋានគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

នាយកដ្ឋានគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋមានតួនាទីនឹងភារកិច្ចដូចតទៅ៖ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ លើកសំណើ និងសម្របសម្រួលការងារលទ្ធកម្មសាធារណៈរបស់ក្រសួង រៀបចំនិងគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋដែលក្រសួងកាន់កាប់តាមឆ្នាំគោល និងឆ្នាំនីមួយៗព្រមទាំងការជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋ គ្រប់គ្រង និងបែងចែកការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ ឧបករណ៍ បរិក្ខារ សម្ភារៈ និងភស្តុភារទាំងអស់របស់ក្រសួង សម្របសម្រួលការរៀបចំធ្វើផែនការតម្រូវការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ ឧបករណ៍ បរិក្ខារ សម្ភារៈ និងភស្តុភារប្រចាំឆ្នាំដោយសហការជាមួយអង្គភាពក្រោមឱវាទក្រសួង គ្រប់គ្រងសារពើភណ្ឌ និងការប្រើប្រាស់ថែទាំនិងជួសជុលយានយន្ត ព្រមទាំងយានដ្ឋានរបស់ក្រសួង គ្រប់គ្រងការសាងសង់ ថែទាំនិងជួសជុលហេដ្ឋារចនាសម្ព័ន្ធអគារ ឧបករណ៍ បរិក្ខារ សម្ភារៈ និងបណ្តាញផ្សេងៗ ទទួលបន្ទុកការងារសន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យក្នុងអគារ និងក្នុងបរិវេណរបស់ក្រសួង រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ និងទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។[11]

### ២.១.២.៥ នាយកដ្ឋានហិរញ្ញវត្ថុ និងគណនេយ្យ

នាយកដ្ឋានហិរញ្ញវត្ថុនិងគណនេយ្យរបស់ក្រសួងមានតួនាទីនិងភារកិច្ចដូចតទៅ៖គ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ និងគណនេយ្យរបស់ក្រសួង ផ្សព្វផ្សាយ និងជំរុញការអនុវត្តគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងថវិការដ្ឋ សម្របសម្រួលការអនុវត្តគោលនយោបាយនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលទទួលខុសត្រូវ និងសហការជាមួយអង្គភាពពាក់ព័ន្ធនៅក្នុង

[10] មាត្រា១២ នៃអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

[11] ដ.ឯ.ម មាត្រា១៣ នៃអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១

ដំណើរការរៀបចំគ្រោងឥណទានប្រចាំឆ្នាំ គ្រប់គ្រងរដ្ឋទេយ្យបុរេប្រទាន និងចំណាយបេសកកម្មក្នុង និងក្រៅប្រទេស ពិនិត្យនិងតាមដានតារាងសមតុល្យរបស់ក្រសួង ដើម្បីធានាស្ថិរភាពនៃប្រតិបត្តិការហិរញ្ញវត្ថុ រៀបចំបើកផ្តល់ប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ លាភការ និងប្រាក់រង្វាន់ផ្សេងៗដល់មន្ត្រីរាជការ និងបុគ្គលិកទាំងក្នុងក្របខណ្ឌ និងក្រៅក្របខណ្ឌគ្រប់គ្រងគណនីទាំងអស់របស់ក្រសួង និងទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។[12]

### ២.១.៣ អគ្គនាយកដ្ឋានគោលនយោបាយ និងយុទ្ធសាស្ត្រ

អគ្គនាយកដ្ឋានគោលនយោបាយ និងយុទ្ធសាស្ត្រ បំពេញមុខងារជាសេនាធិការឱ្យក្រសួងបរិស្ថានក្នុងការរៀបចំតាមដានការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រពាក់ព័ន្ធ និងវិស័យបរិស្ថាននិងការអភិវឌ្ឍប្រកបដោយចីរភាពដែលមានតួនាទីភារកិច្ចៈ[13] ដឹកនាំ សម្របសម្រួល តាមដាន វាយតម្លៃការអនុវត្តផែនការសកម្មភាពកម្មវិធីគម្រោងនានា ពាក់ព័ន្ធ និងវិស័យបរិស្ថានការអភិវឌ្ឍប្រកបដោយចីរភាពជាការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងការអភិរក្សជីវៈចម្រុះ។

អគ្គនាយកដ្ឋានគោលនយោបាយ និងយុទ្ធសាស្ត្រមាននាយកដ្ឋានចំណុះដូចខាងក្រោមៈ

- នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ
- នាយកដ្ឋានប្រែប្រួលអាកាសធាតុ
- នាយកដ្ឋានសេដ្ឋកិច្ចបៃតង
- នាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- នាយកដ្ឋានជីវៈចម្រុះ។

#### ២.១.៣.១ នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ

នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុមានតួនាទីនិងភារកិច្ចដូចតទៅៈ គ្រប់គ្រងផ្នែករដ្ឋបាល និងសម្របសម្រួលការងារនិងដំណើរការទូទៅរបស់អគ្គនាយកដ្ឋានសម្របសម្រួលការរៀបចំលិខិតបទដ្ឋានគតិយុត្តផែនការយុទ្ធសាស្ត្រ ផែនការថវិកា ផែនការសកម្មភាពជាមួយនាយកដ្ឋានចំណុះឱ្យអគ្គនាយកដ្ឋានបំពេញការងារ ជាច្រកចេញចូលតែមួយសម្រាប់ការងារគោលនយោបាយ យុទ្ធសាស្ត្រ និង ផែនការពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងការអភិវឌ្ឍប្រកបដោយចីរភាពគ្រប់គ្រង និងចរាចរឯកសារនិងលិខិតបទដ្ឋានគតិយុត្តរបស់អគ្គនាយកដ្ឋាន លើកសំណើ និងសម្របសម្រួលការងារលទ្ធកម្មសាធារណៈរបស់អគ្គនាយកដ្ឋាន គ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិ ឧបករណ៍និងសម្ភារៈការិយាល័យរបស់អគ្គនាយកដ្ឋាន គ្រប់គ្រងនិងកសាងសមត្ថភាព

---

[12] មាត្រា១៤ នៃអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
[13] ដ.ឯ.ម មាត្រា១៥ នៃអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១

មន្ត្រីរាជការ និងបុគ្គលិកទាំងក្នុងក្របខណ្ឌនិងក្រៅក្របខណ្ឌរបស់អគ្គនាយកដ្ឋាន គ្រប់គ្រងគណនេយ្យ និងហិរញ្ញវត្ថុរបស់អគ្គនាយកដ្ឋានគ្រប់គ្រងការងារពិធីការកិច្ចគាំពារសង្គមនិងកិច្ចសហប្រតិបត្តិការរបស់អគ្គនាយកដ្ឋាន រៀបចំ តាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកានាយកដ្ឋានចំណុះឱ្យអគ្គនាយកដ្ឋានរៀបចំកិច្ចប្រជុំនានានិងធ្វើកំណត់ហេតុនិងរបាយការណ៍កិច្ចប្រជុំរបស់អគ្គនាយកដ្ឋាន និងទទួលអនុវត្តភារកិច្ចការផ្សេងៗទៀតដែលអគ្គនាយកដ្ឋានប្រគល់ឱ្យ។[14]

**២.១.៣.២ នាយកដ្ឋានប្រែប្រួលអាកាសធាតុ**

នាយកដ្ឋានប្រែប្រួលអាកាសធាតុមានតួនាទីនិងភារកិច្ចដូចតទៅ៖សម្របសម្រួលនិងតាមដានការអនុវត្តលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធីនិងគម្រោងនានាដែលរួមចំណែកដល់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការបន្សាំ នឹងការប្រែប្រួលអាកាសធាតុ ធ្វើរបាយការណ៍ជាប្រចាំពង្រឹងនិងពង្រីកកិច្ចសហការ និងការសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ បណ្តុះបណ្តាល និងកសាងសមត្ថភាពមន្ត្រីនាយកដ្ឋានជំនាញ ការគ្រប់គ្រងហិរញ្ញវត្ថុអង្កេតតាមដានការងារផ្ទៃក្នុង និងគ្រប់គ្រងការងាររដ្ឋបាលនានា ដែលពាក់ព័ន្ធនឹងតួនាទីនិងភារកិច្ចរបស់នាយកដ្ឋាន សម្របសម្រួល ជំរុញ និងផ្តល់ការគាំទ្រ បច្ចេកទេសដល់ស្ថាប័ននានាក្នុងការធ្វើសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់នៅតាមប្រភពបញ្ចេញនានា សម្របសម្រួល ការវាយតម្លៃហានិភ័យភាពងាយរងគ្រោះ និងកាលានុវត្តភាពនានាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងជំរុញការសិក្សា និងស្រាវជ្រាវវិទ្យាសាស្ត្រអាកាសធាតុ រៀបចំនិងគ្រប់គ្រងប្រព័ន្ធព័ត៌មាន និងចំណេះដឹងស្តីពីការប្រែប្រួលអាកាសធាតុ ព្រមទាំងអប់រំនិងផ្សព្វផ្សាយវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់រាជរដ្ឋាភិបាលជូនដល់សាធារណជន ដៃគូអភិវឌ្ឍ និងសហគមន៍អន្តរជាតិ សម្របសម្រួលការបញ្ជ្រាបការងារប្រែប្រួលអាកាសធាតុនៅក្នុងគោលនយោបាយ ផែនការ យុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ផែនការតាមវិស័យ និងផែនការថវិកាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបំពេញភារកិច្ចជាអង្គភាពបង្គោលជាតិនៃអនុសញ្ញា ពិធីសារនិងកិច្ចព្រមព្រៀងអន្តរជាតិនានាពាក់ព័ន្ធនឹងការងារប្រែប្រួលអាកាសធាតុ សម្របសម្រួលការងារជាមួយមន្ត្រីបង្គោល នៅតាមបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធសម្រាប់ការងារប្រែប្រួលអាកាសធាតុ និងទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គនាយកដ្ឋានប្រគល់ឱ្យ។[15]

**២.១.៣.៣ នាយកដ្ឋានសេដ្ឋកិច្ចបៃតង**

នាយកដ្ឋានសេដ្ឋកិច្ចបៃតងមានតួនាទី និងភារកិច្ចដូចតទៅ៖ សម្របសម្រួលនិងអនុវត្តលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធីនិងគម្រោងនានា ដើម្បីគាំទ្រ

---

[14] មាត្រា១៧ នៃអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

[15] ដ.ឯ.ម មាត្រា១៨ នៃអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១

ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង ព្រមទាំងពិនិត្យ តាមដានវាយតម្លៃ និងធ្វើរបាយការណ៍ជាប្រចាំ សម្របសម្រួលការសិក្សាស្រាវជ្រាវអំពីផលប៉ះពាល់ និងអត្ថប្រយោជន៍ជាក់ស្តែងនិងសកម្មភាពអភិវឌ្ឍន៍មកលើសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌ រៀបចំឧបករណ៍គាំទ្រដល់ការធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធនឹងថាមពល និរន្តរភាព ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ឧស្សាហកម្មបៃតង និងហិរញ្ញប្បទានបៃតង រៀបចំគោលនយោបាយនិងយន្តការនានាពាក់ព័ន្ធនឹងការប្រើប្រាស់និងផលិតកម្មដោយនិរន្តរភាព ការផ្តល់ស្លាកសញ្ញាបរិស្ថាន ការធ្វើលទ្ធកម្មសាធារណៈបៃតង និងការផ្តល់វិញ្ញាបនបត្របៃតង និងសេដ្ឋកិច្ចវិលជុំ ជំរុញការអនុវត្តផែនការទីក្រុងបៃតង ភាពងាយរងគ្រោះរបស់ទីក្រុងថាមពលនិរន្តរភាព ការដឹកជញ្ជូនបៃតង អាគារបៃតង ទីធ្លាសាធារណៈបៃតង និងបេតិកភណ្ឌវប្បធម៌កម្មន្តសាលបៃតង ការផ្គត់ផ្គង់ទឹកស្អាត និងការគ្រប់គ្រង សំណល់រឹង រាវ ដើម្បីឱ្យការអភិវឌ្ឍទីក្រុងនិងទីប្រជុំជនមាននិរន្តរភាព ផ្សព្វផ្សាយគោលនយោបាយ និងវិធានការនានារបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងការអភិវឌ្ឍសេដ្ឋកិច្ច បៃតងជូនដល់សាធារណជន ដៃគូអភិវឌ្ឍ និងសហគមន៍អន្តរជាតិ សម្របសម្រួលការងារជាមួយមន្ត្រីបង្គោលនៅតាមបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង និងទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។[16]

### ២.១.៣.៤ នាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

នាយកដ្ឋានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាមានតួនាទីនិងភារកិច្ចដូចតទៅ ៖សម្របសម្រួលនិងអនុវត្តលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធីនិងគម្រោងនានា ដើម្បីគាំទ្រដល់ការស្រាវជ្រាវ ការអភិវឌ្ឍ និងការប្រើប្រាស់បច្ចេកវិទ្យាទម្លាប់ប្រតិបត្តិ និងទម្រង់ដទៃទៀតនៃនវានុវត្តន៍សំដៅលើកកម្ពស់វិស័យបរិស្ថាន និងការអភិវឌ្ឍប្រកបដោយចីរភាពនិងឱកាសសម្រាប់ការកែលម្អដោយផ្អែកលើភស្តុតាងវិទ្យាសាស្ត្រ គាំទ្រដល់ដំណើរការនៃការបង្កើតវិធីសាស្ត្រសិក្សាស្រាវជ្រាវរួមពាក់ព័ន្ធនឹងការអភិវឌ្ឍប្រកបដោយចីរភាព កសាងនិងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល វិស័យឯកជន គ្រឹះស្ថានសិក្សាស្រាវជ្រាវ និងភាគីពាក់ព័ន្ធដើម្បីកៀរគរធនធាននិងការគាំទ្រសម្រាប់ពង្រឹងសមត្ថភាព លើកកម្ពស់ការយល់ដឹងរបស់សាធារណជនពីតួនាទីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៅក្នុងការគ្រប់គ្រងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការអភិវឌ្ឍប្រកបដោយចីរភាព សម្របសម្រួលនិងជំរុញការផ្ទេរបច្ចេកវិទ្យានិងប្រើប្រាស់បច្ចេកវិទ្យាថ្មីៗរួមទាំងបច្ចេកវិទ្យាណាណូ បច្ចេកវិទ្យាសិប្បនិម្មិត និងបច្ចេកវិទ្យាថាមពលនុយក្លេអ៊ែរសម្រាប់បម្រើឱ្យគោលបំណង សន្តិភាពរៀបចំបង្កើតក្រុមសីលធម៌ និងយន្តការសម្រាប់វាយតម្លៃការស្រាវជ្រាវនិងនវានុវត្តន៍ពាក់ព័ន្ធនឹងវិស័យបរិស្ថាន។[17]

[16] មាត្រា១៩ នៃអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
[17] ដ.ឯ.ម មាត្រា២០ នៃអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១

#### ២.១.៣.៥ នាយកដ្ឋានជីវៈចម្រុះ

នាយកដ្ឋានជីវៈចម្រុះបំពេញមុខងារជាមជ្ឈមណ្ឌលជីវៈចម្រុះជាតិមានតួនាទី និងភារកិច្ចដូចតទៅៈ សម្របសម្រួលនិងអនុវត្តលិខិតបទដ្ឋានគតិយុត្តគោលនយោបាយ ក្របខ័ណ្ឌការងារ នីតិវិធីផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធី និងគម្រោងនានា សម្រាប់ធានាការការពារនិងអភិរក្សធនធានធម្មជាតិជីវៈចម្រុះ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ី ជីវសុវត្ថិភាព និងការបែងចែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានពន្ធុ និងចំណេះដឹងជាប្រពៃណីពាក់ព័ន្ធ ព្រមទាំងពិនិត្យ តាមដាន វាយតម្លៃ និងធ្វើរបាយការណ៍ រៀបចំបង្កើត និងគ្រប់គ្រងប្រព័ន្ធព័ត៌មាន ទិន្នន័យនិងសម្របសម្រួលការប្រមូលនិងធ្វើសារពើភណ្ឌពាក់ព័ន្ធនឹងធនធានជីវៈចម្រុះ សេវាកម្មប្រព័ន្ធអេកូឡូស៊ី ជីវសុវត្ថិភាព ធនធានពន្ធុនិងចំណេះដឹងជាប្រពៃណីពាក់ព័ន្ធ វាយតម្លៃ គ្រប់គ្រង និងឃ្លាំមើលហានិភ័យពាក់ព័ន្ធ នឹងការគ្រប់គ្រងចលនាឆ្លងដែននៃសារពាង្គកាយកែច្នៃនិងកែច្នៃរស់ដោយសហការជាមួយស្ថាប័នជាតិ វិស័យឯកជន និងគ្រឹះស្ថានសិក្សាស្រាវជ្រាវ ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍនិងភាគីពាក់ព័ន្ធ ដើម្បីកៀរគរធនធាន និងគាំទ្រដល់ការអភិរក្សនិងការគ្រប់គ្រងធនធានជីវៈចម្រុះសេវាកម្មប្រព័ន្ធអេកូឡូស៊ីនិងជីវសុវត្ថិភាព រៀបចំ ចងក្រង និងផលិតសារអប់រំផ្សព្វផ្សាយ កម្មវិធីបណ្តុះបណ្តាលនិងកសាងសមត្ថភាពពាក់ព័ន្ធនឹងជីវៈចម្រុះ សេវាកម្មប្រព័ន្ធអេកូឡូស៊ី និងជីវសុវត្ថិភាព រួមទាំងរៀបចំទិវាជីវៈចម្រុះអន្តរជាតិ និងវេទិកាកេសរកូជាតិសម្របសម្រួលការរៀបចំរបាយកាណ៍ជាតិ និងការអនុវត្តកាតព្វកិច្ចនានារបស់រាជរដ្ឋាភិបាលនៅក្រោមអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះនិងពិធីសារពាក់ព័ន្ធ បំពេញភារកិច្ចជាអង្គភាពបង្គោលជាតិនៃអនុសញ្ញាពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនឹងជីវៈចម្រុះនិងសម្របសម្រួលការងារជាមួយមន្ត្រីបង្គោលនៅតាមបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធ និងទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។[18]

### ២.១.៤ អគ្គនាយកដ្ឋានគាំពារបរិស្ថាន

អគ្គនាយកដ្ឋានគាំពារបរិស្ថាន ជាសេនាធិការឱ្យក្រសួងបរិស្ថានក្នុងការគ្រប់គ្រងនិងសម្របសម្រួលកិច្ចគាំពារបរិស្ថាន ហើយមានតួនាទីនិងភារកិច្ចដូចខាងក្រោមៈ[19]

- ពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន តាមរយៈការចុះត្រួតពិនិត្យនិងធ្វើអធិការកិច្ចលើទីតាំង ឬមធ្យោបាយនៃផលិតកម្ម អាជីវកម្ម ឬសេវាកម្មដែលពាក់ព័ន្ធនឹងការបង្កើត ការផលិត ការប្រើប្រាស់ ការកែច្នៃ ការទាញយកធនធាន ការធ្វើប្រព្រឹត្តកម្មការបញ្ចេញចោល និងការទុកដាក់ចុងក្រោយនៃសំណល់ សារធាតុបំពុល ការបញ្ចេញសំឡេង រំញ័រ ការសាយភាយកាំរស្មី

[18] មាត្រា២១នៃអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
[19] ដ.ឯ.ម មាត្រា២២នៃអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១

វិទ្យុសកម្មនិងអេឡិចត្រូម៉ាញ៉េទិក និងត្រួតពិនិត្យការអនុវត្តផែនការគ្រប់គ្រងការបំពុលបរិស្ថាន របស់គម្រោងវិនិយោគ

- ផ្តល់ការគាំទ្របច្ចេកទេសត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងការងារគ្រប់គ្រងសំរាមសំណល់រឹង ទឹកកខ្វក់ទីប្រជុំជនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បំពេញភារកិច្ចជាអង្គភាពបង្គោលជាតិ ជំរុញនិងសម្របសម្រួលការអនុវត្តកិច្ចព្រមព្រៀង អនុសញ្ញាពិធីសារ អន្តរជាតិ និងការងារសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍជាតិ នឹងអន្តរជាតិពាក់ព័ន្ធនឹងវិស័យកិច្ចគាំពារបរិស្ថាន។

អគ្គនាយកដ្ឋានគាំពារបរិស្ថានមាននាយកដ្ឋានចំណុះ និងមន្ទីរពិសោធន៍មួយដែលមានថ្នាក់ស្មើនាយកដ្ឋានដូចខាងក្រោម៖

- នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ
- នាយកដ្ឋានគ្រប់គ្រងគុណភាពខ្យល់ សំឡេង និងរំញ័រ
- នាយកដ្ឋានគ្រប់គ្រងគុណភាពទឹក
- នាយកដ្ឋានគ្រប់គ្រងសំណល់រឹង
- នាយកដ្ឋានគ្រប់គ្រង់សារធាតុគ្រោះថ្នាក់
- នាយកដ្ឋានធិការកិច្ចនិងពង្រឹងការអនុវត្តច្បាប់
- មន្ទីរពិសោធន៍។

### ២.១.៤.១ នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ

នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុមានតួនាទីនិងភារកិច្ចដូចតទៅ៖បំពេញការងារជាច្រកចេញចូលតែមួយសម្រាប់ការងារគោលនយោបាយ យុទ្ធសាស្ត្រនិងផែនការពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងការអភិវឌ្ឍប្រកបដោយចីរភាព គ្រប់គ្រងនិងចរាចរឯកសារនិងលិខិតបទដ្ឋានគតិយុត្តរបស់អគ្គនាយកដ្ឋាន លើកសំណើ និងសម្របសម្រួលការងារលទ្ធកម្មសាធារណៈរបស់អគ្គនាយកដ្ឋាន គ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិឧបករណ៍ និងសម្ភារៈការិយាល័យរបស់អគ្គនាយកដ្ឋានកសាង សមត្ថភាពមន្ត្រីរាជការ និងបុគ្គលិកទាំងក្នុងក្របខណ្ឌនិងក្រៅក្របខណ្ឌរបស់អគ្គនាយកដ្ឋាន គ្រប់គ្រងគណនេយ្យនិងហិរញ្ញវត្ថុរបស់អគ្គនាយកដ្ឋាន គ្រប់គ្រងការងារពិធីការកិច្ចគាំពារសង្គម និងកិច្ចសហប្រតិបត្តិការរបស់អគ្គនាយកដ្ឋាន រៀបចំ និងតាមដាននិងការវាយតម្លៃការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកានាយកដ្ឋានចំណុះឱ្យអគ្គនាយកដ្ឋាន រៀបចំកិច្ចប្រជុំនានានិងធ្វើកំណត់ហេតុ និងរបាយការណ៍កិច្ចប្រជុំរបស់អគ្គនាយកដ្ឋាន និងទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

**២.១.៤.២ នាយកដ្ឋានគ្រប់គ្រងគុណភាពខ្យល់ សំឡេង និងរំញ័រ**

នាយកដ្ឋានគ្រប់គ្រងគុណភាពខ្យល់ សំឡេងនិងរំញ័រមានតួនាទីនិងភារកិច្ចដូចតទៅ៖ ពិនិត្យ និងផ្តល់យោបល់បច្ចេកទេសពាក់ព័ន្ធនឹងការបញ្ចេញសារធាតុបំពុលខ្យល់ សំឡេង និងរំញ័រនៃគម្រោងវិនិយោគសាធារណៈនិងឯកជន សិក្សាស្រាវជ្រាវ និងផ្សព្វផ្សាយបច្ចេកទេសបច្ចេកវិទ្យាគ្រប់គ្រងការបំពុលខ្យល់ សំឡេង និងរំញ័រពីប្រភពនិងអចល័ត និងភាពគ្រោះថ្នាក់នៃសារធាតុបំពុលខ្យល់ក្នុងខ្យល់បរិយាកាសនិងខ្យល់ក្នុងអគារ បំពេញភារកិច្ចជាអង្គភាពបង្គោលជាតិនៃអនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនឹងការការពារ និងការត្រួតពិនិត្យការបំពុលខ្យល់ ជាអាទិ៍បញ្ហាផ្សែងអ័ព្ទ អាស៊ីដបរិយាកាស កិច្ចការពារស្រទាប់អូហ្សូន និងការងារប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិពាក់ព័ន្ធនឹងការទប់ស្កាត់ការបំពុលខ្យល់ បំពេញភារកិច្ចពង្រឹងសមត្ថភាពជំនាញដល់មន្ទីរបរិស្ថានរាជធានី ខេត្ត អង្គភាពពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិអំពីការគ្រប់គ្រងការបំពុលខ្យល់ សំឡេង រំញ័រ និងកិច្ចការអនុសញ្ញា និងពិធីសារអន្តរជាតិពាក់ព័ន្ធ។

**២.១.៤.៣ នាយកដ្ឋានគ្រប់គ្រងគុណភាពទឹក**

នាយកដ្ឋានគ្រប់គ្រងគុណភាពទឹកមានតួនាទីនិងភារកិច្ចដូចតទៅ៖ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃគុណភាពទឹកនៅតំបន់ទទួលរងការបំពុល និងសាធាតុបំពុលដែលសាយភាយចូលក្នុងតំបន់ទឹកសាធារណៈ គ្រប់គ្រងទិន្នន័យប្រភពបង្កការបំពុលទឹក ទិន្នន័យគុណភាពទឹកទទួលរងការបំពុលនិងសារធាតុបំពុលដែលសាយភាយចូលក្នុងតំបន់ទឹកសាធារណៈពិនិត្យ និងវាយតម្លៃមធ្យោបាយគ្រប់គ្រង និងប្រព័ន្ធប្រព្រឹត្តកម្មសំណល់រាវទឹកកខ្វក់នៅតាមទីតាំងសកម្មភាពផលិតកម្ម អាជីវកម្ម និងសេវាកម្មដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ បំពេញភារកិច្ចជាអង្គភាពបង្គោលជាតិនៃអនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនឹងការគ្រប់គ្រងគុណភាពទឹកនៅក្នុងក្របខ័ណ្ឌតំបន់ និងពិភពលោក បំពេញភារកិច្ចពង្រឹងសមត្ថភាពជំនាញដល់មន្ទីរបរិស្ថានរាជធានី ខេត្ត អង្គភាពពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិអំពីការគ្រប់គ្រងការបំពុលទឹក និងកិច្ចព្រមព្រៀងអន្តរជាតិនិងតំបន់ពាក់ព័ន្ធនឹងបញ្ហាការបំពុលទឹកសហការជាមួយក្រសួងស្ថាប័ននិងអង្គភាពពាក់ព័ន្ធនិងអន្តរជាតិក្នុងការរៀបចំផែនការសកម្មភាពមធ្យោបាយ និងធនធានសម្រាប់ការឆ្លើយតបបន្ទាន់ចំពោះករណីគ្រោះឧបទ្ទវហេតុនៃការកំពប់ និងការលេចធ្លាយសារធាតុបំពុលបរិស្ថាន។

**២.១.៤.៤ នាយកដ្ឋានគ្រប់គ្រងសំណល់រឹង**

នាយកដ្ឋានគ្រប់គ្រងសំណល់រឹងមានតួនាទី និងភារកិច្ចដូចតទៅ ៖ត្រួតពិនិត្យនិងវាយតម្លៃមធ្យោបាយវិធីសាស្ត្រគ្រប់គ្រងសំណល់រឹងឬបរិក្ខារប្រព្រឹត្តកម្មសំណល់រឹងនៅតាមទីតាំងបង្កើតឬសកម្មភាពផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធវាយតម្លៃកិច្ចប្រតិបត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិលើការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ពិនិត្យនិងផ្តល់សេវាលើសំណើសុំការអនុញ្ញាតបញ្ចេញសំណល់រឹង ការប្រមូលទិញ ការនាំចេញ ការនាំចូលសំណល់រឹងកែច្នៃ ផលិតផលប្លាស្ទិក

និងការស្នើសុំធ្វើអាជីវកម្មកែច្នៃទាញយកធនធានបង្កើតឡដុតសំណល់ ធ្វើប្រព្រឹត្តកម្ម និងការទុកដាក់សំណល់រឹង ផ្សព្វផ្សាយបច្ចេកទេសនិងបច្ចេកវិទ្យាថ្មីៗសម្រាប់គ្រប់គ្រងសំណល់រឹងបំពេញភារកិច្ចពង្រឹងសមត្ថភាពជំនាញដល់មន្ទីរបរិស្ថានរាជធានី ខេត្ត អង្គភាពពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិអំពីការគ្រប់គ្រងសំណល់រឹង។

**២.១.៤.៥ នាយកដ្ឋានគ្រប់គ្រងសារធាតុគ្រោះថ្នាក់**

នាយកដ្ឋានគ្រប់គ្រងសារធាតុគ្រោះថ្នាក់មានតួនាទី និងភារកិច្ចដូចតទៅៈ តាមដាននិងត្រួតពិនិត្យការគ្រប់គ្រងសំណល់គ្រោះថ្នាក់ សំណល់វេជ្ជសាស្ត្រ និងសំណល់វេជ្ជសាស្ត្រដែលមានផ្ទុកសារធាតុវិទ្យុសកម្មនៅតាមសកម្មភាពផលិតកម្ម អាជីវកម្ម ឬសេវាកម្មរួមទាំងសកម្មភាពនាំចេញនាំចូល និងដឹកឆ្លងកាត់ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ អប់រំផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្ត ស្តង់ដា និងគោលការណ៍ណែនាំបច្ចេកទេសដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសារធាតុគ្រោះថ្នាក់ សំណល់គ្រោះថ្នាក់ សំណល់វេជ្ជសាស្ត្រ និងសំណល់ដែលមានផ្ទុកសារធាតុវិទ្យុសកម្ម សម្របសម្រួលជាមួយ ស្ថាប័នឬអង្គភាពពាក់ព័ន្ធជាតិ និងអន្តរជាតិក្នុងការរៀបចំផែនការសកម្មភាពឆ្លើយតបនិងការត្រៀមសម្ភារៈមធ្យោបាយ និងធនធានសម្រាប់ការឆ្លើយតបបន្ទាន់ចំពោះករណីគ្រោះឧបទ្ទវហេតុនៃការឆេះ ការផ្ទុះ ការកំពប់ការលេចធ្លាយសារធាតុគ្រោះថ្នាក់ ឬសំណល់គ្រោះថ្នាក់ រៀបចំរបាយការណ៍វាយតម្លៃប្រចាំឆ្នាំអំពីស្ថានភាពនៃការគ្រប់គ្រងសារធាតុគ្រោះ ថ្នាក់សំណល់គ្រោះថ្នាក់ សំណល់វេជ្ជសាស្ត្រ និងសំណល់ដែលមានផ្ទុកសារធាតុវិទ្យុសកម្ម។

**២.១.៤.៦ នាយកដ្ឋានអធិការកិច្ចនិងពង្រឹងការអនុវត្តច្បាប់**

នាយកដ្ឋានអធិការកិច្ចនិងពង្រឹងការអនុវត្តច្បាប់មានតួនាទី និងភារកិច្ចដូចតទៅៈតាមដាននិងត្រួតពិនិត្យការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន និងការរៀបចំផែនការសកម្មភាពនិងផែនការថវិកា ផ្សព្វផ្សាយ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធកិច្ចគាំពារបរិស្ថានដល់ម្ចាស់ទីតាំង សកម្មភាពផលិតកម្ម អាជីវកម្ម និងសេវាកម្មដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ករណីលើកសំណើចាត់វិធានការបទល្មើសបំពុលបរិស្ថាន ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន និងបទល្មើសមិនបានអនុវត្តតាមផែនការគ្រប់គ្រងបរិស្ថានដូចមានកំណត់ក្នុងរបាយកាណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងកិច្ចសន្យាការពារបរិស្ថាននៃគម្រោងវិនិយោគសាធារណៈ និងគម្រោងវិនិយោគឯកជន រៀបចំនីតិវិធីសម្រាប់ការត្រួតពិនិត្យនិងអធិការកិច្ចបទល្មើសបំពុលបរិស្ថាននៅទីតាំងសកម្មភាព ផលិតកម្ម អាជីវកម្ម និងសេវាកម្ម ដែលពាក់ព័ន្ធការបញ្ចេញសំណល់ឬសារធាតុបំពុលចូលក្នុងបរិស្ថានណែនាំដល់មន្ទីរបរិស្ថានរាជធានី ខេត្តអំពីនីតិវិធីសម្រាប់ការត្រួតពិនិត្យនិងអធិការកិច្ចបទល្មើសបំពុលបរិស្ថាន និងអង្កេតសហការជាមួយនាយកដ្ឋានចំណុះនៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន អង្គភាពពាក់ព័ន្ធ និងមន្ទីរបរិស្ថាន រាជធានី ខេត្ត ចុះធ្វើអធិការកិច្ច ដោះស្រាយវិវាទ និងបណ្តឹងការបំពុលបរិស្ថាន។

#### ២.១.៤.៧ មន្ទីរពិសោធន៍

មន្ទីរពិសោធន៍មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំគ្រប់គ្រងថែទាំនិងធ្វើទំនើបកម្មឧបករណ៍និងបរិក្ខារពិសោធន៍គុណភាពបរិស្ថាន អាស៊ីដបរិយាកាស សារធាតុវិទ្យុសកម្ម គីមីគ្រោះថ្នាក់បរិស្ថាន ជីវសាស្ត្រ លោហិតសាស្ត្រ បាក់តេរីសាស្ត្រ ពន្ធុសាស្ត្រនិងពង្រីកវិសាលភាពវិភាគ
- រៀបចំនិងធ្វើបច្ចុប្បន្នភាពបទដ្ឋានវិធីសាស្ត្រវិភាគថ្មីៗ ស្របតាមបទដ្ឋានអន្តរជាតិ លើការវិភាគគុណភាពបរិស្ថាន អាស៊ីដបរិយាកាស សារធាតុវិទ្យុសកម្ម គីមីគ្រោះថ្នាក់បរិស្ថាន ជីវសាស្ត្រ លោហិតសាស្ត្រ បាក់តេរីសាស្ត្រ និងពន្ធុសាស្ត្រ
- ផ្តល់សេវាកម្មក្នុងការចុះយកសំណាកពិសោធន៍ និងវិភាគសំណាកដល់អង្គភាពនានានៃក្រសួងបរិស្ថាន ស្ថាប័នរដ្ឋ និងវិស័យឯកជន។

### ២.១.៥ អគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិ

អគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិជាសេនាធិការឱ្យក្រសួងបរិស្ថាន ក្នុងការគ្រប់គ្រងនិងសម្របសម្រួលការងារអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប និងប្រកបដោយចីរភាពក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា ហើយមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖[20]

- រៀបចំនីតិវិធីសម្រាប់គ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ និងជីវៈចម្រុះនៅតាមតំបន់ការពារធម្មជាតិ ដីគោក ដីសើមទឹកសាប និងតំបន់ឆ្នេរនិងសមុទ្រ
- អប់រំនិងផ្សព្វផ្សាយអំពីច្បាប់ គោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រជាតិ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ
- ពង្រឹងនិងជំរុញការអនុវត្តច្បាប់លើការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិដោយចុះត្រួតពិនិត្យនិងធ្វើអធិការកិច្ចលើដំណើរការគ្រប់គ្រងការពារ និងអភិរក្សធនធានធម្មជាតិ និងជីវៈចម្រុះនៅតាមតំបន់ការពារធម្មជាតិនីមួយៗ
- តាមដាន ត្រួតពិនិត្យ វាយតម្លៃនិងតម្រង់ទិសលើការអនុវត្តគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធលើការគ្រប់គ្រងរបស់មន្ទីរបរិស្ថាននិងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ និងជំរុញការរៀបចំហេដ្ឋារចនាសម្ព័ន្ធក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិដើម្បីបម្រើផលប្រយោជន៍សេដ្ឋកិច្ចសង្គមនិងបរិស្ថាន។

អគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិមាននាយកដ្ឋានចំណុះដូចខាងក្រោម៖

[20] មាត្រា៣១នៃអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

- នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ
- នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងកើតទន្លេមេគង្គ
- នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាប
- នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងត្បូងបឹងទន្លេសាប
- នាយកដ្ឋានអភិរក្សតំបន់ដីសើមទឹកសាប
- នាយកដ្ឋានអភិរក្សតំបន់ឆ្នេរនិងសមុទ្រ
- នាយកដ្ឋានអធិការកិច្ចនិងពង្រឹងការអនុវត្តច្បាប់។

**២.១.៥.១ នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ**

នាយកដ្ឋានរដ្ឋបាល ផែនការនិងហិរញ្ញវត្ថុមានតួនាទីនិងភារកិច្ចដូចតទៅ៖សម្របសម្រួលការរៀបចំលិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការថវិកា ផែនការសកម្មភាពជាមួយនាយកដ្ឋានចំណុះឱ្យអគ្គនាយកដ្ឋាន បំពេញការងារជាមួយច្រកចេញចូលតែមួយសម្រាប់ការងារគោលនយោបាយយុទ្ធសាស្ត្រ និងផែនការពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងការអភិវឌ្ឍប្រកបដោយចីរភាព គ្រប់គ្រងនិងចរាចរឯកសារនិងលិខិតបទដ្ឋានគតិយុត្តរបស់អគ្គនាយកដ្ឋាន លើកសំណើនិងសម្របសម្រួលការងារលទ្ធកម្មសាធារណៈរបស់អគ្គនាយកដ្ឋានរៀបចំនិងតាមដាននិងការវាយតម្លៃការអនុវត្តគោលននយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកានាយកដ្ឋានចំណុះឱ្យអគ្គនាយកដ្ឋានធ្វើកំណត់ហេតុនិងរបាយការណ៍កិច្ចប្រជុំរបស់អគ្គនាយកដ្ឋាន។

**២.១.៥.២ នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងកើតទន្លេមេគង្គ**

នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងកើតទន្លេមេគង្គមានតួនាទី និងភារកិច្ចដូចតទៅ៖ គ្រប់គ្រងធនធានធម្មជាតិជីវៈចម្រុះនិងសេវាកម្មប្រព័ន្ធអេកូឡូស៊ីក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ សហការស្រាវជ្រាវ ទប់ស្កាត់ បង្ក្រាប និងដោះស្រាយបទល្មើសធនធានធម្មជាតិនិងបរិស្ថានក្នុងតំបន់ការពារធម្មជាតិ ចុះពង្រឹងអនុវត្តលើការងារគ្រប់គ្រង អភិរក្ស ថែរក្សាធនធានធម្មជាតិ ជីវៈចម្រុះ និងចូលរួមទប់ស្កាត់ការនាំចូលប្រភេទសត្វនិងរុក្ខជាតិរាតត្បាតដែលគំរាមកំហែងដល់ប្រភេទដើមនៅក្នុងតំបន់ការពារធម្មជាតិ រៀបចំចងក្រងទិន្នន័យប្រភេទសត្វនិងរុក្ខជាតិ ពិសេសប្រភេទធនធានសេនេទិកដែលជិតផុតពូជ កម្រ កំពុងរងគ្រោះ និងងាយរងគ្រោះ និងរៀបចំផែនការអភិរក្ស និងស្តារឡើងវិញនៅតាមតំបន់ការពារធម្មជាតិ តម្រង់ទិសលើការអនុវត្តគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងរបស់មន្ទីរបរិស្ថាន និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ និងជំរុញការរៀបចំហេដ្ឋារចនាសម្ព័ន្ធក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិដើម្បីបម្រើផលប្រយោជន៍សេដ្ឋកិច្ច សង្គម និងបរិស្ថាន។

**២.១.៥.៣ នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាប**

នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាបមានតួនាទីនិងភារកិច្ចៈ ចុះពង្រឹងអនុវត្តលើការងារគ្រប់គ្រង អភិរក្ស ថែរក្សាធនធានធម្មជាតិ ជីវៈចម្រុះនិងចូលរួមទប់ស្កាត់ការនាំចូលប្រភេទសត្វនិងរុក្ខជាតិរាតត្បាតដែលគំរាមកំហែងដល់ប្រភេទដើម នៅក្នុងតំបន់ការពារធម្មជាតិ សិក្សារៀបចំព្រំតំបន់ការពារធម្មជាតិ និងកសាងផែនទីសម្រាប់ការកំណត់និងបែងចែកតំបន់គ្រប់គ្រង ការចុះបញ្ជីដីរដ្ឋនិងការបង្កើតតំបន់ការពារធម្មជាតិ និងជីវៈចម្រុះក្នុងតំបន់ការពារធម្មជាតិ រៀបចំចងក្រងទិន្នន័យប្រភេទសត្វនិងរុក្ខជាតិពិសេសប្រភេទធនធានសេនេទិកដែលជិតផុតពូជ កម្រកំពុងរងគ្រោះ និងងាយរងគ្រោះ និងរៀបចំផែនការអភិរក្សនិងស្តារឡើងវិញនៅតាមតំបន់ការពារធម្មជាតិ តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងតម្រង់ទិសលើការអនុវត្តគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងរបស់មន្ទីរបរិស្ថាន និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ និងជំរុញការរៀបចំហេដ្ឋារចនាសម្ព័ន្ធក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិដើម្បីបម្រើផលប្រយោជន៍សេដ្ឋកិច្ច សង្គម និងបរិស្ថាន។

**២.១.៥.៤ នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងត្បូងបឹងទន្លេសាប**

នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងត្បូងបឹងទន្លេសាបមានតួនាទី និងភារកិច្ចដូចជាៈ ចុះពង្រឹងអនុវត្តលើការងារគ្រប់គ្រង អភិរក្ស ថែរក្សាធនធានធម្មជាតិ ជីវៈចម្រុះ និងចូលរួមទប់ស្កាត់ការនាំចូលប្រភេទសត្វនិងរុក្ខជាតិរាតត្បាត ដែលគំរាមកំហែងដល់ប្រភេទដើមនៅក្នុងតំបន់ការពារធម្មជាតិ សិក្សារៀបចំព្រំតំបន់ការពារធម្មជាតិនិងកសាងផែនទីសម្រាប់ការកំណត់និងបែងចែកតំបន់គ្រប់គ្រងការចុះបញ្ជីដីរដ្ឋនិងការបង្កើតតំបន់ការពារធម្មជាតិថ្មីៗបន្ថែម សម្រាប់ការពារ អភិរក្សនិងប្រើប្រាស់ប្រកបដោយចីរភាពលើធនធានធម្មជាតិ និងជីវៈចម្រុះក្នុងតំបន់ការពារធម្មជាតិ តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងតម្រង់ទិសលើការអនុវត្តគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងរបស់មន្ទីរបរិស្ថាននិងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ និងជំរុញការរៀបចំហេដ្ឋារចនាសម្ព័ន្ធក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិដើម្បីបម្រើផលប្រយោជន៍សេដ្ឋកិច្ច សង្គម និងបរិស្ថាន។

**២.១.៥.៥ នាយកដ្ឋានអភិរក្សតំបន់ដីសើមទឹកសាប**

នាយកដ្ឋានអភិរក្សតំបន់ដីសើមទឹកសាបមានតួនាទី និងភារកិច្ចៈ សិក្សារៀបចំព្រំតំបន់ ការពារធម្មជាតិ និងកសាងផែនទីសម្រាប់ការកំណត់និងបែងចែកតំបន់គ្រប់គ្រងការចុះបញ្ជីដីរដ្ឋ និងការបង្កើតតំបន់ការពារធម្មជាតិដីសើមទឹកសាបថ្មីៗបន្ថែមសម្រាប់ការពារអភិរក្ស និងប្រើប្រាស់ប្រកបដោយចីរភាពលើធនធានធម្មជាតិ និងជីវៈចម្រុះក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងតម្រង់ទិសលើការអនុវត្តគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងរបស់មន្ទីរបរិស្ថាននិងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោម

ក្នុងការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ និងជំរុញការរៀបចំហេដ្ឋារចនាសម្ព័ន្ធក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ដើម្បីបម្រើផលប្រយោជន៍សេដ្ឋកិច្ច សង្គម និងបរិស្ថាន។

**២.១.៥.៦ នាយកដ្ឋានអភិរក្សតំបន់ឆ្នេរនិងសមុទ្រ**

នាយកដ្ឋានអភិរក្សតំបន់ឆ្នេរ និងសមុទ្រមានតួនាទីនិងភារកិច្ចដូចតទៅៈសម្របសម្រួលនិងសហការស្រាវជ្រាវ ទប់ស្កាត់ បង្ក្រាបនិងដោះស្រាយបទល្មើសធនធានធម្មជាតិនិងបរិស្ថាននៅតាមតំបន់អភិរក្សឆ្នេរនិងសមុទ្រ សិក្សារៀបចំព្រំប្រទល់តំបន់ការពារធម្មជាតិ និងកសាងផែនទីសម្រាប់ការកំណត់និងបែងចែកតំបន់គ្រប់គ្រង ការចុះបញ្ជីដីរដ្ឋ និងការបង្កើតតំបន់ការពារធម្មជាតិថ្មីៗបន្ថែមសម្រាប់ការពារ អភិរក្ស និងប្រើប្រាស់ប្រកបដោយចីរភាពលើធនធានធម្មជាតិ និងជីវៈចម្រុះក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងតម្រង់ទិសលើការអនុវត្តគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនិងការគ្រប់គ្រងរបស់មន្ទីរបរិស្ថាន និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ និងជំរុញការរៀបចំហេដ្ឋារចនាសម្ព័ន្ធក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិដើម្បីបម្រើផលប្រយោជន៍សេដ្ឋកិច្ច សង្គម និងបរិស្ថាន។

**២.១.៥.៧ នាយកដ្ឋានអធិការកិច្ច និងពង្រឹងការអនុវត្តច្បាប់**

នាយកដ្ឋានអធិការកិច្ចនិងពង្រឹងការអនុវត្តច្បាប់មានតួនាទីនិងភារកិច្ចដូចខាងក្រោមៈ បណ្តុះបណ្តាលសមត្ថភាពមន្ត្រីជំនាញ ព្រមទាំងភាគីពាក់ព័ន្ធក្នុងការចូលរួមធ្វើអធិការកិច្ច ពិសេសពង្រឹងជំនាញអនុវត្តច្បាប់ដល់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ឱ្យមានសមត្ថភាពនិងប្រសិទ្ធភាពសម្រាប់កិច្ចការពារ និងអភិរក្សធនធានក្នុងតំបន់ការពារធម្មជាតិ ដឹកនាំមន្ត្រីនគរបាលយុត្តិធម៌និងភ្នាក់ងារនគរបាលយុត្តិធម៌ក្នុងការស្រាវជ្រាវនិងប្រមូលចងក្រងទិន្នន័យបទល្មើសធនធានធម្មជាតិ ការពិន័យអន្តរការណ៍ ការកសាងសំណុំរឿងបទល្មើសធនធានធម្មជាតិដើម្បីពិនិត្យតាមដាននិងចាត់វិធានការបន្ត ដឹកនាំនិងសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធដើម្បីធ្វើអធិការកិច្ចដោះស្រាយវិវាទនិងបណ្តឹងលើទីតាំង ឬគោលដៅសកម្មភាពផលិតកម្ម អាជីវកម្ម និងសេវាកម្មនានា ដែលមានផលប៉ះពាល់ដល់ប្រព័ន្ធសេវាកម្មអេកូឡូស៊ីក្នុងតំបន់ការពារធម្មជាតិ តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងតម្រង់ទិសលើការអនុវត្តច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងរបស់មន្ទីរបរិស្ថាន និងការអនុវត្តមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ។

**២.១.៦ អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន**

អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋានមានតួនាទី និងភារកិច្ចៈ រៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនិងការពារអភិវឌ្ឍន៍សហគម៍មូលដ្ឋាននិងសហគមន៍តំបន់ការពារធម្មជាតិ គ្រប់គ្រងកិច្ចការរដ្ឋបាល ផែនការហិរញ្ញវត្ថុ គណនេយ្យ និងមន្ត្រីរបស់អគ្គនាយកដ្ឋាន ដឹកនាំការសិក្សាស្រាវជ្រាវ ការរៀបចំបង្កើត និងការគ្រប់គ្រងសហគមន៍មូលដ្ឋាន ការគ្រប់គ្រងតំបន់បេតិកភណ្ឌធម្មជាតិ សម្រួបសម្រួលសហការជាមួយ

ក្រសួង ស្ថាប័ន អង្គភាពជំនាញពាក់ព័ន្ធនិងវិស័យឯកជនក្នុងការគ្រប់គ្រងគម្រោងវិនិយោគទេសចរណ៍ធម្មជាតិ ដឹកនាំការសិក្សាស្រាវជ្រាវ ការរៀបចំបង្កើត និងការគ្រប់គ្រងតំបន់បេតិកភណ្ឌធម្មជាតិ។[21]

អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋានមាននាយកដ្ឋានចំណុះដូចខាងក្រោម៖

- នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ
- នាយកដ្ឋានជីវភាពសហគមន៍
- នាយកដ្ឋានបេតិកភណ្ឌ
- នាយកដ្ឋានទេសចរណ៍ធម្មជាតិ។

**២.១.៦.១ នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ**

នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖សម្របសម្រួលការរៀបចំលិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការថវិកា ផែនការសកម្មភាពជាមួយនាយកដ្ឋានចំណុះឱ្យអគ្គនាយកដ្ឋានបំពេញការងារជាច្រកចេញចូលតែមួយ សម្រាប់ការងារគោលនយោបាយយុទ្ធសាស្ត្រនិងផែនការពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងការអភិវឌ្ឍប្រកបដោយចីរភាព លើកសំណើនិងសម្របសម្រួលការងារលទ្ធកម្មសាធារណៈរបស់អគ្គនាយកដ្ឋាន រៀបចំនិងតាមដានវាយតម្លៃការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពនិងផែនការថវិកានាយកដ្ឋានចំណុះឱ្យអគ្គនាយកដ្ឋាន និងរៀបចំកិច្ចប្រជុំនានា និងធ្វើកំណត់ហេតុ និងរបាយការណ៍កិច្ចប្រជុំរបស់អគ្គនាយកដ្ឋាន។

**២.១.៦.២ នាយកដ្ឋានជីវភាពសហគមន៍**

នាយកដ្ឋានជីវភាពសហគមន៍មានតួនាទីនិងភារកិច្ចដូចតទៅ៖ រៀបចំកិច្ចព្រមព្រៀង ផែនការគ្រប់គ្រង និងកម្មវិធីអភិវឌ្ឍន៍សហគមន៍តំបន់ការពារធម្មជាតិ សម្របសម្រួលការរៀបចំលក្ខន្តិកៈ និងការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិតាមអាណត្តិ រៀបចំកម្មវិធីបណ្តុះបណ្តាលស្តីពី ការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ការគ្រប់គ្រងធនធានធម្មជាតិក្នុងសហគមន៍តំបន់ការពារធម្មជាតិ ការពារ អភិរក្ស និងស្តារធនធានធម្មជាតិ និងជីវៈចម្រុះក្នុងសហគមន៍តំបន់ការពារធម្មជាតិដោយសហការជាមួយស្ថាប័នអង្គភាពពាក់ព័ន្ធនិងដៃគូអភិវឌ្ឍ សម្របសម្រួល ជំរុញនិងលើកទឹកចិត្តដល់ប្រជាសហគមន៍តំបន់ការពារធម្មជាតិក្នុងការបង្កើតនិងផ្សារភ្ជាប់ផលិតផលសហគមន៍ទៅនឹងទីផ្សារ សម្របសម្រួលដោះស្រាយទំនាស់ដែលកើតមាននៅក្នុងដីធ្លីដែលគ្រប់គ្រងដោយសហគមន៍តំបន់ការពារធម្មជាតិ សម្របសម្រួលការអនុវត្តកិច្ចព្រមព្រៀង អនុសញ្ញា និងពិធីសារពាក់ព័ន្ធនឹងសហគមន៍តំបន់ការពារធម្មជាតិ។

[21] មាត្រា៤០ នៃអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

#### ២.១.៦.៣ នាយកដ្ឋានតំបន់បេតិកភណ្ឌ

នាយកដ្ឋានតំបន់បេតិកភណ្ឌមានតួនាទីនិងភារកិច្ចដូចតទៅ៖សម្របសម្រួល និងសហការក្នុងការសិក្សាស្រាវជ្រាវចងក្រងឯកសារបេតិកភណ្ឌធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិ រៀបចំកំណត់ព្រំប្រទល់តំបន់គ្រប់គ្រង និងធ្វើផែនទីសម្រាប់តំបន់បេតិកភណ្ឌដោយសហការជាមួយក្រសួង ស្ថាប័ននិងអង្គភាពពាក់ព័ន្ធ ការពារអភិរក្ស និងស្តារធនធានក្នុងតំបន់បេតិកភណ្ឌធម្មជាតិឱ្យមាននិរន្តរភាពដោយសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធចូលរួមថែរក្សាប្រពៃណីទំនៀមទម្លាប់ និងចូលរួមចំណែកលើកកម្ពស់ សម្របសម្រួល រៀបចំនិងអនុវត្តគោលការណែនាំនានា សម្រាប់កិច្ចការអភិរក្សតំបន់បេតិកភណ្ឌធម្មជាតិ រួមទាំងសកម្មភាពទេសចរណ៍វប្បធម៌និងធម្មជាតិ ចូលរួមសហការក្នុងការស្រាវជ្រាវ តាមដាន ទប់ស្កាត់និងបង្ក្រាបបទល្មើសពាក់ព័ន្ធនឹងបេតិភណ្ឌក្នុងតំបន់ការពារធម្មជាតិ ព្រមទាំងសម្របសម្រួល រៀបចំ និងបង្កើតមជ្ឈមណ្ឌលអភិរក្សវប្បធម៌សហគមន៍ជនជាតិដើមភាគតិចនៅក្នុងតំបន់ការពារធម្មជាតិ។

#### ២.១.៦.៤ នាយកដ្ឋានទេសចរណ៍ធម្មជាតិ

នាយកដ្ឋានទេសចរណ៍ធម្មជាតិមានតួនាទីនិងភារកិច្ចដូចតទៅ៖សម្របសម្រួលនិងគ្រប់គ្រងគម្រោងវិនិយោគអភិវឌ្ឍន៍សហគមន៍ទេសចរណ៍ធម្មជាតិដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ សិក្សាកំណត់ទីតាំងនិងបោះបង្គោលព្រំប្រទល់ដីសម្រាប់គម្រោងវិនិយោគអភិវឌ្ឍទេសចរណ៍ធម្មជាតិ នៅក្នុងតំបន់ការពារធម្មជាតិ ពិនិត្យនិងកែសម្រួលផែនការមេនិងកម្មវិធីអភិវឌ្ឍន៍សម្រាប់គម្រោងវិនិយោគអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិ សម្របសម្រួលដោះស្រាយទំនាស់ និងភាពមិនប្រក្រតីផ្សេងៗដែលកើតឡើងពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីនិងគម្រោងវិនិយោគអភិវឌ្ឍទេសចរណ៍ធម្មជាតិ ព្រមទាំងសិក្សារៀបចំបង្កើតផលិតផលទេសចរណ៍ក្នុងតំបន់ការពារធម្មជាតិ និងការពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិនិងសហគមន៍មូលដ្ឋានលើការអភិវឌ្ឍទេសចរណ៍ធម្មជាតិដោយសហការជាមួយក្រសួង ស្ថាប័ននិងដៃគូអភិវឌ្ឍពាក់ព័ន្ធ។

### ២.១.៧ អគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន

អគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថានជាសេនាធិការឱ្យក្រសួងបរិស្ថានក្នុងការគ្រប់គ្រងទិន្នន័យបរិស្ថាននិងដឹកនាំសម្របសម្រួលការងារអប់រំ និងការផ្សព្វផ្សាយព័ត៌មានបរិស្ថានព្រមទាំងចាត់ចែងរៀបចំព្រឹត្តិការណ៍បរិស្ថានសំខាន់ៗ ហើយមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖[22]

- រៀបចំនិងគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបរិស្ថាន
- រៀបចំរបាយការណ៍ស្តីពីស្ថានភាពបរិស្ថានរៀងរាល់ ៤(បួន)ឆ្នាំម្តង ដោយមានការសហការនិងសម្របសម្រួលជាមួយស្ថាប័ន និងអង្គភាពពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

[22] មាត្រា៤៦ នៃអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

- លើកកម្ពស់ការយល់ដឹងអំពីបរិស្ថានដល់សាធារណជន តាមរយៈការបញ្ជ្រាបការអប់រំបរិស្ថានក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ការផ្សព្វផ្សាយចំណេះដឹងអំពីបរិស្ថាន និងការលើកទឹកចិត្តការប្រតិបត្តិមេត្រីបរិស្ថាន
- ផលិត និងផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានស្តីពីសកម្មភាព ស្ថានភាព និងសមិទ្ធផលទាក់ទងនឹងកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ និងការរស់នៅប្រកបដោយចីរភាព។

អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថានមាននាយកដ្ឋានចំណុះដូចខាងក្រោមៈ

- នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ
- នាយកដ្ឋានសេវាកម្មព័ត៌មានភូមិសាស្ត្រ
- នាយកដ្ឋានអប់រំបរិស្ថាន
- នាយកដ្ឋានព័ត៌មាន និងផ្សព្វផ្សាយបរិស្ថាន
- នាយកដ្ឋានរង្វាន់ និងលើកទឹកចិត្ត។

### ២.១.៧.១ នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ

នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុមានតួនាទីនិងភារកិច្ច ៖ បំពេញការងារជាច្រកចេញចូលតែមួយសម្រាប់ការងារគោលនយោបាយយុទ្ធសាស្ត្រ និងផែនការពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងការអភិវឌ្ឍប្រកបដោយចីរភាព គ្រប់គ្រងនិងកសាងសមត្ថភាពមន្ត្រីរាជការ និងបុគ្គលិកទាំងក្នុងក្របខណ្ឌ និងក្រៅក្របខណ្ឌរបស់អគ្គនាយកដ្ឋាន រៀបចំនិងតាមដាននិងការវាយតម្លៃការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកានាយកដ្ឋានចំណុះឱ្យអគ្គនាយកដ្ឋាន ព្រមទាំងរៀបចំកិច្ចប្រជុំនានានិងធ្វើកំណត់ហេតុ និងរបាយការណ៍កិច្ចប្រជុំរបស់អគ្គនាយកដ្ឋាន។

### ២.១.៧.២ នាយកដ្ឋានសេវាកម្មព័ត៌មានភូមិសាស្ត្រ

នាយកដ្ឋានសេវាកម្មព័ត៌មានភូមិសាស្ត្រមានតួនាទីនិងភារកិច្ចដូចតទៅៈ ផលិតនិងផ្តល់សេវាកម្មព័ត៌មានភូមិសាស្ត្ររួមទាំងផែនទី ដើម្បីគាំទ្រដល់កិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ ការអភិវឌ្ឍប្រកបដោយចីរភាព និងកិច្ចការពាក់ព័ន្ធនានា សិក្សារៀបចំបង្កើតនិងសម្របសម្រួលការអនុវត្តវិធីសាស្ត្រសារពើភណ្ឌធនធានព្រៃឈើនិងសន្និធិកាបូនរួមទាំងបង្កើតមេគុណបំភាយនិងស្រូបនៃកាបូនព្រៃឈើការកំណត់ជាមួយអង្គភាពនានាក្រោមឱវាទក្រសួងស្ថាប័នពាក់ព័ន្ធដៃគូអភិវឌ្ឍ និងវិស័យឯកជន ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និងបង្កើនប្រសិទ្ធភាពការងារគ្រប់គ្រង ទិន្នន័យបរិស្ថាន ការសាងនិងពង្រឹងសមត្ថភាពជំនាញប្រព័ន្ធព័ត៌មានភូមិសាស្ត្រទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

### ២.១.៧.៣ នាយកដ្ឋានអប់រំបរិស្ថាន

នាយកដ្ឋានអប់រំបរិស្ថានមានតួនាទី និងភារកិច្ចដូចតទៅៈ បញ្ជ្រាបការអប់រំបរិស្ថានទៅក្នុងកម្មវិធីអប់រំនៅគ្រប់លំដាប់ថ្នាក់ទាំងការអប់រំក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធនិងការផ្សព្វផ្សាយចំណេះដឹងបរិស្ថាន ដើម្បីសម្រេច

បាននូវការងារអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព លើកកម្ពស់ការប្រឡងប្រណាំងបរិស្ថានមានដូចជា សាលាមេត្រីបរិស្ថាន អារាមមេត្រីបរិស្ថាន សកម្មភាពបរិស្ថាននានាជាដើម សម្របសម្រួលការងារអភិបាលកិច្ចអប់រំបរិស្ថានជាមួយភាគីពាក់ព័ន្ធ ពង្រឹងសមត្ថភាពជំនាញអប់រំបរិស្ថានទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងកសាងបណ្ដាញអ្នកបន្តវេនអប់រំបរិស្ថានសម្របសម្រួល ការផលិតឯកសារ និងសម្ភារៈឧបទេសបរិស្ថាន ។

**២.១.៧.៤ នាយកដ្ឋានព័ត៌មាននិងផ្សព្វផ្សាយបរិស្ថាន**

នាយកដ្ឋានព័ត៌មាននិងផ្សព្វផ្សាយបរិស្ថានមានតួនាទីនិងភារកិច្ចដូចតទៅ៖ រៀបចំផ្សព្វផ្សាយតាមប្រព័ន្ធ និងគ្រប់គ្រងព័ត៌មានបរិស្ថានតាមរយៈគេហទំព័រ សាអេឡិចត្រូនិកនិងបណ្ដាញព័ត៌មានសង្គម ផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធសមិទ្ធផលសកម្មភាពការងារថ្នាក់ដឹកនាំនិងអង្គភាពចំណុះឱ្យក្រសួងបរិស្ថាន បទយកការណ៍បរិស្ថាននិងប្រតិទិនការងារតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា សម្របសម្រួលការរៀបចំសម្ភារៈផ្សព្វផ្សាយ ការបោះពុម្ពផ្សាយរួមមានទស្សនាវដ្ដីបរិស្ថាន ព្រឹត្តិបត្រព័ត៌មាន បណ្ណផ្សព្វផ្សាយព័ត៌មាន ព្រមទាំងសម្របសម្រួលជាមួយអគ្គនាយកដ្ឋានជំនាញក្នុងការរៀបចំសុន្ទរកថា សេចក្ដីថ្លែងការណ៍ សេចក្ដីប្រកាសព័ត៌មាន សេចក្ដីជូនដំណឹង និងព្រឹត្តិការណ៍បរិស្ថាន សម្របសម្រួលការផ្ដល់ព័ត៌មានដល់អ្នកសារព័ត៌មាននិងប្រព័ន្ធផ្សព្វផ្សាយនានា រួមទាំងរៀបចំ សហការ និងអនុវត្តព្រឹត្តិការណ៍ និងយុទ្ធនាការបរិស្ថានជាអាទិ៍ ទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ៥មិថុនា និងទិវាអនាម័យបរិស្ថាន២៣វិច្ឆកា។

**២.១.៨ អគ្គាធិការដ្ឋាន**

អគ្គាធិការដ្ឋានជាសេនាធិការឱ្យក្រសួងបរិស្ថាន លើការងារអធិការកិច្ចនិងអភិបាលកិច្ចល្អហើយមានតួនាទី និងភារកិច្ចដូចតទៅ៖ ចូលរួមដឹកនាំនិងសម្របសម្រួលការរៀបចំគោលការណ៍ នីតិវិធីនិងលក្ខណវិនិច្ឆ័យ សម្រាប់ដំណើរការវាយតម្លៃនិងទទួលស្គាល់អង្គភាពគំរូក្នុងវិស័យបរិស្ថានហើយធ្វើអធិការកិច្ចជាប្រចាំទៅលើ គ្រប់អង្គភាពក្រោមឱវាទក្រសួង និងធ្វើការត្រួតពិនិត្យ ការដឹកនាំ និងការគ្រប់គ្រងពាក់ព័ន្ធនឹងការងាររដ្ឋបាល ការងារបុគ្គលិកនិងទ្រព្យសម្បត្តិរដ្ឋ ត្រួតពិនិត្យលើការអនុវត្តគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត កិច្ចព្រមព្រៀង គោលការណ៍និងលិខិតបទដ្ឋានផ្សេងៗតាមការប្រគល់ភារកិច្ចពីរដ្ឋមន្ត្រី ពិនិត្យរាល់លិខិតស្នាមពាក្យបណ្ដឹង និងព័ត៌មានព្រមទាំងចុះស្រាវជ្រាវបាតុភាព និងភាពអសកម្មនានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងនិងការដឹកនាំរបស់ប្រធានអង្គភាព មន្ត្រីពាក់ព័ន្ធ បុគ្គលនិងភាគីពាក់ព័ន្ធធ្វើអធិការកិច្ចលើករណីក្លែងបន្លំនិងភាពប្រក្រតីក្នុងការ គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋក្នុងក្របខណ្ឌក្រសួង កោះអញ្ជើញមន្ត្រីពាក់ព័ន្ធ តាមរយៈអង្គភាពមកបំភ្លឺនិងចូលរួមសហការក្នុងដំណើរការនៃការធ្វើអធិការកិច្ច និងទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរដ្ឋមន្ត្រីប្រគល់ឱ្យ។[23]

[23] មាត្រា៥៣ នៃអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

### ២.១.៩ នាយកដ្ឋានសវនកម្មផ្ទៃក្នុង

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ទទួលបន្ទុកអនុវត្តកាតព្វកិច្ចតាមអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥។[24]




### ២.១.១០ នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ជាសេនាធិការឱ្យក្រសួងបរិស្ថានក្នុងកិច្ចការពាក់ព័ន្ធនិងការវាយតម្លៃប៉ះពាល់បរិស្ថាន ដែលមានតួនាទីនិងភារកិច្ចដូចជា៖

- រៀបចំសេចក្តីព្រាងអនុវត្តគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ផែនការថវិកា គោលការណ៍ណែនាំបច្ចេកទេស នីតិវិធីនានាសម្រាប់ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម
- រៀបចំអនុវត្តវិធានផ្ទៃក្នុងសម្រាប់គ្រប់គ្រងការពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម

[24] សំ សុផល "ការបោះត្រាលើលិខិតចូលនៅនាយកដ្ឋានរដ្ឋបាល នៃក្រសួងបរិស្ថាន" ឆ្នាំ២០១៧,ទំព័រទី៦

- ពិនិត្យវិភាគវាយតម្លៃសម្រាប់កំណត់ទីតាំងគម្រោងវិនិយោគសាធារណៈ និងគម្រោងឯកជន
- ពិនិត្យវាយតម្លៃលើចំណាត់ថ្នាក់គម្រោង ដើម្បីកំណត់អំពីតម្រូវការសម្រាប់រៀបចំរបាយការណ៍ពិនិត្យវាយតម្លៃហេតុប៉ះពាល់បរិស្ថានសង្គម
- កំណត់លក្ខខណ្ឌការងារគោលការបច្ចេកទេស សម្រាប់រៀបចំគោលការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- ពិនិត្យផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម នៃគម្រោងវិនិយោគសាធារណៈនិងគម្រោងវិនិយោគឯកជន ព្រមទាំងដំណើការទាំងមូលនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- តាមដាន ត្រួតពិនិត្យជំរុញការអនុវត្តការប្រមូល និងប្រើប្រាស់មូលនិធិបរិស្ថាន និងសង្គម
- គ្រប់គ្រងទទួលខុសត្រូវសម្របសម្រួលការងាររដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ គណនេយ្យ ផែនការថវិការយៈពេលខ្លី មធ្យម រយៈពេលវែង និងអង្កេតតាមដានការងារផ្ទៃក្នុងរបស់នាយកដ្ឋាន
- ជំរុញឱ្យមានការចូលរួមជាប្រចាំរបស់សាធារណជន និងការទទួលបានព័ត៌មាននៅក្នុងដំណើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- សម្របសម្រួលការងារជាមួយបណ្តាអគ្គនាយកដ្ឋានក្រោមឱវាទក្រសួងបរិស្ថាន អង្គភាពពាក់ព័ន្ធដៃគូអភិវឌ្ឍសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- ពិនិត្យផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនៃគម្រោងវិនិយោគសាធារណៈ និងគម្រោងវិនិយោគឯកជន ព្រមទាំងដំណើការទាំងមូលនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។

## ២.២ អង្គភាពថ្នាក់ក្រោមជាតិ

នៅតាមរាជធានី ខេត្តនីមួយៗមានមន្ទីរបរិស្ថានរាជធានី ខេត្ត ចំនួនមួយដែលទទួលបន្ទុកអនុវត្តនិងសម្របសម្រួលសកម្មភាពនានារបស់ក្រសួង។ ការរៀបចំនិងការប្រព្រឹត្តទៅនៃមន្ទីរបរិស្ថានរាជធានី ខេត្តត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

## ២.៣ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ

គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈនានាដែលស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងបរិស្ថានត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

# ជំពូកទី៣
# សមិទ្ធផល បញ្ហាប្រឈម ដំណោះស្រាយ

## ៣.១ សមិទ្ធផល

កន្លងមកក្រសួងបរិស្ថាន ក៏ដូចជាក្រុមប្រឹក្សានិងក្រុមប្រឹក្សាជាតិអភិវឌ្ឍដោយចីរភាព សម្រេចបាននូវសមិទ្ធផលជាច្រើនដែលត្រូវបានអបអរសាទរជាទូទៅ នៅក្នុងនោះបានអនុវត្តទៅលើកំណែទម្រង់ទៅតាមជំហានជាបន្តបន្ទាប់នៅក្នុងដំណើរឆ្ពោះទៅកាន់កសាងនូវរដ្ឋបាលទំនើបដែលឆ្លើយតបទៅនឹង តម្រូវការការវិវត្តរបស់សង្គមកម្ពុជា និងធានាសម្រេចបាននូវបេសកម្មនៅក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការគ្រប់គ្រងធនធានធម្មជាតិ និងការអភិវឌ្ឍដោយចីរភាព។ កិច្ចខិតខំប្រឹងប្រែង និងសមិទ្ធផលទាំងអស់នេះ គឺឈរនៅលើមូលដ្ឋានគ្រឹះនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ផែនការសកម្មភាពបរិស្ថានជាតិឆ្នាំ២០១៦-២០៣០ ផែនការជាតិនានាពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងបំណងប្រាថ្នាដ៏ពិសិទ្ធិរបស់ប្រជាជនកម្ពុជា ជាពិសេសគឺមតិដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា** ដោយសម្លឹងទៅរកចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០-២០៥០នៅក្នុងគោលបំណងក្តាប់មកវិញនៅមោទនភាព ការកសាងជាតិទំនើបមួយដ៏រស់រវើកនៅក្នុងសេចក្តីប៉ងប្រាថ្នាប្រែក្លាយទៅជាប្រទេសដែលមានចំណូលខ្ពស់ រដ្ឋរឹងមាំ សង្គមយុត្តិធម៌ ពលរដ្ឋមានសមត្ថភាព និងបរិស្ថានរស់នៅល្អ គុណភាពបរិស្ថាននិងនិរន្តភាពបរិស្ថានត្រូវបានធានា។[25]

### ៣.៣.១ លទ្ធផលការងារសម្រេចបាន

#### ៣.១.១.១ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

ក្រសួងបរិស្ថាន មានមន្ត្រីក្របខណ្ឌក្រសួងបរិស្ថានសរុប ចំនួន២៧៥៥ នាក់(ស្រី៥២១នាក់) និងមន្ត្រីក្របខណ្ឌនៅទីស្តីការក្រសួងបរិស្ថានចំនួន១០១១នាក់ មន្ត្រីរាជការនៅមន្ទីរបរិស្ថានរាជធានី-ខេត្តចំនួន១៧៤៤នាក់ ព្រមទាំងមានបុគ្គលិកស្ម័គ្រចិត្តនៅទីស្តីការក្រសួងបរិស្ថាន ដែលជាការផ្តល់ឱកាសដ៏ល្អទៅដល់សិស្សនិស្សិតគ្រប់រូបទទួលបាននូវការសិក្សារៀនសូត្រ បណ្តុះសមត្ថភាព តាមរយៈការងារស្ម័គ្រចិត្ត។[26] ជាពិសេសបានផ្តល់អាទិភាពខ្ពស់លើការកសាងធនធានមនុស្ស តាមរយៈការរៀបចំជាប្រចាំនូវវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីរាជការ មន្ត្រីឧទ្យានុរក្ស ជាពិសេសនៅបណ្តាការិយាល័យក្រុង-ស្រុក មន្ទីរបរិស្ថានរាជធានី ខេត្ត លើការគ្រប់គ្រងធនធានធម្មជាតិ ការងារគ្រប់គ្រងរដ្ឋបាល វិធីសាស្ត្រល្បាតក្នុងតំបន់ការពារធម្មជាតិ និងក្របខណ្ឌច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងបញ្ជូនមន្ត្រីរាជការទៅបន្តការសិក្សាទាំងនៅក្នុងប្រទេស

[25] គេហទំព័រ https://youtu.be/R_IxiaXddEQ ដកស្រង់នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២១

[26] ក្រសួងបរិស្ថាន "របាយការណ៍បូកសរុបការងារបរិស្ថានប្រចាំឆ្នាំ២០២១ " នៅទំព័រទី២

និងក្រៅប្រទេស។ លើសពីនេះទៀត ការយកចិត្តទុកដាក់ចំពោះមន្ត្រីរាជការគ្រប់រូបគឺពិតជាសំខាន់នឹងបញ្ជាក់ពីសាមគ្គីភាពរវាងថ្នាក់ដឹកនាំនិងអ្នកក្រោមឱវាទ ដោយក្រសួងបរិស្ថាន បានអនុវត្តនូវកិច្ចគាំពារមន្ត្រីរាជការ ក្នុងការលើកទឹកចិត្តមន្ត្រីសកម្មការងារ និងគិតគូរជាចម្បងដល់ជីវភាព និងទុក្ខលំបាករបស់មន្ត្រីរាជការ តាមរយៈការឧបត្ថម្ភមានជាអាទិ៍៖ មន្ត្រីរៀបអាពាហ៍ពិពាហ៍ មន្ត្រីសម្រាលបុត្រ មន្ត្រីទទួលមរណៈភាព អាហារថ្ងៃត្រង់សម្រាប់មន្ត្រីដែលមានជីវភាពខ្វះខាត និងមន្ត្រីសម្រាកព្យាបាលជំងឺតាមសភាពជាក់ស្តែង ក៏ដូចជាការលើកទឹកចិត្តដល់មន្ត្រីរាជការក្នុងការបំពេញការងារ តាមរយៈការផ្តល់គ្រឿងឥស្សរិយស ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់ និងការផ្តល់លាភការផ្សេងៗ ទាំងនេះសុទ្ធសឹងតែជាលទ្ធផលដែលក្រសួងសម្រេចបាន ព្រមទាំងមានការសាទរពីសំណាកមន្ត្រីរាជការគ្រប់រូប និងអង្គភាពពាក់ព័ន្ធផ្សេងទៀត។

ប្រទេសកម្ពុជា ក៏ជាប្រទេសមួយក្នុងចំណោមប្រទេសជាច្រើនទៀតលើសកលលោកដែលទទួលរងឥទ្ធិពលដោយបញ្ហាជំងឺកូវីដ-១៩ ស្ថិតក្រោមការដឹកនាំនឹងយកចិត្តទុកដាក់គិតគូរយ៉ាងល្អិតល្អន់ពីសំណាករាជរដ្ឋាភិបាលក្នុងយុទ្ធនាការស្រោចស្រពវ៉ាក់សាំងជូនប្រជាពលរដ្ឋនិងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់។ ដោយឡែកក្រសួងបរិស្ថានបានចាត់វិធានការយ៉ាងតឹងរឹង ធានាសុវត្ថិភាពនៅកន្លែងបំពេញការងារ ដោយបានអនុវត្តហ្មត់ចត់នូវបណ្តាវិធានការបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ដោយក្នុងនោះបានបំពាក់ឧបករណ៍ និងសម្ភារៈមួយចំនួនដូចជា ម៉ាស៊ីនវាស់កម្តៅ ម៉ាស៊ីនបាញ់អាកុលដោយស្វ័យប្រវត្តិ ម៉ាស៊ីនសម្លាប់មេរោគ អាកុល ជេល និងម៉ាស់មុខជាដើម ស្របតាមការណែនាំរបស់ក្រសួងសុខាភិបាល និងបានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវ **វិធានការការពារ ៣កុំ និង ៣ការពារ របស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃប្រទេសកម្ពុជា។[27]

### ៣.១.១.២ អគ្គនាយកដ្ឋានគោលនយោបាយ និងយុទ្ធសាស្ត្រ

បានលើកកម្ពស់ តួនាទីរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពក្នុងឋានៈជាស្ថាប័នឈានមុខក្នុងការគិតគូរតាក់តែងគោលនយោបាយ និងយុទ្ធសាស្ត្រនានាដើម្បីធានានូវការអភិវឌ្ឍដោយចីរភាព ដោយជំរុញការអភិវឌ្ឍបញ្ចេញកាបូនតិច និងមានប្រសិទ្ធភាពថាមពល សេដ្ឋកិច្ចបៃតង និងការត្រៀមខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដោយធ្វើយ៉ាងណារក្សាតុល្យភាពរវាងសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌នៅកម្ពុជា ព្រមទាំងបានរៀបចំប្លង់ និងផែនការមេសម្រាប់មជ្ឈមណ្ឌលស្រាវជ្រាវនិងអភិរក្សកេសរកូលសុខ អាន ភ្នំគូលែន និងបានបញ្ចប់សេចក្តីព្រាងស្តីពីសៀវភៅមគ្គុទេសក៍គ្រឿងទេសនៅកម្ពុជា ព្រមទាំងបាន និងកំពុងសិក្សា រៀបចំបង្កើតមជ្ឈមណ្ឌលធនធានពិន្ទុ (សេណេទិច) ផ្សេងៗរបស់ជាតិ បន្ថែមពីលើនេះទៀត ក៏បានសម្របសម្រួលដល់ការផ្តល់មធ្យោបាយទុក ដាក់ និងដឹកជញ្ជូនសំរាម សំណល់រឹង ដូចជាធុងផ្ទុកសំរាមខ្នាតធំ ឡានដឹងសំរាម ម៉ូតូកង់បីដឹកសំរាម និងឡដុតសំរាមខ្នាតតូច ជូនរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការ

[27] គេហទំព័រ https://fb.watch/eoOXVSXhoX/ ដកស្រង់នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២

អនុវត្តកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដែលជាការរួមចំណែកចូលរួមគ្រប់គ្រងនិងទុកដាក់កាកសំណល់បានត្រឹមត្រូវ។[28]

### ៣.១.១.៣ អគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិ

ក្រសួងបរិស្ថាន បានបង្កើតតំបន់ការពារធម្មជាតិថ្មីៗចំនួន១០តំបន់បន្ថែមទៀត ដែលធ្វើឱ្យតំបន់ការពារធម្មជាតិកើនឡើង ដល់ ៦៧កន្លែង គ្របដណ្តប់លើផ្ទៃដីទំហំប្រមាណ ៧,២លានហិកតា ស្មើនឹង៤១% នៃផ្ទៃប្រទេស ដែលជាអត្រាខ្ពស់បំផុតបើប្រៀបធៀបផ្ទៃដីតំបន់ការពារធម្មជាតិនៅប្រទេសមួយចំនួនក្នុងពិភពលោក។ ការបង្កើតតំបន់ការពារធម្មជាតិ គឺដើម្បីអភិរក្ស និងការពារធម្មជាតិដែលនៅជុំវិញតំបន់ការពារ មិនតែប៉ុណ្ណោះការបង្កើតតំបន់ការពារធម្មជាតិ ជាការរួមចំណែកដ៏សំខាន់ជួយដល់ជីវភាពរស់នៅរបស់សហគមន៍ នៅក្នុងតំបន់នោះឱ្យមានភាពប្រសើឡើង តាមរយៈការទៅទស្សនកិច្ច ឬកំសាន្តនៅតាមតំបន់ការពារធម្មជាតិ។ ថែមទាំងបានរៀបចំផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ ២០១៧-២០៣១ និងផែនការសកម្មភាពសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រជាតិគ្រប់គ្រងតំបន់ការពារធម្មជាតិ ២០១៨-២០២២។ ក្រៅពីនេះ បានសហការជាមួយអង្គការដៃគូអភិរក្សក្នុងការសិក្សាស្រាវជ្រាវប្រភេទរុក្ខជាតិ និងសត្វព្រៃ ដោយបានចុះសិក្សា និងដាក់ឧបករណ៍តាមដានប្រភេទសត្វ និងជីវៈចម្រុះនានានិងបានរៀបចំឯកសារមុខងារនិងតម្លៃនៃធនធាននៅក្នុងតំបន់អភិរក្សដីគោក និងតំបន់ដីសើម ព្រមទាំងបានរៀបចំផែនការគ្រប់គ្រងទិន្នន័យសត្វដំរី ប្រភេទសត្វព្រៃ និងសត្វស្លាប នៅតាមតំបន់ការពារធម្មជាតិមួយចំនួន ហើយបាននឹងកំពុងយកចិត្តទុកដាក់លើការងារអាទិភាពសំខាន់ៗផ្សេងទៀតរួមមាន ការបណ្តុះបណ្តាលមន្ត្រីជំនាញ និងមន្ត្រីឧទ្យានុរក្ស ការកសាងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងតំបន់ការពារធម្មជាតិជាអាទិ៍៖ ការសាងសង់ទីស្នាក់ការ ការបំពាក់ឧបករណ៍សម្ភារៈ និងមធ្យោបាយចាំបាច់សម្រាប់ការងារល្បាត និងទប់ស្កាត់បទល្មើសធនធានធម្មជាតិ។[29]

មិនតែប៉ុណ្ណោះ បានរៀបចំបែងចែក និងកំណត់តំបន់គ្រប់គ្រងតំបន់ការពារធម្មជាតិចំនួន៥ រួមមាន៖ ១.ដែនជម្រកសត្វព្រៃពាមក្រសោម ២.ដែនជម្រកសត្វព្រៃភ្នំព្រេច ៣.ដែនជម្រកសត្វព្រៃស្រែពក ៤.ដែនជម្រកសត្វព្រៃសៀងប៉ាង និង៥.ដែនជម្រកសត្វព្រៃលំផាត់។ [30] ជារួមបញ្ហាដីធ្លីពាក់ព័ន្ធនឹងតំបន់ការពារធម្មជាតិត្រូវបានដោះស្រាយបានមួយចំនួនធំបន្ទាប់ពីការពិនិត្យ និងវាយតម្លៃ គម្រោងដីសម្បទានដីសេដ្ឋកិច្ច កាលពីអាណត្តិទី៥កន្លងមក ហើយបច្ចុប្បន្ននេះ ក្រសួងបាននិងកំពុងពិនិត្យសិក្សាកាត់ឆ្វៀលចេញនូវដីភូមិឋាន និងដីដែលប្រជាពលរដ្ឋប្រើប្រាស់ និងអាស្រ័យផលជាក់ស្តែង ព្រមទាំងកំណត់ជាតំបន់សហគមន៍ ការបោះបង្គោលព្រំ និងការចុះបញ្ជីដីរដ្ឋ។

---

[28] ក្រសួងបរិស្ថាន " របាយការណ៍សន្និបាតបូកសរុបលទ្ធផលការងារបរិស្ថានឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០ " ទំព័រទី២

[29] ក្រសួងបរិស្ថាន " របាយការណ៍បូកសរុបការងារបរិស្ថានប្រចាំឆ្នាំ២០២១ " នៅទំព័រទី២

[30] គេហទំព័រ https://www.moe.gov.kh/index/29971 ដកស្រង់នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២

### ៣.១.១.៤ អគ្គនាយកដ្ឋានគាំពារបរិស្ថាន

កាតព្វកិច្ចគាំពារបរិស្ថាន គួរតែត្រូវបានអនុវត្តគ្រប់ៗគ្នាដោយទូទៅមិនចំពោះ ដើម្បីសោភ័ណ្ឌភាពនិងភាពរីកចម្រើននៃប្រទេសជាតិយើង ហេតុនេះបានរៀបចំគោលនយោបាយគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន គោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន អនុក្រឹត្យស្តីពីការបង្កើតសហគ្រាសគ្រប់គ្រងស្ថានីយផ្ទេរ និងទីលានទុកដាក់សំរាម សំណល់រឹង និងធ្វើវិសោធនកម្មអនុក្រឹត្យចំនួនពីរ ស្តីពីការត្រួតពិនិត្យការបំពុលទឹក និងការគ្រប់គ្រងសារធាតុបំផ្លាញស្រទាប់អូហ្សូន និងរៀបចំសេចក្តីព្រាងអនុក្រឹត្យចំនួនពីរ ស្តីពីការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងការអនុវត្តវិធានស្វ័យត្រួតពិនិត្យការបំពុលបរិស្ថាន សំដៅពង្រឹងកិច្ចគាំពារបរិស្ថាន លើកកម្ពស់សុខភាពសាធារណៈ និងជំរុញការអភិវឌ្ឍដោយចីរភាព ប្រកាសស្តីពីការដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំសម្រាប់រៀបចំការប្រតិបត្តិ និងការថៃទាំឡដុតសំរាម សំណល់រឹងទីប្រជុំជន ប្រកាសស្តីពី សមត្ថកិច្ចមន្ទីរបរិស្ថានរាជធានី ខេត្ត ក្នុងការងារគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ប្រកាសអន្តរក្រសួងស្តីពីការកែសម្រួល និងបន្ថែមសមាសភាពក្រុមការងារដើម្បីត្រួតពិនិត្យ និងដាក់បញ្ចូលវិធានការអនាម័យ និងបរិស្ថានទៅក្នុងលក្ខណៈសម្បត្តិនៃគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព សេចក្តីសម្រេចស្តីពីការកំណត់យន្តការសម្រាប់ពង្រឹងប្រសិទ្ធភាពការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន សេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារដឹកនាំពង្រឹងប្រសិទ្ធភាព និងសមត្ថភាពវិស័យបរិស្ថានជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងបានចូលរួមធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងសំរាមនៅរាជធានីភ្នំពេញ ដោយមានការគិតគូរគ្រប់ជ្រុងជ្រោយពីដើមខ្សែដល់ចុងខ្សែ និងរៀបចំប្រព័ន្ធថ្មីនៅក្រុងព្រះសីហនុ លើសពីនេះទៀត បានជំរុញការផ្តល់សេវា ប្រមូល សម្អាត ដឹកជញ្ជូន និងទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅតាមបណ្តាក្រុងស្រុកជាអាទិ៍។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការសេវារបស់អតិថិជន ទាក់ទិននឹងការផ្តល់លិខិតអនុញ្ញាតបញ្ចេញសំណល់រឹង រាវ ផ្សែង ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រួតពិនិត្យ និងការធ្វើអធិការកិច្ចប្រភពបំពុល ក៏បានពង្រឹង និងពង្រីកសមត្ថភាពមន្ទីរពិសោធន៍ទាក់ទងនឹងការវិភាគឱ្យកាន់តែមានភាពច្បាស់លាស់ប្រាកដប្រជាបន្ថែមទៀត និងបានបំពេញកាតព្វកិច្ចក្នុងការអនុវត្តអនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិ តំបន់ និងទ្វេភាគីនានាពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន។[31]

### ៣.១.១.៥ អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន

ប្រទេសជាតិរីកចម្រើនទៅបាន អាស្រ័យទៅលើមានការអភិវឌ្ឍន៍ចាប់តាំងពីថ្នាក់មូលដ្ឋាន ភូមិ ឃុំ សង្កាត់ ទីជនបទ ទីប្រជុំជនឡើងទៅ ដូចនេះក្រសួងបរិស្ថានដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល បានដើរតួយ៉ាងសំខាន់

[31] ក្រសួងបរិស្ថាន " របាយរណ៍បូកសរុបការងារបរិស្ថានប្រចាំឆ្នាំ២០២១ " នៅទំព័រទី៣

គិតគូរទៅលើបញ្ហាដែលពាក់ព័ន្ធបានរៀបចំបង្កើតសហគមន៍នៅគ្រប់តំបន់ការពារធម្មជាតិ និងចងក្រងសហគមន៍ជាបណ្តាញថ្នាក់មូលដ្ឋាន ថ្នាក់តំបន់ និងថ្នាក់ជាតិ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រង សំដៅចូលរួមការពារបរិស្ថាន និងអភិរក្សធនធានធម្មជាតិផង និងលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋានផងឱ្យកាន់តែមានភាពប្រសើរឡើង។ មិនតែប៉ុណ្ណោះ បាននិងកំពុងសិក្សា និងជំរុញការពង្រីកមូលដ្ឋានផ្សេងៗទៀតនៃសេដ្ឋកិច្ចសហគមន៍ តាមរយៈចម្ការឈើដាំ ដូចជាដើមម៉ៃសាក់ អាកាស្យា ជាដើម និងគំនិតផ្តួចផ្តើមផ្សេងៗ ដែលអាចរួមចំណែកលើកស្ទួយជីវភាពសហគមន៍ផង និងរួមចំណែកការពារធម្មជាតិ និងអភិរក្សជីវៈចម្រុះផង។ បន្ទាប់ពីបង្កើតតំបន់ការពារធម្មជាតិរួចហើយ កត្តាដែលសំខាន់គឺត្រូវជំរុញ លើកទឹកចិត្ត ឱ្យមានការចូលរួមថែរក្សា ការពារ និងជំរុញឱ្យមានការទទួលស្គាល់ជាថ្នាក់ជាតិ និងអន្តរជាតិ ដោយបានពង្រឹងការគ្រប់គ្រងតំបន់អេកូទេសចរណ៍ជាពិសេសគម្រោងអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិទំហំក្រោម ១០ហិកតា ស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ដែលបាននិងកំពុងដើរតួនាទីយ៉ាងសំខាន់ ចូលរួមចំណែកជំរុញចលនាទេសចរក្នុងស្រុក លើកស្ទួយជីវភាពសហគមន៍មូលដ្ឋាន និងរួមចំណែកក្នុងកិច្ចការពារនិងអភិរក្សធនធានធម្មជាតិ ដោយបានបោះបង្គោលព្រំប្រទល់ដី គម្រោងអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីមូលដ្ឋានគ្រឹះនៃការផ្តល់សេវាកម្មទេសចរណ៍ធម្មជាតិដល់គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ និងបានបញ្ជ្រាបការយល់ដឹងអំពីសក្តានុពលនៃតំបន់ទេសចរណ៍ធម្មជាតិ និងតំបន់បេតិកភណ្ឌធម្មជាតិ-វប្បធម៌ ដល់សាធារណៈជន តាមរយៈការផ្តល់ស្លាកសញ្ញាផែនទីសហគមន៍តំបន់ការពារធម្មជាតិ និងការផ្សព្វផ្សាយអំពីសក្តានុពល និងភាពទាក់ទាញនៃតំបន់ទាំងនោះ ទាំងកេតនភណ្ឌធម្មជាតិ និងវប្បធម៌ជាដើម។ បន្ថែមលើគម្រោងលើកកម្ពស់ជីវភាពសហគមន៍ជាប្រចាំរបស់ក្រសួងបរិស្ថាននាកន្លងមកក៏បានសិក្សា និងរៀបចំកម្មវិធីអន្តរាគមន៍ជួយដល់សហគមន៍មួយចំនួនក្នុងអំឡុង និងក្រោយវិបត្តិកូវីដ-១៩ តាមរយៈការផ្តល់ពូជសត្វគោ និងមាន់ ដល់សហគមន៍ក្នុងខេត្តគោលដៅអាទិភាពមួយចំនួនផងដែរ។[32]

### ៣.១.១.៦ អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន

ការផ្សព្វផ្សាយព័ត៌មានបរិស្ថាន គឺជាកត្តាលីករដ៏សំខាន់ ដែលដើរតួនាទីស្នូលជំរុញឱ្យសាធារណជនគ្រប់មជ្ឈដ្ឋានទទួលបានព័ត៌មានអំពីបញ្ហាបរិស្ថាន ការលើកស្ទួយវិស័យបរិស្ថាន ការរួមគ្នាថែរក្សាបរិស្ថាន ការចូលរួមធ្វើអនាម័យបរិស្ថាន និងផលប៉ះពាល់ផ្សេងៗទៀតពាក់ព័ន្ធនឹងបរិស្ថានដោយបានបង្កើនការផ្សព្វផ្សាយព័ត៌មានបរិស្ថានតាមបណ្តាញផ្សព្វផ្សាយសំខាន់ៗ ជាពិសេសបណ្តាញព័ត៌មានសង្គមរហូតក្លាយជាកម្លាំងចលករមួយជួយជំរុញឱ្យមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់នូវផ្នត់គំនិត និងឥរិយាបថរបស់សាធារណជន ងាកទៅរករបៀបរស់នៅថ្មី ដែលមានមេត្រីភាពបរិស្ថាន អនាម័យ និងសុខុមាលភាពជាងមុន។ ដើម្បីឱ្យការផ្សព្វផ្សាយ

[32] ក្រសួងបរិស្ថាន " របាយការណ៍សន្និបាតបូកសរុបលទ្ធផលការងារបរិស្ថានឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០ " ទំព័រទី២៤

កាន់តែមានភាពស៊ីជម្រៅជាងនេះ ក្រសួងបរិស្ថានបានយកចិត្តទុកដាក់ និងផ្តោតទៅលើការងារសំខាន់ៗមួយចំនួនទៀត ក្នុងនោះគឺបានរៀបចំចងក្រងឯកសារអប់រំបរិស្ថានរួមមាន៖ ព័ត៌មានអត្ថបទបរិស្ថាន វីដេអូចម្រៀងបរិស្ថាន ឯកសារវីដេអូ ទស្សនាវដ្តីបរិស្ថាន កម្មវិធីកិច្ចសន្ទនាបរិស្ថាន និងការសម្ភាសន៍ជាមួយថ្នាក់ដឹកនាំក្រសួង និងអគ្គនាយកដ្ឋានចំណុះក្រសួង។ ឯកសារអប់រំបរិស្ថានទាំងនេះ បានដាក់ផ្សាយតាមប្រព័ន្ធបណ្តាញសង្គមក្រសួងបរិស្ថាន គេហទំព័រក្រសួងបរិស្ថាន (www.moe.gov.kh) បណ្តាស្ថានីយ៍វិទ្យុនិងទូរស្សន៍ និងតាមបណ្តាញ YouTube (Moe Cambodia) ព្រមជាមួយនឹងការរៀបចំឃោសនាផ្សព្វផ្សាយ ទិវាអនាម័យបរិស្ថានជាតិ ២៣វិច្ឆិកា និងទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ៥មិថុនា។ មួយទៀតសោត បានជំរុញលើកទឹកចិត្តប្រតិបត្តិមេត្រីភាពបរិស្ថាន តាមរយៈការផ្តល់បណ្ណសរសើមេត្រីភាពបរិស្ថាន និងលិខិតថ្លែងអំណរគុណដល់ទីតាំងប្រតិបត្តិផ្ទាល់ ប្រតិបត្តិករគំរូ ក្រុមការងារអនុវត្តគម្រោងជេដបូកជាតិ អ្នកចូលរួមធ្វើអនាម័យបរិស្ថានក្នុងព្រះរាជពិធីបុណ្យអុំទូក អកអំបុក បណ្តែតប្រទីប និងសំពះព្រះខែ និងផ្តល់បណ្ណជ័យលាភី លិខិតថ្លែងអំណរគុណដល់អង្គភាពចំណុះក្រសួងបរិស្ថាន និងសហគមន៍មូលដ្ឋានដែលបានជាប់ជ័យលាភីជាអង្គភាពសេវាសាធារណៈគំរូក្នុងវិស័យបរិស្ថាន ព្រមទាំងលើកទឹកចិត្តដល់ការប្រតិបត្តិមេត្រីភាពបរិស្ថាន តាមរយៈការប្រគល់ជូនធុងញែកសំរាមជូនដល់សាលារៀន និងអង្គភាពពាក់ព័ន្ធ និងតម្លើងធុងចម្រោះទឹកស្អាតជូនដល់ វិទ្យាស្ថាន វិទ្យាល័យ សាកលវិទ្យាល័យ អនុវិទ្យាល័យ វត្តអារាម និងអង្គភាពពាក់ព័ន្ធ ដែលជាការលើកកម្ពស់បរិស្ថានស្អាត និងអនាម័យបរិស្ថានទូទាំងប្រទេស និងបានរៀបចំសិក្ខាសាលាជាច្រើន ដើម្បីលើកកម្ពស់ការយល់ដឹងអំពីភាពចាំបាច់នៃបរិស្ថានដល់មន្ត្រី និងសាធារណៈជន។[33]

### ៣.១.២ ការពង្រឹងអភិបាលកិច្ចល្អ និងកិច្ចគាំពារបរិស្ថាន

ការពង្រឹងសមត្ថភាពមន្ត្រីរាជការតាមរយៈ ការបណ្តុះបណ្តាលជំនាញរដ្ឋបាលនិងគ្រប់គ្រងហិរញ្ញវត្ថុតាមគ្រឹះស្ថានបណ្តុះបណ្តាលនានា និងនៅក្រសួងផ្ទាល់ រៀបចំអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរបរិស្ថានទាំង២៥ រាជធានី ខេត្ត។ ទន្ទឹមនិងសមិទ្ធផលការងារសំខាន់ៗដែលបានរៀបរាប់ខាងលើនេះ ក្រសួងបរិស្ថានក៏បានបំពេញការងារ និងទទួលបាននូវសមិទ្ធផលសំខាន់ៗដ៏ទៃទៀតជាច្រើនផងដែរ ដែលមានរៀបរាប់លម្អិតនៅក្នុងរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ក្រសួងបរិស្ថានប្រចាំឆ្នាំ។

តាមរយៈការដឹកនាំដ៏ឆ្លាតវៃរបស់ **ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន** ធ្វើឱ្យមន្ត្រីមានទឹកចិត្តក្នុងការបំពេញការងារ និងមានប្រសិទ្ធភាពការងារជាងមុន តាមរយៈគោលនយោបាយលើកទឹកចិត្តមន្ត្រីរាជការដូចជា ការផ្តល់ប្រាក់ឧបត្ថម្ភដល់មន្ត្រីរាជការរៀបអាពាហ៍ពិពាហ៍ ការផ្តល់អាហារថ្ងៃត្រង់ដល់មន្ត្រីរាជការ ការផ្តល់ជាកាតសាំងប្រចាំខែ និងយានជំនិះជូនដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ការយកចិត្តទុកដាក់

[33] ក្រសួងបរិស្ថាន " របាយការណ៍សន្និបាតបូកសរុបលទ្ធផលការងារបរិស្ថានឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០ " ទំព័រទី៥១

គិតគូរពីបញ្ហាសុខភាពមន្ត្រីរាជការ សុវត្ថិភាពនៃការរីករាលដាលជំងឺឆ្លងនានា ដោយបានដាក់ចេញនូវគោលនយោបាយស្តីពី កិច្ចគាំពារមន្ត្រីរាជការក្រសួងបរិស្ថាន ដែលជាកត្តាធ្វើឱ្យមន្ត្រីរាជការទាំងអស់ទទួលបាននូវការយកចិត្តទុកដាក់ ទទួលបាននូវសាមគ្គីភាព ប្រសិទ្ធភាព ប្រសិទ្ធផល និងអត្ថប្រយោជន៍ផ្សេងៗទៀតជាច្រើនដែលផ្តល់ជូនពីរាជរដ្ឋាភិបាល។

ដោយមានការខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តរបស់ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ក្រសួងបរិស្ថានបានអនុវត្តនូវបណ្តាភារៈកិច្ចសំខាន់ៗដូចជាៈ ការងារគ្រប់ធនធានមនុស្ស ការងារគ្រប់គ្រងចំណូលចំណាយការងារចងក្រងឯកសារស្រាវជ្រាវទាក់ទងនឹងបច្ចេកវិទ្យា និងវិទ្យាសាស្ត្រសេដ្ឋកិច្ចបៃតង កិច្ចសហប្រតិបត្តិការជាមួយដៃគូរអភិវឌ្ឍន៍ ការងារតាមដានគុណភាពទឹក និងខ្យល់សាធារណៈ ការពិនិត្យផ្តល់យោបល់ និងឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការសិក្សាដីប្រើប្រាស់អាស្រ័យផលរបស់ប្រជាសហគមន៍ក្នុងតំបន់ការពារធម្មជាតិ ការទប់ស្កាត់និងបង្ក្រាបបទល្មើសធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ ការអប់រំផ្សព្វផ្សាយការងារបរិស្ថាន ការរៀបចំនិងចូលរួមកិច្ចប្រជុំ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាល ព្រមទាំងប្រកាន់ខ្ជាប់នូវវិធានការសុខាភិបាលក្នុងការចូលរួមទប់ស្កាត់ និងការពារការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩។

ទោះបីជា បញ្ហាកូវីដ-១៩បានវាយលុកក្នុងពិភពលោកក្នុងនោះកម្ពុជាក៏ប្រឈមនូវបញ្ហាកូវីដ-១៩ យ៉ាងណាក្តីក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ការខិតខំប្រឹងប្រែងយកចិត្តទុកដាក់ខ្វល់ខ្វាយ និងខិតខំស្រោចស្រង់ កសាងស្តារប្រទេសឱ្យរួចផុតពីឥទ្ធិពលអាក្រក់នៃជំងឺកូវីដ-១៩ ធ្វើឱ្យកម្ពុជានៅតែអាចគ្រប់គ្រងប្រទេសបានដោយល្អ និងនៅតែបន្តកសាងប្រទេសជានិច្ចនិរន្តរ៍។

### ៣.១.៣ ទិសដៅការងារ២០២២

- **កិច្ចគាំពារបរិស្ថាន**

- បន្តចុះពិនិត្យតាមដានគុណភាពទឹកសាធារណៈតាមគោលដៅផែនការសកម្មភាព និងស្ថានីយតាមដានគុណភាពទឹកទន្លេចតុមុខ (កោះពេជ្រ) តាមដានគុណភាពខ្យល់សាធារណៈ នៅតាមទីតាំងគោលដៅ
- ពង្រឹងការបំពាក់អាងប្រព្រឹត្តកម្មតាមទីតាំងអគារអាជីវកម្ម បុរីលំនៅដ្ឋាន ទីក្រុងរណប មណ្ឌលកំសាន្ត ឬរមណីយដ្ឋាន (ស្មារតីអនុក្រឹត្យ២៣៥)
- ចុះត្រួតពិនិត្យការគ្រប់គ្រងសារធាតុ និងសំណល់គ្រោះថ្នាក់ នៅតាមប្រភពបំពុលរោងចក្រ សហគ្រាសតាមសំណើសុំផ្តល់សេវាសាធារណៈ តាមបណ្តារាជធានី-ខេត្ត

- បន្តពង្រឹងដឹកនាំការងារចុះត្រួតពិនិត្យធ្វើអធិការកិច្ច ដោះស្រាយពាក្យបណ្តឹង ឱ្យមានប្រសិទ្ធភាពខ្ពស់ និងស្របទៅតាមលិខិតបទដ្ឋានច្បាប់ និងតាមដានការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ដែលមានចែងក្នុងរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន លើគម្រោងដែលបានអនុម័តរួច
- បន្តអនុវត្តការផ្តល់សេវាសាធារណៈពាក់ព័ន្ធកិច្ចគាំពារបរិស្ថាន អនុលោមតាមប្រកាសរួម លេខ ១៤២៨ សហវ.ប្រក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤ ព្រមទាំងបន្តអនុវត្តការងារ និងតួនាទីដែលថ្នាក់ដឹកនាំប្រគល់ជូន ព្រមទាំងជំរុញ និងបន្តការចុះបញ្ជីដីសាធារណៈរបស់រដ្ឋការកំណត់បែងចែកតំបន់គ្រប់គ្រង និងបោះបង្គោលព្រំឱ្យបានគ្រប់តំបន់ការពារធម្មជាតិ

- **ការងារគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ**

- បន្តរៀបចំ ការបែងចែកតំបន់គ្រប់គ្រង នៅដែនជម្រកសត្វព្រៃតាតៃ តំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង និងឧទ្យានជាតិបទុមសាគរ និងផែនការគ្រប់គ្រងនៅដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ និងភ្នំសំកុស
- សហការជាមួយមន្ទីរបរិស្ថានខេត្ត ដើម្បីបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវស្តារកាយសម្បទារសត្វនិងព្យាបាលសត្វមានរបួស និងបង្កាត់ពូជសត្វដែលជិតផុតពូជនៅក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះតាមភូមិសាស្ត្រដែលប្រឈមនឹងការបរបាញ់ ដោយអាវុធកែច្នៃ ដាក់ ចាប់អន្ទាក់ និងប្រការផ្សេងទៀតប៉ះពាល់ដល់សត្វព្រៃ។
- បន្តបោះបង្គោលព្រំនៅឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង ខេត្តកោះកុង និង (ដែនជម្រកសត្វព្រៃស្រែពក ដែនជម្រកសត្វព្រៃភ្នំព្រេច ដែនជម្រកសត្វព្រៃកែវសីម៉ា និងតំបន់ការពារទេសភាពបឹងលំកុដ) ខេត្តមណ្ឌលគីរី
- បន្តជំរុញលើកទឹកចិត្តឱ្យសហគមន៍មូលដ្ឋានមានការចូលរួមការពារ និងគ្រប់គ្រងធនធានធម្មជាតិ នៅក្នុងតំបន់ដែលពួកគាត់បាននិងកំពុងប្រើប្រាស់អាស្រ័យផល តាមរយៈការផ្សព្វផ្សាយ អំពីការងារសហគមន៍តំបន់ការពារធម្មជាតិ
- បន្តសហការជាមួយអាជ្ញាធរដែនដី និងអ្នកជំនាញពាក់ព័ន្ធនានា ការអប់រំផ្សព្វផ្សាយពីសារៈសំខាន់នៃធនធានធម្មជាតិ ជីវៈចម្រុះ និងតំបន់ដីសើម ក៏ដូចជាធ្វើការផ្សព្វផ្សាយបន្ថែមពីច្បាប់ស្តីពីតំបន់ការពារធម្មជាតិដល់សិស្សានុសិស្ស និងសហគមន៍មូលដ្ឋាន
- បន្តកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍នានា ក្នុងការកៀរគរជំនួយថវិកា និងបច្ចេកទេស ដើម្បីបន្តអនុវត្តនូវសកម្មភាពការងារគ្រប់គ្រងតំបន់ដីសើមប្រកបដោយភាពឈ្លាសវៃ និងសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ មន្ទីរពាក់ព័ន្ធ សហគមន៍មូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល

ដៃគូអភិវឌ្ឍន៍ វិស័យឯកជន ក្នុងការចូលរួមការពារ គ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិ និងជីវៈចម្រុះប្រកបដោយនិរន្តរភាព

- ជំរុញ និងបន្តការចុះបញ្ជីដីសាធារណៈរបស់រដ្ឋ ការកំណត់បែងចែកតំបន់គ្រប់គ្រង និងបោះបង្គោលព្រំឱ្យបានគ្រប់តំបន់ការពារធម្មជាតិ

- **ការងារអភិវឌ្ឍសហគមន៍មូលដ្ឋាន**

- បន្តរៀបចំស្នើសុំបង្កើតតំបន់ ក)តំបន់ភ្នំប្រាំពីរ ខ)តំបន់ភ្នំទាក់ទ្រាំង គ)តំបន់គិរីយ៉ង់ ជាតំបន់បេតិកភណ្ឌធម្មជាតិ ស្ថិតក្នុងភូមិសាស្ត្រខេត្តបាត់ដំបង និងតំបន់ ឃ)តំបន់ភ្នំស្វាយ ង)តំបន់ភ្នំជញ្ជាំង ច)តំបន់ភ្នំបាក់ ឆ)តំបន់ភ្នំកងរ៉ា ជ)តំបន់ភ្នំព្រះ-ភ្នំវែង ឈ)តំបន់ភ្នំព្រះនេត្រព្រះ ញ)តំបន់ភ្នំយាយសំ ជាតំបន់បេតិកភណ្ឌធម្មជាតិ ស្ថិតក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ
- ចុះកំណត់ទីតាំងព្រំទល់ព្រៃសហគមន៍តំបន់ការពារធម្មជាតិ និងរៀបចំបោះបង្គោលព្រំប្រទល់តំបន់បេតិកភណ្ឌធម្មជាតិ និងចុះសិក្សាសក្តានុពលភាពសម្រាប់បង្កើតសហគមន៍តំបន់ការពារធម្មជាតិ ត្រួតពិនត្យវាយតម្លៃ និងផ្តល់យោបល់លើការអនុវត្តការងារគ្រប់គ្រងធម្មជាតិ
- ការបញ្ជូនមន្ត្រីទៅចូលរួមប្រជុំ និងសិក្ខាសាលាក្នុងប្រទេស និងក្រៅប្រទេស
- រៀបចំទីផ្សាសហគមន៍មូលដ្ឋាន ដើម្បីផ្តល់លទ្ធភាពជូនសហគមន៍លក់ និងចែកចាយផលិតផលដល់ទីប្រជុំជន និងជំរុញការធ្វើសមាហរណកម្មផែនការសកម្មភាពនៅផែនការគ្រប់គ្រងសហគមន៍ទៅក្នុងផែនការវិនិយោគឃុំ/សង្កាត់ដែលពាក់ព័ន្ធ
- បន្តសិក្សាពីប្រពៃណីទំនៀមទំលាប់ សហគមន៍មូលដ្ឋាន (ជនជាតិដើមភាគតិច) និងរៀបចំចងក្រងឯកសារអត្តសញ្ញាណ អភិរក្សវប្បធម៌សហគមន៍ជនជាតិដើមភាគតិច ដែលរស់នៅក្នុង និងក្បែរតំបន់ការពារធម្មជាតិ
- សិក្សាពីលទ្ធភាពក្នុងការទាក់ទាញដៃគូវិនិយោគ លើការអភិវឌ្ឍទេសចរណ៍ធម្មជាតិក្នុងតំបន់ការពារធម្មជាតិ ដែលអាចលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋាន និងការងារអភិរក្ស

- **ការគ្រប់គ្រងការអភិវឌ្ឍដោយចីរភាព**

- ការងារកសាង និងពង្រឹងធនធានមនុស្ស សមត្ថភាព ក៏ដូចជារៀបចំសិក្ខាសាលាលើកកម្ពស់ចំណេះដឹងវិទ្យាសាស្ត្របច្ចេកវិទ្យា នវានុវត្តន៍ និងបោះពុម្ពឯកសារផ្សព្វផ្សាយពាក់ព័ន្ធ
- ចូលរួមសន្និសីទ សិក្ខាសាលា វគ្គបណ្តុះបណ្តាល កិច្ចប្រជុំ និងវេទិកាពាក់ព័ន្ធនានា
- រៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព ៥ឆ្នាំ (២០១៩-២០២៤) ស្តីពីការស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងនវានុវត្តន៍

- សិក្សាស្រាវជ្រាវ វាយតម្លៃរៀបចំយុទ្ធសាស្ត្រ ក្របខណ្ឌការងារ និងលើកកម្ពស់ការកសាងសមត្ថភាព និងកិច្ចប្រតិបត្តិបត្តការអន្តរជាតិ និងអាស៊ាន

- **ការគ្រប់គ្រងចំណេះដឹង និងព័ត៌មានបរិស្ថាន**

- រៀបចំសិក្ខាសាលា ស្តីពីកម្មវិធីអប់រំបរិស្ថានក្នុងប្រព័ន្ធ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ពង្រឹងសមត្ថភាពអប់រំបរិស្ថានដល់ គរុសិស្ស និងមន្ត្រីថ្នាក់ក្រោមជាតិ ជំរុញ និងលើកទឹកចិត្ត ការអនុវត្តកម្មវិធីសាលាមេត្រីបរិស្ថាន និងអារាមមេត្រីបរិស្ថាន
- ផលិតវីដេអូឯកសារស្តីពីតំបន់ការពារធម្មជាតិ និងសហគមន៍តំបន់ការពារធម្មជាតិក៏ដូចជារៀបចំសិក្ខាសាលាជនបង្គោលព័ត៌មានស្តីពី «មូលដ្ឋានគ្រឹះនៃការសរសេរនិងឆ្លើយតបព័ត៌មានបរិស្ថាន» លើវិស័យបរិស្ថានទៅដល់យុវជន និងជនបង្គោលព័ត៌មានថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងជំនួយការថ្នាក់ដឹកនាំក្រសួងបរិស្ថាន
- បន្តកិច្ចសហការពីបណ្តាអង្គភាព ស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន ដើម្បីលើកទឹកចិត្តដល់សកម្មភាពប្រតិបត្តិមេត្រីភាពបរិស្ថានរបស់វិនិយោគិនជាតិ-អន្តរជាតិ ក្នុងការមកបណ្តាក់ទុនលើវិស័យសេដ្ឋកិច្ចបៃតង និងគម្រោងវិនិយោគនានា ដែលបានបញ្ជ្រាបមេត្រីភាពបរិស្ថាន
- បន្តផ្សព្វផ្សាយតាមប្រព័ន្ធវេបសាយ និងបណ្តាញទំនាក់ទំនងសង្គមរបស់ក្រសួង រៀបចំទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ៥មិថុនា និងទិវាអនាម័យបរិស្ថានជាតិ ២៣វិច្ឆិកា និងបន្តផលិតវីដេអូឯកសារវីដេអូអប់រំបរិស្ថាន និងបទចម្រៀងបរិស្ថាន ព្រមទាំងបកប្រែអត្ថបទ និងវីដេអូអប់រំបរិស្ថានសម្រាប់ផ្សព្វផ្សាយក្នុងបណ្តាញសង្គម

- **សេវាគាំទ្រការងារបរិស្ថាន និងធនធានធម្មជាតិ**

- ពង្រឹងការយល់ដឹង និងសមត្ថភាពរបស់មន្ត្រី ដើម្បីអនុវត្តការងាររដ្ឋបាលប្រកបដោយប្រសិទ្ធភាព ផ្តល់សេវាសាធារណៈតាមការិយាល័យច្រកចេញ-ចូលតែមួយឱ្យមានតម្លាភាព និងគណនេយ្យភាព
- ពង្រឹងការងារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ ជំរុញការងារចុះបញ្ជីដីកម្មសិទ្ធិដីធ្លី តាមអង្គភាពមន្ទីររាជធានី ខេត្តទាំងអស់ និងបន្តជំរុញការចុះបញ្ជីដីបណ្ណកម្មសិទ្ធដីធ្លីនៅតំបន់ការពារធម្មជាតិទាំងអស់ ព្រមទាំងពង្រឹងការងារថែទាំ និងអនាម័យ សួនច្បារនិងទីធ្លាក្រសួង
- បន្តចុះផ្សព្វផ្សាយ ស្តីពីការថែរក្សា និងសារៈសំខាន់នៃធនធានធម្មជាតិ និងការគ្រប់គ្រងសំណល់រឹងដល់មាតាបិតា មន្ត្រីឧទ្យានុរក្ស និងកុមារនៅតាមសាលារៀនក្នុងសហគមន៍តំបន់ការពារធម្មជាតិ
- បន្តសម្របសម្រួលការងារផ្តល់សេវាសាធារណៈច្រកចេញ-ចូលតែមួយ ឱ្យមានតម្លាភាព និងគណនេយ្យភាព រៀបចំវគ្គបណ្តុះបណ្តាលជូនមន្ត្រីរាជការ នៅសាលាភូមិន្ទរដ្ឋបាល វិទ្យាស្ថានការទូតនិងទំនាក់ទំនង

អន្តរជាតិ និងសាលានាយទាហានសកម្ម បន្តរៀបចំផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំរំកិល ២០២៣-២០២៥ និងផែនការថវិកាឆ្នាំ២០២៣

- បន្តរៀបចំលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេស ពាក់ព័ន្ធនឹងគុណភាព ទឹក ខ្យល់ សំឡេង និងរំញ័រ គ្រប់គ្រងទិន្នន័យគុណភាពទឹក គុណភាពខ្យល់ និងធ្វើបច្ចុប្បន្នភាពសំរាម សំណល់រឹង ទីប្រជុំជន សំណល់ប្លាស្ទិក និងការកែច្នៃសំណល់ (រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)
- បន្តពង្រឹងការងារចុះអធិការកិច្ច ដោះស្រាយបណ្តឹងការបំពុលបរិស្ថាន និងចុះតាមដានការអនុវត្តផែនការគ្រប់គ្រងបរិស្ថានដែលកំណត់ក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងបង្កើនចំនួនឧទ្យានុរក្ស សម្រាប់ពង្រឹងការល្បាតក្នុងតំបន់ការពារធម្មជាតិ

## ៣.២ បញ្ហាប្រឈម

### ៣.២.១ កិច្ចគាំពារបរិស្ថាន

ការចុះតាមដាន និងត្រួតពិនិត្យគុណភាពបរិស្ថាននៅមានកម្រិត ហើយកិច្ចសហការការងារអគ្គនាយកដ្ឋាននៅមិនទាន់រលូន និងល្អប្រសើរ ការកំណត់ទិសដៅការងារ និងការអនុវត្តជាក់ស្តែងមិនទាន់ឆ្លើយតប មិនត្រឹមតែប៉ុណ្ណោះប្រភពបំពុលមួយចំនួនពុំទាន់មានភាពស្មោះត្រង់ ក្នុងការធ្វើប្រព្រឹត្តកម្មសំណល់តាមលក្ខណៈបច្ចេកទេសជាប់ជាប្រចាំ និងមិនមានបុគ្គលិកបច្ចេកទេសទទួលការងារគ្រប់គ្រងបរិស្ថាននៅក្នុងទីតាំងរបស់ខ្លួនជាពិសេសមានបញ្ហានិងការងារអាទិភាពមួយចំនួនដែលអគ្គនាយកដ្ឋានត្រូវដោះស្រាយ។

### ៣.២.២ ការងារគ្រប់គ្រងនិងអភិរក្សធនធានធម្មជាតិ

ខេត្តមួយចំនួនមិនទាន់ផ្តល់អាទិភាពក្នុងការអភិរក្សនូវឡើយ ដោយសារមានការចូលឈូសឆាយកាប់ឆ្ការ ដុតរុករានទន្ទ្រានកាប់ដីព្រៃធ្វើជាកម្មសិទ្ធិ ការទិញ-លក់ដីរដ្ឋ និងការបញ្ជាក់ការទិញដី-លក់ដីរដ្ឋដោយខុសច្បាប់នៅតែកើតមាននៅតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះដែលមានសន្ទុះខ្លាំងឡើងនៅដែនជម្រកសត្វព្រៃលំផាត់ ដែនជម្រកសត្វព្រៃកែវសីមាខេត្តមណ្ឌលគិរីជាដើម។ តំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះមួយចំនួននៅមិនទាន់បានកំណត់បែងចែកតំបន់គ្រប់គ្រង រៀបចំផែនការគ្រប់គ្រងនិងបោះបង្គោលព្រំប្រទល់ ព្រមទាំងចុះបញ្ជីដីរដ្ឋនៅឡើយ។ ជាពិសេសសមត្ថភាពរបស់មន្ត្រីឧទ្យានុរក្សនៅមិនទាន់ឆ្លើយតបសម្រាប់ការអនុវត្តការងារឱ្យមានប្រសិទ្ធភាពត្រូវការបណ្តុះបណ្តាលបន្ថែមដូចជា ការប្រើប្រាស់GPS ផែនទី ការសរសេររបាយការណ៍ និងកំណត់ហេតុល្បាតទំនាក់ទំនង និងសម្របសម្រួលជូនភ្ញៀវទេសចរស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះនិងគ្រាប់រំសេវ រៀបចំផែនការល្បាត សង្គ្រោះបឋម ការសិក្សាស្រាវជ្រាវ អនាម័យនិងការថែទាំសុខភាព។

### ៣.២.៣ ការគ្រប់គ្រងអភិរក្សដោយចីរភាព

សមត្ថភាពជំនាញរបស់មន្ត្រីនៅមានកម្រិតជាពិសេសផ្នែកស្រាវជ្រាវ វិភាគទិន្នន័យ រៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការ និងសំណើគម្រោងហើយមិនទាន់មានក្រុមការងារបច្ចេកទេសដើម្បីពិនិត្យនិងតាមដានលើគោលនយោបាយស្តីពីការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី មិនត្រឹមតែប៉ុណ្ណោះការបង្កើតមណ្ឌលស្រាវជ្រាវនិងអភិរក្សកេសរកូលទទួលបានការចាប់អារម្មណ៍និងគាំទ្រពីសាធារណជន ទាំងថ្នាក់ជាតិនិងអន្តរជាតិដែលជាផ្នែកមួយចូលរួមលើកកម្ពស់ជីវភាពប្រជាជនក៏ដូចជាអភិវឌ្ឍន៍ប្រកបដោយចីរភាព។

### ៣.២.៤ ការគ្រប់គ្រងចំណេះដឹងនិងព័ត៌មានបរិស្ថាន

គឺពុំទាន់មាន ដៃគូគាំទ្រផ្នែកហិរញ្ញវត្ថុក៏ដូចជាធនធានមនុស្សគ្រប់គ្រាន់ ក្នុងការរៀបចំវិភាគនិងចងក្រងរបាយការណ៍ស្ថានភាពបរិស្ថាន ហើយខ្វះមន្ត្រីជំនាញបម្រើការងារតាមការិយាល័យចំណុះឱ្យនាយកដ្ឋានកង្វះខាតបច្ចេកទេសក្នុងការគ្រប់គ្រងប្រព័ន្ធទិន្នន័យ មានការសំណូមពរឱ្យបន្តមានវគ្គបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពមន្ត្រីជំនាញក្នុងការិយាល័យលើការគ្រប់គ្រងទិន្នន័យព័ត៌មានភូមិសាស្ត្រ ជាពិសេសទិន្នន័យដែលបានធ្វើបច្ចុប្បន្នភាពនៅមានកម្រិតនៅឡើយក្នុងការប្រើប្រាស់។

### ៣.២.៥ សេវាគាំទ្រការងារបរិស្ថាន និងធនធានធម្មជាតិ

ការងារចាត់ចែងលិខិតស្នាមមួយចំនួនជួបការលំបាកដោយខ្វះប្រព័ន្ធព័ត៌មានវិទ្យា ខ្វះសម្ភារៈបច្ចេកទេសក្នុងការគ្រប់គ្រងមន្ត្រីរាជការ ហើយពុំទាន់មានពេលក្នុងការផ្តល់គ្រឿងឥស្សរិយយស ការដំឡើងឋានន្តរសក្តិ និងថ្នាក់ពីបណ្តាលអង្គភាពផ្សេងៗ និងសមត្ថភាពក្នុងការផ្គត់ផ្គង់ផ្តល់កម្លាំង INTERNET នៅមានកម្រិតនៅឡើយជាពិសេសខ្វះការសហការមិនទាន់ពេញលេញពីអ្នកពាក់ព័ន្ធឬមុខសញ្ញាអធិការកិច្ចក្នុងការធ្វើអធិការកិច្ចផងដែរ។

## ៣.៣ ដំណោះស្រាយ

### ៣.៣.១ វិធានការច្បាប់

ថ្នាក់ដឹកនាំក្រសួងបរិស្ថានត្រូវមានការជួយអន្តរាគមន៍បន្ថែមទៀត ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសស្ថាប័នតុលាការ អយ្យការ ឱ្យបានទាន់ពេលវេលា ក្នុងការចាត់វិធានការលើសំណុំរឿងបទល្មើសធនធម្មជាតិ ដែលមន្ទីរបរិស្ថានខេត្ត បានកសាងនិងដាក់ជូនសាលាដំបូងខេត្តសាមី ជាពិសេសមន្ទីរបរិស្ថានត្រូវបន្តពង្រឹងការអនុវត្តច្បាប់នៅក្នុងដែនសមត្ថភាពកិច្ចរបស់ខ្លួន និងបញ្ជូនសំណុំរឿង តាមនីតិវិធីទៅសាលាដំបូងសាមី និងសូមរៀបចំស្នើសុំបញ្ចូលមន្ត្រីទទួលបាននីតិសម្បទា ជាភ្នាក់ងារនគរបាលយុត្តិធម៌ ហើយបន្តពិភាក្សាជាមួយកងកម្លាំងប្រដាប់អាវុធ ធ្វើយ៉ាងណាឱ្យមានសំណើច្បាស់លាស់ ដោយកំណត់នូវទីតាំង យាមការ និងទំហំតំបន់ដែលត្រូវរៀបចំសម្រាប់គ្រួសារកងទ័ព និងសូមចូលរួមការពារព្រៃនៅតាមដងទន្លេសេកុង និងបញ្ឈប់កុំឱ្យមានការកាប់រានដីព្រៃធ្វើជាកម្មសិទ្ធិ។

### ៣.៣.២ ពង្រឹង និងពង្រីកការផ្សព្វផ្សាយ

គួររៀបចំវគ្គបណ្តុះបណ្តាលបន្ថែមដល់មន្ទីរបរិស្ថានខេត្ត មន្ត្រីឧទ្យានុរក្ស និងអ្នកពាក់ព័ន្ធទាក់ទងនឹងការសរសេរបាយការណ៍ កំណត់ហេតុបទល្មើសធនធានធម្មជាតិ និងនីតិវិធីកសាងសំណុំរឿងព្រមទាំងផ្តល់គ្រូឧទ្ទេសនាម បើកវគ្គបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពមន្ត្រីអំពីការត្រួតពិនិត្យការបំពុលបរិស្ថាន មន្ត្រីនគរបាលយុត្តិធម៌ ហើយក្រសួងគួរតែណែនាំអំពីដំណើរការក្នុងការរៀបចំសាលាមេត្រីបរិស្ថាន និងកម្មវិធីអប់រំផ្សេងៗទៀត។ ជាពិសេសត្រូវអំពាវនាវឱ្យប្រជាពលរដ្ឋបញ្ឈប់ការចូលព្រៃកាប់ឈើ ធ្វើជាមុខរបរ និងចាត់វិធានការឱ្យបានតឹងរឹងទៅការបំពុលបរិស្ថាន ការទុកដាក់សំរាម ការបរបាញ់សត្វព្រៃ ការកាប់រុករានដីព្រៃដើម្បីធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនមួយវិញទៀត អាជ្ញាធរដែលមានសមត្ថកិច្ចត្រូវចុះសិក្សាពិនិត្យ ក៏ដូចជាចុះពន្យល់ណែនាំទៅដល់ប្រជាពលរដ្ឋដែលបានប្រព្រឹត្តអំពើខុសច្បាប់ទាក់ទងទៅនឹងតំបន់ដែលហាមឃាត់ ដូចជាតំបន់អភិរក្ស តំបន់ការពារធម្មជាតិជាដើម។

### ៣.៣.៣ ការផ្តល់ជាមធ្យោបាយ

ជារៀងរាល់រាល់ឆ្នាំ ថ្នាក់ដឹកនាំក្រសួងបរិស្ថានតែងតែយកទុកដាក់ និងគិតគូរទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងស្ថាប័នពាក់ព័ន្ធទាក់ទងទៅនឹងវិស័យបរិស្ថាន ការលុបបំបាត់នូវបទល្មើសធនធានធម្មជាតិ ព្រមទាំងគិតគូរពីសុខុមាលភាពសាធារណៈ ការថែរក្សាសណ្តាប់ធ្នាប់សាធារណៈ តាមរយៈការផ្តល់ជាមធ្យោបាយដឹកជញ្ជូនផ្សេងៗ មានដូចជា ឡានដឹកសំរាម ធុនធំនិងធុនតូចរ៉ឺម៉ងដឹកសំរាម ដើម្បីការរស់នៅស្អាត ភូមិឋានស្អាត។ គួរបញ្ជាក់ឱ្យដឹងថា មធ្យោបាយទាំងនេះនឹងចូលរួមគាំទ្រផ្តល់សេវាប្រមូល សម្អាត ដឹកជញ្ជូនសំរាម សំណល់រឹងនៅក្នុងមូលដ្ឋានដែលពង្រីកសេវាប្រមូលដោយខ្លួនឯង ឱ្យស្អាត ឱ្យអស់ទាន់ពេលវេលា និងធានានិរន្តរភាព ដោយធ្វើភាពជាម្ចាស់ក្នុងការគ្រប់គ្រងសំរាម ការប្រមូល សម្អាត ដឹកជញ្ជូន ទុកដាក់ កែច្នៃ និងទាញយកធនធានពីសំរាម ព្រមទាំងចូលរួមអនុវត្តគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព របស់រាជរដ្ឋាភិបាលឱ្យកាន់តែមានប្រសិទ្ធភាពផងដែរ។ លើសពីនេះ ក្រសួងក៏បានផ្តល់នូវធុងចម្រោះទឹកស្អាត ទៅតាមបណ្តាសាលារៀននានាទូទាំងប្រទេសក្នុងការគាំទ្រការរស់នៅស្អាត អនាម័យស្អាត ដោយបានបង្កើតអាងប្រព្រឹត្តិកម្មទឹកកង្វក់ និងផ្តល់ធុងសំរាម ដើម្បីដាក់ចល័តនៅតាមទីសាធារណៈនានាជាការរួមចំណែកថែរក្សាបរិស្ថាន។

### ៣.៣.៤ បញ្ជ្រាបចំណេះដឹង

ការផ្សព្វផ្សាយ និងការបញ្ជ្រាបចំណេះដឹងបរិស្ថាន គឺជាចំណុចស្នូល ដែលជាមធ្យោបាយក្នុងការទាក់ទាញឱ្យប្រជាពលរដ្ឋស្រលាញ់ និងចូលរួមថែរក្សាបរិស្ថាន តាមរយៈការប្រារព្ធនូវទិវាបរិស្ថានជាតិ ការបើកយុទ្ធនាការដាំដើមឈើនៅតាមបណ្តាខេត្ត វត្តអារាម និងទីសាធារណៈ ការសហការជាមួយដៃគូរអភិវឌ្ឍន៍ វិស័យឯកជន បណ្តាអង្គភាពពាក់ព័ន្ធ ដើម្បីរៀបចំនូវកម្មវិធីនិងវគ្គបណ្តុះបណ្តាល សិក្ខាសាលានានា ពាក់ព័ន្ធវិស័យបរិស្ថាន

ទៅដល់សាធារណជន សិស្ស-និស្សិត ជាពិសេសប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍តំបន់ការពារ។ មិនតែប៉ុណ្ណោះ ក្រសួងបរិស្ថានក៏បានបើកនូវ **យុទ្ធនាការអន្ទាក់សូន្យ** នៅក្នុងតំបន់ការពារធម្មជាតិកម្ពុជាដែលផ្តួចផ្តើម និងដឹកនាំរៀបចំដោយក្រសួងបរិស្ថានដោយមានការចូលរួមរបស់អង្គការអន្តរជាតិ ដៃគូក្នុងកិច្ចការអភិរក្សធនធានធម្មជាតិ នឹងចាប់ផ្តើមជាផ្លូវការនៅថ្ងៃទី**០៣ ខែមីនា ឆ្នាំ២០២២** សម្រាប់រយៈពេល ០៦ខែនៅក្នុងបណ្តាខេត្តខាងកើតទន្លេមេគង្គរួមមានខេត្ត ក្រចេះ ស្ទឹងត្រែង រតនៈគិរី មណ្ឌលគិរី ព្រះវិហារ និងកំពង់ធំ ដើម្បីលុបបំបាត់នូវ ការបរបាញ់ ចាប់ ដាក់អន្ទាក់ សត្វព្រៃគ្រប់ប្រភេទយកមកជួញដូរដោយខុសច្បាប់ ដូចពាក្យថា **អន្ទាក់ គឺជាឃាតករលាក់មុខ អាចបង្ករគ្រោះថ្នាក់ដល់សត្វព្រៃនិងមនុស្ស**។ គោលបំណងសំខាន់ នៃយុទ្ធនាការនេះរួមមាន ការផ្សព្វផ្សាយអប់រំអំពីផលប៉ះពាល់ដោយសារអន្ទាក់ទៅលើជីវិតសត្វ និងជីវិតមនុស្ស ពង្រឹងការអនុវត្តច្បាប់ ការផ្លាស់ប្តូរឥរិយាបថពលរដ្ឋឱ្យបង្កើនការប្រតិបត្តិមេត្រីបរិស្ថាន ស្រលាញ់សត្វព្រៃ ជីវៈចម្រុះ និងការលុបបំបាត់ការបរបាញ់សត្វ ការដាក់អន្ទាក់ខុសច្បាប់ និងការលុបបំបាត់ការជួញដូរសាច់សត្វព្រៃ ក៏ដូចជាបង្កើនសុវត្ថិភាពដល់សត្វព្រៃគ្រប់ប្រភេទ។

### ៣.៣.៥ វិធានការការពារ និងទប់ស្កាត់

ពិតណាស់រាជរដ្ឋាភិបាលតែងតែគិតគូដល់បញ្ហាជាច្រើននៅក្នុងប្រទេសមិនថាជាបញ្ហាបរិស្ថាន ឬបញ្ហាដទៃទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា មិនត្រឹមតែប៉ុណ្ណោះតែងតែយកចិត្តទុកដាក់ហើយបានប្រគល់តួនាទីនេះទៅដល់ក្រសួងបរិស្ថាន ដែលចូលរួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យ និងភាពប្រាកដនិយមរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះថ្នាក់ដឹកនាំក្រសួងបរិស្ថាន បានដាក់ចេញនូវវិធានការក៏ដូចជាលិខិតបទដ្ឋានគតិយុត្តមួយចំនួនរួមមានៈ ច្បាប់ស្តីពីកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ និងច្បាប់ជីវសុវត្ថិភាពព្រមទាំងយុទ្ធនាការអន្ទាក់សូន្យ ដើម្បីទប់ស្កាត់ និងបង្ការការប្រព្រឹត្តបទល្មើសទៅលើព្រៃឈើ សត្វព្រៃ ជីវៈចម្រុះជាដើម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមខាងលើឱ្យទទួលបានជោគជ័យ និងមានប្រសិទ្ធភាព ក្រសួងបរិស្ថានគួរតែយកចិត្តទុកដាក់ និងផ្តោតសំខាន់ទៅលើៈ

- **កិច្ចគាំពារបរិស្ថានៈ** គឺទប់ស្កាត់ និងកាត់បន្ថយការបំពុលបរិស្ថាន សំដៅលើកកម្ពស់សុខភាពសាធារណៈ ការអភិរក្សជីវៈចម្រុះ និងគុណភាពបរិស្ថាន
- **ការគ្រប់គ្រងនិងអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍសហគមន៍មូលដ្ឋានៈ** ធានានូវការគ្រប់គ្រងការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិ ក្នុងតំបន់ការពារធម្មជាតិប្រកបដោយនិរន្តរភាព
- **ការគ្រប់គ្រងការអភិវឌ្ឍន៍ដោយចីរភាពៈ** គោលបំណងគាំទ្រគោលដៅអភិវឌ្ឍន៍ដោយចីរភាព តាមរយៈការសិក្សាស្រាវជ្រាវ និងកសាងសមត្ថភាព, ជំរុញ ការរៀបចំ និងអនុវត្តគោលនយោបាយ យន្តការគតិយុត្ត

និងឧបករណ៍ជំនួយដល់ការធ្វើសេចក្តីសេចក្តីចិត្តការលើកកម្ពស់ប្រសិទ្ធភាព ក្នុងការប្រើប្រាស់មូលដ្ឋានធម្មជាតិ និងការកាត់បន្ថយការបំពុលបរិស្ថាន

- **ការគ្រប់គ្រងចំណេះដឹង និងព័ត៌មានបរិស្ថាន:** លើកកម្ពស់ចំណេះដឹងដល់សាធារណៈជន ដើម្បីប្រតិបត្តិបរិស្ថានល្អ
- **សេវាគាំទ្រការងារបរិស្ថាន និងធនធានធម្មជាតិ:** គោលបំណង ពង្រឹងការអនុវត្តរដ្ឋបាលទំនើបក្នុងវិស័យបរិស្ថាន។

# សេចក្តីសន្និដ្ឋាន

យោងតាមការសិក្សាស្រាវជ្រាវ និងការចុះសាកសួរព័ត៌មានផ្ទាល់ជាក់ស្តែងនៅក្នុងនាយកដ្ឋានធនធានមនុស្ស នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ព្រមទាំងមន្ត្រីដែលអនុវត្តការងារនៅក្នុងក្រសួងបរិស្ថាន ដើម្បីធ្វើការសិក្សាឈ្វេងយល់ប្រធានបទស្តីពី“ **ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងបរិស្ថាន** ” យើងសង្កេតឃើញថា កន្លងមករហូតមកទល់បច្ចុប្បន្ននេះ ចំពោះបញ្ហាបរិស្ថាន នូវតែជាបញ្ហាចោទដ៏ធំមួយនៅក្នុងសង្គម ជាពិសេសនៅក្នុងប្រទេសដែលកំពុងតែមានការអភិវឌ្ឍន៍ដូចជាប្រទេសកម្ពុជាជាដើម។ ហេតុនេះ ទើបរាជរដ្ឋាភិបាលសម្រេចបង្កើតនូវក្រសួងបរិស្ថាន ដើម្បីគ្រប់គ្រងដឹកនាំ រៀបចំ ហេដ្ឋារចនាសម្ព័ន្ធ ការគ្រប់គ្រងសណ្តាប់ធ្នាប់សាធារណៈផ្សេងៗ ទាក់ទាក់នឹងបញ្ហាបរិស្ថាន ដែលកន្លងមកនេះ ក្រសួងបរិស្ថានបានបំពេញភារកិច្ចរបស់ខ្លួនដោយសម្រេចបានជោគជ័យ និងប្រកបដោយមោទនជាប្រវត្តិសាស្ត្រ ក្នុងក្របខណ្ឌកែទម្រង់រចនាសម្ព័ន្ធក្រសួង ការអនុវត្តផែនការថវិកា កម្មវិធី ផែនការយុទ្ធសាស្ត្រ៣ឆ្នាំរំកិល ដែលជាធនធានថវិការជាតិសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការអនុវត្តនូវប្រសិទ្ធភាពការងាររៀងៗខ្លួន។ ក្រសួងបរិស្ថាន បានកំណត់ចក្ខុវិស័យរបស់ខ្លួនក្នុងបំណងប្រាថ្នា “សង្គមកម្ពុជាមួយប្រកប ដោយភាពបៃតងតាមរយៈការបង្កើនចំនួនតំបន់ការពារធម្មជាតិ បរិស្ថានមានគុណភាពល្អស្អាត ការអភិវឌ្ឍន៍ ចីរភាព ជីវភាពសហគមន៍មូលដ្ឋាន និងប្រជាជនរុងរឿងដែលជាឧត្តមប្រយោជន៍ និងមានសុខដុមរម្យនាសម្រាប់ប្រជាពលរដ្ឋគ្រប់ៗជំនាន់ ”។

ទន្ទឹមនឹងការអភិវឌ្ឍន៍នេះផងដែរ ក៏តែងតែជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន ជាពិសេសស្ថិតក្នុងបរិការណ៍នៃការឆ្លងរីករាលដាលខ្លាំងក្លាពាសពេញពិភពលោកនៃជំងឺកូវីដ-១៩ ដែលឆ្លងចូលក្នុងសហគមន៍នៃព្រឹត្តិការណ៍ ២០ កុម្ភៈ ឆ្នាំ២០២១ បានធ្វើឱ្យរាជរដ្ឋាភិបាលដាក់ចេញវិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការទប់ស្កាត់ការរីករាលដាលពាសពេញប្រទេស ដោយបិទការឆ្លងកាត់ពីរាជធានី និងខេត្ត និងពីខេត្តមួយទៅខេត្តមួយក៏ដោយក៏ក្រសួងបរិស្ថាននៅតែបន្តការខិតខំបំពេញការងារ និងសម្រេចបាននូវបណ្តាភារកិច្ចស្នូលសំខាន់ៗដូចជាៈ ការងារគ្រប់គ្រងធនធានមនុស្ស ការរៀបចំគោលនយោបាយបរិស្ថាន និងផែនការយុទ្ធសាស្ត្រនានា ការសិក្សាស្រាវជ្រាវ ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូរអភិវឌ្ឍន៍ ការពង្រឹងការគ្រប់គ្រងសំណល់រឹងទីប្រជុំជន ការទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ ការអប់រំផ្សព្វផ្សាយការងារបរិស្ថាន ការរៀបចំកិច្ចប្រជុំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលនានាតាមរយៈប្រព័ន្ធអនទ្បាញជាដើម។ ទោះបីជាយ៉ាងនេះក្តីបទល្មើសការរុករានទន្ទ្រានដីធ្លីក្នុងតំបន់ការពារធម្មជាតិយកធ្វើជាកម្មសិទ្ធនៅតែបន្តកើតមាន ដោយសារកត្តាមួយចំនួនដូចជាៈ តម្រូវការដីធ្វើកសិកម្ម ការបញ្ជាក់របស់អាជ្ញាធរមូលដ្ឋានលើឯកសារកាន់កាប់ ឬឯកសារលក់-ទិញដោយខុសច្បាប់ក្នុងតំបន់ការពារធម្មជាតិ និងការធ្វេសប្រហែស ឬការឃុបឃិតគ្នារវាងអ្នកទន្ទ្រានដី និងមន្ត្រីខិលខូចមួយចំនួនតូចផងដែរ។

ដើម្បីសម្រេចបានជោគជ័យ នៃការងារខាងលើក្រសួងបរិស្ថានបានធ្វើប្រតិភូកម្ម និងផ្ទេរមុខងារដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរបរិស្ថានខេត្ត-រាជធានី បានជំរុញនិងលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តកិច្ចគាំពារបរិស្ថាន ការអភិរក្ស និងថែរក្សាធនធានធម្មជាតិ ការអភិវឌ្ឍន៍ដោយចីរភាព ដែលឆ្លើយតបទៅនឹងលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នៃរាជរដ្ឋាភិបាលកម្ពុជា។ យ៉ាងណាមិញក្រសួងបន្តលើកកម្ពស់ និងជំរុញអនុវត្តឱ្យបានទូលំទូលាយចំពោះ គោលនយោបាយស្តីពីកិច្ចគាំពារមន្ត្រីរាជការក្រសួងបរិស្ថាន និងបន្តពង្រឹងកែលម្អចំណុចខ្វះខាតលើការងាររដ្ឋបាល ការងារហិរញ្ញវត្ថុ ការងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ការងារគ្រប់គ្រងធនធានមនុស្ស ឱ្យកាន់តែមានប្រសិទ្ធភាពក៏ដូចជាបន្តផ្តល់សេវាសាធារណៈតាមការិយាល័យច្រកចេញ-ចូលតែមួយ ឱ្យកាន់តែមានតម្លាភាព និងគណនេយ្យភាព ព្រមទាំងចូលរួមអនុវត្តនូវគោលនយោបាយនានាដែលដាក់ចេញដោយរាជរដ្ឋាភិបាល។

# អនុសាសន៍

ឆ្លងតាមការសិក្សាស្រាវជ្រាវ និងសេចក្តីសន្និដ្ឋានខាងលើ យើងខ្ញុំសូមចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល និងអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ជាពិសេសក្រសួងបរិស្ថានផ្ទាល់ ដើម្បីសម្រេចបានជោគជ័យ និងធ្វើជាប់ជាប្រចាំឆ្លើយតបទៅនឹងដំណើរវិវឌ្ឍន៍នៃសង្គមជាតិ ពង្រឹងប្រសិទ្ធភាពការងារ ការកសាងទំនុកចិត្ត និងភាពប្រសើរឡើងនៃការផ្តល់សេវាសាធារណៈ។ ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យ និងភាពប្រាកដនិយមរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ផ្អែកលើមូលដ្ឋានយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ បានកំណត់លម្អិតជាគោលនយោបាយអាទិភាព សកម្មភាពអនុវត្តគោលនយោបាយអាទិភាពនិងវិស័យជាក់លាក់ ដើម្បីបែងចែកដល់គ្រប់ក្រសួងស្ថាប័នចំណុះរាជរដ្ឋាភិបាល ម្ចាស់ការ ចូលរួម និងសហការអនុវត្ត តាមគោលដៅសូចនាករ សមិទ្ធកម្មប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ទៅតាមតួនាទី និងបេសកកម្មដែលកំណត់ដោយរាជរដ្ឋាភិបាល។ បើទោះបីជាមានការវិវត្តន៍ពីមួយឆ្នាំទៅមួយឆ្នាំស្របទៅតាមផែនការយុទ្ធសាស្រ្ត និងទិសដៅការងារយ៉ាងណាក៏ដោយ ចំណុចខ្វះខាតមួយចំនួននូវតែកើតមានឡើង ដូច្នេះយើងខ្ញុំ សូមចូលរួមជាអនុសាសន៍មួយចំនួន ដើម្បីឱ្យការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងបរិស្ថានកាន់តែល្អប្រសើរជាងនេះមួយកម្រិតទៀត៖

- ស្នើសុំមន្ត្រីជំនាញបន្ថែមទៀត និងបន្តស្នើសុំបុគ្គលិកស្ម័គ្រចិត្ត ជាពិសេសនិស្សិតដែលទើបបញ្ចប់ការសិក្សានៅមហាវិទ្យាល័យ និងសាកលវិទ្យាល័យ ដែលចង់សាកល្បងការងារ ដើម្បីទទួលបានបទពិសោធន៍
- ស្នើសុំឱ្យមានការគាំទ្រ ដល់យន្តទាំងឡាយណាដែលជួយជំរុញឱ្យមានការចូលរួម និងសហការពីស្ថាប័នពាក់ព័ន្ធនិងដៃគូអភិវឌ្ឍន៍នានា
- គួរមានការពង្រឹងសមត្ថភាព និងភាពទទួលខុសត្រូវរបស់រដ្ឋបាលក្រុង ស្រុក ដោយរៀបចំឱ្យមានការបណ្តុះបណ្តាលអ្នកទទួលខុសត្រូវនិងអ្នកពាក់ព័ន្ធ
- ស្នើសុំឱ្យបង្កើនកិច្ចសហការក្នុងការចែករំលែកព័ត៌មានពីស្ថាប័នពាក់ព័ន្ធ
- គួរជំរុញការរៀបចំយន្តការច្បាស់លាស់ សមស្របនិងមានសមត្ថភាពនៅតាមក្រុង ស្រុកឱ្យទទួលខុសត្រូវលើការងារគ្រប់គ្រងសំរាមទីប្រជុំជន
- ជាភាពចាំបាច់មន្ត្រីជំនាញទាំងអស់គួរទទួលបានការធានារ៉ាប់រងសុខភាព និងអាយុជីវិត ចំពោះមន្ត្រីជំនាញដែលចុះបំពេញបេសកកម្ម ស្រាវជ្រាវនៅតាមតំបន់ដាច់ស្រយាល និងតំបន់ព្រៃភ្នំនានាដែលប្រឈមមុខនឹងគ្រោះថ្នាក់ខ្លាំងផ្នែកសុខភាព និងអាយុជីវិត
- ស្នើសុំឱ្យក្រសួងស្ថាប័នពាក់ព័ន្ធយកចិត្តទុកដាក់ និងបង្កើនការផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយទាន់ពេលវេលានិងមានប្រសិទ្ធភាពទាក់ទងនិងចំណេះដឹងបរិស្ថានដល់សាធារណជន

- ជំរុញឱ្យមានការចូលរួមរបស់ប្រជាជនក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ការទុកដាក់បែងចែកសំរាមឱ្យបានត្រឹមត្រូវ
- ការផ្សព្វផ្សាយយន្តការពង្រឹងការអនុវត្តច្បាប់ អនុក្រឹត្យ ប្រកាស គោលការណ៍ណែនាំ និងលិខិតបទដ្ឋានគតិយុត្តឱ្យទាន់ពេលវេលា និងទូលំទូលាយដល់ម្ចាស់ប្រភពបំពុល និងស្ថាប័នពាក់ព័ន្ធ
- ជំរុញឱ្យមានការចូលរួម កាត់បន្ថយការប្រើប្រាស់ប្លាស្ទិក តាមរយៈការប្រារព្ធនូវយុទ្ធនាការផ្សេងៗ។

# ឯកសារយោង

# ឯកសារយោង

## ក. ផ្នែកបទដ្ឋានគតិយុត្ត

១. ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន

២. ព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤០៣ ចុះថ្ងៃទី០៩ ឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិ អភិវឌ្ឍន៍ដោយចីរភាព

៣. អនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

៤. អនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

៥. អនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

៦. អនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

៧. អនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន។

## ខ. ឯកសារផ្សេងៗ

៨. របាយការណ៍សន្និបាតបូកសរុបលទ្ធផលការងារបរិស្ថានឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០

៩. របាយការណ៍បូកសរុបការងារបរិស្ថានប្រចាំឆ្នាំ២០២១

១០. ផែនការថវិកាយុទ្ធសាស្ត្រ ៣ឆ្នាំរំកិលឆ្នាំ ២០២២-២០២៣

១១. របាយការណ៍លទ្ធផលការងារបរិស្ថានឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨

១២. ឯកសារជំនួយស្មារតីក្នុងកិច្ចពិភាក្សាការងារបរិស្ថាន និងធនធានធម្មជាតិ ឆ្នាំ២០២១

១៣. របាយការណ៍កម្មសិក្សាសិស្សមន្ត្រីក្រមការជំនាន់ទី៧ របស់លោក សំ សុផល ឆ្នាំ២០១៧

១៤. របាយការណ៍កម្មសិក្សាសិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី១០ របស់លោក អ៊ុន ច័ន្ទកុសល្យ ឆ្នាំ២០១៩

១៥. របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សារបស់និស្សិតឈ្មោះ គឹម ចន្ទ្រា និង ហុង អេងលី ឆ្នាំ២០១៧

១៦. គេហទំព័រ https://fb.watch/eoOXVSXhoX/ ដកស្រង់នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២

១៧. គេហទំព័រ https://www.moe.gov.kh/index/29971 ដកស្រង់នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

- **ឧបសម្ព័ន្ធរូបភាព**

  រូបភាពទី១  ១.១.២ ទីតាំងក្រសួងបរិស្ថាន

  រូបភាពទី២  ១.១.៣ ស្លាកសញ្ញានៃក្រសួងបរិស្ថាន

- **ឧបសម្ព័ន្ធជាលិខិតបទដ្ឋានគតិយុត្ត**

- **ឧបសម្ព័ន្ធទី១** ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- **ឧបសម្ព័ន្ធទី២** អនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- **ឧបសម្ព័ន្ធទី៣** អនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- **ឧបសម្ព័ន្ធទី៤** អនុក្រឹត្យលេខ ២៣៨ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- **ឧបសម្ព័ន្ធទី៥** ប្រកាសលេខ៥៤  បដ្ឋ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៣  ស្តីពីការទទួលស្គាល់មន្ត្រីរាជការបំរើការងារនៅក្រសួងបរិស្ថាន
- **ឧបសម្ព័ន្ធទី៦** របាយការណ៍បូកសរុបការងារបរិស្ថានប្រចាំឆ្នាំ២០២១ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២២
- **ឧបសម្ព័ន្ធទី៧** ឯកសារពាក់ព័ន្ធនឹងលិខិតអនុញ្ញាតការចុះស្រាវជ្រាវ

# ឧបសម្ព័ន្ធជារូបភាព

រូបភាពទី១  ១.១.២ ទីតាំងក្រសួងបរិស្ថាន



រូបភាពទី២ ១.១.៣ ស្លាកសញ្ញានៃក្រសួងបរិស្ថាន



# ឧបសម្ព័ន្ធ
# ជាលិខិតបទដ្ឋានគតិយុត្ត

# ឧបសម្ព័ន្ធទី១

# ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រើច្បាប់ស្ដីពីការបង្កើតក្រសួងបរិស្ថាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

# ស្តីពី

# ការបង្កើតក្រសួង
# បរិស្ថាន

# ព្រះរាជក្រម នស/រកម/០១៩៦/២១

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស
## ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម
## ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

## ប្រកាសអោយប្រើ

**ច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន ដែលរដ្ឋសភាបានអនុម័ត នាសម័យ ប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :**

# ច្បាប់

## ស្តីពី

## ការបង្កើតក្រសួងបរិស្ថាន

**មាត្រា ១** : ត្រូវបានបង្កើតក្រសួងបរិស្ថាន ចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

**មាត្រា ២** : ក្រសួងបរិស្ថានមានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យបរិស្ថាន នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣** : ក្រសួងបរិស្ថាន ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអាចអមដោយរដ្ឋលេខាធិការនិង ឬអនុរដ្ឋលេខាធិការ តាមការចាំបាច់ ។

**មាត្រា ៤** : ការរៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តិទៅរបស់ក្រសួងបរិស្ថាន ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥** : បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦** : ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

**ព្រះហស្ថលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រីទី ១** **នាយករដ្ឋមន្ត្រីទី ២**

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

* * *

# ឧបសម្ព័ន្ធទី២

## អនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

# ឧបសម្ព័ន្ធទី៣

## អនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃ ទី០៤ ខែមេសា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

១៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៥ អនក្រ.បក

ក្រសួងបរិស្ថាន
លេខ: ២៤៨៥
ថ្ងៃទី០២ ខែ០៦ ឆ្នាំ២០១៤
ម៉ោង ០៥,៣០

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់បេសកកម្ម ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាននិងបណ្តាអង្គភាពក្រោមឱវាទក្រសួង។

- រៀបចំនិងអនុវត្តលិខិតបទដ្ឋានគតិយុត្តនិងនីតិវិធីនានាសម្រាប់ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងការពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់គម្រោងវិនិយោគសាធារណៈ និងគម្រោងវិនិយោគឯកជន
- គ្រប់គ្រងនិងសម្របសម្រួលការងារការពារនិងអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព
- ប្រមូល វិភាគ និងគ្រប់គ្រងទិន្នន័យបរិស្ថាននិងធនធានធម្មជាតិ
- រៀបចំរបាយការណ៍ស្តីពីស្ថានភាពបរិស្ថាននៅព្រះរាជាណាចក្រកម្ពុជាឱ្យបានទៀងទាត់
- លើកសំណើជូនរាជរដ្ឋាភិបាលអំពីការចូលរួមក្នុងកិច្ចព្រមព្រៀង អនុសញ្ញា និងពិធីសារអន្តរជាតិនានា ដែលទាក់ទងនឹងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍដោយចីរភាព ព្រមទាំងអនុវត្តកិច្ចការជំនាញពាក់ព័ន្ធ សម្រាប់ជាមូលដ្ឋានជូនរាជរដ្ឋាភិបាលក្នុងការបំពេញកាតព្វកិច្ច និងការទទួលខុសត្រូវនៅក្រោមកិច្ចព្រមព្រៀង អនុសញ្ញា និងពិធីសារទាំងនោះ
- ជំរុញនិងលើកទឹកចិត្តឱ្យមានការវិនិយោគក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព និងការរស់នៅដោយចីរភាព
- កៀរគរនិងគ្រប់គ្រងធនធានសម្រាប់កិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងនិរន្តរភាព និងការរស់នៅដោយចីរភាព
- សហការជាមួយបណ្តាប្រទេសនៅក្នុងតំបន់និងពិភពលោក អង្គការជាតិ អង្គការអន្តរជាតិ និងសហគមន៍មូលដ្ឋាន ដើម្បីធានាឱ្យមានកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព និងការរស់នៅដោយចីរភាព
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីរាជរដ្ឋាភិបាល។

**មាត្រា៤ ..**

ក្រសួងបរិស្ថានមានរចនាសម្ព័ន្ធដូចខាងក្រោម៖

**ក. ថ្នាក់កណ្តាល**

- អគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន
- អគ្គនាយកដ្ឋានគាំពារបរិស្ថាន
- អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ
- អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- អគ្គាធិការដ្ឋាន
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង
- ខុទ្ទកាល័យរដ្ឋមន្ត្រី។

**ខ. អង្គភាពមូលដ្ឋាន**

**គ. គ្រឹះស្ថានសាធារណៈក្រោមអាណាព្យាបាល។**

អង្គការលេខនៃក្រសួងបរិស្ថានមានភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៦ ..**

នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងផ្នែករដ្ឋបាលនិងសម្របសម្រួលការងាររបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រង និងចរាចរឯកសាររបស់អគ្គនាយកដ្ឋាន
- លើកសំណើ និងសម្របសម្រួលការងារលទ្ធកម្មសាធារណៈរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិ ឧបករណ៍ និងសម្ភារៈការិយាល័យរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងមន្ត្រីរាជការ និងបុគ្គលិកទាំងក្នុងក្របខ័ណ្ឌ និងក្រៅក្របខ័ណ្ឌ និងការកសាងសមត្ថភាពរបស់អគ្គនាយកដ្ឋាន
- សម្របសម្រួលការរៀបចំផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ផែនការថវិកា និងផែនការត្រួតពិនិត្យនិងវាយតម្លៃរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងគណនេយ្យនិងហិរញ្ញវត្ថុរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងការងារពិធីការរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងការងារសង្គមកិច្ចរបស់អគ្គនាយកដ្ឋាន
- ធ្វើកំណត់ហេតុប្រជុំរបស់អគ្គនាយកដ្ឋាន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការការប្រគល់ជូនពីអគ្គនាយក។

**មាត្រា៧ ..**

នាយកដ្ឋានសេវាកម្មព័ត៌មានភូមិសាស្ត្រមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការ និងថវិកា លើកស្ទួយកិច្ចសហការជាមួយអ្នកពាក់ព័ន្ធ កសាងសមត្ថភាពមន្ត្រីនាយកដ្ឋាន គ្រប់គ្រងហិរញ្ញវត្ថុ អង្កេតតាមដានការងារផ្ទៃក្នុង និងគ្រប់គ្រងការងាររដ្ឋបាលនានា ដែលពាក់ព័ន្ធនឹងតួនាទីនិងភារកិច្ចរបស់នាយកដ្ឋាន
- អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យព័ត៌មានភូមិសាស្ត្រនិងទូរវិញ្ញាណ ស្តីពីគុណភាពបរិស្ថាន ធនធានធម្មជាតិ និងជីវៈចម្រុះ
- ប្រមូល វិភាគ ចងក្រង និងគ្រប់គ្រងព័ត៌មានភូមិសាស្ត្រនិងព័ត៌មានស្តីពីគុណភាពបរិស្ថាន ធនធានធម្មជាតិ និងជីវៈចម្រុះ ព្រមទាំងព័ត៌មានដទៃទៀតពាក់ព័ន្ធនឹងបរិស្ថាន
- ផលិតនិងផ្តល់សេវាកម្មព័ត៌មានភូមិសាស្ត្រ រួមទាំងផែនទី ដើម្បីគាំទ្រដល់កិច្ចគាំពារបរិស្ថាន និងការអភិរក្សធនធានធម្មជាតិនិងជីវៈចម្រុះ
- ផ្តល់ការគាំទ្រដល់ការសិក្សាស្រាវជ្រាវនិងវិភាគអំពីការប្រែប្រួលធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ និងការប្រែប្រួលអាកាសធាតុតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ
- សម្របសម្រួលការកំណត់និងចងក្រងសូចនាករសម្រាប់តាមដានស្ថានភាពធនធានធម្មជាតិនិងគុណភាពបរិស្ថាន

- ធ្វើបច្ចុប្បន្នភាពព័ត៌មានពាក់ព័ន្ធវិស័យបរិស្ថាន ដូចជាគោលនយោបាយ លិខិតបទដ្ឋានគតិយុត្តផែនការ សកម្មភាព និងសមិទ្ធផលរបស់ក្រសួង ព្រមទាំងសកម្មភាពការងាររបស់ថ្នាក់ដឹកនាំក្រសួង តាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន
- សហការនិងសម្របសម្រួលការរៀបចំសម្ភារៈផ្សព្វផ្សាយ និងការបោះពុម្ពផ្សាយ រួមមាន ទស្សនាវដ្ដីបរិស្ថាន ព្រឹត្តិប័ត្រព័ត៌មាន ប័ណ្ណផ្សព្វផ្សាយព័ត៌មាន
- សម្របសម្រួលការរៀបចំសុន្ទរកថា សេចក្តីថ្លែងការណ៍ សេចក្តីប្រកាសព័ត៌មានបរិស្ថានរបស់ក្រសួង
- សម្របសម្រួលការផ្តល់ព័ត៌មានបរិស្ថានដល់អ្នកសារព័ត៌មាននិងប្រព័ន្ធផ្សព្វផ្សាយនានា
- សម្របសម្រួលការរៀបចំនិងផលិតឯកសារបរិស្ថានប្រចាំឆ្នាំស្តីពីសមិទ្ធផលការងារគ្រប់គ្រងបរិស្ថាន រួមមាន របាយការណ៍វឌ្ឍនភាពបរិស្ថានប្រចាំឆ្នាំនិងប្រតិទិនការងារ
- រៀបចំនិងគ្រប់គ្រងវិចិត្រសាលនិងបណ្ណាល័យរបស់ក្រសួង
- រៀបចំផែនការនិងចាត់ចែងពិធីនិងយុទ្ធនាការបរិស្ថាននានា ជាអាទិ៍ទិវាបរិស្ថាន ទិវាជីវៈចម្រុះ ទិវាដីសើម
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីអគ្គនាយក។

**មាត្រា១០ ..**

នាយកដ្ឋានរង្វាន់និងលើកទឹកចិត្ត មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការ និងថវិកា លើកស្ទួយកិច្ចសហការជាមួយអ្នកពាក់ព័ន្ធ កសាងសមត្ថភាពមន្ត្រីនាយកដ្ឋាន គ្រប់គ្រងហិរញ្ញវត្ថុ អង្កេតតាមដានការងារផ្ទៃក្នុង និងគ្រប់គ្រងការងាររដ្ឋបាលនានា ដែលពាក់ព័ន្ធនឹងតួនាទីនិងភារកិច្ចរបស់នាយកដ្ឋាន
- បង្កើតកម្មវិធីសម្រាប់ជំរុញទម្លាប់ល្អខាងប្រតិបត្តិការបៃតង ឬ មេត្រីភាពបរិស្ថាន
- ផ្សព្វផ្សាយជាសាធារណៈនូវស្តង់ដារនិងគោលការណ៍ណែនាំនានា អំពីទម្លាប់ល្អខាងប្រតិបត្តិការបៃតង ឬ មេត្រីភាពបរិស្ថាន ដល់វិស័យសេដ្ឋកិច្ចនានាជាគោលដៅ និងសាធារណៈជនទូទៅ
- សម្របសម្រួលការរៀបចំលក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃគុណវុឌ្ឍិលើទម្លាប់ល្អខាងប្រតិបត្តិការបៃតង ឬ មេត្រីភាពបរិស្ថាន
- សហការជាមួយបណ្តាអង្គភាពក្រោមឱវាទក្រសួង ក្នុងការចងក្រងស្ថិតិនិងតាមដានប្រតិបត្តិការពាក់ព័ន្ធនឹងទម្លាប់ល្អខាងប្រតិបត្តិការបៃតង ឬ មេត្រីភាពបរិស្ថាន
- ផ្តល់ការគាំទ្របច្ចេកទេសស្តីពីទម្លាប់ល្អខាងប្រតិបត្តិការបៃតង ឬ មេត្រីភាពបរិស្ថាន ដល់បុគ្គលវិស័យសាធារណៈ វិស័យឯកជន សង្គមស៊ីវិល ដើម្បីលើកទឹកចិត្តក្នុងការទទួលបានសមិទ្ធផលដែលគួរទទួលរង្វាន់
- ពិនិត្យ វាយតម្លៃ និងផ្តល់យោបល់លើការផ្តល់រង្វាន់និងលើកទឹកចិត្តដល់បុគ្គល វិស័យសាធារណៈ វិស័យឯកជន សង្គមស៊ីវិល ដែលមានស្នាដៃក្នុងការអនុវត្តទម្លាប់ល្អខាងប្រតិបត្តិការបៃតង ឬ មេត្រីភាពបរិស្ថាន

- អនុវត្តការផ្តល់សេវាកម្មសាធារណៈពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន ដែលមានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្ត
- ពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាតាមរយៈការចុះត្រួតពិនិត្យ និងធ្វើអធិការកិច្ចលើទីតាំង ឬ មធ្យោបាយនៃផលិតកម្ម អាជីវកម្ម ឬ សេវាកម្ម ដែលពាក់ព័ន្ធនឹងការនាំចូល ការនាំចេញ ការឆ្លងកាត់ ការបង្កើត ការផលិត ការប្រើប្រាស់ ការកែច្នៃ ការធ្វើប្រព្រឹត្តកម្ម និងការបោះបង់ចោល ឬ ការបញ្ចេញចោលសំណល់និងសារធាតុគ្រោះថ្នាក់បរិស្ថាន
- ត្រួតពិនិត្យនិងផ្តល់យោបល់លើដំណើរការទាំងមូលនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការពិនិត្យតាមដានផែនការគ្រប់គ្រងបរិស្ថាន
- ផ្តល់យោបល់និងសម្របសម្រួលជាមួយស្ថាប័ន ឬ អង្គភាពពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការទប់ស្កាត់ ឬ លុបបំបាត់ការបំពុលបរិស្ថាន ការស្តារគុណភាពបរិស្ថានឡើងវិញ និងចូលរួមវាយតម្លៃអំពីការខូចខាត ឬ ផលប៉ះពាល់បរិស្ថាន ដែលបណ្តាលមកពីការបំពុលបរិស្ថាន
- រៀបចំផែនការត្រៀមបង្ការសម្រាប់ឆ្លើយតបបន្ទាន់លើករណីឧបទ្ទវហេតុនៃគ្រោះបំពុលបរិស្ថានផ្សេងៗ
- ផ្តល់សេវាកម្មមន្ទីរពិសោធន៍សម្រាប់គាំទ្រដល់ការងារកិច្ចគាំពារបរិស្ថាន និងសម្រាប់សាធារណជនទូទៅ
- បំពេញកិច្ចការជំនាញតាមកិច្ចព្រមព្រៀង អនុសញ្ញា និងពិធីសារអន្តរជាតិនានា ទាំងថ្នាក់តំបន់ និងថ្នាក់ពិភពលោក ពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន ដែលកម្ពុជាជាសមាជិក ហើយដែលក្រសួងបរិស្ថានជាស្ថាប័នបង្គោលជាតិ
- រៀបចំរបាយការណ៍ជាតិស្តីពីស្ថានភាពគុណភាពបរិស្ថាន ឬ ស្ថានភាពនៃការបំពុលបរិស្ថាន ជាពិសេសនៅតាមតំបន់ ដែលមានសក្តានុពលសម្រាប់ការអភិវឌ្ឍនិងងាយរងការបំពុលបរិស្ថាន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តការកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីរដ្ឋមន្ត្រី។

អគ្គនាយកដ្ឋានគាំពារបរិស្ថានដឹកនាំដោយអគ្គនាយកមួយរូប អមដោយអគ្គនាយករងមួយចំនួនតាមការចាំបាច់។

អគ្គនាយកដ្ឋានគាំពារបរិស្ថាន មាននាយកដ្ឋានចំណុះដូចខាងក្រោម៖

- នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ
- នាយកដ្ឋានគ្រប់គ្រងគុណភាពខ្យល់និងសំឡេង
- នាយកដ្ឋានគ្រប់គ្រងគុណភាពទឹក
- នាយកដ្ឋានគ្រប់គ្រងសំណល់រឹង
- នាយកដ្ឋានគ្រប់គ្រងសារធាតុគ្រោះថ្នាក់
- នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- នាយកដ្ឋានអធិការកិច្ចនិងពង្រឹងការអនុវត្តច្បាប់
- មន្ទីរពិសោធន៍។

នាយកដ្ឋាននីមួយៗ និងមន្ទីរពិសោធន៍ដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួនតាមការចាំបាច់។

- សហការជាមួយស្ថាប័ន ឬ អង្គភាពពាក់ព័ន្ធ ធ្វើការត្រួតពិនិត្យគុណភាពឥន្ធនៈហ្វូស៊ីល ដែលផលិតក្នុងស្រុកនិងនាំចូលពីបរទេស
- ផ្សព្វផ្សាយនិងណែនាំដល់ប្រតិបត្តិករនៃទីតាំង ឬ សកម្មភាពផលិតកម្ម អាជីវកម្ម ឬ សេវាកម្ម អំពីច្បាប់ លិខិតបទដ្ឋានគតិយុត្ត ស្តង់ដារ និងគោលការណ៍ណែនាំបច្ចេកទេស ដែលពាក់ព័ន្ធនឹងការការពារគុណភាពខ្យល់បរិយាកាស ខ្យល់ក្នុងអាគារ និងការកាត់បន្ថយភាពរំខាននៃសំឡេង និងរំញ័រ
- សិក្សា ស្រាវជ្រាវ វាយតម្លៃ និងផ្សព្វផ្សាយអំពីបច្ចេកវិទ្យាថ្មីៗសម្រាប់តាមដាន ទប់ស្កាត់ និងត្រួតពិនិត្យការសាយភាយសារធាតុបំពុលខ្យល់ ការបញ្ចេញសំឡេង ឬ រំញ័រពីប្រភពចល័តនិងអចល័ត
- សិក្សាស្រាវជ្រាវ និងផ្សព្វផ្សាយអំពីប្រភេទ កម្រិត និងភាពគ្រោះថ្នាក់នៃសារធាតុបំពុលខ្យល់ដែលបានសាយភាយចូលក្នុងខ្យល់បរិយាកាស និងខ្យល់ក្នុងអគារ
- ប្រមូលចងក្រងនិងគ្រប់គ្រងទិន្នន័យប្រភពបង្កការបំពុលខ្យល់ គុណភាពខ្យល់បរិយាកាស គុណភាពខ្យល់ក្នុងអគារ និងសារធាតុបំពុលដែលសាយភាយចូលទៅក្នុងខ្យល់
- រៀបចំរបាយការណ៍ជាតិអំពីស្ថានភាពគុណភាពខ្យល់បរិយាកាស និងខ្យល់ក្នុងអគារ
- បំពេញការកិច្ចជាស្ថាប័នបង្គោលជាតិនៃអនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិ ពាក់ព័ន្ធនឹងការការពារ និងការត្រួតពិនិត្យការបំពុលខ្យល់ ជាអាទិ៍ បញ្ហាផ្សែងអ័ព្ទ អាស៊ីតបរិយាកាស កិច្ចការពារស្រទាប់អូហ្សូន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីអគ្គនាយក។

**មាត្រា១៤ ..**

នាយកដ្ឋានគ្រប់គ្រងគុណភាពទឹកមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការ និងថវិកា លើកស្ទួយកិច្ចសហការជាមួយអ្នកពាក់ព័ន្ធ កសាងសមត្ថភាពមន្ត្រីនាយកដ្ឋាន គ្រប់គ្រងហិរញ្ញវត្ថុ អង្កេតតាមដានការងារផ្ទៃក្នុង និងគ្រប់គ្រងការងាររដ្ឋបាលនានា ដែលពាក់ព័ន្ធនឹងតួនាទីនិងភារកិច្ចរបស់នាយកដ្ឋាន
- រៀបចំលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនានាពាក់ព័ន្ធនឹងការការពារគុណភាពទឹក ស្តង់ដារគុណភាពទឹកនៃតំបន់ទឹកសាធារណៈ និងស្តង់ដារនៃការបញ្ចេញទឹកល្អ និងសំណល់រាវ
- អង្កេត តាមដាន និងវាយតម្លៃអំពីស្ថានភាពគុណភាពទឹកនៃតំបន់ទឹកសាធារណៈ
- ត្រួតពិនិត្យមធ្យោបាយគ្រប់គ្រង ឬ បរិក្ខារប្រព្រឹត្តកម្មទឹកល្អ សំណល់រាវ នៅតាមទីតាំង ឬ សកម្មភាពផលិតកម្ម អាជីវកម្ម ឬ សេវាកម្ម
- ពិនិត្យ និងផ្តល់យោបល់លើពាក្យស្នើសុំការអនុញ្ញាតបញ្ចេញទឹកល្អ និងសំណល់រាវ
- ផ្សព្វផ្សាយ និងណែនាំដល់ប្រតិបត្តិករនៃទីតាំង ឬ សកម្មភាពផលិតកម្ម អាជីវកម្ម ឬ សេវាកម្ម អំពីច្បាប់ លិខិតបទដ្ឋានគតិយុត្ត ស្តង់ដារ និងគោលការណ៍ណែនាំបច្ចេកទេស ដែលពាក់ព័ន្ធការការពារគុណភាពទឹកនិងការកាត់បន្ថយការសាយភាយសារធាតុបំពុល ចូលក្នុងតំបន់ទឹកសាធារណៈ./

- រៀបចំស្តង់ដារបច្ចេកទេសសម្រាប់សេវាកម្មប្រមូល និងដឹកជញ្ជូន ការកែច្នៃ ការកសាងឡដុត ឬ ការបង្កើតទីលានចាក់សំណល់រឹង
- ផ្តល់យោបល់ជូនក្រសួងលើសំណើសុំវិនិយោគលើសេវាកម្មប្រមូលនិងដឹកជញ្ជូន រោងចក្រកែច្នៃ បង្កើតឡដុត និងទីលានចាក់សំណល់រឹង
- ត្រួតពិនិត្យមធ្យោបាយ វិធីសាស្ត្រគ្រប់គ្រងសំណល់រឹង ឬ បរិក្ខារប្រព្រឹត្តកម្មសំណល់រឹង នៅតាមទីតាំងបង្កើត ទីតាំងស្តុក ឬ ប្រមូលទិញ ទីតាំងប្រតិបត្តិការសេវាកម្មប្រមូលនិងដឹកជញ្ជូន ទីតាំងកែច្នៃ និងទីលានចាក់សំណល់រឹង
- ពិនិត្យ និងផ្តល់យោបល់លើការស្នើសុំលិខិតអនុញ្ញាតប្រមូលទិញសំណល់កែច្នៃ នាំចេញ ឬ នាំចូលសំណល់កែច្នៃ
- ប្រមូល ចងក្រង និងគ្រប់គ្រងទិន្នន័យសំណល់រឹងទីប្រជុំជននៅតាមរាជធានីខេត្ត មានជាអាទិ៍ បរិមាណបង្កើតសរុប និងតាមប្រភេទ បរិមាណដែលបានប្រមូល បរិមាណដែលបានកែច្នៃ បរិមាណដែលបាននាំយកទៅចាក់នៅទីលាន
- សិក្សា ស្រាវជ្រាវ និងផ្សព្វផ្សាយជាសាធារណៈអំពីផលប៉ះពាល់ដល់បរិស្ថាន សុខភាព និងសង្គម ពាក់ព័ន្ធនឹងបញ្ហាប្រឈមនៃសំណល់រឹង
- រៀបចំរបាយការណ៍ជាតិស្តីពីស្ថានភាពនៃការគ្រប់គ្រងសំណល់រឹងទីប្រជុំជននៅតាមរាជធានី ខេត្ត
- បំពេញភារកិច្ចជាស្ថាប័នបង្គោលជាតិនៃ អនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធការគ្រប់គ្រងសំណល់រឹង នៅក្នុងក្របខ័ណ្ឌតំបន់ និងពិភពលោក
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាសនិងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីអគ្គនាយក។

**មាត្រា១៦ ..**

នាយកដ្ឋានគ្រប់គ្រងសារធាតុគ្រោះថ្នាក់មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការ និងថវិកា លើកស្ទួយកិច្ចសហការជាមួយអ្នកពាក់ព័ន្ធ កសាងសមត្ថភាពមន្ត្រីនាយកដ្ឋាន គ្រប់គ្រងហិរញ្ញវត្ថុ អង្កេតតាមដានការងារផ្ទៃក្នុង និងគ្រប់គ្រងការងាររដ្ឋបាលនានា ដែលពាក់ព័ន្ធនឹងតួនាទីនិងភារកិច្ចរបស់នាយកដ្ឋាន
- រៀបចំលិខិតបទដ្ឋានគតិយុត្តនិងគោលការណ៍ណែនាំនានាពាក់ព័ន្ធនឹងការត្រួតពិនិត្យលើដំណើរការគ្រប់គ្រង កែច្នៃ កម្ទេចចោល និងការបោះបង់ចោលសារធាតុគ្រោះថ្នាក់រួមទាំងការស្មី វិទ្យុសកម្ម និងអេឡិចត្រូម៉ាញ៉េទិក និងសំណល់គ្រោះថ្នាក់ និងការកំណត់អំពីប្រភេទ និងចំណាត់ថ្នាក់នៃសារធាតុគ្រោះថ្នាក់ និងសំណល់គ្រោះថ្នាក់
- រៀបចំគោលការណ៍ណែនាំបច្ចេកទេស សម្រាប់ការគ្រប់គ្រងប្រកបដោយសុវត្ថិភាពនូវសារធាតុគ្រោះថ្នាក់ ដើម្បីធានាសុខភាពសាធារណៈនិងបរិស្ថាន
- រៀបចំស្តង់ដារបច្ចេកទេសសម្រាប់ប្រតិបត្តិការសេវាកម្មប្រមូល និងដឹកជញ្ជូន ការកែច្នៃ ការធ្វើប្រព្រឹត្តកម្ម និងទីលានទុកដាក់សំណល់គ្រោះថ្នាក់

- ជំរុញការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និងកិច្ចសន្យាការពារបរិស្ថាន ដោយសម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- រៀបចំនិងអនុវត្តវិធានផ្ទៃសម្រាប់គ្រប់គ្រងការពិនិត្យលើដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម
- រៀបចំឯកសារស្តីពីគោលការណ៍ណែនាំ និងលក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃក្រុមហ៊ុន ដែលស្នើសុំចុះបញ្ជីជាក្រុមហ៊ុនទីប្រឹក្សាសម្រាប់ការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម
- ពិនិត្យ វាយតម្លៃ និងផ្តល់យោបល់លើការស្នើសុំចុះបញ្ជីជាក្រុមហ៊ុនទីប្រឹក្សាសម្រាប់ការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម
- ពិនិត្យនិងផ្តល់យោបល់លើរាល់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនៃគម្រោងវិនិយោគសាធារណៈ និងគម្រោងវិនិយោគឯកជន
- ធានានូវការទទួលបានព័ត៌មាន និងជំរុញឱ្យមានការចូលរួមជាប្រចាំរបស់សាធារណជន នៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម
- ពិនិត្យនិងវាយតម្លៃលើចំណាត់ថ្នាក់គម្រោង និងលក្ខខណ្ឌការងារគម្រោង ដើម្បីកំណត់អំពីតម្រូវការសម្រាប់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមពេញលេញ ឬ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដំបូង ឬ កិច្ចសន្យាការពារបរិស្ថាន កំណត់លក្ខខណ្ឌសម្រាប់ផែនការគ្រប់គ្រងបរិស្ថាន និងកិច្ចសន្យាការពារបរិស្ថានជាមួយម្ចាស់គម្រោងដែលរួមទាំងកម្រៃដែលត្រូវបង់ចូលមូលនិធិទាយជ្ជទានបរិស្ថាននិងមូលនិធិបរិស្ថាននិងសង្គម
- ជំរុញការអនុវត្តការបង់មូលនិធិទាយជ្ជទានបរិស្ថាន និងមូលនិធិបរិស្ថាននិងសង្គម
- សម្របសម្រួលជាមួយស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដើម្បីចុះអង្កេត តាមដាន និងពង្រឹងការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ដែលមានចែងក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមនិងកិច្ចសន្យាការពារបរិស្ថាន
- ពិនិត្យនិងវាយតម្លៃលើរបាយការណ៍អង្កេតតាមដានបរិស្ថាននៃគម្រោងសាធារណៈ និងគម្រោងវិនិយោគឯកជន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីអគ្គនាយក។

**មាត្រា១៨ .-**

នាយកដ្ឋានអធិការកិច្ចនិងពង្រឹងការអនុវត្តច្បាប់ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖
- រៀបចំសេចក្តីព្រាងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការ និងថវិកា លើកស្ទួយកិច្ចសហការជាមួយអ្នកពាក់ព័ន្ធ កសាងសមត្ថភាពមន្ត្រីនាយកដ្ឋាន គ្រប់គ្រងហិរញ្ញវត្ថុ អង្កេតតាមដានការងារផ្ទៃក្នុង និងគ្រប់គ្រងការងាររដ្ឋបាលនានា ដែលពាក់ព័ន្ធនឹងតួនាទីនិងភារកិច្ចរបស់នាយកដ្ឋាន

## ជំពូកទី៥
## អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ

**មាត្រា២០ ..**

អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិជាសេនាធិការឱ្យក្រសួងបរិស្ថានក្នុងការគ្រប់គ្រងនិងសម្របសម្រួលការងារអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប និងមាននិរន្តរភាពក្នុងតំបន់ការពារធម្មជាតិ ហើយមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយនិងផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនឹងការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព
- រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ
- អប់រំ បណ្ដុះបណ្ដាល និងផ្សព្វផ្សាយ អំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ
- ពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ
- គ្រប់គ្រងកិច្ចការរដ្ឋបាល ផែនការ ហិរញ្ញវត្ថុ គណនេយ្យ និងមន្ត្រីរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌របស់អគ្គនាយកដ្ឋាន
- ដឹកនាំការគ្រប់គ្រង និងការអភិរក្សជីវៈចម្រុះនៅក្នុងតំបន់ការពារធម្មជាតិ
- ធានាការគ្រប់គ្រង និងការប្រើប្រាស់ធនធានក្នុងតំបន់ការពារធម្មជាតិឱ្យមាននិរន្តរភាព
- ដឹកនាំការសិក្សា ស្រាវជ្រាវ និងការរៀបចំទិន្នន័យប្រភេទសត្វ និងរុក្ខជាតិដែលកម្រ ងាយរងគ្រោះ កំពុងរងគ្រោះ និងជិតផុតពូជនៅក្នុងតំបន់ការពារធម្មជាតិ
- ដឹកនាំការអនុវត្តសកម្មភាពថែរក្សាប្រពៃណី ទំនៀមទម្លាប់ និងរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍ជនជាតិដើមភាគតិច ដែលរស់នៅក្នុងតំបន់ការពារធម្មជាតិ តាមរយៈការអភិវឌ្ឍសហគមន៍តំបន់ការពារធម្មជាតិ រួមទាំងសកម្មភាពទេសចរណ៍ធម្មជាតិ
- គ្រប់គ្រងតំបន់ដីសើមនិងធនធានទឹកសាប
- គ្រប់គ្រងធនធានសមុទ្រនិងតំបន់ឆ្នេរ
- គ្រប់គ្រងនិងអភិរក្សតំបន់បេតិកភណ្ឌនៅក្នុងតំបន់ការពារធម្មជាតិ
- ពិនិត្យ តាមដាន និងវាយតម្លៃសកម្មភាពសេដ្ឋកិច្ចនៅក្នុងតំបន់ការពារធម្មជាតិ
- បំពេញកិច្ចការជំនាញតាមកិច្ចព្រមព្រៀង អនុសញ្ញា និងពិធីសារអន្តរជាតិនានា ទាំងថ្នាក់តំបន់និងថ្នាក់ពិភពលោក ពាក់ព័ន្ធនឹងកិច្ចការពារ និងអភិរក្សធម្មជាតិ ដែលកម្ពុជាជាសមាជិក
- សិក្សា និងកំណត់តំបន់គ្រប់គ្រងនីមួយៗ សម្រាប់ការអភិរក្ស និងអភិវឌ្ឍន៍
- ធ្វើការស្ដារ ដាំដុះព្រៃឈើនៅតំបន់រេចរិល និងអភិរក្សព្រៃឈើនៅក្នុងតំបន់ការពារធម្មជាតិ ដើម្បីរួមចំណែកកាត់បន្ថយការរេចរឹល និងការបាត់បង់ព្រៃឈើ ព្រមទាំងកាត់បន្ថយការប្រែប្រួលអាកាសធាតុ

**មាត្រា២២.-**

នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិជីគោក មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការ និងថវិកា លើកស្ទួយកិច្ចសហការជាមួយអ្នកពាក់ព័ន្ធ កសាងសមត្ថភាពមន្ត្រីនាយកដ្ឋាន គ្រប់គ្រងហិរញ្ញវត្ថុ អង្កេតតាមដានការងារផ្ទៃក្នុង និងគ្រប់គ្រងការងាររដ្ឋបាលនានា ដែលពាក់ព័ន្ធនឹងតួនាទីនិងភារកិច្ចរបស់នាយកដ្ឋាន
- រៀបចំយុទ្ធសាស្ត្រ ផែនការគ្រប់គ្រង ផែនការសកម្មភាព និងគោលការណ៍ណែនាំបច្ចេកទេសសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិជីគោក
- រៀបចំការកំណត់ព្រំប្រទល់ ការកំណត់តំបន់គ្រប់គ្រង និងការធ្វើផែនទីសម្រាប់តំបន់ការពារធម្មជាតិជីគោក ដោយសហការជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា
- សិក្សា ស្រាវជ្រាវ និងរៀបចំទិន្នន័យប្រភេទសត្វ និងរុក្ខជាតិដែលកម្រ ងាយរងគ្រោះ កំពុងរងគ្រោះ និងជិតផុតពូជនៅក្នុងតំបន់ការពារធម្មជាតិជីគោក
- អនុវត្តការងារការពារ អភិរក្ស និងស្តារធនធានធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិជីគោកឱ្យមាននិរន្តរភាព
- អនុវត្តសកម្មភាពថែរក្សាប្រពៃណី ទំនៀមទម្លាប់ និងរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍ជនជាតិដើមភាគតិច ដែររស់នៅក្នុងតំបន់ការពារធម្មជាតិជីគោក
- កៀរគរជំនួយហិរញ្ញវត្ថុនិងបច្ចេកទេសពីដៃគូអភិវឌ្ឍន៍នានាសម្រាប់គាំទ្រដល់ការអភិរក្សតំបន់ការពារធម្មជាតិជីគោកប្រកបដោយនិរន្តភាព
- សម្របសម្រួលការអនុវត្តគម្រោងនានានៅក្នុងតំបន់ការពារធម្មជាតិជីគោក
- រៀបចំផែនការគ្រប់គ្រង និងចាត់វិធានការទប់ស្កាត់ភ្លើងឆេះព្រៃក្នុងតំបន់ការពារធម្មជាតិជីគោក
- តាមដាននិងត្រួតពិនិត្យការអនុវត្តលិខិតបទដ្ឋានគិតយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិជីគោក
- អប់រំផ្សព្វផ្សាយដល់សាធារណជន ដើម្បីជំរុញឱ្យមានការចូលរួមថែរក្សា និងការពារធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិជីគោក
- សម្របសម្រួល រៀបចំ និងអនុវត្តគោលការណ៍ណែនាំនានាសម្រាប់កិច្ចការអភិរក្សតំបន់ការពារធម្មជាតិជីគោក រួមទាំងការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប ពិសេសទេសចរណ៍ធម្មជាតិ
- ចាត់វិធានការស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិជីគោក និងកសាងសំណុំរឿងបញ្ជូនទៅតុលាការ ក្នុងនីតិសម្បទាជានគរបាលយុត្តិធម៌ស្របតាមនីតិវិធីច្បាប់
- រៀបចំសំណុំរឿង និងដោះស្រាយបទល្មើសធនធានធម្មជាតិនិងបរិស្ថានក្នុងតំបន់ការពារធម្មជាតិជីគោកតាមនីតិវិធីក្នុងនាមជានគរបាលយុត្តិធម៌ ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
- សម្របសម្រួលការអនុវត្តកិច្ចព្រមព្រៀង អនុសញ្ញា និងពិធីសារ ពាក់ព័ន្ធនឹងតំបន់ការពារធម្មជាតិជីគោក

- សម្របសម្រួលការអនុវត្តកិច្ចព្រមព្រៀង អនុសញ្ញា និងពិធីសារ ពាក់ព័ន្ធនឹងតំបន់ដីសើមទឹកសាប
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តការកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីអគ្គនាយក។

**មាត្រា២៤ ._**

នាយកដ្ឋានអភិរក្សសមុទ្រនិងតំបន់ឆ្នេរមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការ និងថវិកា លើកស្ទួយកិច្ចសហការជាមួយអ្នកពាក់ព័ន្ធ កសាងសមត្ថភាពមន្ត្រីនាយកដ្ឋាន គ្រប់គ្រងហិរញ្ញវត្ថុ អង្កេតតាមដានការងារផ្ទៃក្នុង និងគ្រប់គ្រងការងាររដ្ឋបាលនានា ដែលពាក់ព័ន្ធនឹងតួនាទីនិងភារកិច្ចរបស់នាយកដ្ឋាន
- រៀបចំយុទ្ធសាស្ត្រ ផែនការគ្រប់គ្រងផែនការសកម្មភាព និងគោលការណ៍ណែនាំបច្ចេកទេសសម្រាប់គ្រប់គ្រងធនធានសមុទ្រ និងតំបន់ឆ្នេរ
- សិក្សា ស្រាវជ្រាវ និងរៀបចំសំណើក្នុងការបង្កើតឧទ្យានសមុទ្រ
- រៀបចំការកំណត់ព្រំប្រទល់ ការកំណត់តំបន់គ្រប់គ្រង និងការធ្វើផែនទីសម្រាប់ធនធានសមុទ្រ និងតំបន់ឆ្នេរដោយសហការជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា
- សិក្សា ស្រាវជ្រាវ និងរៀបចំបង្កើតផែនទី និងទិន្នន័យស្តីពីការប្រើប្រាស់ធនធានសមុទ្រ និងតំបន់ឆ្នេរ
- ពិនិត្យតាមដាន និងរាយការណ៍អំពីស្ថានភាព និងសុខភាពសមុទ្រ និងតំបន់ឆ្នេរ
- អនុវត្តការងារការពារអភិរក្ស និងស្តារធនធានធម្មជាតិនៅក្នុងដែនសមុទ្រ និងតំបន់ឆ្នេរឱ្យមាននិរន្តរភាព
- កៀរគរជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសពីដៃគូអភិវឌ្ឍន៍នានាក្នុងការគាំទ្រដល់ការគ្រប់គ្រងធនធានសមុទ្រ និងតំបន់ឆ្នេរប្រកបដោយនិរន្តភាព
- សម្របសម្រួលការអនុវត្តគម្រោងវិនិយោគអភិវឌ្ឍន៍នានានៅក្នុងតំបន់សមុទ្រ និងតំបន់ឆ្នេរ
- តាមដាន និងត្រួតពិនិត្យការអនុវត្តលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសក្នុងការគ្រប់គ្រងធម្មជាតិនៅក្នុងដែនសមុទ្រ និងតំបន់ឆ្នេរ
- អប់រំផ្សព្វផ្សាយដល់សាធារណជន ដើម្បីជំរុញឱ្យមានការចូលរួមថែរក្សា និងការពារធនធានធម្មជាតិក្នុងដែនសមុទ្រ និងតំបន់ឆ្នេរ
- សម្របសម្រួលរៀបចំ និងអនុវត្តគោលការណ៍ណែនាំនានាសម្រាប់ការការពារ និងអភិរក្សធម្មជាតិនៅក្នុងដែនសមុទ្រ និងតំបន់ឆ្នេរ រួមទាំងការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប និងមាននិរន្តរភាព
- ចាត់វិធានការដើម្បីស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិក្នុងដែនសមុទ្រ និងតំបន់ឆ្នេរ និងកសាងសំណុំរឿងបញ្ជូនទៅតុលាការ ក្នុងនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ស្របតាមនីតិវិធីច្បាប់
- រៀបចំសំណុំរឿង និងដោះស្រាយបទល្មើសធនធានធម្មជាតិ និងបរិស្ថានក្នុងដែនសមុទ្រ និងតំបន់ឆ្នេរតាមនីតិវិធី ក្នុងនីតិសម្បទាជានគរបាលយុត្តិធម៌ ស្របតាមនីតិវិធីច្បាប់

- ចាត់វិធានការដើម្បីស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានវប្បធម៌ និងធម្មជាតិក្នុងតំបន់បេតិកភណ្ឌ និងកសាងសំណុំរឿងបញ្ជូនទៅតុលាការ ក្នុងនីតិសម្បទាជានគរបាលយុត្តិធម៌ ស្របតាមនីតិវិធីច្បាប់
- រៀបចំសំណុំរឿងនិងដោះស្រាយបទល្មើសធនធានធម្មជាតិ និងវប្បធម៌ក្នុងតំបន់បេតិកភណ្ឌ ក្នុងនីតិសម្បទាជានគរបាលយុត្តិធម៌ ស្របតាមនីតិវិធីច្បាប់
- សម្របសម្រួលការអនុវត្តកិច្ចព្រមព្រៀង អនុសញ្ញា និងពិធីសារ ពាក់ព័ន្ធនឹងតំបន់បេតិកភណ្ឌ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តការកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីអគ្គនាយក។

**មាត្រា២៦ .-**

នាយកដ្ឋានសហគមន៍តំបន់ការពារធម្មជាតិមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការ និងថវិកា លើកស្ទួយកិច្ចសហការជាមួយអ្នកពាក់ព័ន្ធ កសាងសមត្ថភាពមន្ត្រីនាយកដ្ឋាន គ្រប់គ្រងហិរញ្ញវត្ថុ អង្កេតតាមដានការងារផ្ទៃក្នុង និងគ្រប់គ្រងការងាររដ្ឋបាលនានា ដែលពាក់ព័ន្ធនឹងតួនាទីនិងភារកិច្ចរបស់នាយកដ្ឋាន
- រៀបចំយុទ្ធសាស្ត្រ ផែនការគ្រប់គ្រងផែនការសកម្មភាព និងគោលការណ៍ណែនាំបច្ចេកទេសសម្រាប់គ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ស្របតាមគោលការណ៍ច្បាប់
- សិក្សាស្រាវជ្រាវ និងរៀបចំសំណើក្នុងការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ
- រៀបចំការកំណត់ព្រំប្រទល់ ការកំណត់តំបន់គ្រប់គ្រង និងការធ្វើផែនទីសម្រាប់សហគមន៍តំបន់ការពារធម្មជាតិ ដោយសហការជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា
- សម្របសម្រួលការរៀបចំលក្ខន្តិកៈ កិច្ចព្រមព្រៀង ផែនការគ្រប់គ្រង និងកម្មវិធីអភិវឌ្ឍន៍សហគមន៍តំបន់ការពារធម្មជាតិ
- សិក្សា ស្រាវជ្រាវ និងរៀបចំបង្កើតផែនទី និងទិន្នន័យសហគមន៍តំបន់ការពារធម្មជាតិ
- រៀបចំកម្មវិធីបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងធនធានធម្មជាតិក្នុងសហគមន៍តំបន់ការពារធម្មជាតិដល់មន្ត្រីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងប្រជាសហគមន៍នៅមូលដ្ឋាន
- ពិនិត្យតាមដានវាយតម្លៃ និងរាយការណ៍អំពីស្ថានភាពសហគមន៍តំបន់ការពារធម្មជាតិ
- ការពារ អភិរក្ស និងស្តារធនធានធម្មជាតិក្នុងសហគមន៍តំបន់ការពារធម្មជាតិឱ្យមាននិរន្តរភាព ដោយសហការជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា
- អនុវត្តសកម្មភាពលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍តំបន់ការពារធម្មជាតិ រួមទាំងការថែរក្សាប្រពៃណី និងទំនៀមទម្លាប់របស់សហគមន៍ជនជាតិដើមភាគតិច
- កៀរគរជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសពីដៃគូអភិវឌ្ឍន៍នានាសម្រាប់គាំទ្រដល់ការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិប្រកបដោយប្រសិទ្ធភាព
- ចូលរួមសម្របសម្រួលការអនុវត្តគម្រោងនានានៅក្នុងតំបន់ការពារធម្មជាតិ

- ផ្តល់កិច្ចអន្តរាគមន៍នានាក្នុងការសម្របសម្រួលដោះស្រាយទំនាស់ និងភាពមិនប្រក្រតីផ្សេងៗ ដែលកើតមានទាក់ទងនឹងគម្រោងវិនិយោគអភិវឌ្ឍន៍ក្នុងតំបន់ការពារធម្មជាតិ
- ចាត់វិធានការទប់ស្កាត់ និងបង្ក្រាបបទល្មើសក្នុងតំបន់វិនិយោគអភិវឌ្ឍន៍ និងកសាងសំណុំរឿងបញ្ជូនទៅតុលាការ ក្នុងនីតិសម្បទាជានគរបាលយុត្តិធម៌ ស្របតាមនីតិវិធីច្បាប់
- ចូលរួមលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាសហគមន៍នៅក្នុងតំបន់ការពារធម្មជាតិ រួមទាំងការថែរក្សាប្រពៃណី និងទំនៀមទម្លាប់របស់សហគមន៍ជនជាតិដើមភាគតិច
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីអគ្គនាយក។

**មាត្រា២៨.-**

នាយកដ្ឋានអធិការកិច្ចនិងពង្រឹងការអនុវត្តច្បាប់មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖
- រៀបចំសេចក្តីព្រាងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការ និងថវិកា លើកស្ទួយកិច្ចសហការជាមួយអ្នកពាក់ព័ន្ធ កសាងសមត្ថភាពមន្ត្រីនាយកដ្ឋាន គ្រប់គ្រងហិរញ្ញវត្ថុ អង្កេតតាមដានការងារផ្ទៃក្នុង និងគ្រប់គ្រងការងាររដ្ឋបាលនានា ដែលពាក់ព័ន្ធនឹងតួនាទីនិងភារកិច្ចរបស់នាយកដ្ឋាន
- រៀបចំនីតិវិធីសម្រាប់ការធ្វើអធិការកិច្ចលើបទល្មើសធនធានធម្មជាតិ ឬ សកម្មភាពផលិតកម្ម អាជីវកម្ម និងសេវាកម្មនានា នៅក្នុងតំបន់ការពារធម្មជាតិ
- ផ្សព្វផ្សាយនិងណែនាំដល់អ្នកពាក់ព័ន្ធអំពីនីតិវិធីសម្រាប់ការធ្វើអធិការកិច្ចលើបទល្មើសធនធានធម្មជាតិ ឬ សកម្មភាពផលិតកម្ម អាជីវកម្ម និងសេវាកម្មនានា នៅក្នុងតំបន់ការពារធម្មជាតិ
- សហការជាមួយនាយកដ្ឋានចំណុះអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ មន្ទីរបរិស្ថាន និងអង្គភាពពាក់ព័ន្ធ ដើម្បីធ្វើអធិការកិច្ចលើទីតាំង ឬ សកម្មភាពផលិតកម្ម អាជីវកម្ម និងសេវាកម្មនានា ឬ លើសកម្មភាពបទល្មើសធនធានធម្មជាតិ តាមផែនការ ឬ តាមការចាំបាច់
- ស្នើសុំគោលការណ៍សម្រាប់ចាត់វិធានការរដ្ឋបាល វិធានការពិន័យអន្តរការណ៍ ឬ បន្តនីតិវិធីបណ្តឹងទៅតុលាការចំពោះករណីបទល្មើសធនធានធម្មជាតិ ដែលបានរកឃើញក្នុងពេលធ្វើអធិការកិច្ច
- បំពេញភារកិច្ចជាអង្គភាពដើមបណ្តឹងក្នុងនាមក្រសួង សម្រាប់ករណីបណ្តឹងបទល្មើសធនធានធម្មជាតិទៅតុលាការ
- សម្របសម្រួលជាមួយភ្នាក់ងារច្បាប់ និងតុលាការ ជាអាទិ៍ ព្រះរាជអាជ្ញា និងមេធាវី តាមការចាំបាច់ និងស្របតាមករណីនីមួយៗ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីអគ្គនាយក។

អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ មាននាយកដ្ឋានចំណុះដូចខាងក្រោម៖

- នាយកដ្ឋានរដ្ឋបាល
- នាយកដ្ឋានធនធានមនុស្ស
- នាយកដ្ឋានផែនការនិងថវិកា
- នាយកដ្ឋានគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- នាយកដ្ឋានហិរញ្ញវត្ថុនិងគណនេយ្យ។

នាយកដ្ឋាននីមួយៗដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា៣០ ._**

នាយកដ្ឋានរដ្ឋបាល មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងនិងសម្របសម្រួលកិច្ចការរដ្ឋបាលនៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាលជាមួយអង្គភាពក្រោមឱវាទនៅថ្នាក់ក្រោមជាតិ
- គ្រប់គ្រងនិងចរាចរឯកសាររដ្ឋបាលផ្សេងៗ
- រៀបចំពិនិត្យនិងកែសម្រួលលិខិតរដ្ឋបាលទូទៅ
- គ្រប់គ្រងការងារនីតិកម្ម
- សម្របសម្រួលការរៀបចំសេចក្តីព្រាងនិងចងក្រងរក្សាទុកលិខិតបទដ្ឋានគតិយុត្តនានាជាអាទិ៍ សេចក្តីសម្រេច ប្រកាស ប្រកាសអន្តរក្រសួង អនុក្រឹត្យ ព្រះរាជក្រឹត្យ ច្បាប់ និងកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងបរិស្ថាន
- សម្របសម្រួលនិងសហការជាមួយអង្គភាពពាក់ព័ន្ធក្នុងការរៀបចំផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានាដែលកំពុងមានជាធរមាន
- គ្រប់គ្រងការងារពិធីការរបស់ក្រសួង
- ដើរតួជាច្រកចេញចូលតែមួយសម្រាប់សេវាសាធារណៈ
- ធ្វើកំណត់ហេតុនិងរបាយការណ៍ប្រជុំរបស់ក្រសួង
- គ្រប់គ្រងបណ្ណាសារដ្ឋានរបស់ក្រសួង
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់នាយកដ្ឋាននិងរបស់អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីអគ្គនាយក។

**មាត្រា៣១ ._**

នាយកដ្ឋានធនធានមនុស្ស មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងមន្ត្រីរាជការនិងបុគ្គលិកទាំងក្នុងក្របខ័ណ្ឌនិងក្រៅក្របខ័ណ្ឌ
- រៀបចំនិងគ្រប់គ្រងព័ត៌មាន ទិន្នន័យ និងស្ថិតិពាក់ព័ន្ធនឹងមន្ត្រីរាជការនិងបុគ្គលិកទាំងក្នុងក្របខ័ណ្ឌនិងក្រៅក្របខ័ណ្ឌ ដោយធ្វើបច្ចុប្បន្នភាពជាប្រចាំ

- សម្របសម្រួលការរៀបចំធាតុចូលសម្រាប់ដំណើរការកសាងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការថ្នាក់ជាតិ
- សម្របសម្រួលការអនុវត្តគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល
- សម្របសម្រួលភាពជាដៃគូ ការកៀរគរធនធានពីដៃគូអភិវឌ្ឍន៍ និងការអនុវត្តថវិកាហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- សម្របសម្រួលការរៀបចំក្របខ័ណ្ឌអង្កេតតាមដាន និងវាយតម្លៃ រួមទាំងការបង្កើតចំណុចដៅ និងសូចនាករ សម្រាប់វាស់សមិទ្ធផលនៃផែនការនានា
- ទទួលខុសត្រូវ និងសហការក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការពាក់ព័ន្ធនឹងវិស័យបរិស្ថាន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ របស់ក្រសួងបរិស្ថានជូនរាជរដ្ឋាភិបាល
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីអគ្គនាយក។

**មាត្រា៣៣ ..**

នាយកដ្ឋានគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖
- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- លើកសំណើនិងសម្របសម្រួលការងារលទ្ធកម្មសាធារណៈរបស់របស់ក្រសួង
- រៀបចំនិងគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដែលក្រសួងកាន់កាប់ តាមឆ្នាំគោល និងឆ្នាំនីមួយៗ ព្រមទាំងការជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋ
- គ្រប់គ្រងនិងបែងចែកការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ ឧបករណ៍ បរិក្ខារ សម្ភារៈ និងភស្តុភាទាំងអស់របស់ក្រសួង
- សម្របសម្រួលការរៀបចំធ្វើផែនការតម្រូវការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ ឧបករណ៍ បរិក្ខារ សម្ភារៈ និងភស្តុភាប្រចាំឆ្នាំដោយសហការជាមួយអង្គភាពក្រោមឱវាទក្រសួង
- គ្រប់គ្រងសារពើភណ្ឌ និងការប្រើប្រាស់ ថែទាំ និងជួសជុលយានយន្ត ព្រមទាំងយានដ្ឋានរបស់ក្រសួង
- គ្រប់គ្រងការសាងសង់ ថែទាំ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធអគារ ឧបករណ៍ បរិក្ខារ សម្ភារៈ និងបណ្តាញផ្សេងៗ
- ទទួលបន្ទុកការងារសន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យក្នុងអគារនិងក្នុងបរិវេណរបស់ក្រសួង
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីអគ្គនាយក។

**មាត្រា៣៤ ..**

នាយកដ្ឋានហិរញ្ញវត្ថុនិងគណនេយ្យ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖
- ផ្សព្វផ្សាយនិងជំរុញការអនុវត្តច្បាប់ គោលនយោបាយ និងសារាចរណែនាំរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុនិងថវិការដ្ឋ ជាពិសេសកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ

## ជំពូកទី៨
## នាយកដ្ឋានសវនកម្មផ្ទៃក្នុង

**មាត្រា៣៦ ._**

នាយកដ្ឋានសវនកម្មផ្ទៃក្នុងទទួលបន្ទុកអនុវត្តភារកិច្ចតាមអនុក្រឹត្យលេខ៤០អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុងនៅក្នុងក្រសួងស្ថាប័ន និងសហគ្រាសសាធារណៈ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួន តាមការចាំបាច់។

## ជំពូកទី៩
## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា៣៧ ._**

ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងបរិស្ថានទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលបានកំណត់ក្នុងអនុក្រឹត្យលេខ២០អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន។

## ជំពូកទី១០
## អង្គភាពមូលដ្ឋាន

**មាត្រា៣៨ ._**

នៅតាមរាជធានី ខេត្តនីមួយៗមានមន្ទីរបរិស្ថានរាជធានី ខេត្ត ចំនួនមួយ ដែលទទួលបន្ទុកអនុវត្ត និងសម្របសម្រួលសកម្មភាពនានារបស់ក្រសួង។

នៅតាមក្រុង ស្រុក ខណ្ឌនីមួយៗមានការិយាល័យបរិស្ថានក្រុង ស្រុក ខណ្ឌ ចំនួនមួយ ដែលទទួលបន្ទុកអនុវត្ត និងសម្របសម្រួលសកម្មភាពនានារបស់ក្រសួង ក្រោមការគ្រប់គ្រងរបស់មន្ទីរ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃមន្ទីរបរិស្ថានរាជធានី ខេត្ត និងការិយាល័យបរិស្ថានក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

## ជំពូកទី១១
## គ្រឹះស្ថានសាធារណៈក្រោមអាណាព្យាបាល

**មាត្រា៣៩ ._**

គ្រឹះស្ថានសាធារណៈនានាដែលស្ថិតក្រោមអាណាព្យាបាលរបស់ក្រសួងបរិស្ថានត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

វក្សធម្មជាតិបំពេញបន្ថែមលើអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ ២០០៨។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល៖**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា៤៤
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ២០១៥**

**អង្គការលេខរបស់ក្រសួងបរិស្ថាន**



# ឧបសម្ព័ន្ធទី៤

# អនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៣៤ អនក្រ.បក

ក្រសួងបរិស្ថាន
ចូល
លេខ 7154
ថ្ងៃទី ២២ ខែ ១១ ឆ្នាំ២០២១
ម៉ោង 5:00

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាននិងបណ្តាអង្គភាពក្រោមឱវាទក្រសួង។

## ជំពូកទី២

## បេសកកម្ម មុខងារ ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា២ .-**

ក្រសួងបរិស្ថានត្រូវបានរាជរដ្ឋាភិបាលប្រគល់បេសកកម្មឱ្យដឹកនាំនិងគ្រប់គ្រងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព និងការរស់នៅប្រកបដោយចីរភាព សម្រាប់ជាឧត្តមប្រយោជន៍យូរអង្វែងរបស់ប្រជាជនគ្រប់រូបនិងគ្រប់ជំនាន់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ .-**

ក្រសួងបរិស្ថានជាសេនាធិការរបស់រាជរដ្ឋាភិបាលមានមុខងារនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំទស្សនវិស័យ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រ ព្រមទាំងកំណត់អាទិភាពអភិវឌ្ឍន៍ប្រកបដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- តាក់តែងនិងអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព និងការរស់នៅប្រកបដោយចីរភាព
- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និងកម្មវិធីនានាពាក់ព័ន្ធនឹងវិស័យបរិស្ថាន
- ផ្តល់យោបល់ដល់ក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីធានាការអភិរក្ស ការអភិវឌ្ឍ និងការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព
- គ្រប់គ្រងទិន្នន័យបរិស្ថាននិងដឹកនាំសម្របសម្រួលការងារអប់រំនិងការផ្សព្វផ្សាយបរិស្ថាន ព្រមទាំងចាត់ចែងព្រឹត្តិការណ៍សំខាន់ៗទាក់ទងនឹងវិស័យបរិស្ថាន
- លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព និងការរស់នៅប្រកបដោយចីរភាព តាមរយៈការផ្សព្វផ្សាយព័ត៌មាននិងសកម្មភាពបង្កើនការយល់ដឹងនានា
- លើកទឹកចិត្តឱ្យមានការចូលរួមជាសាធារណៈក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព និងការរស់នៅប្រកបដោយចីរភាព តាមរយៈការពិគ្រោះយោបល់ជាសាធារណៈនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចនានា
- ផលិតនិងផ្សព្វផ្សាយព័ត៌មានស្តីពីសកម្មភាពទាក់ទងនឹងកិច្ចគាំពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិជូនសាធារណជន

- គ្រប់គ្រងនិងសម្របសម្រួលកិច្ចគាំពារបរិស្ថាន រួមមានការគ្រប់គ្រងគុណភាពទឹក ខ្យល់ និងដី ការគ្រប់គ្រងសំឡេងនិងរំញ័រ និងការគ្រប់គ្រងការបំភាយកាំរស្មីវិទ្យុសកម្មនិងអេឡិចត្រូម៉ាញ៉េទិក
- រៀបចំនិងអនុវត្តលិខិតបទដ្ឋានគតិយុត្តនិងនីតិវិធីនានាសម្រាប់ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងការពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់គម្រោងវិនិយោគសាធារណៈនិងគម្រោងវិនិយោគឯកជន
- គ្រប់គ្រងនិងសម្របសម្រួលការងារការពារនិងអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព
- ប្រមូលវិភាគនិងគ្រប់គ្រងទិន្នន័យបរិស្ថាននិងធនធានធម្មជាតិ
- ជំរុញនិងលើកទឹកចិត្តឱ្យមានការវិនិយោគក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព និងការរស់នៅប្រកបដោយចីរភាព
- កៀរគរនិងគ្រប់គ្រងធនធានសម្រាប់កិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព និងការរស់នៅប្រកបដោយចីរភាព
- សហការជាមួយបណ្តាប្រទេសនៅក្នុងតំបន់និងពិភពលោក អង្គការជាតិ អង្គការអន្តរជាតិ និងសហគមន៍មូលដ្ឋាន ដើម្បីធានាឱ្យមានកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព និងការរស់នៅប្រកបដោយចីរភាព
- លើកសំណើជូនរាជរដ្ឋាភិបាលអំពីការចូលរួមក្នុងកិច្ចព្រមព្រៀង អនុសញ្ញា និងពិធីសារអន្តរជាតិនានា ដែលទាក់ទងនឹងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះនិងការអភិវឌ្ឍប្រកបដោយចីរភាព ព្រមទាំងអនុវត្តកិច្ចការជំនាញពាក់ព័ន្ធសម្រាប់ជាមូលដ្ឋានជូនរាជរដ្ឋាភិបាលក្នុងការបំពេញកាតព្វកិច្ចនិងការទទួលខុសត្រូវនៅក្រោមកិច្ចព្រមព្រៀងអនុសញ្ញានិងពិធីសារទាំងនេះ
- រៀបចំរបាយការណ៍ស្តីពីស្ថានភាពបរិស្ថាននៅព្រះរាជាណាចក្រកម្ពុជាឱ្យបានទៀងទាត់
- ទទួលអនុវត្តការកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ឱ្យ។

**មាត្រា៤ .-**

ក្រសួងបរិស្ថានមានរចនាសម្ព័ន្ធដូចខាងក្រោម៖

**ក. អង្គភាពថ្នាក់ជាតិ**

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានគោលនយោបាយនិងយុទ្ធសាស្ត្រ
- អគ្គនាយកដ្ឋានគាំពារបរិស្ថាន
- អគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិ
- អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន
- អគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន
- អគ្គាធិការដ្ឋាន
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង
- នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

ខ. អង្គភាពថ្នាក់ក្រោមជាតិ

- មន្ទីរបរិស្ថានរាជធានី ខេត្ត។

គ. គ្រឹះស្ថានសាធារណៈរដ្ឋបាលនិងសហគ្រាសសាធារណៈ

- គ្រឹះស្ថានសាធារណៈរដ្ឋបាលនិងសហគ្រាសសាធារណៈស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងបរិស្ថាន។

**មាត្រា៥ .-**

អគ្គនាយកដ្ឋានដឹកនាំដោយអគ្គនាយកមួយរូបនិងអមដោយអគ្គនាយករងមួយចំនួនជាជំនួយការតាមការចាំបាច់ អនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

អគ្គាធិការដ្ឋានដឹកនាំដោយអគ្គាធិការមួយរូបនិងអមដោយអគ្គាធិការរងមួយចំនួនជាជំនួយការតាមការចាំបាច់ អនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

នាយកដ្ឋាននិងអង្គភាពថ្នាក់ស្មើនាយកដ្ឋានដឹកនាំដោយប្រធានមួយរូបនិងអមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ អនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

មន្ទីរបរិស្ថានរាជធានី ខេត្ត ដឹកនាំដោយប្រធានមួយរូបនិងអមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ អនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

អង្គការលេខរបស់ក្រសួងបរិស្ថានជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៦ .-**

ការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យនីមួយៗនិងអង្គភាពនានាក្រោមឱវាទនាយកដ្ឋាន និងអង្គភាពថ្នាក់ក្រោមជាតិនៃក្រសួងបរិស្ថានត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

## ជំពូកទី៣
## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា៧ .-**

ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងបរិស្ថានទទួលបន្ទុកបេសកកម្មទាំងឡាយដែលបានកំណត់ក្នុងអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន។

## ជំពូកទី៤
## អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ

**មាត្រា៨ .-**

អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុជាសេនាធិការឱ្យក្រសួងបរិស្ថានក្នុងការដឹកនាំ គ្រប់គ្រង និងសម្របសម្រួលកិច្ចការរដ្ឋបាលទូទៅ បុគ្គលិក ហិរញ្ញវត្ថុ សហប្រតិបត្តិការ ទ្រព្យសម្បត្តិរដ្ឋ និងការកសាងផែនការថវិកា ហើយមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងនិងសម្របសម្រួលរាល់សកម្មភាពរដ្ឋបាលរបស់ក្រសួងនៅថ្នាក់ជាតិនិងរវាងអង្គភាពថ្នាក់ជាតិនិងអង្គភាពថ្នាក់ក្រោមជាតិ
- ទទួលខុសត្រូវនិងសម្របសម្រួលកិច្ចការរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុទូទៅ

- រៀបចំ គ្រប់គ្រងរាល់ការងារទាក់ទងនឹងមន្ត្រីរាជការនិងអភិវឌ្ឍធនធានមនុស្សរបស់ក្រសួង
- គ្រប់គ្រងហិរញ្ញវត្ថុនិងគណនេយ្យ
- សម្របសម្រួលការងារហិរញ្ញវត្ថុនៃអគ្គនាយកដ្ឋាននិងអង្គភាពក្រោមឱវាទទាំងអស់របស់ក្រសួង
- សហការសម្របសម្រួលនិងគ្រប់គ្រងការងារទាក់ទងកិច្ចសហប្រតិបត្តិការក្នុងប្រទេសនិងអន្តរជាតិរបស់ក្រសួង
- គ្រប់គ្រងនិងសម្របសម្រួលការងារលទ្ធកម្មសាធារណៈ
- គ្រប់គ្រងសម្ភារៈ បរិក្ខារ និងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង
- សម្របសម្រួលការរៀបចំសេចក្តីព្រាងនិងចងក្រងរក្សាទុកលិខិតបទដ្ឋានគតិយុត្តនានា ជាអាទិ៍ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ប្រកាសអន្តរក្រសួង សេចក្តីសម្រេច និងកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងបរិស្ថាន
- រៀបចំលិខិតរដ្ឋបាលនិងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ
- ផ្តល់យោបល់ផ្នែកច្បាប់លើអត្ថបទកិច្ចសន្យា កិច្ចព្រមព្រៀង ករណីរឿងក្តី និងករណីវិវាទដែលពាក់ព័ន្ធនឹងក្រសួង
- ទទួលខុសត្រូវនិងសម្របសម្រួលការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងផែនការថវិការបស់ក្រសួងរយៈពេលខ្លី មធ្យម និងវែង ស្របតាមគោលនយោបាយនិងផែនការរបស់រាជរដ្ឋាភិបាល
- សម្របសម្រួលការអនុវត្តគោលនយោបាយកំណែទម្រង់របស់រាជរដ្ឋាភិបាល ជាអាទិ៍ការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- សម្របសម្រួលជាមួយអគ្គនាយកដ្ឋាននិងអង្គភាពដទៃទៀតក្រោមឱវាទក្រសួងជាប្រចាំ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងាររបស់ក្រសួង
- គ្រប់គ្រងបណ្ណសាររបស់ក្រសួង
- គ្រប់គ្រងនិងចាត់ចែងកិច្ចគាំពារសង្គមសម្រាប់មន្ត្រីរាជការនិងបុគ្គលិកទាំងក្នុងក្របខ័ណ្ឌនិងក្រៅក្របខ័ណ្ឌរបស់ក្រសួង
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរដ្ឋមន្ត្រីប្រគល់ឱ្យ។

**មាត្រា៩ .-**

អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុមាននាយកដ្ឋានចំណុះដូចខាងក្រោម៖

- នាយកដ្ឋានរដ្ឋបាល
- នាយកដ្ឋានធនធានមនុស្ស
- នាយកដ្ឋានផែនការ ថវិកា និងសហប្រតិបត្តិការ
- នាយកដ្ឋានគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- នាយកដ្ឋានហិរញ្ញវត្ថុនិងគណនេយ្យ។

**មាត្រា១០ .-**

នាយកដ្ឋានរដ្ឋបាលមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងនិងសម្របសម្រួលកិច្ចការរដ្ឋបាលនៅថ្នាក់ជាតិ និងរវាងអង្គភាពថ្នាក់ជាតិជាមួយអង្គភាពថ្នាក់ក្រោមជាតិ

- គ្រប់គ្រងនិងចរាចរឯកសាររដ្ឋបាលផ្សេងៗ
- រៀបចំពិនិត្យនិងកែសម្រួលលិខិតរដ្ឋបាលទូទៅ
- គ្រប់គ្រងការងារនីតិកម្ម
- សម្របសម្រួលការរៀបចំសេចក្តីព្រាងនិងចងក្រងរក្សាទុកលិខិតបទដ្ឋានគតិយុត្តនានា ជាអាទិ៍ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ប្រកាសអន្តរក្រសួង សេចក្តីសម្រេច និងកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងបរិស្ថាន
- សម្របសម្រួលនិងសហការជាមួយអង្គភាពពាក់ព័ន្ធក្នុងការរៀបចំផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានាដែលកំពុងមានជាធរមាន
- គ្រប់គ្រងការងារពិធីការរបស់ក្រសួង
- គ្រប់គ្រងបណ្ណសាររបស់ក្រសួង
- ធ្វើកំណត់ហេតុនិងរបាយការណ៍ប្រជុំរបស់ក្រសួង
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

**មាត្រា១១ .-**

នាយកដ្ឋានធនធានមនុស្សមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងមន្ត្រីរាជការនិងបុគ្គលិកទាំងក្នុងក្របខ័ណ្ឌនិងក្រៅក្របខ័ណ្ឌ
- រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការនិងបុគ្គលិកទាំងក្នុងក្របខ័ណ្ឌនិងក្រៅក្របខ័ណ្ឌ រួមមានការជ្រើសរើស ការបញ្ឈប់ពីការងារ ការដាក់ឱ្យនៅទំនេរដោយគ្មានបៀវត្ស ការចូលនិវត្តន៍ ការដំឡើងឋានន្តរសក្តិ ការដំឡើងថ្នាក់ ការរៀបចំបៀវត្ស ការផ្តល់រង្វាន់ ការផ្តល់គ្រឿងឥស្សរិយយស ការដាក់វិន័យ ការផ្ទេរភារកិច្ច និងកិច្ចការដទៃទៀត
- សម្របសម្រួលការអនុវត្តគោលនយោបាយកំណែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល
- រៀបចំនិងគ្រប់គ្រងព័ត៌មាន ទិន្នន័យ និងស្ថិតិពាក់ព័ន្ធនឹងមន្ត្រីរាជការនិងបុគ្គលិកទាំងក្នុងក្របខ័ណ្ឌនិងក្រៅក្របខ័ណ្ឌ ដោយធ្វើបច្ចុប្បន្នភាពជាប្រចាំ
- សម្របសម្រួលនិងរៀបចំធ្វើបណ្ណសម្គាល់មន្ត្រីរាជការជូនបុគ្គលិកទាំងក្នុងក្របខ័ណ្ឌនិងក្រៅក្របខ័ណ្ឌ
- សម្របសម្រួលការរៀបចំផែនការគ្រប់គ្រងនិងបណ្តុះបណ្តាលមន្ត្រីរាជការនិងបុគ្គលិកទាំងក្នុងក្របខ័ណ្ឌនិងក្រៅក្របខ័ណ្ឌ ដោយធ្វើការវាយតម្លៃអំពីតម្រូវការសម្រាប់បណ្តុះបណ្តាលរយៈពេលខ្លីនិងវែងឱ្យបានទៀងទាត់និងហ្មត់ចត់
- សម្របសម្រួលនិងចាត់ចែងការបណ្តុះបណ្តាលទាំងនៅក្នុងនិងក្រៅប្រទេសសម្រាប់បុគ្គលិកទាំងក្នុងក្របខ័ណ្ឌនិងក្រៅក្របខ័ណ្ឌ ព្រមទាំងការធ្វើកម្មសិក្សានានា
- សម្របសម្រួលនិងសហការអនុវត្តនីតិវិធីនៃការជ្រើសរើស ការបញ្ឈប់ពីការងារ ការដាក់ឱ្យនៅទំនេរដោយគ្មានបៀវត្ស ការចូលនិវត្តន៍ ការដំឡើងឋានន្តរសក្តិ ការដំឡើងថ្នាក់ ការរៀបចំបៀវត្ស ការផ្តល់រង្វាន់ ការផ្តល់គ្រឿងឥស្សរិយយស ការដាក់វិន័យ ការផ្ទេរភារកិច្ចមន្ត្រីរាជការដែលកំពុងបំពេញការងារនៅថ្នាក់ក្រោមជាតិ
- រៀបចំ សម្របសម្រួលស្នើសុំគ្រឿងឥស្សរិយយសនិងកម្មវិធីប្រឡងប្រណាំងលើកទឹកចិត្តដទៃទៀត

- សម្របសម្រួលនិងចាត់ចែងកិច្ចគាំពារសង្គមសម្រាប់មន្ត្រីរាជការនិងបុគ្គលិកទាំងក្នុងក្របខ័ណ្ឌនិងក្រៅក្របខ័ណ្ឌរបស់អគ្គនាយកដ្ឋានរបស់ខ្លួននិងក្រសួង
- ត្រួតពិនិត្យនិងវាយតម្លៃគុណផលមន្ត្រីរាជការនិងបុគ្គលិកទាំងក្នុងក្របខ័ណ្ឌនិងក្រៅក្របខ័ណ្ឌ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តការកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

**មាត្រា១២ ..**

នាយកដ្ឋានផែនការ ថវិកា និងសហប្រតិបត្តិការមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ដឹកនាំសម្របសម្រួលជាមួយបណ្ដាអង្គភាពក្រោមឱវាទក្រសួង ក្នុងការរៀបចំគម្រោងផែនការយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិល និងផែនការថវិកាប្រចាំឆ្នាំ
- ផ្សព្វផ្សាយឯកសារសម្រាប់ដំណើរការកសាងផែនការយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិលនិងផែនការថវិកាប្រចាំឆ្នាំដល់បណ្ដាអង្គភាពក្រោមឱវាទក្រសួង
- សម្របសម្រួលការងារសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិក្នុងវិស័យបរិស្ថាន
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោងផែនការថវិកា សម្រាប់ការិយបរិច្ឆេទនីមួយៗ នៅតាមបណ្ដាអង្គភាពក្រោមឱវាទក្រសួង
- សម្របសម្រួលជាមួយអង្គភាពជំនាញ ដើម្បីផ្ដល់យោបល់ជូនថ្នាក់ដឹកនាំពាក់ព័ន្ធនឹងការចូលជាភាគីនៃសន្ធិសញ្ញា អនុសញ្ញា ពិធីសារ កិច្ចព្រមព្រៀង និងអនុស្សរណៈនៃការយោគយល់គ្នា មុននឹងស្នើសុំការសម្រេចដើម្បីអង្គភាពជំនាញចាត់ចែងបន្ត
- ប្រមូល ចងក្រង និងរក្សាទុកនូវរាល់ឯកសារពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងនិងលិខិតូបករណ៍អន្តរជាតិពាក់ព័ន្ធវិស័យបរិស្ថាន
- ប្រមូល រក្សា និងធ្វើបច្ចុប្បន្នភាពបញ្ជីគម្រោងនិងកម្មវិធីនានាដែលបាននិងកំពុងអនុវត្តដោយអង្គភាពក្រោមឱវាទក្រសួង
- ប្រមូលនិងរៀបចំឯកសារពាក់ព័ន្ធនឹងគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និងផែនការថវិកាពីបណ្ដាអង្គភាពក្រោមឱវាទក្រសួង
- រៀបចំឯកសារពាក់ព័ន្ធនឹងស្ថានភាពនៃការអនុវត្តគម្រោងនិងកម្មវិធី ដើម្បីដាក់ជូនថ្នាក់ដឹកនាំទទួលបន្ទុក
- ជួយសម្របសម្រួលការកៀរគរជំនួយបច្ចេកទេសនិងហិរញ្ញវត្ថុពីស្ថាប័នជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍនានាលើកិច្ចការងារគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍប្រកបដោយចីរភាព
- តាមដានសុពលភាព ប្រសិទ្ធភាព និងការអនុវត្តសន្ធិសញ្ញា អនុសញ្ញា ពិធីសារ កិច្ចព្រមព្រៀង និងអនុស្សរណៈនៃការយោគយល់គ្នា និងការងារផ្សេងៗទៀតដែលស្ថិតក្រោមក្របខ័ណ្ឌសហប្រតិបត្តិការឬជំនួយទ្វេភាគីនិងពហុភាគី
- សម្របសម្រួលការអនុវត្តគោលនយោបាយនៃការកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំរបស់ក្រសួងបរិស្ថានជូនរាជរដ្ឋាភិបាល
- ទទួលអនុវត្តការកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

**មាត្រា១៣ ..**

នាយកដ្ឋានគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- លើកសំណើនិងសម្របសម្រួលការងារលទ្ធកម្មសាធារណៈរបស់ក្រសួង
- រៀបចំនិងគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋដែលក្រសួងកាន់កាប់តាមឆ្នាំគោលនិងឆ្នាំនីមួយៗ ព្រមទាំងការជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋ
- គ្រប់គ្រងនិងបែងចែកការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ ឧបករណ៍ បរិក្ខារ សម្ភារៈ និងភស្តុភារទាំងអស់របស់ក្រសួង
- សម្របសម្រួលការរៀបចំធ្វើផែនការតម្រូវការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ ឧបករណ៍ បរិក្ខារ សម្ភារៈ និងភស្តុភារប្រចាំឆ្នាំដោយសហការជាមួយអង្គភាពក្រោមឱវាទក្រសួង
- គ្រប់គ្រងសារពើភណ្ឌនិងការប្រើប្រាស់ថែទាំនិងជួសជុលយានយន្ត ព្រមទាំងយានដ្ឋានរបស់ក្រសួង
- គ្រប់គ្រងការសាងសង់ ថែទាំ និងជួលជុលហេដ្ឋារចនាសម្ព័ន្ធអគារ ឧបករណ៍ បរិក្ខារ សម្ភារៈ និងបណ្តាញផ្សេងៗ
- ទទួលបន្ទុកការងារសន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យក្នុងអគារនិងក្នុងបរិវេណរបស់ក្រសួង
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តការកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

**មាត្រា១៤ ..**

នាយកដ្ឋានហិរញ្ញវត្ថុនិងគណនេយ្យមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុនិងគណនេយ្យរបស់ក្រសួង
- ផ្សព្វផ្សាយនិងជំរុញការអនុវត្តគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុនិងថវិការដ្ឋ
- សម្របសម្រួលការអនុវត្តគោលនយោបាយនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល
- ទទួលខុសត្រូវនិងសហការជាមួយអង្គភាពពាក់ព័ន្ធនៅក្នុងដំណើរការរៀបចំគ្រោងឥណទានប្រចាំឆ្នាំ
- គ្រប់គ្រងចំណូល ចំណាយ និងគ្រប់គ្រងច្រកចេញចូលតែមួយសម្រាប់ចំណូលសេវាសាធារណៈ
- គ្រប់គ្រងរដ្ឋទេយ្យបុរេប្រទាននិងចំណាយបេសកកម្មក្នុងនិងក្រៅប្រទេស
- ពិនិត្យនិងតាមដានតារាងសមតុល្យរបស់ក្រសួង ដើម្បីធានាស្ថិរភាពនៃប្រតិបត្តិការហិរញ្ញវត្ថុ
- រៀបចំបើកផ្តល់ប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ លាភការ និងប្រាក់រង្វាន់ផ្សេងៗដល់មន្ត្រីរាជការនិងបុគ្គលិកទាំងក្នុងក្របខ័ណ្ឌនិងក្រៅក្របខ័ណ្ឌ
- គ្រប់គ្រងគណនីទាំងអស់របស់ក្រសួង
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តការកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

## ជំពូកទី៥

## អគ្គនាយកដ្ឋានគោលនយោបាយនិងយុទ្ធសាស្ត្រ

**មាត្រា១៥ ..**

អគ្គនាយកដ្ឋានគោលនយោបាយនិងយុទ្ធសាស្ត្របំពេញមុខងារជាសេនាធិការឱ្យក្រសួងបរិស្ថាន ក្នុងការរៀបចំនិងតាមដានការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងការអភិវឌ្ឍប្រកបដោយចីរភាព ហើយមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលនិងរៀបចំទស្សនវិស័យ ចក្ខុវិស័យ គោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់វិស័យបរិស្ថាននិងការអភិវឌ្ឍប្រកបដោយចីរភាព
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសម្រាប់ វិស័យបរិស្ថាននិងការអភិវឌ្ឍប្រកបដោយចីរភាព
- រៀបចំនិងផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្ត សេចក្តីណែនាំស្តីពីនីតិវិធីនានាសម្រាប់ការរៀបចំ គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការរយៈពេលខ្លី មធ្យម និងវែងពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងការអភិវឌ្ឍប្រកបដោយចីរភាព
- ដឹកនាំ សម្របសម្រួល និងអនុវត្តការងារក្នុងនាមជាអង្គភាពបង្គោលនៃកិច្ចព្រមព្រៀង សន្ធិសញ្ញា អនុសញ្ញា ពិធីសារអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងការអភិរក្សជីវៈចម្រុះ
- ពង្រឹងនិងលើកកម្ពស់កិច្ចសហប្រតិបត្តិការពាក់ព័ន្ធនឹងការរៀបចំនិងតាមដានការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងការអភិវឌ្ឍប្រកបដោយចីរភាព ជាមួយដៃគូអភិវឌ្ឍ សង្គមស៊ីវិល វិស័យឯកជន គ្រឹះស្ថានស្រាវជ្រាវ និងភាគីពាក់ព័ន្ធទាំងថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ
- កៀរគរធនធាននិងជំនួយបច្ចេកទេសសម្រាប់ការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធី និងគម្រោងនានាពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងការអភិវឌ្ឍប្រកបដោយចីរភាព
- គ្រប់គ្រងសម្របសម្រួល តាមដាន និងវាយតម្លៃការអនុវត្តផែនការសកម្មភាព កម្មវិធី និងគម្រោងនានាពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងការអភិវឌ្ឍប្រកបដោយចីរភាព ជាអាទិ៍ការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងការអភិរក្សជីវៈចម្រុះ
- ដឹកនាំសម្របសម្រួលនិងអនុវត្តការងារសិក្សាស្រាវជ្រាវ ដើម្បីផ្តល់ព័ត៌មានវិទ្យាសាស្ត្រសម្រាប់គាំទ្រដល់ការរៀបចំនិងវាយតម្លៃការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការនានាពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងការអភិវឌ្ឍប្រកបដោយចីរភាព
- ដឹកនាំសម្របសម្រួលនិងរៀបចំបង្កើតប្រព័ន្ធទិន្នន័យមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវនិងសារមន្ទីរដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងការអភិរក្សជីវៈចម្រុះ
- គ្រប់គ្រងកិច្ចការរដ្ឋបាល ផែនការ ហិរញ្ញវត្ថុ គណនេយ្យ និងមន្ត្រីរបស់អគ្គនាយកដ្ឋាន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ឱ្យ។

**មាត្រា១៦ ..**

អគ្គនាយកដ្ឋានគោលនយោបាយនិងយុទ្ធសាស្ត្រមាននាយកដ្ឋានចំណុះដូចខាងក្រោម៖

- នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ
- នាយកដ្ឋានប្រែប្រួលអាកាសធាតុ
- នាយកដ្ឋានសេដ្ឋកិច្ចបៃតង
- នាយកដ្ឋានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- នាយកដ្ឋានជីវៈចម្រុះ។

**មាត្រា១៧ ..**

នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងផ្នែករដ្ឋបាលនិងសម្របសម្រួលការងារនិងដំណើរការទូទៅរបស់អគ្គនាយកដ្ឋាន
- សម្របសម្រួលការរៀបចំលិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការថវិកា ផែនការសកម្មភាពជាមួយនាយកដ្ឋានចំណុះឱ្យអគ្គនាយកដ្ឋាន
- បំពេញការងារជាច្រកចេញចូលតែមួយសម្រាប់ការងារគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងការអភិវឌ្ឍប្រកបដោយចីរភាព
- គ្រប់គ្រងនិងចរាចរឯកសារនិងលិខិតបទដ្ឋានគតិយុត្តរបស់អគ្គនាយកដ្ឋាន
- លើកសំណើនិងសម្របសម្រួលការងារលទ្ធកម្មសាធារណៈរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិ ឧបករណ៍ និងសម្ភារៈការិយាល័យរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងនិងកសាងសមត្ថភាពមន្ត្រីរាជការនិងបុគ្គលិកទាំងក្នុងក្របខ័ណ្ឌនិងក្រៅក្របខ័ណ្ឌរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងគណនេយ្យនិងហិរញ្ញវត្ថុរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងការងារពិធីការ កិច្ចគាំពារសង្គម និងកិច្ចសហប្រតិបត្តិការរបស់អគ្គនាយកដ្ឋាន
- រៀបចំ តាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពនិងផែនការថវិកានាយកដ្ឋានចំណុះឱ្យអគ្គនាយកដ្ឋាន
- រៀបចំកិច្ចប្រជុំនានានិងធ្វើកំណត់ហេតុនិងរបាយការណ៍កិច្ចប្រជុំរបស់អគ្គនាយកដ្ឋាន
- រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ និងរបាយការណ៍ផែនការយុទ្ធសាស្ត្រនិងគោលនយោបាយរបស់អគ្គនាយកដ្ឋាន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

**មាត្រា១៨ ..**

នាយកដ្ឋានប្រែប្រួលអាកាសធាតុមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពនិងផែនការថវិកា
- សម្របសម្រួលនិងតាមដានការអនុវត្តលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធី និងគម្រោងនានាដែលរួមចំណែកដល់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងធ្វើរបាយការណ៍ជាប្រចាំ

- ពង្រឹងនិងពង្រីកកិច្ចសហការនិងការសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ
- បណ្តុះបណ្តាលនិងកសាងសមត្ថភាពមន្ត្រីនាយកដ្ឋានជំនាញ ការគ្រប់គ្រងហិរញ្ញវត្ថុ អង្កេតតាមដានការងារផ្ទៃក្នុង និងគ្រប់គ្រងការងាររដ្ឋបាលនានាដែលពាក់ព័ន្ធនឹងតួនាទីនិងភារកិច្ចរបស់នាយកដ្ឋាន
- ដឹកនាំនិងសម្របសម្រួលការរៀបចំនិងគ្រប់គ្រងការធ្វើសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់ របាយការណ៍ជាតិនិងការអនុវត្តកាតព្វកិច្ចនានារបស់រាជរដ្ឋាភិបាលនៅក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ពិធីសារ និងកិច្ចព្រមព្រៀងនានាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ
- សម្របសម្រួល ជំរុញ និងផ្តល់ការគាំទ្របច្ចេកទេសដល់ស្ថាប័ននានាក្នុងការធ្វើសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់នៅតាមប្រភពបញ្ចេញនានា
- ដឹកនាំនិងសម្របសម្រួលការវាយតម្លៃហានិភ័យ ភាពងាយរងគ្រោះ និងកាលានុវត្តភាពនានាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងជំរុញការសិក្សានិងស្រាវជ្រាវវិទ្យាសាស្ត្រអាកាសធាតុ
- ពង្រឹងនិងពង្រីកភាពជាដៃគូនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ តំបន់ និងដើម្បីកៀរគរធនធានសម្រាប់ការអនុវត្តវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ
- លើកសំណើបង្កើតនិងគ្រប់គ្រងមូលនិធិអាកាសធាតុ ដើម្បីគាំទ្រដល់ការអនុវត្តគោលនយោបាយឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ
- រៀបចំនិងគ្រប់គ្រងប្រព័ន្ធព័ត៌មាននិងចំណេះដឹងស្តីពីការប្រែប្រួលអាកាសធាតុ ព្រមទាំងអប់រំនិងផ្សព្វផ្សាយវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់រាជរដ្ឋាភិបាលជូនដល់សាធារណជន ដៃគូអភិវឌ្ឍ និងសហគមន៍អន្តរជាតិ
- ដឹកនាំនិងសម្របសម្រួលការបញ្ជ្រាបការងារប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ ផែនការតាមវិស័យ និងផែនការថវិកាទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បំពេញភារកិច្ចជាអង្គភាពបង្គោលជាតិនៃអនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិនានាពាក់ព័ន្ធនឹងការងារប្រែប្រួលអាកាសធាតុ
- សម្របសម្រួលការងារជាមួយមន្ត្រីបង្គោលនៅតាមបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធសម្រាប់ការងារប្រែប្រួលអាកាសធាតុ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

**មាត្រា១៩ .-**

នាយកដ្ឋានសេដ្ឋកិច្ចបៃតងមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖
- រៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកា
- សម្របសម្រួលនិងអនុវត្តលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធីនិងគម្រោងនានា ដើម្បីគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចបៃតង ព្រមទាំងពិនិត្យ តាមដានវាយតម្លៃ និងធ្វើរបាយការណ៍ជាប្រចាំ
- សម្របសម្រួលការសិក្សាស្រាវជ្រាវអំពីផលប៉ះពាល់និងអត្ថប្រយោជន៍ជាក់ស្តែងនៃសកម្មភាពអភិវឌ្ឍន៍មកលើសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌

- សម្របសម្រួលការសិក្សានិងរៀបចំឧបករណ៍គាំទ្រដល់ការធ្វើសេចក្ដីសម្រេចចិត្តពាក់ព័ន្ធនឹងថាមពលនិរន្តរភាព ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ឧស្សាហកម្មបៃតង និងហិរញ្ញប្បទានបៃតង
- សិក្សាស្រាវជ្រាវនិងរៀបចំគោលនយោបាយនិងយន្តការនានាពាក់ព័ន្ធនឹងការប្រើប្រាស់និងផលិតកម្មដោយនិរន្តរភាព ការផ្ដល់ស្លាកសញ្ញាបរិស្ថាន ការធ្វើលទ្ធកម្មសាធារណៈបៃតង និងការផ្ដល់វិញ្ញាបនបត្របៃតងនិងសេដ្ឋកិច្ចវិលជុំ
- សម្របសម្រួលការរៀបចំនិងជំរុញការអនុវត្តផែនការទីក្រុងបៃតង ភាពងាយរងគ្រោះរបស់ទីក្រុង ថាមពលនិរន្តរភាព ការដឹកជញ្ជូនបៃតង អគារបៃតង ទីធ្លាសាធារណៈបៃតង និងបេតិកភណ្ឌវប្បធម៌ កម្មន្តសាលបៃតង ការផ្គត់ផ្គង់ទឹកស្អាតនិងការគ្រប់គ្រងសំណល់រឹង រាវ ដើម្បីឱ្យការអភិវឌ្ឍទីក្រុងនិងទីប្រជុំជនមាននិរន្តរភាព
- កសាងនិងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល វិស័យឯកជន គ្រឹះស្ថានសិក្សាស្រាវជ្រាវ និងភាគីពាក់ព័ន្ធផ្សេងទៀត ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង
- ពង្រឹងភាពជាដៃគូនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីកៀរគរធនធានសម្រាប់អនុវត្តគោលនយោបាយនិងកម្មវិធីនានាពាក់ព័ន្ធនឹងការអភិវឌ្ឍសេដ្ឋកិច្ចបៃតង
- ផ្សព្វផ្សាយគោលនយោបាយនិងវិធានការនានារបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងការអភិវឌ្ឍសេដ្ឋកិច្ចបៃតងជូនដល់សាធារណជន ដៃគូអភិវឌ្ឍ និងសហគមន៍អន្តរជាតិ
- សម្របសម្រួលការងារជាមួយមន្ត្រីបង្គោលនៅតាមបណ្ដាក្រសួងស្ថាប័នពាក់ព័ន្ធសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

**មាត្រា២០ ..**

នាយកដ្ឋានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំសេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកា
- សម្របសម្រួលនិងអនុវត្តលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធីនិងគម្រោងនានា ដើម្បីគាំទ្រដល់ការស្រាវជ្រាវ ការអភិវឌ្ឍ និងការប្រើប្រាស់បច្ចេកវិទ្យាទម្លាប់ប្រតិបត្តិនិងទម្រង់ដទៃទៀតនៃនវានុវត្តន៍សំដៅលើកកម្ពស់វិស័យបរិស្ថាននិងការអភិវឌ្ឍប្រកបដោយចីរភាព
- សិក្សានិងតាមដានលើការវិវឌ្ឍវិទ្យាសាស្ត្រដើម្បីរៀបចំសំណើគោលនយោបាយស្របតាមបរិបទសាកល តំបន់ និងអនុតំបន់ ដើម្បីលើកតម្កើងការអភិវឌ្ឍប្រកបដោយចីរភាព
- កសាងនិងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍនិងភាគីពាក់ព័ន្ធលើការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ ក្នុងគោលដៅកំណត់នូវគោលនយោបាយតម្រង់ទិសតាមវិស័យ
- កំណត់នូវរបៀបវារៈនិងសម្របសម្រួលការសិក្សាស្រាវជ្រាវ ដើម្បីផ្ដល់ព័ត៌មានវិទ្យាសាស្ត្រ សម្រាប់រួមចំណែកដល់ការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងយន្តការនានាពាក់ព័ន្ធនឹងការអភិវឌ្ឍប្រកបដោយចីរភាព

- សម្របសម្រួលការសិក្សានិងវាយតម្លៃកំណត់ស្តង់ដាបរិស្ថាន និងវឌ្ឍនភាពទៅរកការអភិវឌ្ឍប្រកបដោយចីរភាព និងឱកាសសម្រាប់ការកែលម្អដោយផ្អែកលើភស្តុតាងវិទ្យាសាស្ត្រ
- សម្របសម្រួលនិងគាំទ្រដល់ដំណើរការនៃការបង្កើតវិធីសាស្ត្រសិក្សាស្រាវជ្រាវរួម ពាក់ព័ន្ធនឹងការអភិវឌ្ឍប្រកបដោយចីរភាព
- កសាងនិងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល វិស័យឯកជន គ្រឹះស្ថានសិក្សាស្រាវជ្រាវ និងភាគីពាក់ព័ន្ធ ដើម្បីកៀរគរធនធាននិងការគាំទ្រសម្រាប់ពង្រឹងសមត្ថភាព និងលើកកម្ពស់ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- សម្របសម្រួលការប្រើប្រាស់បច្ចេកវិទ្យាបៃតងនិងជំរុញការអភិវឌ្ឍដែលបញ្ចេញកាបូនតិច
- លើកកម្ពស់ការយល់ដឹងរបស់សាធារណជនពីតួនាទីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៅក្នុងការគ្រប់គ្រងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាពនិងការអភិវឌ្ឍប្រកបដោយចីរភាព
- សម្របសម្រួលនិងជំរុញការផ្ទេរបច្ចេកវិទ្យានិងប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ រួមទាំងបច្ចេកវិទ្យាណាណូ បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត និងបច្ចេកវិទ្យាថាមពលនុយក្លេអ៊ែរសម្រាប់បម្រើឱ្យគោលបំណងសន្តិភាព
- រៀបចំបង្កើតក្រមសីលធម៌និងយន្តការសម្រាប់វាយតម្លៃការស្រាវជ្រាវនិងនវានុវត្តន៍ពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងការអភិវឌ្ឍប្រកបដោយចីរភាព
- សម្របសម្រួលការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធសម្រាប់ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តការកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

**មាត្រា២១ .-**

នាយកដ្ឋានជីវៈចម្រុះបំពេញមុខងារជាមជ្ឈមណ្ឌលជីវៈចម្រុះជាតិមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ក្របខ័ណ្ឌការងារ នីតិវិធី ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកា
- សម្របសម្រួលនិងអនុវត្តលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ក្របខ័ណ្ឌការងារ នីតិវិធី ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធី និងគម្រោងនានា សម្រាប់ធានាការការពារ និងការអភិរក្សធនធានធម្មជាតិ ជីវៈចម្រុះនិងសេវាកម្មប្រព័ន្ធអេកូឡូស៊ី ជីវសុវត្ថិភាព និងការបែងចែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានពន្ធុ និងចំណេះដឹងជាប្រពៃណីពាក់ព័ន្ធ ព្រមទាំងពិនិត្យ តាមដាន វាយតម្លៃ និងធ្វើរបាយការណ៍
- រៀបចំបង្កើតនិងគ្រប់គ្រងប្រព័ន្ធព័ត៌មាន ទិន្នន័យ និងសម្របសម្រួលការប្រមូលនិងការធ្វើសារពើភណ្ឌពាក់ព័ន្ធនឹងធនធានជីវៈចម្រុះ សេវាកម្មប្រព័ន្ធអេកូឡូស៊ី ជីវសុវត្ថិភាព ធនធានពន្ធុ និងចំណេះដឹងជាប្រពៃណីពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស នវានុវត្តន៍ និងវាយតម្លៃអំពីធនធានជីវៈចម្រុះ សេវាកម្មប្រព័ន្ធអេកូឡូស៊ី និងជីវសុវត្ថិភាព ដោយសហការជាមួយក្រសួង ស្ថាប័ន វិស័យឯកជន គ្រឹះស្ថានសិក្សាស្រាវជ្រាវ និងភាគីពាក់ព័ន្ធ

- វាយតម្លៃ គ្រប់គ្រង និងឃ្លាំមើលហានិភ័យពាក់ព័ន្ធនឹងការគ្រប់គ្រងចលនាឆ្លងដែននៃសារពាង្គកាយកែច្នៃពន្ធុនិងកែច្នៃរស់ ដោយសហការជាមួយស្ថាប័នជាតិ វិស័យឯកជន និងគ្រឹះស្ថានសិក្សាស្រាវជ្រាវ
- កសាងនិងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍនិងភាគីពាក់ព័ន្ធ ដើម្បីកៀរគរធនធាន និងគាំទ្រដល់ការអភិរក្សនិងការគ្រប់គ្រងធនធានជីវៈចម្រុះ សេវាកម្មប្រព័ន្ធអេកូឡូស៊ី និងជីវសុវត្ថិភាព
- រៀបចំបង្កើត សហការគ្រប់គ្រង និងប្រតិបត្តិការមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវ និងអភិរក្សកេសរកូលសុខ អាន ភ្នំគូលែន សារមន្ទីរប្រវត្តិសាស្ត្រធម្មជាតិ សួនរុក្ខជាតិ សួនរុក្ខពុទ្ធសាស្ត្រ ធនាគារពូជ និងធនាគារពន្ធុ សម្រាប់ការអភិរក្សក្រៅដែនធម្មជាតិ
- រៀបចំ ចងក្រង និងផលិតសារ សម្ភារៈអប់រំផ្សព្វផ្សាយ កម្មវិធីបណ្តុះបណ្តាល និងកសាងសមត្ថភាពពាក់ព័ន្ធនឹងជីវៈចម្រុះ សេវាកម្មប្រព័ន្ធអេកូឡូស៊ី និងជីវសុវត្ថិភាព រួមទាំងរៀបចំទិវាជីវៈចម្រុះអន្តរជាតិ និងវេទិកាកេសរកូលជាតិ
- សម្របសម្រួលការរៀបចំរបាយការណ៍ជាតិនិងការអនុវត្តកាតព្វកិច្ចនានារបស់រាជរដ្ឋាភិបាល នៅក្រោមអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះនិងពិធីសារពាក់ព័ន្ធ
- បំពេញភារកិច្ចជាអង្គភាពបង្គោលជាតិនៃអនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនឹងជីវៈចម្រុះ និងសម្របសម្រួលការងារជាមួយមន្ត្រីបង្គោលនៅតាមបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

## ជំពូកទី៦

## អគ្គនាយកដ្ឋានគាំពារបរិស្ថាន

**មាត្រា២២ .-**

អគ្គនាយកដ្ឋានគាំពារបរិស្ថានជាសេនាធិការឱ្យក្រសួងបរិស្ថានក្នុងការគ្រប់គ្រងនិងសម្របសម្រួលកិច្ចគាំពារបរិស្ថាន ហើយមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនានាពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន ស្តង់ដាគុណភាពបរិស្ថាន និងស្តង់ដានៃការបញ្ចេញសំណល់ ឬសារធាតុបំពុល ផ្សែង សំឡេង និងរំញ័រ
- គ្រប់គ្រងគុណភាពទឹក ដី ខ្យល់ គ្រប់គ្រងសំឡេងនិងរំញ័រ និងគ្រប់គ្រងការបំភាយសារធាតុគ្រោះថ្នាក់ រួមទាំងកាំរស្មីវិទ្យុសកម្មនិងអេឡិចត្រូម៉ាញ៉េទិក
- គ្រប់គ្រងទិន្នន័យប្រភពបំពុល ទិន្នន័យសំណល់ សារធាតុបំពុល សំឡេង រំញ័រ សំណល់វិទ្យុសកម្ម
- ពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន តាមរយៈការចុះត្រួតពិនិត្យនិងធ្វើអធិការកិច្ចលើទីតាំងឬមធ្យោបាយនៃផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ដែលពាក់ព័ន្ធនឹងការបង្កើត ការផលិត ការប្រើប្រាស់ ការកែច្នៃ ការទាញយកធនធាន ការធ្វើប្រព្រឹត្តកម្ម ការបញ្ចេញចោល និងការទុកដាក់ចុងក្រោយនៃសំណល់ សារធាតុបំពុល ការបញ្ចេញសំឡេង រំញ័រ ការសាយភាយកាំរស្មីវិទ្យុសកម្មនិងអេឡិចត្រូម៉ាញ៉េទិក និងត្រួតពិនិត្យការអនុវត្តផែនការគ្រប់គ្រងការបំពុលបរិស្ថានរបស់គម្រោងវិនិយោគ

- ពិនិត្យនិងផ្តល់យោបល់បច្ចេកទេសពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថានលើគម្រោងវិនិយោគសាធារណៈ និងឯកជន
- សិក្សា ស្រាវជ្រាវ និងវាយតម្លៃអំពីការសាយភាយសារធាតុគីមីពុលចូលក្នុងបរិស្ថាន វាយតម្លៃកម្រិតនៃការបំពុលបរិស្ថាននិងផលប៉ះពាល់ទៅលើសុខភាព
- រៀបចំផែនការត្រៀមបង្ការនិងឆ្លើយតបបន្ទាន់ចំពោះករណីគ្រោះថ្នាក់បំពុលបរិស្ថាន
- ផ្តល់យោបល់និងសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធឬរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការទប់ស្កាត់ការលុបបំបាត់ការបំពុលបរិស្ថាននិងការស្តារគុណភាពបរិស្ថានឡើងវិញ
- ផ្តល់ការគាំទ្របច្ចេកទេស ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងការងារគ្រប់គ្រងសំរាមសំណល់រឹង ទឹកកខ្វក់ទីប្រជុំជនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បំពេញភារកិច្ចជាអង្គភាពបង្គោលជាតិ ជំរុញនិងសម្របសម្រួលការអនុវត្តកិច្ចព្រមព្រៀង អនុសញ្ញា ពិធីសារអន្តរជាតិ និងការងារសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិពាក់ព័ន្ធនឹងវិស័យកិច្ចគាំពារបរិស្ថាន
- គ្រប់គ្រងការផ្តល់សេវាសាធារណៈពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាននិងសេវាមន្ទីរពិសោធន៍
- អភិវឌ្ឍសមត្ថភាពជំនាញកិច្ចគាំពារបរិស្ថានដល់មន្ទីរបរិស្ថានរាជធានី ខេត្ត អង្គភាព ពាក់ព័ន្ធនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ
- គ្រប់គ្រងកិច្ចការរដ្ឋបាល ផែនការ គណនេយ្យ ហិរញ្ញវត្ថុ មន្ត្រីរាជការ និងបុគ្គលិកក្នុងអគ្គនាយកដ្ឋាន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរដ្ឋមន្ត្រីប្រគល់ឱ្យ។

**មាត្រា២៣ ..**

អគ្គនាយកដ្ឋានគាំពារបរិស្ថានមាននាយកដ្ឋានចំណុះនិងមន្ទីរពិសោធន៍មួយដែលមានថ្នាក់ស្មើនាយកដ្ឋានដូចខាងក្រោម៖

- នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ
- នាយកដ្ឋានគ្រប់គ្រងគុណភាពខ្យល់ សំឡេង និងរំញ័រ
- នាយកដ្ឋានគ្រប់គ្រងគុណភាពទឹក
- នាយកដ្ឋានគ្រប់គ្រងសំណល់រឹង
- នាយកដ្ឋានគ្រប់គ្រងសារធាតុគ្រោះថ្នាក់
- នាយកដ្ឋានអធិការកិច្ចនិងពង្រឹងការអនុវត្តច្បាប់
- មន្ទីរពិសោធន៍។

**មាត្រា២៤ ..**

នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងផ្នែករដ្ឋបាលនិងសម្របសម្រួលការងារនិងដំណើរការទូទៅរបស់អគ្គនាយកដ្ឋាន
- សម្របសម្រួលការរៀបចំលិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការថវិកា ផែនការសកម្មភាពជាមួយនាយកដ្ឋានចំណុះឱ្យអគ្គនាយកដ្ឋាន



ម

- បំពេញការងារជាច្រកចេញចូលតែមួយសម្រាប់ការងារគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងការអភិវឌ្ឍប្រកបដោយចីរភាព
- គ្រប់គ្រងនិងចរាចរឯកសារនិងលិខិតបទដ្ឋានគតិយុត្តរបស់អគ្គនាយកដ្ឋាន
- លើកសំណើនិងសម្របសម្រួលការងារលទ្ធកម្មសាធារណៈរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិ ឧបករណ៍ និងសម្ភារៈការិយាល័យរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងនិងកសាងសមត្ថភាពមន្ត្រីរាជការនិងបុគ្គលិកទាំងក្នុងក្របខ័ណ្ឌនិងក្រៅក្របខ័ណ្ឌរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងគណនេយ្យនិងហិរញ្ញវត្ថុរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងការងារពិធីការ កិច្ចគាំពារសង្គម និងកិច្ចសហប្រតិបត្តិការរបស់អគ្គនាយកដ្ឋាន
- រៀបចំនិងតាមដាននិងការវាយតម្លៃការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកានាយកដ្ឋានចំណុះឱ្យអគ្គនាយកដ្ឋាន
- រៀបចំកិច្ចប្រជុំនានានិងធ្វើកំណត់ហេតុនិងរបាយការណ៍កិច្ចប្រជុំរបស់អគ្គនាយកដ្ឋាន
- រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ និងរបាយការណ៍ផែនការយុទ្ធសាស្ត្រនិងគោលនយោបាយរបស់អគ្គនាយកដ្ឋាន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

**មាត្រា២៥ ..**

នាយកដ្ឋានគ្រប់គ្រងគុណភាពខ្យល់ សំឡេង និងរំញ័រមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំបច្ចេកទេសពាក់ព័ន្ធការគ្រប់គ្រងគុណភាពខ្យល់ សំឡេង និងរំញ័រ និងការរៀបចំផែនការសកម្មភាពនិងផែនការថវិកា
- អនុវត្តការ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃគុណភាពខ្យល់បរិយាកាស និងផ្សព្វផ្សាយស្ថានភាពគុណភាពខ្យល់បរិយាកាសជាសាធារណៈ
- គ្រប់គ្រងទិន្នន័យប្រភពបំពុលខ្យល់ គុណភាពខ្យល់បរិយាកាស គុណភាពខ្យល់ក្នុងអគារ និងសារធាតុបំពុលដែលសាយភាយចូលទៅក្នុងខ្យល់
- អនុវត្តការត្រួតពិនិត្យគុណភាពខ្យល់ កម្រិតសំឡេង និងរំញ័រក្នុងអគារ ផលិតកម្ម អាជីវកម្ម និងសេវាកម្មដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- ពិនិត្យនិងផ្តល់យោបល់បច្ចេកទេសពាក់ព័ន្ធនឹងការបញ្ចេញសារធាតុបំពុលខ្យល់ សំឡេង និងរំញ័រនៃគម្រោងវិនិយោគសាធារណៈនិងឯកជន
- ត្រួតពិនិត្យនិងវាយតម្លៃមធ្យោបាយគ្រប់គ្រង បរិក្ខារប្រព្រឹត្តកម្មផ្សេង ចំហាយឧស្ម័ន ភាគល្អិតនិចលសំឡេង និងរំញ័រនៅតាមទីតាំងសកម្មភាពផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- ពិនិត្យនិងផ្តល់សេវាលើសំណើសុំការអនុញ្ញាតបញ្ចេញផ្សេង និងលិខិតបញ្ជាក់គុណភាពខ្យល់ សំឡេងនិងរំញ័រ
- សហការជាមួយស្ថាប័នឬអង្គភាពពាក់ព័ន្ធក្នុងការរៀបចំនីតិវិធីអនុវត្តការត្រួតពិនិត្យការបញ្ចេញសារធាតុបំពុលខ្យល់ សំឡេង និងរំញ័រពីប្រភពចល័ត និងត្រួតពិនិត្យសមាសធាតុផ្សំក្នុងឥន្ធនៈផូស៊ីល

- សិក្សា ស្រាវជ្រាវ និងផ្សព្វផ្សាយបច្ចេកទេស បច្ចេកវិទ្យាគ្រប់គ្រងការបំពុលខ្យល់ សំឡេង និងរំញ័រ ពីប្រភពចល័តនិងអចល័ត និងភាពគ្រោះថ្នាក់នៃសារធាតុបំពុលខ្យល់ក្នុងខ្យល់បរិយាកាសនិងខ្យល់ក្នុងអគារ
- បំពេញភារកិច្ចជាអង្គភាពបង្គោលជាតិនៃអនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនឹងការការពារនិងការត្រួតពិនិត្យការបំពុលខ្យល់ ជាអាទិ៍បញ្ហាផ្សែងអ័ព្ទ អាស៊ីដបរិយាកាស កិច្ចការពារស្រទាប់អូហ្សូន និងការងារសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិពាក់ព័ន្ធនឹងការទប់ស្កាត់ការបំពុលខ្យល់
- បំពេញភារកិច្ចពង្រឹងសមត្ថភាពជំនាញដល់មន្ទីរបរិស្ថានរាជធានី ខេត្ត អង្គភាពពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិអំពីការគ្រប់គ្រងការបំពុលខ្យល់ សំឡេង រំញ័រ និងកិច្ចការអនុសញ្ញា និងពិធីសារអន្តរជាតិពាក់ព័ន្ធ
- រៀបចំរបាយការណ៍វាយតម្លៃប្រចាំឆ្នាំអំពីស្ថានភាពគុណភាពខ្យល់បរិយាកាសនិងខ្យល់ក្នុងអគារ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

**មាត្រា២៦.-**

នាយកដ្ឋានគ្រប់គ្រងគុណភាពទឹកមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសពាក់ព័ន្ធ ការគ្រប់គ្រងគុណភាពទឹកឬការបំពុលទឹកនៅតំបន់ទទួលរងការបំពុល ការគ្រប់គ្រងសំណល់រាវ និងការរៀបចំ ផែនការសកម្មភាពនិងផែនការថវិកា
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃគុណភាពទឹកនៅតំបន់ទទួលរងការបំពុលទឹក និងផ្សព្វផ្សាយស្ថានភាពគុណភាពទឹកជាសាធារណៈ
- គ្រប់គ្រងទិន្នន័យប្រភពបង្កការបំពុលទឹក ទិន្នន័យគុណភាពទឹកនៅតំបន់ទទួលរងការបំពុល និងសារធាតុបំពុលដែលសាយភាយចូលក្នុងតំបន់ទឹកសាធារណៈ
- ពិនិត្យនិងវាយតម្លៃមធ្យោបាយគ្រប់គ្រងនិងប្រព័ន្ធប្រព្រឹត្តកម្មសំណល់រាវទឹកកខ្វក់នៅតាមទីតាំងសកម្មភាពផលិតកម្ម អាជីវកម្ម និងសេវាកម្ម ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- ពិនិត្យនិងផ្តល់យោបល់បច្ចេកទេសបរិស្ថានលើប្រព័ន្ធប្រព្រឹត្តកម្មសំណល់រាវទឹកកខ្វក់នៃគម្រោងវិនិយោគសាធារណៈនិងឯកជន និងលើការទទួលស្គាល់ផ្តល់វិញ្ញាបនបត្រវិស្វកម្មបរិស្ថានប្រព័ន្ធប្រព្រឹត្តកម្មសំណល់រាវទឹកកខ្វក់
- ពិនិត្យនិងផ្តល់សេវាសំណើសុំលិខិតអនុញ្ញាតបញ្ចេញទឹកកខ្វក់និងសំណល់រាវទៅប្រភពទឹកសាធារណៈ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវនិងផ្សព្វផ្សាយបច្ចេកទេស បច្ចេកវិទ្យាទប់ស្កាត់ កាត់បន្ថយការសាយភាយសារធាតុបំពុលចូលទៅក្នុងតំបន់ទឹកសាធារណៈ និងភាពគ្រោះថ្នាក់នៃសារធាតុបំពុលទៅលើសុខភាព បរិស្ថាន និងជីវៈចម្រុះ
- បំពេញភារកិច្ចជាអង្គភាពបង្គោលជាតិនៃអនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនឹងការគ្រប់គ្រងគុណភាពទឹកនៅក្នុងក្របខ័ណ្ឌតំបន់និងពិភពលោក

- បំពេញភារកិច្ចពង្រឹងសមត្ថភាពជំនាញដល់មន្ទីរបរិស្ថានរាជធានី ខេត្ត អង្គភាពពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិអំពីការគ្រប់គ្រងការបំពុលទឹកនិងកិច្ចព្រមព្រៀងអន្តរជាតិនិងតំបន់ពាក់ព័ន្ធនឹងបញ្ហាការបំពុលទឹក
- សហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធជាតិនិងអន្តរជាតិក្នុងការរៀបចំផែនការសកម្មភាពមធ្យោបាយ និងធនធានសម្រាប់ការឆ្លើយតបបន្ទាន់ចំពោះករណីគ្រោះឧបទ្ទវហេតុនៃការកំពប់និងការលេចធ្លាយសារធាតុបំពុលបរិស្ថាន
- រៀបចំរបាយការណ៍វាយតម្លៃប្រចាំឆ្នាំអំពីស្ថានភាពគុណភាពទឹកតំបន់ទឹកសាធារណៈ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

**មាត្រា២៧ ..**

នាយកដ្ឋានគ្រប់គ្រងសំណល់រឹងមានតួនាទីនិងភារកិច្ចដូចខាងក្រោមៈ

- រៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំបច្ចេកទេសពាក់ព័ន្ធ ការគ្រប់គ្រងសំណល់រឹង និងការរៀបចំផែនការសកម្មភាពនិងផែនការថវិការបស់នាយកដ្ឋាន
- គ្រប់គ្រងទិន្នន័យសំណល់រឹងឧស្សាហកម្ម និងសំរាម សំណល់រឹងទីប្រជុំជន
- ពិនិត្យនិងផ្តល់យោបល់លើគម្រោងស្នើសុំវិនិយោគសាធារណៈនិងឯកជនធ្វើអាជីវកម្ម ឬការផ្តល់សេវាប្រមូលដឹកជញ្ជូន ការកែច្នៃ ការទាញយកធនធាន ការបង្កើតឡដុតសំណល់ ការធ្វើប្រព្រឹត្តកម្ម ការបង្កើតស្ថានីយផ្ទេរ និងការបង្កើតទីលានទុកដាក់សំណល់រឹង
- ចុះត្រួតពិនិត្យនិងវាយតម្លៃមធ្យោបាយ វិធីសាស្ត្រគ្រប់គ្រងសំណល់រឹង ឬបរិក្ខារប្រព្រឹត្តកម្មសំណល់រឹងនៅតាមទីតាំងបង្កើតឬសកម្មភាពផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃកិច្ចប្រតិបត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិលើការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ផ្សព្វផ្សាយនិងណែនាំដល់ប្រតិបត្តិករនៃទីតាំងសកម្មភាពផលិតកម្ម អាជីវកម្ម ឬសេវាកម្ម អំពីច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសដែលពាក់ព័ន្ធនឹងការញែក ការវេចខ្ចប់ ការប្រមូលដឹកជញ្ជូន ការកែច្នៃ ការទាញយកធនធាន ការបង្កើតឡដុតសំណល់ ការធ្វើប្រព្រឹត្តកម្ម ការផ្ទេរ និងការទុកដាក់សំណល់រឹង ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- ពិនិត្យនិងផ្តល់សេវាលើសំណើសុំការអនុញ្ញាតបញ្ចេញសំណល់រឹង ការប្រមូលទិញ ការនាំចេញ ការនាំចូលសំណល់រឹងកែច្នៃ ផលិតផលប្លាស្ទិក និងការស្នើសុំធ្វើអាជីវកម្មកែច្នៃទាញយកធនធាន បង្កើតឡដុតសំណល់ ធ្វើប្រព្រឹត្តកម្ម និងការទុកដាក់សំណល់រឹង
- សិក្សា ស្រាវជ្រាវ និងផ្សព្វផ្សាយបច្ចេកទេសនិងបច្ចេកវិទ្យាថ្មីៗសម្រាប់គ្រប់គ្រងសំណល់រឹង
- បំពេញភារកិច្ចជាអង្គភាពបង្គោលជាតិនៃអនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់រឹងនៅក្នុងក្របខ័ណ្ឌតំបន់និងពិភពលោក
- បំពេញភារកិច្ចពង្រឹងសមត្ថភាពជំនាញដល់មន្ទីរបរិស្ថានរាជធានី ខេត្ត អង្គភាពពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិអំពីការគ្រប់គ្រងសំណល់រឹង

- រៀបចំរបាយការណ៍វាយតម្លៃប្រចាំឆ្នាំអំពីស្ថានភាពនៃការគ្រប់គ្រងសំណល់រឹង
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

**មាត្រា២៨ ._**

នាយកដ្ឋានគ្រប់គ្រងសារធាតុគ្រោះថ្នាក់មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ផែនការថវិកា និងគោលការណ៍ណែនាំបច្ចេកទេសពាក់ព័ន្ធ ការគ្រប់គ្រងសារធាតុគ្រោះថ្នាក់ សំណល់គ្រោះថ្នាក់ សំណល់វេជ្ជសាស្ត្រ សំណល់ដែលមានផ្ទុកសារធាតុវិទ្យុសកម្ម និងការបោះបង់ចោលសារធាតុគ្រោះថ្នាក់ រួមទាំងកាំរស្មីវិទ្យុសកម្មនិងអេឡិចត្រូម៉ាញ៉េទិក
- គ្រប់គ្រងទិន្នន័យនិងព័ត៌មានប្រភពប្រើប្រាស់សារធាតុគ្រោះថ្នាក់ សំណល់គ្រោះថ្នាក់ សំណល់វេជ្ជសាស្ត្រ និងសំណល់ដែលមានផ្ទុកសារធាតុវិទ្យុសកម្ម
- តាមដាននិងត្រួតពិនិត្យការគ្រប់គ្រងសំណល់គ្រោះថ្នាក់ សំណល់វេជ្ជសាស្ត្រ និងសំណល់ដែលមានផ្ទុកសារធាតុវិទ្យុសកម្មនៅតាមសកម្មភាពផលិតកម្ម អាជីវកម្ម ឬសេវាកម្ម រួមទាំងសកម្មភាពនាំចេញ នាំចូល និងដឹកឆ្លងកាត់ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- ពិនិត្យនិងផ្តល់យោបល់លើសំណើគម្រោងវិនិយោគសេវាប្រមូល ដឹកជញ្ជូន កែច្នៃ ធ្វើប្រព្រឹត្តកម្ម កម្ទេចចោល និងទីលានទុកដាក់សារធាតុគ្រោះថ្នាក់ សំណល់គ្រោះថ្នាក់ សំណល់វេជ្ជសាស្ត្រ និងសំណល់ដែលមានផ្ទុកសារធាតុវិទ្យុសកម្ម
- ពិនិត្យនិងផ្តល់សេវាលើការស្នើសុំការអនុញ្ញាតបញ្ចេញ នាំចេញ នាំចូល និងដឹកឆ្លងកាត់នូវសារធាតុគ្រោះថ្នាក់ សំណល់គ្រោះថ្នាក់ សំណល់វេជ្ជសាស្ត្រ និងសំណល់ដែលមានផ្ទុកសារធាតុវិទ្យុសកម្ម
- អប់រំផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្ត ស្តង់ដា និងគោលការណ៍ណែនាំបច្ចេកទេសដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសារធាតុគ្រោះថ្នាក់ សំណល់គ្រោះថ្នាក់ សំណល់វេជ្ជសាស្ត្រ និងសំណល់ដែលមានផ្ទុកសារធាតុវិទ្យុសកម្ម
- សិក្សា ស្រាវជ្រាវ និងផ្សព្វផ្សាយអំពីប្រភេទ កម្រិតគ្រោះថ្នាក់ ឬផលប៉ះពាល់នៃសារធាតុគ្រោះថ្នាក់ សំណល់គ្រោះថ្នាក់ សំណល់វេជ្ជសាស្ត្រ សំណល់ដែលមានផ្ទុកសារធាតុវិទ្យុសកម្ម ដែលសាយភាយចូលទៅក្នុងបរិស្ថាន
- បំពេញភារកិច្ចជាអង្គភាពបង្គោលជាតិនៃអនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនឹងការគ្រប់គ្រងសារធាតុគ្រោះថ្នាក់សំណល់គ្រោះថ្នាក់ និងសំណល់ដែលមានផ្ទុកសារធាតុវិទ្យុសកម្ម
- បំពេញភារកិច្ចពង្រឹងសមត្ថភាពជំនាញដល់មន្ទីរបរិស្ថានរាជធានី ខេត្ត អង្គភាពពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិអំពីការគ្រប់គ្រងសារធាតុគ្រោះថ្នាក់ សំណល់គ្រោះថ្នាក់ សំណល់វេជ្ជសាស្ត្រ និងសំណល់ដែលមានផ្ទុកសារធាតុវិទ្យុសកម្មនិងកិច្ចការអនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធ
- សម្របសម្រួលជាមួយស្ថាប័នឬអង្គភាពពាក់ព័ន្ធជាតិនិងអន្តរជាតិក្នុងការរៀបចំផែនការសកម្មភាពឆ្លើយតប និងការត្រៀមសម្ភារៈ មធ្យោបាយ និងធនធានសម្រាប់ការឆ្លើយតបបន្ទាន់ចំពោះករណីគ្រោះឧបទ្ទវហេតុនៃការឆេះ ការផ្ទុះ ការកំពប់ ការលេចធ្លាយសារធាតុគ្រោះថ្នាក់ឬសំណល់គ្រោះថ្នាក់

- រៀបចំរបាយការណ៍វាយតម្លៃប្រចាំឆ្នាំអំពីស្ថានភាពនៃការគ្រប់គ្រងសារធាតុគ្រោះថ្នាក់ សំណល់គ្រោះថ្នាក់ សំណល់វេជ្ជសាស្ត្រ និងសំណល់ដែលមានផ្ទុកសារធាតុវិទ្យុសកម្ម
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

**មាត្រា២៩.-**

នាយកដ្ឋានអធិការកិច្ចនិងពង្រឹងការអនុវត្តច្បាប់មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំលិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំបច្ចេកទេសពាក់ព័ន្ធនឹងការត្រួតពិនិត្យ អធិការកិច្ចការបំពុលបរិស្ថាន ការចុះអង្កេត តាមដាន និងត្រួតពិនិត្យការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន និងការរៀបចំផែនការសកម្មភាពនិងផែនការថវិកា
- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធកិច្ចគាំពារបរិស្ថាន ដល់ម្ចាស់ទីតាំងសកម្មភាពផលិតកម្ម អាជីវកម្ម និងសេវាកម្ម ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- លើកសំណើចាត់វិធានការបទល្មើសបំពុលបរិស្ថាន ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន និងបទល្មើសមិនបានអនុវត្តតាមផែនការគ្រប់គ្រងបរិស្ថាន ដូចមានកំណត់ក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងកិច្ចសន្យាការពារបរិស្ថាននៃគម្រោងវិនិយោគសាធារណៈ និងគម្រោងវិនិយោគឯកជន
- រៀបចំសំណុំបែបបទពាក់ព័ន្ធនឹងបទល្មើសបំពុលបរិស្ថានដើម្បីដោះស្រាយតាមនីតិវិធីច្បាប់
- សម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអង្គភាពមានសមត្ថកិច្ច ក្នុងការធ្វើអធិការកិច្ចនិងពង្រឹងការអនុវត្តច្បាប់លើបទល្មើសបំពុលបរិស្ថាន
- គ្រប់គ្រងទិន្នន័យប្រភពបំពុល គម្រោងវិនិយោគសាធារណៈនិងគម្រោងវិនិយោគឯកជន
- រៀបចំនីតិវិធីសម្រាប់ការត្រួតពិនិត្យនិងអធិការកិច្ចបទល្មើសបំពុលបរិស្ថាននៅទីតាំងសកម្មភាពផលិតកម្ម អាជីវកម្ម និងសេវាកម្ម ដែលពាក់ព័ន្ធការបញ្ចេញសំណល់ឬសារធាតុបំពុលចូលក្នុងបរិស្ថាន
- ជំរុញការអនុវត្តច្បាប់ពាក់ព័ន្ធកិច្ចគាំពារបរិស្ថាន តាមរយៈការចុះត្រួតពិនិត្យនិងអធិការកិច្ចប្រភពបំពុល និងតាមដានត្រួតពិនិត្យការអនុវត្តផែនការគ្រប់គ្រងបរិស្ថាននៃគម្រោងវិនិយោគ
- ផ្សព្វផ្សាយនិងណែនាំដល់មន្ទីរបរិស្ថានរាជធានី ខេត្ត អំពីនីតិវិធីសម្រាប់ការត្រួតពិនិត្យ និងអធិការកិច្ចបទល្មើសបំពុលបរិស្ថាន និងអង្កេត តាមដាន និងត្រួតពិនិត្យការអនុវត្តផែនការគ្រប់គ្រងបរិស្ថាននៅទីតាំងសកម្មភាពផលិតកម្ម អាជីវកម្ម និងសេវាកម្ម ដែលពាក់ព័ន្ធការបញ្ចេញសំណល់ឬសារធាតុបំពុលចូលក្នុងបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពថ្នាក់ក្រោមជាតិពាក់ព័ន្ធ
- សហការជាមួយនាយកដ្ឋានចំណុះនៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន អង្គភាពពាក់ព័ន្ធ និងមន្ទីរបរិស្ថានរាជធានី ខេត្ត ចុះធ្វើអធិការកិច្ច ដោះស្រាយវិវាទ និងបណ្តឹងការបំពុលបរិស្ថាន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

**មាត្រា៣០.-**

មន្ទីរពិសោធន៍មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការគ្រប់គ្រង ផែនការសកម្មភាព ផែនការថវិកា និងពង្រឹងសមត្ថភាពមន្ទីរពិសោធន៍

- រៀបចំគ្រប់គ្រង ថែទាំ និងធ្វើទំនើបកម្មឧបករណ៍និងបរិក្ខារពិសោធន៍គុណភាពបរិស្ថាន អាស៊ីដបរិយាកាស សារជាតុវិទ្យុសកម្ម គីមីគ្រោះថ្នាក់បរិស្ថាន ជីវសាស្ត្រ លោហិតសាស្ត្រ បាក់តេរីសាស្ត្រ ពន្ធុសាស្ត្រ និងពង្រឹកវិសាលភាពវិភាគ
- រៀបចំនិងធ្វើបច្ចុប្បន្នភាពបទដ្ឋានវិធីសាស្ត្រវិភាគថ្មីៗ ស្របតាមបទដ្ឋានអន្តរជាតិ លើការវិភាគគុណភាពបរិស្ថាន អាស៊ីដបរិយាកាស សារជាតុវិទ្យុសកម្ម គីមីគ្រោះថ្នាក់បរិស្ថាន ជីវសាស្ត្រ លោហិតសាស្ត្រ បាក់តេរីសាស្ត្រ និងពន្ធុសាស្ត្រ
- ផ្តល់ការគាំទ្រ សិក្សាស្រាវជ្រាវ បណ្តុះបណ្តាល ពង្រឹង និងពង្រីកសមត្ថភាពមន្ទីរពិសោធន៍
- ផ្តល់កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ អង្គការសង្គមស៊ីវិល វិស័យឯកជន គ្រឹះស្ថានសិក្សាស្រាវជ្រាវ និងភាគីពាក់ព័ន្ធផ្សេងទៀតក្នុងការលើកកម្ពស់ការស្រាវជ្រាវ ទាក់ទងនឹងការវិភាគគុណភាពបរិស្ថាន អាស៊ីដបរិយាកាស សារជាតុវិទ្យុសកម្ម គីមីគ្រោះថ្នាក់ បរិស្ថាន ជីវសាស្ត្រ លោហិតសាស្ត្រ បាក់តេរីសាស្ត្រ និងពន្ធុសាស្ត្រ
- រៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងគុណភាពវិភាគ ដើម្បីធានាបាននូវលទ្ធផលវិភាគដែលមានគុណភាព និងសុវត្ថិភាព
- ពិនិត្យនិងផ្តល់យោបល់បច្ចេកទេសលើការសិក្សាស្រាវជ្រាវផ្នែកគុណភាពបរិស្ថាន អាស៊ីដបរិយាកាស សារជាតុវិទ្យុសកម្ម គីមីគ្រោះថ្នាក់បរិស្ថាន ជីវសាស្ត្រ លោហិតសាស្ត្រ បាក់តេរីសាស្ត្រ និងពន្ធុសាស្ត្រ
- ផ្តល់សេវាកម្មក្នុងការចុះយកសំណាកពិសោធន៍ និងវិភាគសំណាកដល់អង្គភាពនានានៃក្រសួងបរិស្ថាន ស្ថាប័នរដ្ឋ និងវិស័យឯកជន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

## ជំពូកទី៧

## អគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិ

**មាត្រា៣១ ..**

អគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិជាសេនាធិការឱ្យក្រសួងបរិស្ថាន ក្នុងការគ្រប់គ្រងនិងសម្របសម្រួលការងារអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងប្រកបដោយចីរភាពក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា ហើយមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនានាពាក់ព័ន្ធនឹងការគ្រប់គ្រង ការការពារ ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិ នៅតាមតំបន់ការពារធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព
- រៀបចំនីតិវិធីសម្រាប់គ្រប់គ្រងនិងអភិរក្សធនធានធម្មជាតិនិងជីវៈចម្រុះនៅតាមតំបន់ការពារធម្មជាតិ ដីគោក ដីសើមទឹកសាប និងតំបន់ឆ្នេរនិងសមុទ្រ
- អប់រំនិងផ្សព្វផ្សាយអំពីច្បាប់ គោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រជាតិ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ
- ពង្រឹងនិងជំរុញការអនុវត្តច្បាប់លើការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ ដោយចុះត្រួតពិនិត្យ និងធ្វើអធិការកិច្ចលើដំណើរការគ្រប់គ្រង ការពារ និងអភិរក្សធនធានធម្មជាតិនិងជីវៈចម្រុះនៅតាមតំបន់ការពារធម្មជាតិនីមួយៗ



ៗ

- តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងតម្រង់ទិសលើការអនុវត្តគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធលើការគ្រប់គ្រងរបស់មន្ទីរបរិស្ថាននិងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ និងជំរុញការរៀបចំហេដ្ឋារចនាសម្ព័ន្ធក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិដើម្បីបម្រើផលប្រយោជន៍សេដ្ឋកិច្ចសង្គមនិងបរិស្ថាន
- ដឹកនាំការបណ្ដុះបណ្ដាលនិងសម្របសម្រួលលើកិច្ចការពារនិងអភិរក្សជីវៈចម្រុះនិងធនធានធម្មជាតិដល់មន្ត្រីប្រតិបត្តិរបស់អគ្គនាយកដ្ឋាននិងស្ថាប័ន អង្គភាពពាក់ព័ន្ធ
- ដឹកនាំនិងផ្ដល់យោបល់លើការសិក្សាស្រាវជ្រាវនិងរៀបចំចងក្រងទិន្នន័យប្រភេទសត្វនិងរុក្ខជាតិដែលជិតផុតពូជ កម្រ កំពុងរងគ្រោះ និងងាយរងគ្រោះនៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ
- ដឹកនាំសិក្សានិងរៀបចំផែនទីកំណត់និងបែងចែកតំបន់គ្រប់គ្រងនៅតាមតំបន់ការពារធម្មជាតិនីមួយៗ និងរៀបចំកំណត់ព្រំ បោះបង្គោលព្រំ និងចុះបញ្ជីដីរដ្ឋក្នុងតំបន់ការពារធម្មជាតិ
- ដឹកនាំជាំស្ដារព្រៃឈើឡើងវិញនៅទីតាំងរេចរឹលក្នុងតំបន់ការពារធម្មជាតិដើម្បីកាត់បន្ថយការបាត់បង់សេវាកម្មប្រព័ន្ធអេកូឡូស៊ី ព្រមទាំងចូលរួមការកាត់បន្ថយការប្រែប្រួលអាកាសធាតុ
- ផ្ដល់យោបល់លើទីតាំងស្នើសុំវិនិយោគនិងការប្រើប្រាស់ដីនានាក្នុងតំបន់ការពារធម្មជាតិ ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងនិងរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច
- គ្រប់គ្រងទិន្នន័យព័ត៌មានស្ដីពីការប្រើប្រាស់ដីនិងធនធានធម្មជាតិក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ
- ចូលរួមពិនិត្យ សិក្សា និងវាយតម្លៃលើហេតុប៉ះពាល់ដល់ជីវៈចម្រុះនិងធនធានធម្មជាតិពីគម្រោងវិនិយោគអភិវឌ្ឍន៍នានានៅក្នុងតំបន់ការពារធម្មជាតិ
- បំពេញភារកិច្ចជាអង្គភាពបង្គោលជាតិ ជំរុញនិងសម្របសម្រួលការអនុវត្តអនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិពាក់ពន្ធ័នឹងកិច្ចការពារនិងអភិរក្សជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ីនៃតំបន់ការពារធម្មជាតិដើម្បីឆ្លើយតបទៅនឹងកាតព្វកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា ទាំងក្នុងក្របខ័ណ្ឌតំបន់និងសកល
- សហការនិងកៀរគរជំនួយបច្ចេកទេស មូលនិធិ និងហិរញ្ញវត្ថុពីស្ថាប័នដៃគូនានាទាំងថ្នាក់ជាតិនិងអន្តរជាតិសម្រាប់ពង្រឹងការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ និងជំរុញការរៀបចំប្រមូលចំណូលពីសេវាកម្មប្រព័ន្ធអេកូឡូស៊ីតាមតំបន់ការពារធម្មជាតិ
- គ្រប់គ្រងកិច្ចការរដ្ឋបាល ផែនការ គណនេយ្យ ហិរញ្ញវត្ថុ និងមន្ត្រីជំនាញ មន្ត្រីនគរបាលយុត្តិធម៌និងភ្នាក់ងារនគរបាលយុត្តិធម៌ក្នុងក្របខ័ណ្ឌអគ្គនាយកដ្ឋាន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរដ្ឋមន្ត្រីប្រគល់ឱ្យ។

**មាត្រា៣២ ..**

អគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិមាននាយកដ្ឋានចំណុះដូចខាងក្រោម៖

- នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ
- នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងកើតទន្លេមេគង្គ
- នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាប
- នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងត្បូងបឹងទន្លេសាប

- នាយកដ្ឋានអភិរក្សតំបន់ដីសើមទឹកសាប
- នាយកដ្ឋានអភិរក្សតំបន់ឆ្នេរនិងសមុទ្រ
- នាយកដ្ឋានអធិការកិច្ចនិងពង្រឹងការអនុវត្តច្បាប់។

**មាត្រា៣៣ ._**

នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងផ្នែករដ្ឋបាលនិងសម្របសម្រួលការងារនិងដំណើរការទូទៅរបស់អគ្គនាយកដ្ឋាន
- សម្របសម្រួលការរៀបចំលិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការថវិកា ផែនការសកម្មភាព ជាមួយនាយកដ្ឋានចំណុះឱ្យអគ្គនាយកដ្ឋាន
- បំពេញការងារជាច្រកចេញចូលតែមួយសម្រាប់ការងារគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការ ពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងការអភិវឌ្ឍប្រកបដោយចីរភាព
- គ្រប់គ្រងនិងចរាចរឯកសារនិងលិខិតបទដ្ឋានគតិយុត្តរបស់អគ្គនាយកដ្ឋាន
- លើកសំណើនិងសម្របសម្រួលការងារលទ្ធកម្មសាធារណៈរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិ ឧបករណ៍ និងសម្ភារៈការិយាល័យរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងនិងកសាងសមត្ថភាពមន្ត្រីរាជការនិងបុគ្គលិកទាំងក្នុងក្របខ័ណ្ឌនិងក្រៅក្របខ័ណ្ឌរបស់ អគ្គនាយកដ្ឋាន
- គ្រប់គ្រងគណនេយ្យនិងហិរញ្ញវត្ថុរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងការងារពិធីការ កិច្ចគាំពារសង្គម និងកិច្ចសហប្រតិបត្តិការរបស់អគ្គនាយកដ្ឋាន
- រៀបចំនិងតាមដាននិងការវាយតម្លៃការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកានាយកដ្ឋានចំណុះឱ្យអគ្គនាយកដ្ឋាន
- រៀបចំកិច្ចប្រជុំនានានិងធ្វើកំណត់ហេតុនិងរបាយការណ៍កិច្ចប្រជុំរបស់អគ្គនាយកដ្ឋាន
- រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ និងរបាយការណ៍ ផែនការយុទ្ធសាស្ត្រនិងគោលនយោបាយរបស់អគ្គនាយកដ្ឋាន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

**មាត្រា៣៤ ._**

នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងកើតទន្លេមេគង្គមានតួនាទីនិងភារកិច្ចដូច ខាងក្រោម៖

- រៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំបច្ចេកទេស ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាពាក់ព័ន្ធនឹងការងារគ្រប់គ្រងតំបន់ការពារធម្មជាតិដីគោក ខាងកើតទន្លេមេគង្គ
- ពង្រឹងសមត្ថភាពជំនាញបច្ចេកទេសដល់មន្ត្រីនាយកដ្ឋាននិងមន្ត្រីឧទ្យានុរក្សសម្រាប់គាំទ្រដល់ ការងារគ្រប់គ្រងធនធានធម្មជាតិ ជីវៈចម្រុះ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ីក្នុងប្រព័ន្ធតំបន់ការពារ ធម្មជាតិ
- សម្របសម្រួលនិងសហការស្រាវជ្រាវ ទប់ស្កាត់ បង្ក្រាប និងដោះស្រាយ បទល្មើសធនធានធម្មជាតិ និងបរិស្ថានក្នុងតំបន់ការពារធម្មជាតិ

- ចុះពង្រឹងអនុវត្តលើការងារគ្រប់គ្រង អភិរក្ស ថែរក្សាធនធានធម្មជាតិ ជីវៈចម្រុះ និងចូលរួមទប់ស្កាត់ការនាំចូលប្រភេទសត្វនិងរុក្ខជាតិ រាតត្បាត ដែលគំរាមកំហែងដល់ប្រភេទដើម នៅក្នុងតំបន់ការពារធម្មជាតិ
- អប់រំផ្សព្វផ្សាយច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងកិច្ចព្រមព្រៀងនានា ដើម្បីពង្រឹងប្រសិទ្ធភាពការងារអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងប្រកបដោយចីរភាពក្នុងតំបន់ការពារធម្មជាតិ
- សិក្សារៀបចំព្រំតំបន់ការពារធម្មជាតិនិងកសាងផែនទីសម្រាប់ការកំណត់និងបែងចែកតំបន់គ្រប់គ្រង ការចុះបញ្ជីដីរដ្ឋ និងការបង្កើតតំបន់ការពារធម្មជាតិថ្មីៗបន្ថែម សម្រាប់ការពារ អភិរក្ស និងប្រើប្រាស់ប្រកបដោយចីរភាពលើធនធានធម្មជាតិនិងជីវៈចម្រុះក្នុងតំបន់ការពារធម្មជាតិ
- សិក្សាស្រាវជ្រាវនិងរៀបចំចងក្រងទិន្នន័យប្រភេទសត្វនិងរុក្ខជាតិ ពិសេស ប្រភេទធនធានសេនេទិក ដែលជិតផុតពូជ កម្រ កំពុងរងគ្រោះ និងងាយរងគ្រោះ និងរៀបចំផែនការអភិរក្សនិងស្តារឡើងវិញនៅតាមតំបន់ការពារធម្មជាតិ
- តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងតម្រង់ទិសលើការអនុវត្តគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងរបស់មន្ទីរបរិស្ថាន និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ និងជំរុញការរៀបចំហេដ្ឋារចនាសម្ព័ន្ធក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិដើម្បីបម្រើផលប្រយោជន៍សេដ្ឋកិច្ច សង្គម និងបរិស្ថាន
- កៀរគរជំនួយបច្ចេកទេស មូលនិធិ និងហិរញ្ញវត្ថុពីដៃគូអភិរក្សនិងអភិវឌ្ឍនានាទាំងថ្នាក់ជាតិនិងអន្តរជាតិ សម្រាប់ពង្រឹងការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិនិងសេវាកម្មប្រព័ន្ធអេកូឡូស៊ី ឱ្យមានចីរភាព
- បំពេញភារកិច្ចជាអង្គភាពបង្គោលជាតិក្នុងការចូលរួមអនុវត្ត អនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនឹងការអភិរក្សធនធានធម្មជាតិ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គនាយកប្រគល់ឱ្យ។

**មាត្រា៣៥ ..**

នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាបមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំបច្ចេកទេស ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាពាក់ព័ន្ធនឹងការងារគ្រប់គ្រងតំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាប
- ពង្រឹងសមត្ថភាពជំនាញបច្ចេកទេសដល់មន្ត្រីនាយកដ្ឋាននិងមន្ត្រីឧទ្យានុរក្សសម្រាប់គាំទ្រដល់ការងារគ្រប់គ្រងធនធានធម្មជាតិ ជីវៈចម្រុះ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ីក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ
- សម្របសម្រួលនិងសហការស្រាវជ្រាវ ទប់ស្កាត់ បង្ក្រាប និងដោះស្រាយ បទល្មើសធនធានធម្មជាតិ និងបរិស្ថានក្នុងតំបន់ការពារធម្មជាតិ

- ចុះពង្រឹងអនុវត្តលើការងារគ្រប់គ្រង អភិរក្ស ថែរក្សាធនធានធម្មជាតិ ជីវៈចម្រុះ និងចូលរួមទប់ស្កាត់ការនាំចូលប្រភេទសត្វនិងរុក្ខជាតិរាតត្បាត ដែលគំរាមកំហែងដល់ប្រភេទដើម នៅក្នុងតំបន់ការពារធម្មជាតិ
- អប់រំផ្សព្វផ្សាយច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងកិច្ចព្រមព្រៀងនានា ដើម្បីពង្រឹងប្រសិទ្ធភាពការងារអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងប្រកបដោយចីរភាពក្នុងតំបន់ការពារធម្មជាតិ
- សិក្សារៀបចំព្រំតំបន់ការពារធម្មជាតិនិងកសាងផែនទីសម្រាប់ការកំណត់និងបែងចែកតំបន់គ្រប់គ្រង ការចុះបញ្ជីដីរដ្ឋ និងការបង្កើតតំបន់ការពារធម្មជាតិថ្មីៗបន្ថែម សម្រាប់ការពារ អភិរក្ស និងប្រើប្រាស់ប្រកបដោយចីរភាពលើធនធានធម្មជាតិនិងជីវៈចម្រុះក្នុងតំបន់ការពារធម្មជាតិ
- សិក្សាស្រាវជ្រាវនិងរៀបចំចងក្រងទិន្នន័យប្រភេទសត្វនិងរុក្ខជាតិ ពិសេស ប្រភេទធនធានសេនេទិកដែលជិតផុតពូជ កម្រ កំពុងរងគ្រោះ និងងាយរងគ្រោះ និងរៀបចំផែនការអភិរក្សនិងស្តារឡើងវិញនៅតាមតំបន់ការពារធម្មជាតិ
- តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងតម្រង់ទិសលើការអនុវត្តគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងរបស់មន្ទីរបរិស្ថាន និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ និងជំរុញការរៀបចំហេដ្ឋារចនាសម្ព័ន្ធក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិដើម្បីបម្រើផលប្រយោជន៍សេដ្ឋកិច្ច សង្គម និងបរិស្ថាន
- កៀរគរជំនួយបច្ចេកទេស មូលនិធិ និងហិរញ្ញវត្ថុពីដៃគូអភិរក្សនិងអភិវឌ្ឍនានាទាំងថ្នាក់ជាតិនិងអន្តរជាតិ សម្រាប់ពង្រឹងការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិនិងសេវាកម្មប្រព័ន្ធអេកូឡូស៊ី ឱ្យមានចីរភាព
- បំពេញភារកិច្ចជាអង្គភាពបង្គោលជាតិ ក្នុងការចូលរួមអនុវត្ត អនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនឹងការអភិរក្សធនធានធម្មជាតិ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

**មាត្រា៣៦ ..**

នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងត្បូងបឹងទន្លេសាបមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំបច្ចេកទេស ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាពាក់ព័ន្ធនឹងការងារគ្រប់គ្រងតំបន់ការពារធម្មជាតិដីគោកខាងត្បូងបឹងទន្លេសាប
- ពង្រឹងសមត្ថភាពជំនាញបច្ចេកទេសដល់មន្ត្រីនាយកដ្ឋាននិងមន្ត្រីឧទ្យានុរក្សសម្រាប់គាំទ្រដល់ការងារគ្រប់គ្រងធនធានធម្មជាតិ ជីវៈចម្រុះ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ីក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ
- សម្របសម្រួលនិងសហការស្រាវជ្រាវ ទប់ស្កាត់ បង្ក្រាប និងដោះស្រាយបទល្មើសធនធានធម្មជាតិនិងបរិស្ថានក្នុងតំបន់ការពារធម្មជាតិ

- ចុះពង្រឹងអនុវត្តលើការងារគ្រប់គ្រង អភិរក្ស ថែរក្សាធនធានធម្មជាតិ ជីវៈចម្រុះ និងចូលរួមទប់ស្កាត់ការនាំចូលប្រភេទសត្វនិងរុក្ខជាតិរាតត្បាត ដែលគំរាមកំហែងដល់ប្រភេទដើម នៅក្នុងតំបន់ការពារធម្មជាតិ
- អប់រំផ្សព្វផ្សាយច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងកិច្ចព្រមព្រៀងនានា ដើម្បីពង្រឹងប្រសិទ្ធភាពការងារអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងប្រកបដោយចីរភាព ក្នុងតំបន់ការពារធម្មជាតិ
- សិក្សារៀបចំព្រំតំបន់ការពារធម្មជាតិនិងកសាងផែនទីសម្រាប់ការកំណត់និងបែងចែកតំបន់គ្រប់គ្រង ការចុះបញ្ជីដីរដ្ឋ និងការបង្កើតតំបន់ការពារធម្មជាតិថ្មីៗបន្ថែម សម្រាប់ការពារ អភិរក្ស និងប្រើប្រាស់ប្រកបដោយចីរភាពលើធនធានធម្មជាតិនិងជីវៈចម្រុះក្នុងតំបន់ការពារធម្មជាតិ
- សិក្សាស្រាវជ្រាវនិងរៀបចំចងក្រងទិន្នន័យប្រភេទសត្វនិងរុក្ខជាតិ ពិសេស ប្រភេទធនធានសេនេទិកដែលជិតផុតពូជ កម្រ កំពុងរងគ្រោះ និងងាយរងគ្រោះ និងរៀបចំផែនការអភិរក្សនិងស្តារឡើងវិញ នៅតាមតំបន់ការពារធម្មជាតិ
- តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងតម្រង់ទិសលើការអនុវត្តគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងរបស់មន្ទីរបរិស្ថាន និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ និងជំរុញការរៀបចំហេដ្ឋារចនាសម្ព័ន្ធក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ដើម្បីបម្រើផលប្រយោជន៍សេដ្ឋកិច្ច សង្គម និងបរិស្ថាន
- កៀរគរជំនួយបច្ចេកទេស មូលនិធិ និងហិរញ្ញវត្ថុពីដៃគូអភិរក្សនិងអភិវឌ្ឍនានាទាំងថ្នាក់ជាតិនិងអន្តរជាតិ សម្រាប់ពង្រឹងការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិនិងសេវាកម្មប្រព័ន្ធអេកូឡូស៊ី ឱ្យមានចីរភាព
- បំពេញការកិច្ចជាអង្គភាពបង្គោលជាតិ ក្នុងការចូលរួមអនុវត្តអនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនឹងការអភិរក្សធនធានធម្មជាតិ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

**មាត្រា៣៧.-**

នាយកដ្ឋានអភិរក្សតំបន់ដីសើមទឹកសាបមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំបច្ចេកទេស ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាពាក់ព័ន្ធនឹងការងារគ្រប់គ្រងតំបន់អភិរក្សដីសើមទឹកសាប
- ពង្រឹងសមត្ថភាពជំនាញបច្ចេកទេសដល់មន្ត្រីនាយកដ្ឋាននិងមន្ត្រីឧទ្យានុរក្សសម្រាប់គាំទ្រដល់ការងារគ្រប់គ្រងធនធានធម្មជាតិ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ីដីសើមទឹកសាប
- សម្របសម្រួលនិងសហការស្រាវជ្រាវ ទប់ស្កាត់ បង្ក្រាប និងដោះស្រាយបទល្មើសធនធានធម្មជាតិនិងបរិស្ថាននៅតាមតំបន់អភិរក្សដីសើមទឹកសាប
- ចុះពង្រឹងអនុវត្តលើការងារគ្រប់គ្រង អភិរក្ស ថែរក្សាធនធានធម្មជាតិ ជីវៈចម្រុះ ក្នុងតំបន់អភិរក្សដីសើមទឹកសាប និងចូលរួមទប់ស្កាត់ការនាំចូលប្រភេទសត្វនិងរុក្ខជាតិរាតត្បាត ដែលគំរាមកំហែងដល់ប្រភេទដើម នៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ

- អប់រំផ្សព្វផ្សាយច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងកិច្ចព្រមព្រៀងនានា ដើម្បីពង្រឹងប្រសិទ្ធភាពការងារអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិតំបន់ដីសើមទឹកសាបឱ្យបានសមស្របនិងប្រកបដោយចីរភាព
- សិក្សារៀបចំព្រំតំបន់ការពារធម្មជាតិ និងកសាងផែនទីសម្រាប់ការកំណត់និងបែងចែកតំបន់គ្រប់គ្រង ការចុះបញ្ជីដីរដ្ឋ និងការបង្កើតតំបន់ការពារធម្មជាតិដីសើមទឹកសាបថ្មីៗបន្ថែម សម្រាប់ការពារអភិរក្សនិងប្រើប្រាស់ប្រកបដោយចីរភាពលើធនធានធម្មជាតិនិងជីវៈចម្រុះក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ
- សិក្សាស្រាវជ្រាវនិងរៀបចំចងក្រងទិន្នន័យប្រភេទសត្វនិងរុក្ខជាតិ ដែលជិតផុតពូជ កម្រ កំពុងរងគ្រោះ និងងាយរងគ្រោះ និងរៀបចំផែនការអភិរក្សនិងស្ដារឡើងវិញ នៅតាមតំបន់អភិរក្សដីសើមទឹកសាប
- តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងតម្រង់ទិសលើការអនុវត្តគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងរបស់មន្ទីរបរិស្ថាន និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ និងជំរុញការរៀបចំហេដ្ឋារចនាសម្ព័ន្ធក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ដើម្បីបម្រើផលប្រយោជន៍សេដ្ឋកិច្ច សង្គម និងបរិស្ថាន
- កៀរគរជំនួយបច្ចេកទេស មូលនិធិ និងហិរញ្ញវត្ថុពីដៃគូអភិរក្សនិងអភិវឌ្ឍនានាទាំងថ្នាក់ជាតិនិងអន្តរជាតិ សម្រាប់ពង្រឹងការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិនិងសេវាកម្មប្រព័ន្ធអេកូឡូស៊ី ឱ្យមានចីរភាព
- បំពេញភារកិច្ចជាអង្គភាពបង្គោលជាតិ ក្នុងការចូលរួមអនុវត្តអនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនឹងការអភិរក្សតំបន់ដីសើមទឹកសាប
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តការកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

**មាត្រា៣៨ ..**

នាយកដ្ឋានអភិរក្សតំបន់ឆ្នេរនិងសមុទ្រមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំបច្ចេកទេស ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាពាក់ព័ន្ធនឹងការងារគ្រប់គ្រងតំបន់អភិរក្សឆ្នេរនិងសមុទ្រ
- ពង្រឹងសមត្ថភាពជំនាញបច្ចេកទេសដល់មន្ត្រីនាយកដ្ឋាននិងមន្ត្រីឧទ្យានុរក្សសម្រាប់គាំទ្រដល់ការងារគ្រប់គ្រងធនធានធម្មជាតិនិងសេវាកម្មប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរនិងសមុទ្រ
- សម្របសម្រួលនិងសហការស្រាវជ្រាវ ទប់ស្កាត់ បង្ក្រាប និងដោះស្រាយបទល្មើសធនធានធម្មជាតិនិងបរិស្ថាននៅតាមតំបន់អភិរក្សឆ្នេរនិងសមុទ្រ
- ចុះពង្រឹងអនុវត្តលើការងារគ្រប់គ្រង អភិរក្ស ថែរក្សាធនធានធម្មជាតិ ជីវៈចម្រុះ ក្នុងតំបន់អភិរក្សឆ្នេរនិងសមុទ្រ និងចូលរួមទប់ស្កាត់ការនាំចូលប្រភេទសត្វនិងរុក្ខជាតិរាតត្បាត ដែលគំរាមកំហែងដល់ប្រភេទដើម នៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ
- អប់រំផ្សព្វផ្សាយច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងកិច្ចព្រមព្រៀងនានា ដើម្បីពង្រឹងប្រសិទ្ធភាពការងារអភិរក្ស ជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិ នៅតំបន់ឆ្នេរនិងសមុទ្រឱ្យបានសមស្របនិងប្រកបដោយចីរភាព

- សិក្សារៀបចំព្រំតំបន់ការពារធម្មជាតិនិងកសាងផែនទីសម្រាប់ការកំណត់និងបែងចែកតំបន់គ្រប់គ្រង ការចុះបញ្ជីដីរដ្ឋ និងការបង្កើតតំបន់ការពារធម្មជាតិថ្មីៗបន្ថែម សម្រាប់ការពារ អភិរក្ស និងប្រើប្រាស់ប្រកបដោយចីរភាព លើធនធានធម្មជាតិនិងជីវៈចម្រុះក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ
- សិក្សាស្រាវជ្រាវនិងរៀបចំចងក្រងទិន្នន័យប្រភេទសត្វនិងរុក្ខជាតិ ដែលជិតផុតពូជ កម្រ កំពុងរងគ្រោះ និងងាយរងគ្រោះ និងរៀបចំផែនការអភិរក្សនិងស្ដារឡើងវិញ នៅតាមតំបន់អភិរក្សឆ្នេរនិងសមុទ្រ
- តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងតម្រង់ទិស លើការអនុវត្តគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងរបស់មន្ទីរបរិស្ថាន និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ និងជំរុញការរៀបចំហេដ្ឋារចនាសម្ព័ន្ធក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ដើម្បីបម្រើផលប្រយោជន៍សេដ្ឋកិច្ច សង្គម និងបរិស្ថាន
- កៀរគរជំនួយបច្ចេកទេស មូលនិធិ និងហិរញ្ញវត្ថុពីដៃគូអភិរក្សនិងអភិវឌ្ឍនានាទាំងថ្នាក់ជាតិនិងអន្តរជាតិ សម្រាប់ពង្រឹងការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិនិងសេវាកម្មប្រព័ន្ធអេកូឡូស៊ី ឱ្យមានចីរភាព
- បំពេញភារកិច្ចជាអង្គភាពបង្គោលជាតិ ក្នុងការចូលរួមអនុវត្តអនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនឹងការអភិរក្សតំបន់ឆ្នេរនិងសមុទ្រ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

**មាត្រា៣៩ .-**

នាយកដ្ឋានអធិការកិច្ចនិងពង្រឹងការអនុវត្តច្បាប់មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំបច្ចេកទេសពាក់ព័ន្ធ និងការត្រួតពិនិត្យ ដឹកនាំអធិការកិច្ចលើការងារគ្រប់គ្រងតំបន់ការពារធម្មជាតិ និងរៀបចំផែនការសកម្មភាព និងផែនការថវិកា
- រៀបចំនីតិវិធីអនុវត្តសម្រាប់ការធ្វើអធិការកិច្ចលើបទល្មើសធនធានធម្មជាតិ នៅតាមទីតាំងសកម្មភាពផលិតកម្ម អាជីវកម្ម និងសេវាកម្មនានាក្នុងប្រព័ន្ធអេកូឡូស៊ីនៃតំបន់ការពារធម្មជាតិ
- បណ្តុះបណ្តាលសមត្ថភាពមន្ត្រីជំនាញ ព្រមទាំងភាគីពាក់ព័ន្ធក្នុងការចូលរួមធ្វើអធិការកិច្ច ពិសេសពង្រឹងជំនាញអនុវត្តច្បាប់ដល់មន្ត្រីនគរបាលយុត្តិធម៌និងភ្នាក់ងារនគរបាលយុត្តិធម៌ ឱ្យមានសមត្ថភាពនិងប្រសិទ្ធភាពសម្រាប់កិច្ចការពារនិងអភិរក្សធនធានក្នុងតំបន់ការពារធម្មជាតិ
- ផ្សព្វផ្សាយនិងអប់រំ ច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ
- ដឹកនាំមន្ត្រីនគរបាលយុត្តិធម៌និងភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងការស្រាវជ្រាវនិងប្រមូលចងក្រងទិន្នន័យបទល្មើសធនធានធម្មជាតិ ការពិន័យអន្តរការណ៍ ការកសាងសំណុំរឿងបទល្មើសធនធានធម្មជាតិ ដើម្បីពិនិត្យតាមដាននិងចាត់វិធានការបន្ត
- ដឹកនាំលើការគ្រប់គ្រងនិងការប្រើប្រាស់អាវុធជាតិផ្ទុះរបស់មន្ត្រីនគរបាលយុត្តិធម៌និងភ្នាក់ងារនគរបាលយុត្តិធម៌

- ដឹកនាំនិងសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដើម្បីធ្វើអធិការកិច្ច ដោះស្រាយវិវាទ និងបណ្តឹងលើទីតាំង ឬគោលដៅសកម្មភាពផលិតកម្ម អាជីវកម្មនិងសេវាកម្មនានា ដែលមានផលប៉ះពាល់ដល់ប្រព័ន្ធសេវាកម្មអេកូឡូស៊ីក្នុងតំបន់ការពារធម្មជាតិ
- សហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពមានសមត្ថកិច្ចក្នុងការធ្វើអធិការកិច្ចនិងពង្រឹងការអនុវត្តច្បាប់លើបទល្មើសធនធានធម្មជាតិ
- រៀបចំសំណុំបែបបទពាក់ព័ន្ធនឹងបទល្មើសធនធានធម្មជាតិដើម្បីចាត់វិធានការរដ្ឋបាល វិធានការពិន័យអន្តរការណ៍ ឬបន្តនីតិវិធីបណ្តឹងទៅតុលាការ ក្នុងនាមជាមន្ត្រីនគរបាលយុត្តិធម៌ ស្របតាមច្បាប់ជាធរមាន
- តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងតម្រង់ទិសលើការអនុវត្តច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងរបស់មន្ទីរបរិស្ថាន និងការអនុវត្តមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ
- កៀរគរជំនួយបច្ចេកទេស មូលនិធិ និងហិរញ្ញវត្ថុពីដៃគូអភិរក្សនិងអភិវឌ្ឍនានាទាំងថ្នាក់ជាតិនិងអន្តរជាតិ សម្រាប់គាំទ្រដល់សកម្មភាពអនុវត្តច្បាប់របស់មន្ត្រីនគរបាលយុត្តិធម៌និងភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងគោលដៅកិច្ចការពារនិងអភិរក្សប្រព័ន្ធតំបន់ការពារធម្មជាតិឱ្យមានចីរភាព
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

## ជំពូកទី៨
## អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន

**មាត្រា៤០ .-**

អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋានជាសេនាធិការឱ្យក្រសួងបរិស្ថានក្នុងការគ្រប់គ្រង និងសម្របសម្រួលការងារអភិវឌ្ឍសហគមន៍មូលដ្ឋាននិងសហគមន៍តំបន់ការពារធម្មជាតិ ដើម្បីរួមចំណែកក្នុងការគ្រប់គ្រងការពារនិងអភិរក្សធនធានធម្មជាតិ ជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី នៅក្នុងតំបន់ការពារធម្មជាតិ ហើយមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំនិងអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពពាក់ព័ន្ធនឹងការងារអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន សហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ជនជាតិដើមភាគតិចដោយសហការជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ
- រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងនិងការអភិវឌ្ឍសហគមន៍មូលដ្ឋាន សហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ជនជាតិដើមភាគតិច
- គ្រប់គ្រងកិច្ចការរដ្ឋបាល ផែនការ ហិរញ្ញវត្ថុ គណនេយ្យ និងមន្ត្រីរបស់អគ្គនាយកដ្ឋាន
- ដឹកនាំការសិក្សាស្រាវជ្រាវការរៀបចំបង្កើតនិងការគ្រប់គ្រងសហគមន៍មូលដ្ឋាន
- ដឹកនាំការសិក្សាស្រាវជ្រាវការរៀបចំបង្កើតនិងការគ្រប់គ្រងតំបន់បេតិកភណ្ឌធម្មជាតិ
- សម្របសម្រួលនិងសហការជាមួយក្រសួង ស្ថាប័ន អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជនក្នុងការគ្រប់គ្រងគម្រោងវិនិយោគទេសចរណ៍ធម្មជាតិ

- សម្របសម្រួលនិងសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពជំនាញពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍនិងវិស័យឯកជនក្នុងការលើកកម្ពស់សកម្មភាពទេសចរណ៍ធម្មជាតិ នៅក្នុងសហគមន៍មូលដ្ឋាន និងសហគមន៍តំបន់ការពារធម្មជាតិ
- សហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិលើការអប់រំ បណ្តុះបណ្តាល និងផ្សព្វផ្សាយអំពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងនិងការអភិវឌ្ឍសហគមន៍មូលដ្ឋាន សហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ជនជាតិដើមភាគតិច
- សម្របសម្រួលនិងសហការក្នុងការអនុវត្តសកម្មភាពពាក់ព័ន្ធនឹងការលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍ មូលដ្ឋាននិងសហគមន៍តំបន់ការពារធម្មជាតិ រួមទាំងការថែរក្សាប្រពៃណីនិងទំនៀមទម្លាប់របស់សហគមន៍ជនជាតិដើមភាគតិច
- ស្វែងរកការគាំទ្រផ្នែកបច្ចេកទេសនិងកៀរគរធនធានហិរញ្ញវត្ថុទាំងកម្រិតជាតិនិងអន្តរជាតិ សម្រាប់ការអភិវឌ្ឍសហគមន៍មូលដ្ឋាន សហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ជនជាតិដើមភាគតិច និងការគ្រប់គ្រងតំបន់បេតិកភណ្ឌធម្មជាតិ
- បំពេញកិច្ចការជំនាញតាមកិច្ចព្រមព្រៀង អនុសញ្ញា និងពិធីសារអន្តរជាតិនានាពាក់ព័ន្ធនឹងសហគមន៍មូលដ្ឋាន ទេសចរណ៍ធម្មជាតិ និងកិច្ចការពារនិងការអភិរក្ស តំបន់បេតិកភណ្ឌធម្មជាតិដែលព្រះរាជាណាចក្រកម្ពុជាជាសមាជិក
- សហការជាមួយអង្គភាពពាក់ព័ន្ធក្នុងការទប់ស្កាត់និងបង្ក្រាបបទល្មើសធនធានធម្មជាតិនៅក្នុងតំបន់សហគមន៍តំបន់ការពារធម្មជាតិ
- សម្របសម្រួលនិងសហការជាមួយក្រសួងស្ថាប័ននិងអង្គភាពជំនាញពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ ក្នុងការរៀបចំយន្តការអភិរក្សតំបន់បេតិកភណ្ឌវប្បធម៌និងធម្មជាតិរបស់សហគមន៍ជនជាតិដើមភាគតិចនៅក្នុងតំបន់ការពារធម្មជាតិ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរដ្ឋមន្ត្រីប្រគល់ឱ្យ។

**មាត្រា៤១ ..**

អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋានមាននាយកដ្ឋានចំណុះដូចខាងក្រោម៖

- នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ
- នាយកដ្ឋានជីវភាពសហគមន៍
- នាយកដ្ឋានតំបន់បេតិកភណ្ឌ
- នាយកដ្ឋានទេសចរណ៍ធម្មជាតិ។

**មាត្រា៤២ ..**

នាយកដ្ឋានរដ្ឋបាល ផែនការនិងហិរញ្ញវត្ថុមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងផ្នែករដ្ឋបាលនិងសម្របសម្រួលការងារនិងដំណើរការទូទៅរបស់អគ្គនាយកដ្ឋាន
- សម្របសម្រួលការរៀបចំលិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការថវិកា ផែនការសកម្មភាពជាមួយនាយកដ្ឋានចំណុះឱ្យអគ្គនាយកដ្ឋាន

- បំពេញការងារជាច្រកចេញចូលតែមួយសម្រាប់ការងារគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងការអភិវឌ្ឍប្រកបដោយចីរភាព
- គ្រប់គ្រងនិងចរាចរឯកសារនិងលិខិតបទដ្ឋានគតិយុត្តរបស់អគ្គនាយកដ្ឋាន
- លើកសំណើនិងសម្របសម្រួលការងារលទ្ធកម្មសាធារណៈរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិ ឧបករណ៍ និងសម្ភារៈការិយាល័យរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងនិងកសាងសមត្ថភាពមន្ត្រីរាជការនិងបុគ្គលិកទាំងក្នុងក្របខ័ណ្ឌនិងក្រៅក្របខ័ណ្ឌរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងគណនេយ្យនិងហិរញ្ញវត្ថុរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងការងារពិធីការ កិច្ចគាំពារសង្គម និងកិច្ចសហប្រតិបត្តិការរបស់អគ្គនាយកដ្ឋាន
- រៀបចំនិងតាមដាននិងវាយតម្លៃការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកានាយកដ្ឋានចំណុះឱ្យអគ្គនាយកដ្ឋាន
- រៀបចំកិច្ចប្រជុំនានានិងធ្វើកំណត់ហេតុនិងរបាយការណ៍កិច្ចប្រជុំរបស់អគ្គនាយកដ្ឋាន
- រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ និងរបាយការណ៍ផែនការយុទ្ធសាស្ត្រនិងគោលនយោបាយរបស់អគ្គនាយកដ្ឋាន
- ទទួលអនុវត្តការកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

**មាត្រា៤៣ ._**

នាយកដ្ឋានជីវភាពសហគមន៍មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការគ្រប់គ្រង ផែនការសកម្មភាព និងគោលការណ៍ណែនាំបច្ចេកទេសសម្រាប់ការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិស្របតាមគោលការណ៍ច្បាប់
- សិក្សាស្រាវជ្រាវ រៀបចំបង្កើត និងគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ
- រៀបចំកិច្ចព្រមព្រៀង ផែនការគ្រប់គ្រង និងកម្មវិធីអភិវឌ្ឍន៍សហគមន៍តំបន់ការពារធម្មជាតិ
- សម្របសម្រួលការរៀបចំលក្ខន្តិកៈនិងការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិតាមអាណត្តិ
- រៀបចំកម្មវិធីបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ការគ្រប់គ្រងធនធានធម្មជាតិក្នុងសហគមន៍តំបន់ការពារធម្មជាតិ
- ការពារ អភិរក្ស និងស្តារធនធានធម្មជាតិនិងជីវៈចម្រុះ ក្នុងសហគមន៍តំបន់ការពារធម្មជាតិ ដោយសហការជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ
- រៀបចំនិងអនុវត្តផែនការលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍តំបន់ការពារធម្មជាតិនិងសហគមន៍មូលដ្ឋាន
- សម្របសម្រួល ជំរុញ និងលើកទឹកចិត្តដល់ប្រជាសហគមន៍តំបន់ការពារធម្មជាតិក្នុងការបង្កើតនិងផ្សារភ្ជាប់ផលិតផលសហគមន៍ទៅនឹងទីផ្សារ
- បង្កើតកម្មវិធីអប់រំនិងផ្សព្វផ្សាយដល់សាធារណជន ដើម្បីបង្កើនការយល់ដឹងនិងចូលរួមថែរក្សាការពារធនធានធម្មជាតិនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ

- សម្របសម្រួលដោះស្រាយទំនាស់ដែលកើតមាននៅក្នុងដីធ្លីដែលគ្រប់គ្រងដោយសហគមន៍តំបន់ការពារធម្មជាតិ
- សម្របសម្រួលការអនុវត្តកិច្ចព្រមព្រៀង អនុសញ្ញា និងពិធីសារពាក់ព័ន្ធនឹងសហគមន៍តំបន់ការពារធម្មជាតិ
- កៀរគរជំនួយហិរញ្ញវត្ថុនិងបច្ចេកទេសពីដៃគូអភិវឌ្ឍនានា សម្រាប់គាំទ្រដល់ការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិប្រកបដោយប្រសិទ្ធភាព
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

**មាត្រា៤៤ ..**

នាយកដ្ឋានតំបន់បេតិកភណ្ឌមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការគ្រប់គ្រង ផែនការសកម្មភាពនិងគោលការណ៍ណែនាំបច្ចេកទេសសម្រាប់គ្រប់គ្រងតំបន់បេតិកភណ្ឌធម្មជាតិស្របតាមគោលការណ៍ច្បាប់ជាតិនិងអន្តរជាតិ
- សិក្សាស្រាវជ្រាវនិងរៀបចំសំណើក្នុងការបង្កើតតំបន់បេតិកភណ្ឌធម្មជាតិនៅក្នុងនិងក្រៅតំបន់ការពារធម្មជាតិដោយសហការជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធ
- សម្របសម្រួលនិងសហការក្នុងការសិក្សាស្រាវជ្រាវចងក្រងឯកសារបេតិកភណ្ឌធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិ
- រៀបចំកំណត់ព្រំប្រទល់ តំបន់គ្រប់គ្រង និងធ្វើផែនទីសម្រាប់តំបន់បេតិកភណ្ឌដោយសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ
- ពិនិត្យ តាមដាន និងរាយការណ៍អំពីស្ថានភាពគ្រប់គ្រងតំបន់បេតិកភណ្ឌធម្មជាតិ
- ការពារ អភិរក្ស និងស្តារធនធានក្នុងតំបន់បេតិកភណ្ឌធម្មជាតិឱ្យមាននិរន្តរភាពដោយសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ
- ចូលរួមថែរក្សាប្រពៃណីទំនៀមទម្លាប់និងចូលរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍ជនជាតិដើមភាគតិចដែលរស់នៅក្នុងនិងក្បែរតំបន់ការពារធម្មជាតិ
- កៀរគរជំនួយហិរញ្ញវត្ថុនិងបច្ចេកទេសដើម្បីគាំទ្រដល់ការគ្រប់គ្រងតំបន់បេតិកភណ្ឌធម្មជាតិប្រកបដោយនិរន្តរភាព
- សម្របសម្រួលនិងសហការក្នុងការរៀបចំការគ្រប់គ្រងតំបន់អភិរក្សបេតិកភណ្ឌវប្បធម៌និងបេតិកភណ្ឌធម្មជាតិរបស់សហគមន៍ជនជាតិដើមភាគតិចនៅក្នុងតំបន់ការពារធម្មជាតិ
- តាមដាននិងត្រួតពិនិត្យការអនុវត្តលិខិតបទដ្ឋានគតិយុត្តនិងគោលការណ៍ណែនាំបច្ចេកទេសក្នុងការគ្រប់គ្រងតំបន់បេតិកភណ្ឌធម្មជាតិ
- ធ្វើការអប់រំផ្សព្វផ្សាយដល់សាធារណជនក្នុងការចូលរួមថែរក្សានិងការពារធនធានធម្មជាតិក្នុងតំបន់បេតិកភណ្ឌធម្មជាតិ
- សម្របសម្រួល រៀបចំ និងអនុវត្តគោលការណ៍ណែនាំនានាសម្រាប់កិច្ចការអភិរក្សតំបន់បេតិកភណ្ឌធម្មជាតិ រួមទាំងសកម្មភាពទេសចរណ៍វប្បធម៌និងធម្មជាតិ

- ចូលរួមសហការក្នុងការស្រាវជ្រាវ តាមដាន ទប់ស្កាត់ និងបង្ក្រាបបទល្មើសពាក់ព័ន្ធនឹងបេតិកភណ្ឌក្នុងតំបន់ការពារធម្មជាតិ
- សម្របសម្រួលការអនុវត្តកិច្ចព្រមព្រៀង អនុសញ្ញា និងពិធីសារពាក់ព័ន្ធនឹងតំបន់បេតិកភណ្ឌធម្មជាតិ
- សម្របសម្រួល រៀបចំ និងបង្កើតមជ្ឈមណ្ឌលអភិរក្សវប្បធម៌សហគមន៍ជនជាតិដើមភាគតិចនៅក្នុងតំបន់ការពារធម្មជាតិ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

**មាត្រា៤៥ .-**

នាយកដ្ឋានទេសចរណ៍ធម្មជាតិមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការគ្រប់គ្រង ផែនការសកម្មភាព និងគោលការណ៍ណែនាំបច្ចេកទេសសម្រាប់គ្រប់គ្រងគម្រោងវិនិយោគអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិនិងគម្រោងអភិវឌ្ឍន៍សហគមន៍ទេសចរណ៍ធម្មជាតិ
- សិក្សា សម្របសម្រួល និងគ្រប់គ្រងគម្រោងវិនិយោគអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិនិងគម្រោងអភិវឌ្ឍន៍សហគមន៍ទេសចរណ៍ធម្មជាតិដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- សម្របសម្រួលការរៀបចំបង្កើត ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកញ្ចប់ទេសចរណ៍ធម្មជាតិ ដើម្បីទាក់ទាញភ្ញៀវជាតិនិងអន្តរជាតិមកលេងកម្សាន្តនៅក្នុងតំបន់ការពារធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- សម្របសម្រួលសិក្សាកំណត់ទីតាំងនិងបោះបង្គោលព្រំប្រទល់ដី សម្រាប់គម្រោងវិនិយោគអភិវឌ្ឍទេសចរណ៍ធម្មជាតិ នៅក្នុងតំបន់ការពារធម្មជាតិ
- រៀបចំនិងពិនិត្យតាមដានការអនុវត្តកិច្ចសន្យាជួលទីតាំងដីសម្រាប់គម្រោងវិនិយោគអភិវឌ្ឍទេសចរណ៍ធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ
- តាមដាននិងត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តគម្រោងវិនិយោគអភិវឌ្ឍទេសចរណ៍ធម្មជាតិនិងគម្រោងអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិរបស់សហគមន៍
- ពិនិត្យនិងកែសម្រួលផែនការមេនិងកម្មវិធីអភិវឌ្ឍន៍សម្រាប់គម្រោងវិនិយោគអភិវឌ្ឍទេសចរណ៍ធម្មជាតិ
- សម្របសម្រួលដោះស្រាយទំនាស់និងភាពមិនប្រក្រតីផ្សេងៗដែលកើតឡើងពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីនិងគម្រោងវិនិយោគអភិវឌ្ឍទេសចរណ៍ធម្មជាតិ
- រៀបចំយន្តការប្រមូលចំណូលពីសេវាកម្មទេសចរណ៍ធម្មជាតិសម្រាប់ចូលរួមទ្រទ្រង់សកម្មភាពអភិរក្សតំបន់ការពារធម្មជាតិ
- កៀរគរជំនួយហិរញ្ញវត្ថុនិងបច្ចេកទេសពីដៃគូអភិវឌ្ឍនិងវិស័យឯកជននានាសម្រាប់គាំទ្រដល់ការអភិវឌ្ឍទេសចរណ៍ធម្មជាតិប្រកបដោយប្រសិទ្ធភាព
- សិក្សារៀបចំបង្កើតផលិតផលទេសចរណ៍ក្នុងតំបន់ការពារធម្មជាតិ និងការពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិនិងសហគមន៍មូលដ្ឋានលើការអភិវឌ្ឍទេសចរណ៍ធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័ននិងដៃគូអភិវឌ្ឍពាក់ព័ន្ធ



ြ

- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តការកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

## ជំពូកទី៩
## អគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន

**មាត្រា៤៦ ..**

អគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថានជាសេនាធិការឱ្យក្រសួងបរិស្ថាន ក្នុងការគ្រប់គ្រងទិន្នន័យបរិស្ថាននិងដឹកនាំសម្របសម្រួលការងារអប់រំនិងការផ្សព្វផ្សាយព័ត៌មានបរិស្ថាន ព្រមទាំងចាត់ចែងរៀបចំព្រឹត្តិការណ៍បរិស្ថានសំខាន់ៗ ហើយមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ផែនការថវិកា គោលការណ៍ណែនាំ និងកម្មវិធីនានាពាក់ព័ន្ធនឹងការគ្រប់គ្រងទិន្នន័យ ការអប់រំ និងការផ្សព្វផ្សាយព័ត៌មានបរិស្ថាន ព្រមទាំងការវាយតម្លៃការប្រតិបត្តិមេត្រីបរិស្ថាន
- ប្រមូល វិភាគ ចងក្រង និងគ្រប់គ្រងព័ត៌មាននិងទិន្នន័យបរិស្ថាន រួមទាំងកសាងនិងគ្រប់គ្រងប្រព័ន្ធប្រមូលផ្តុំទិន្នន័យបរិស្ថាន
- រៀបចំនិងគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបរិស្ថាន
- រៀបចំរបាយការណ៍ស្តីពីស្ថានភាពបរិស្ថានជាតិរៀងរាល់៤(បួន)ឆ្នាំម្តង ដោយមានការសហការនិងសម្របសម្រួលជាមួយស្ថាប័ននិងអង្គភាពពាក់ព័ន្ធថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- លើកកម្ពស់ការយល់ដឹងអំពីបរិស្ថានដល់សាធារណជន តាមរយៈការបញ្ជ្រាបការអប់រំបរិស្ថានក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ ការផ្សព្វផ្សាយចំណេះដឹងអំពីបរិស្ថាន និងការលើកទឹកចិត្តការប្រតិបត្តិមេត្រីបរិស្ថាន
- ផលិតនិងផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានស្តីពីសកម្មភាព ស្ថានភាព និងសមិទ្ធផលទាក់ទងនឹងកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ និងការរស់នៅប្រកបដោយចីរភាព
- រៀបចំនិងចាត់ចែងព្រឹត្តិការណ៍ជាសាធារណៈពាក់ព័ន្ធនឹងសកម្មភាពផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានស្តីពីបរិស្ថាន
- សម្របសម្រួលនិងសហការជាមួយអង្គភាពនានាក្រោមឱវាទក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងវិស័យឯកជនដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការនិងបង្កើនប្រសិទ្ធភាពការងារគ្រប់គ្រងទិន្នន័យបរិស្ថាននិងការងារអប់រំផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានស្តីពីបរិស្ថាន
- គ្រប់គ្រងកិច្ចការរដ្ឋបាល ផែនការ ហិរញ្ញវត្ថុ គណនេយ្យ មន្ត្រីរាជការ និងបុគ្គលិកក្នុងអគ្គនាយកដ្ឋាន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តការកិច្ចផ្សេងៗទៀតដែលរដ្ឋមន្ត្រីប្រគល់ឱ្យ។

**មាត្រា៤៧ ..**

អគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថានមាននាយកដ្ឋានចំណុះដូចខាងក្រោម៖

- នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ
- នាយកដ្ឋានសេវាកម្មព័ត៌មានភូមិសាស្ត្រ

- នាយកដ្ឋានអប់រំបរិស្ថាន
- នាយកដ្ឋានព័ត៌មាននិងផ្សព្វផ្សាយបរិស្ថាន
- នាយកដ្ឋានរង្វាន់និងលើកទឹកចិត្ត។

**មាត្រា៤៨ ..**

នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងផ្នែករដ្ឋបាលនិងសម្របសម្រួលការងារនិងដំណើរការទូទៅរបស់អគ្គនាយកដ្ឋាន
- សម្របសម្រួលការរៀបចំលិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការថវិកា ផែនការសកម្មភាពជាមួយនាយកដ្ឋានចំណុះឱ្យអគ្គនាយកដ្ឋាន
- បំពេញការងារជាច្រកចេញចូលតែមួយសម្រាប់ការងារគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងការអភិវឌ្ឍប្រកបដោយចីរភាព
- គ្រប់គ្រងនិងចរាចរឯកសារនិងលិខិតបទដ្ឋានគតិយុត្តរបស់អគ្គនាយកដ្ឋាន
- លើកសំណើនិងសម្របសម្រួលការងារលទ្ធកម្មសាធារណៈរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិ ឧបករណ៍ និងសម្ភារៈការិយាល័យរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងនិងកសាងសមត្ថភាពមន្ត្រីរាជការនិងបុគ្គលិកទាំងក្នុងក្របខ័ណ្ឌនិងក្រៅក្របខ័ណ្ឌរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងគណនេយ្យនិងហិរញ្ញវត្ថុរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងការងារពិធីការ កិច្ចគាំពារសង្គម និងកិច្ចសហប្រតិបត្តិការរបស់អគ្គនាយកដ្ឋាន
- រៀបចំនិងតាមដាននិងការវាយតម្លៃការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពនិងផែនការថវិកានាយកដ្ឋានចំណុះឱ្យអគ្គនាយកដ្ឋាន
- រៀបចំកិច្ចប្រជុំនានានិងធ្វើកំណត់ហេតុនិងរបាយការណ៍កិច្ចប្រជុំរបស់អគ្គនាយកដ្ឋាន
- រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ និងរបាយការណ៍ផែនការយុទ្ធសាស្ត្រនិងគោលនយោបាយរបស់អគ្គនាយកដ្ឋាន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

**មាត្រា៤៩ ..**

នាយកដ្ឋានសេវាកម្មព័ត៌មានភូមិសាស្ត្រមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ផែនការថវិកា និងគោលការណ៍ណែនាំបច្ចេកទេសពាក់ព័ន្ធនឹងការងារគ្រប់គ្រងទិន្នន័យបរិស្ថាន ការផ្តល់សេវាកម្មព័ត៌មានភូមិសាស្ត្រ និងការរៀបចំរបាយការណ៍ស្តីពីស្ថានភាពបរិស្ថាន
- កសាង ប្រមូល វិភាគ ចងក្រង និងគ្រប់គ្រងប្រព័ន្ធទិន្នន័យព័ត៌មានភូមិសាស្ត្រនិងរូបភាពពីលើអាកាសស្តីពីគុណភាពបរិស្ថាន ធនធានធម្មជាតិ ជីវៈចម្រុះ និងការអភិវឌ្ឍប្រកបដោយចីរភាព ព្រមទាំងព័ត៌មានដទៃទៀតពាក់ព័ន្ធនឹងបរិស្ថាន
- ផលិតនិងផ្តល់សេវាកម្មព័ត៌មានភូមិសាស្ត្រ រួមទាំងផែនទី ដើម្បីគាំទ្រដល់កិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ ការអភិវឌ្ឍប្រកបដោយចីរភាព និងកិច្ចការពាក់ព័ន្ធនានា

- សិក្សា ស្រាវជ្រាវ និងវិភាគអំពីការប្រែប្រួលធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ តាមរយៈការអភិវឌ្ឍកម្មវិធីស្ដីពីវិធីសាស្ត្របកស្រាយព័ត៌មានភូមិសាស្ត្រ
- សិក្សានិងវាយតម្លៃការប្រែប្រួលសន្និធិកាបូនពីធនធានព្រៃឈើ
- សិក្សា រៀបចំបង្កើត និងសម្របសម្រួលការអនុវត្តវិធីសាស្ត្រសារពើភណ្ឌធនធានព្រៃឈើនិងសន្និធិកាបូន រួមទាំងបង្កើតមេគុណបំភាយនិងស្រូបនៃកាបូនព្រៃឈើ
- សម្របសម្រួលការកំណត់និងចងក្រងសូចនាករសម្រាប់តាមដានស្ថានភាពធនធានធម្មជាតិនិងគុណភាពបរិស្ថាន
- សម្របសម្រួលជាមួយអង្គភាពនានាក្រោមឱវាទក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងវិស័យឯកជន ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការនិងបង្កើនប្រសិទ្ធភាពការងារគ្រប់គ្រងទិន្នន័យបរិស្ថាន
- កសាងនិងពង្រឹងសមត្ថភាពជំនាញប្រព័ន្ធព័ត៌មានភូមិសាស្ត្រទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

**មាត្រា៥០ ..**

នាយកដ្ឋានអប់រំបរិស្ថានមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ផែនការថវិកា និងគោលការណ៍ណែនាំបច្ចេកទេសពាក់ព័ន្ធនឹងការងារអប់រំបរិស្ថាន
- បញ្ជ្រាបការអប់រំបរិស្ថានទៅក្នុងកម្មវិធីអប់រំនៅគ្រប់លំដាប់ថ្នាក់ ទាំងការអប់រំក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ និងការផ្សព្វផ្សាយចំណេះដឹងបរិស្ថាន ដើម្បីសម្រេចបាននូវការងារអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព
- លើកកម្ពស់ការប្រឡងប្រណាំងបរិស្ថាន មានដូចជាសាលាមេត្រីបរិស្ថាន អារាមមេត្រីបរិស្ថាន សកម្មភាពបរិស្ថាននានាជាដើម
- សម្របសម្រួលការងារអភិបាលកិច្ចអប់រំបរិស្ថានជាមួយភាគីពាក់ព័ន្ធ
- ពង្រឹងសមត្ថភាពជំនាញអប់រំបរិស្ថានទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងកសាងបណ្ដាញអ្នកបន្តវេនអប់រំបរិស្ថាន
- កសាងនិងគ្រប់គ្រងមជ្ឈមណ្ឌលធនធានសម្រាប់លើកកម្ពស់ការយល់ដឹងអំពីបរិស្ថានដល់សាធារណជន
- សម្របសម្រួលការផលិតឯកសារនិងសម្ភារៈឧបទេសបរិស្ថាន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

**មាត្រា៥១ ..**

នាយកដ្ឋានព័ត៌មាននិងផ្សព្វផ្សាយបរិស្ថានមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ផែនការថវិកា គោលការណ៍ណែនាំបច្ចេកទេសពាក់ព័ន្ធនឹងការងារផ្សព្វផ្សាយស្ដីពីបរិស្ថានតាមប្រព័ន្ធព័ត៌មានដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- រៀបចំ ផ្សព្វផ្សាយតាមប្រព័ន្ធ និងគ្រប់គ្រងព័ត៌មានបរិស្ថានតាមរយៈគេហទំព័រ សារអេឡិចត្រូនិកនិងបណ្ដាញព័ត៌មានសង្គមរបស់ក្រសួងបរិស្ថាន



ြ

- ផលិតនិងផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធវិស័យបរិស្ថាន សមិទ្ធផលរបស់ក្រសួងបរិស្ថាន សកម្មភាពការងាររបស់ថ្នាក់ដឹកនាំនិងអង្គភាពចំណុះក្រសួងបរិស្ថាន បទយកការណ៍បរិស្ថាន និងប្រតិទិនការងារតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា
- សហការនិងសម្របសម្រួលការរៀបចំសម្ភារៈផ្សព្វផ្សាយនិងការបោះពុម្ពផ្សាយ រួមមានទស្សនាវដ្ដីបរិស្ថាន ព្រឹត្តិបត្រព័ត៌មាន បណ្ណផ្សព្វផ្សាយព័ត៌មាន
- សម្របសម្រួលជាមួយអគ្គនាយកដ្ឋានជំនាញ ក្នុងការរៀបចំសុន្ទរកថា សេចក្ដីថ្លែងការណ៍ សេចក្ដីប្រកាសព័ត៌មាន សេចក្ដីជូនដំណឹង និងព្រឹត្តិការណ៍បរិស្ថាននានា
- សម្របសម្រួលការផ្ដល់ព័ត៌មានបរិស្ថានដល់អ្នកសារព័ត៌មាននិងប្រព័ន្ធផ្សព្វផ្សាយនានា
- រៀបចំនិងគ្រប់គ្រងវិចិត្រសាលនិងបណ្ណាល័យរបស់ក្រសួងបរិស្ថាន
- រៀបចំ សហការ និងអនុវត្តព្រឹត្តិការណ៍និងយុទ្ធនាការបរិស្ថាន ជាអាទិ៍ទិវាបរិស្ថានជាតិនិងបរិស្ថានពិភពលោក៥មិថុនា និងទិវាអនាម័យបរិស្ថាន២៣វិច្ឆិកា
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

**មាត្រា៥២ .-**

នាយកដ្ឋានរង្វាន់និងលើកទឹកចិត្តមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ផែនការថវិកា និងគោលការណ៍ណែនាំបច្ចេកទេសពាក់ព័ន្ធនឹងការងារលើកទឹកចិត្តការប្រតិបត្តិមេត្រីបរិស្ថាន
- រៀបចំនិងផ្សព្វផ្សាយលក្ខណវិនិច្ឆ័យនិងគោលការណ៍ណែនាំសម្រាប់វាយតម្លៃគុណវុឌ្ឍិនៃការប្រតិបត្តិបៃតងនិងមេត្រីបរិស្ថានដល់សាធារណជនទូទៅ
- ផ្ដល់ការគាំទ្របច្ចេកទេសស្ដីពីការប្រតិបត្តិបៃតងនិងមេត្រីបរិស្ថានដល់រូបវន្តបុគ្គលនិងនីតិបុគ្គល ដើម្បីចូលរួមអនុវត្ត
- ពិនិត្យនិងវាយតម្លៃរូបវន្តបុគ្គលនិងនីតិបុគ្គលដែលមានស្នាដៃល្អក្នុងការប្រតិបត្តិបៃតងនិងមេត្រីបរិស្ថាន ដើម្បីផ្ដល់ការលើកទឹកចិត្ត
- បង្កើតកម្មវិធីលើកទឹកចិត្តសម្រាប់ជំរុញការប្រតិបត្តិបៃតងនិងមេត្រីបរិស្ថាន
- រៀបចំ សហការ និងសម្របសម្រួលការប្រឡងប្រណាំងការប្រតិបត្តិបៃតងនិងមេត្រីបរិស្ថានជាសាធារណៈ ដើម្បីផ្ដល់ការលើកទឹកចិត្ត
- សហការជាមួយស្ថាប័ននិងអង្គភាពពាក់ព័ន្ធ ក្នុងការចងក្រងស្ថិតិនិងតាមដានការប្រតិបត្តិបៃតងនិងមេត្រីបរិស្ថាន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឱ្យ។

## ជំពូកទី១០
## អគ្គាធិការដ្ឋាន

**មាត្រា៥៣ .-**

អគ្គាធិការដ្ឋានជាសេនាធិការឱ្យក្រសួងបរិស្ថានលើការងារអធិការកិច្ចនិងអភិបាលកិច្ចល្អ ហើយមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាពាក់ព័ន្ធនឹងការងារអធិការកិច្ច និងអភិបាលកិច្ចល្អក្នុងវិស័យបរិស្ថាន
- ចូលរួមដឹកនាំនិងសម្របសម្រួលការរៀបចំគោលការណ៍ នីតិវិធី និងលក្ខណវិនិច្ឆ័យសម្រាប់ដំណើរការវាយតម្លៃនិងទទួលស្គាល់អង្គភាពគំរូក្នុងវិស័យបរិស្ថាន
- ធ្វើអធិការកិច្ចជាប្រចាំទៅលើគ្រប់អង្គភាពក្រោមឱវាទក្រសួង និងធ្វើការត្រួតពិនិត្យការដឹកនាំនិងការគ្រប់គ្រងពាក់ព័ន្ធនឹងការងាររដ្ឋបាល ការងារបុគ្គលិក និងទ្រព្យសម្បត្តិរដ្ឋ
- តាមដាននិងត្រួតពិនិត្យលើការអនុវត្តគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត កិច្ចព្រមព្រៀង គោលការណ៍ និងលិខិតបទដ្ឋានផ្សេងៗតាមការប្រគល់ភារកិច្ចពីរដ្ឋមន្ត្រី
- ទទួលពិនិត្យរាល់លិខិតស្នាម ពាក្យបណ្ដឹង និងព័ត៌មាន ព្រមទាំងចុះស្រាវជ្រាវបាតុភាព និងភាពអសកម្មនានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងនិងការដឹកនាំរបស់ប្រធានអង្គភាព មន្ត្រីពាក់ព័ន្ធ បុគ្គល និងភាគីពាក់ព័ន្ធក្នុងវិស័យបរិស្ថាន
- ធ្វើអធិការកិច្ចលើករណីក្លែងបន្លំនិងភាពមិនប្រក្រតីក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋក្នុងក្របខ័ណ្ឌក្រសួងបរិស្ថាន
- កោះអញ្ជើញមន្ត្រីពាក់ព័ន្ធ តាមរយៈអង្គភាពមកបំភ្លឺនិងចូលរួមសហការក្នុងដំណើរការនៃការធ្វើអធិការកិច្ច
- បណ្ដុះបណ្ដាលជំនាញពាក់ព័ន្ធនឹងការងារអធិការកិច្ចក្នុងក្របខ័ណ្ឌការងារបរិស្ថាន
- សហការជាមួយស្ថាប័នជាតិនិងអន្តរជាតិ សំដៅបង្កើនប្រសិទ្ធភាពនៃដំណើរការការងារអធិការកិច្ចក្នុងវិស័យបរិស្ថាន
- ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីអំពីការប្រព្រឹត្តទៅរបស់អង្គភាពឬបុគ្គលដែលត្រូវបានធ្វើអធិការកិច្ចរួចហើយនិងធ្វើការចាត់វិធានការឬដំណោះស្រាយជាក់ស្ដែងចំពោះអង្គភាពឬបុគ្គលណាដែលមានកំហុស
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរដ្ឋមន្ត្រីប្រគល់ឱ្យ។

## ជំពូកទី១១
## នាយកដ្ឋានសវនកម្មផ្ទៃក្នុង

**មាត្រា៥៤ ..**

នាយកដ្ឋានសវនកម្មផ្ទៃក្នុងទទួលបន្ទុកអនុវត្តភារកិច្ចតាមអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្ដាស្ថាប័ន ក្រសួងនិងសហគ្រាសសាធារណៈ។

## ជំពូកទី១២
## នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

**មាត្រា៥៥ ..**

នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាសេនាធិការឱ្យក្រសួងបរិស្ថានក្នុងកិច្ចការពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ហើយមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាងនិងអនុវត្តគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ផែនការថវិកា គោលការណ៍ណែនាំបច្ចេកទេស និងនីតិវិធីនានាសម្រាប់ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម
- រៀបចំនិងអនុវត្តវិធានផ្ទៃក្នុង សម្រាប់គ្រប់គ្រងការពិនិត្យលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម
- ពិនិត្យ វិភាគ និងវាយតម្លៃសម្រាប់កំណត់ទីតាំងគម្រោងវិនិយោគសាធារណៈនិងគម្រោងវិនិយោគឯកជន
- ពិនិត្យនិងវាយតម្លៃលើចំណាត់ថ្នាក់គម្រោង ដើម្បីកំណត់អំពីតម្រូវការសម្រាប់រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដំបូង ឬកិច្ចសន្យាការពារបរិស្ថាន
- កំណត់លក្ខខណ្ឌការងារនិងគោលការណ៍បច្ចេកទេសសម្រាប់រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមពេញលេញ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដំបូង កិច្ចសន្យាការពារបរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថានជាមួយម្ចាស់គម្រោងដែលរួមទាំងកម្រៃដែលត្រូវបង់ចូលមូលនិធិទាយជ្ជទានបរិស្ថាននិងមូលនិធិបរិស្ថាននិងសង្គម
- ពិនិត្យនិងផ្តល់យោបល់លើរាល់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមនៃគម្រោងវិនិយោគសាធារណៈនិងគម្រោងវិនិយោគឯកជន ព្រមទាំងដំណើរការទាំងមូលនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- ពិនិត្យនិងរៀបចំកិច្ចសន្យាការពារបរិស្ថាននិងផែនការគ្រប់គ្រងបរិស្ថានសម្រាប់គម្រោងវិនិយោគសាធារណៈនិងគម្រោងវិនិយោគឯកជន
- ពិនិត្យនិងវាយតម្លៃលើរបាយការណ៍អង្កេតតាមដានបរិស្ថាននៃគម្រោងវិនិយោគសាធារណៈនិងគម្រោងវិនិយោគឯកជន
- ជំរុញការអនុវត្តការបង់សេវាការងារសាធារណៈ មូលនិធិទាយជ្ជទានបរិស្ថាន និងថវិកាពិន័យអន្តរការណ៍
- តាមដាន ត្រួតពិនិត្យ និងជំរុញការអនុវត្តការប្រមូលនិងការប្រើប្រាស់មូលនិធិបរិស្ថាននិងសង្គម
- គ្រប់គ្រង ទទួលខុសត្រូវ និងសម្របសម្រួលការងាររដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ គណនេយ្យ ផែនការថវិការយៈពេលខ្លី មធ្យម និងវែង និងអង្កេតតាមដានការងារផ្ទៃក្នុងរបស់នាយកដ្ឋាន
- ជំរុញឱ្យមានការចូលរួមជាប្រចាំរបស់សាធារណជននិងការទទួលបានព័ត៌មាននៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម
- កំណត់នីតិវិធីនិងលក្ខណវិនិច្ឆ័យសម្រាប់វាយតម្លៃក្រុមហ៊ុនដែលស្នើសុំចុះបញ្ជីជាក្រុមហ៊ុនទីប្រឹក្សាសម្រាប់ការសិក្សានិងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម
- ពិនិត្យ វាយតម្លៃ និងផ្តល់យោបល់លើការស្នើសុំចុះបញ្ជីជាក្រុមហ៊ុនទីប្រឹក្សាសម្រាប់ការសិក្សានិងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម
- សម្របសម្រួលការងារជាមួយបណ្តាអគ្គនាយកដ្ឋានក្រោមឱវាទក្រសួងបរិស្ថាន អង្គភាពពាក់ព័ន្ធ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងភាគីពាក់ព័ន្ធនៅក្នុងកិច្ចដំណើរវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

- បំពេញភារកិច្ចពង្រឹងសមត្ថភាពជំនាញការងារវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រនិងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដល់អង្គភាពថ្នាក់ជាតិនិងអង្គភាពថ្នាក់ក្រោមជាតិ វិស័យឯកជន ដៃគូអភិវឌ្ឍ សង្គមស៊ីវិល សហគមន៍ និងភាគីពាក់ព័ន្ធ
- បំពេញភារកិច្ចជាអង្គភាពបង្គោលជាតិនៃអនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនឹងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរដ្ឋមន្ត្រីប្រគល់ឱ្យ។

## ជំពូកទី១៣
## អង្គភាពថ្នាក់ក្រោមជាតិ

**មាត្រា៥៦ ._**

នៅតាមរាជធានី ខេត្តនីមួយៗមានមន្ទីរបរិស្ថានរាជធានី ខេត្ត ចំនួនមួយ ដែលទទួលបន្ទុកអនុវត្តនិងសម្របសម្រួលសកម្មភាពនានារបស់ក្រសួង។

ការរៀបចំនិងការប្រព្រឹត្តទៅនៃមន្ទីរបរិស្ថានរាជធានី ខេត្តត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

## ជំពូកទី១៤
## គ្រឹះស្ថានសាធារណៈរដ្ឋបាលនិងសហគ្រាសសាធារណៈ

**មាត្រា៥៧ ._**

គ្រឹះស្ថានសាធារណៈរដ្ឋបាលនិងសហគ្រាសសាធារណៈនានាដែលស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងបរិស្ថាន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

## ជំពូកទី១៥
## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា៥៨ ._**

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុត្រូវបានបង្កើតឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមលក្ខខណ្ឌនៃបទបញ្ញាកំណត់ក្នុងអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតស្ថាប័នពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាក្នុងបណ្ដាក្រសួង។

## ជំពូកទី១៦
## អន្តរប្បញ្ញត្តិ

**មាត្រា៥៩ ._**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយណាដែលពាក់ព័ន្ធនឹងការតែងតាំងមន្ត្រីរាជការនិងការបង្កើតអង្គភាពចំណុះក្រសួងបរិស្ថាន ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀតរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី១៧
## អវសានប្បញ្ញត្តិ

**មាត្រា៦០ ._**

អនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៦១ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហ ១៣កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធ**

**នៃអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន**



# ឧបសម្ព័ន្ធទី៥

# ប្រកាសលេខ៥៤ បជ្ឍ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ ១៩៩៣ ស្តីពីការទទួលស្គាល់មន្ត្រីរាជការបំរើការងារនៅក្រសួងបរិស្ថាន

រដ្ឋាភិបាលជាតិបណ្ដោះអាសន្ន
ក្រសួងបរិដ្ឋាន
-------
លេខ ៖ ...54...បដ

កម្ពុជា
------

ភ្នំពេញ , ថ្ងៃទី 16 ខែ 8 ឆ្នាំ ១៩៨៣

# ប្រកាស

## ស្ដីពីការទទួលស្គាល់ មន្ត្រី រាជការបំរើ ការងារនៅ ក្រសួងបរិដ្ឋាន

រដ្ឋមន្ត្រី ក្រសួងបរិដ្ឋាន

- បានឃើញព្រឹត្យរបស់ សម្ដេចព្រះឧបយុវរាជ នរោត្តមសីហនុ ព្រះប្រមុខរដ្ឋកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៨៣ ស្ដីពីការរៀបចំរាងរដ្ឋាភិបាលជាតិបណ្ដោះអាសន្នរដ្ឋកម្ពុជា ។
- យោងការចាំបាច់របស់ក្រសួងបរិដ្ឋាន

## សំរេច

ប្រការ ១ ៖ ទទួលស្គាល់មន្ត្រី រាជការចំនួន ២៣រូប និង ក្របខ័ណ្ឌចំនួន ២២ ក៏រ័ត្ន ដែលសល់ពីអតីតក្រសួងព្រួតពិនិត្យ និង ផ្ទេរមកពីវគ្គភាគខាង មកបំរើការងារនៅក្រសួងបរិដ្ឋាន ដូចមានរាយនាមខាងក្រោម ៖

ក- នាយកាល័យ ៖

| | | | | | |
|---|---|---|---|---|---|
| ១ | លោក | ង៉ែម | - | សារឿន | ឧត្តម សង្គមវិជ្ជា |
| ២ | - | សៀង | - | ចំរើន | - ឌ - |
| ៣ | - | ខេង | - | សារិន | បរិញ្ញាបត្រភាគ ១ |
| ៤ | - | ចាន់ | - | បុត្រី | - ឌ - |
| ៥ | - | ស្វាយ | - | សុផល | បរិញ្ញាបត្របឋមភូមិ |
| ៦ | - | ទិប | - | ជំផល | ឧត្តម សង្គមវិជ្ជា |
| ៧ | - | ពេង | - | ការិទ្ធ | បរិញ្ញាបត្រភាគ ២ |
| ៨ | - | អង់ | - | រឹម | - ឌ - |
| ៩ | - | ចាធី | - | ពិបញ្ញ | បរិញ្ញាបត្រទុតិយភូមិ |
| ១០ | - | ផាន | - | សុផល | |
| ១១ | - | ទ្រាយ | - | វិបុល | បរិញ្ញាបត្រភាគ ២ |
| ១២ | - | ម៉ាន | - | សេន | បើកបរ |
| ១៣ | កញ្ញា | ចាង | - | សុខា | [illegible]លេខ |
| ១៤ | - | ទ្រី | - | សុម៉ៃ | - |
| ១៥ | លោកស្រី | រ័កវ | - | បុត្រី | |
| ១៦ | - | បុក | - | ថ្លឹង | |
| ១៧ | លោក | រស់ | - | វ័ណរឿន | - |

| | | | | | |
|---|---|---|---|---|---|
| ១៨- | លោក | អ៊ុម | - | ចន្ទី | មេក្រុមសិក្សាបីក្រុមភាគ ២ |
| ១៩- | - | ស៊ុត | - | គាំ វ៉ុស្រាង | មេក្រុមសិក្សាបីក្រុមភាគ ១ |
| ២០- | - | ពេជ្រ | - | អ៊ុម | មេក្រុមសិក្សាឃុំមភូមិ |
| ២១- | - | ធន់ | - | សារឹម | មេក្រុមសិក្សាឃុំមភូមិ |
| ២២- | - | ទ័ន | - | សារឿន | មេក្រុមសិក្សាបីក្រុមកិច្ច ២ |
| ២៣- | - | ប៊ុក | - | សាវ៉ន | មេក្រុមសិក្សាបីក្រុមភាគ ២ |
| ២៤- | - | សាន់ | - | ចំរើន | មេក្រុមសិក្សាបីក្រុមកិច្ច ១ |
| ២៥- | - | កំពុង | - | ប៊ុណ្ណី | |
| ២៦- | - | ពេជ | - | ពៅ | ថ្នាក់ទី ៧ ចាស់ |
| ២៧- | - | រតា | - | ណែកាង | មេក្រុមសិក្សាបីក្រុមភាគ ១ |
| ២៨- | - | ទុំ | - | សរីឲ្យ | មេក្រុមសិក្សាឃុំមភូមិ |
| ២៩- | - | ទេព | - | ស៊ីថុន | មេក្រុមសិក្សាបីក្រុមភាគ ១ |
| ៣០- | លោកស្រី | ទាង | - | ពៅគង្គី | មេក្រុម ពិភាក្សាខ្ញុំ |
| ៣១- | - | ឃឿង | - | កញ្ញា | មេក្រុមសិក្សាបីក្រុមភាគ ១ |
| ៣២- | កញ្ញា | រស់ | - | ចាន់ណារី | មេក្រុមសិក្សាបីក្រុមកិច្ច ២ |
| ៣៣- | លោក | អ៊ុន | - | ប៊ឹម | មេក្រុមសិក្សាបីក្រុមភាគ ១ |
| ៣៤- | កញ្ញា | ទុំ | - | សុជា | ថ្នាក់ទី ៤ ចាស់ |
| ៣៥- | លោក | ទេព | - | ប៊ុនរឿន | ថ្នាក់ទី ៧ ចាស់ |
| ៣៦- | - | សោម | - | ទ្រព្យរឿង | មេក្រុម ពិភាក្សាខ្ញុំ |
| ៣៧- | - | ណុយ | - | អ៊ុន | មេក្រុម សិក្សាបីក្រុមភាគ ២ |
| ៣៨- | - | ទៀ | - | ទេង | មេក្រុម សិក្សាឃុំមភូមិ |
| ៣៩- | - | ចឹម | - | ម៉ុល | ថ្នាក់ទី ចាស់ |
| ៤០- | - | ខាត់ | - | សុគន្ធ | ថ្នាក់ទី ១១ ថ្មី |
| ៤១- | - | ចាន់ | - | ឡេង | |
| ៤២- | លោកស្រី | ទ័ញ | - | ចូវ | ថ្នាក់ទី ៧ ចាស់ |
| ៤៣- | លោកស្រី | ទ័ន្ត | - | ពៅអូ | |
| ៤៤- | - | ជៀម | - | សារិន | |
| ៤៥- | - | ណា | - | ចាង | |
| ៤៦- | - | លឿក | - | អុល | |
| ៤៧- | - | ងួន | - | សុភ័ក្ត្រ | |
| ៤៨- | - | គុយ | - | ម៉ុល | |
| ៤៩- | - | អ៊ុក | - | សាមេត | |

| | | | | | |
|---|---|---|---|---|---|
| ៩ | លោកស្រី | ម៉ៃ | - | ប៊ុនវណ្ណារី | មធ្យម ធារាសាស្ត្រ |
| ១០ | លោក | កុយ | - | ក្រេង | - ដ - |
| ១១ | - | ញ៉ុយ | - | វ៉ាថារ៉ី | មធ្យម គីមី |
| ១២ | - | ហោក | - | សុផាតិ | វិស្វករ រុក្ខសាស្ត្រ |
| ១៣ | - | ចាស | - | ធានិណា | មធ្យម ធារាសាស្ត្រ |
| ១៤ | - | សុក | - | សុភា | - ដ - |
| ១៥ | - | កុក | - | សុវ៉ាន | វិស្វករ រុក្ខជាតិវិទ្យា |
| ១៦ | កញ្ញា | ពុំ | - | វិចិត្រ | ឧត្តម រុក្ខសាស្ត្រ |
| ១៧ | លោក | និន | - | វ៉ាន់ថា | ឧត្តម សេដ្ឋកិច្ចកសិកម្ម |
| ១៨ | - | ឈិន | - | សំរ៉ាយ | វិស្វករ ធារាសាស្ត្រ |
| ១៩ | កញ្ញា | ប៊ូន | - | ស៊ីមលាង | មធ្យមវារីសាស្ត្រ |
| ២០ | លោក | ម៉ី | - | សុផា | មធ្យម រ៉ែភូគព្ភសាស្ត្រ |
| ២១ | - | ឯក | - | វិមានរិទ្ធ | ឧត្តម សេដ្ឋកិច្ចកសិកម្ម |
| ២២ | - | ឌួ | - | សារ៉ុំ | មធ្យម គ្រឿងយន្តកសិកម្ម |
| ២៣ | - | គង់ | - | អក្ខរា | វិស្វករសំណង់ |
| ២៤ | - | ហូ | - | សុវណ្ណ | គណនេយ្យជាតិនិងវិទ្យុ |
| ២៥ | - | លី | - | ណារត្ន | វិស្វករ រ៉ែ |
| ២៦ | លោកស្រី | ម៉ែន | - | វិមល | ឧត្តម គ្រប់គ្រងសេដ្ឋកិច្ចកសិកម្ម |
| ២៧ | លោក | គុជ | - | កុសល | ឧត្តម សេដ្ឋកិច្ច |
| ២៨ | លោក | គឹម | - | សុវណ្ណ | - ដ - |
| ២៩ | លោកស្រី | ជូ | - | សុផារី | ឧត្តម សេដ្ឋកិច្ចឧស្សាហកម្ម |
| ៣០ | លោក | ប៊ូយ | - | គឹមស្រ៊ាង | ឧត្តម សេដ្ឋកិច្ចវិទ្យាសាស្ត្រ |
| ៣១ | - | ល៉ី | - | ហួត | មធ្យម រុក្ខកម្ម |
| ៣២ | - | យឹម | - | ចាន់ណារិទ្ធ | វិស្វករ សេដ្ឋកិច្ចឧស្សាហកម្ម |
| ៣៣ | - | ត្រី | - | គីរីរត្ន | មធ្យម រ៉ែ |
| ៣៤ | - | អ៊ូ | - | រតនា | មធ្យម ធារាសាស្ត្រ |
| ៣៥ | - | លឹម | - | សុគន្ធ | មធ្យម ហិរញ្ញវត្ថុ |
| ៣៦ | - | រតា | - | វស្សី | វិស្វករ សំណង់ |
| ៣៧ | - | កាន់ | - | បញ្ញា | វិស្វករ គីមី |
| ៣៨ | - | កាន់ | - | វិបុល | វិស្វករ សេដ្ឋកិច្ច |
| ៣៩ | លោកស្រី | ឌុក | - | សុភ័លា | ឧត្តម ធារាសាស្ត្រ |
| ៤០ | លោក | ស្រ៊ុន | - | វ៉ុប | វិស្វករ រុក្ខសាស្ត្រ |
| ៤១ | - | ជា | - | បញ្ញារិទ្ធ | វិស្វករ រ៉ែ |

| | | | | |
|---|---|---|---|---|
| ៥០ | លោកស្រី | មាឃ | - ឡាញ់ | |
| ៥១ | - | មាឃ | - ឡា | |
| ៥២ | លោក | គង់ | - តាំ | អតីតរដ្ឋមន្ត្រីក្រសួងត្រួតពិនិត្យ |
| ៥៣ | - | នុច | - ជន | អតីតអនុរដ្ឋមន្ត្រីក្រសួងត្រួតពិនិត្យ |
| ៥៤ | - | ទឹម | - ផា សោភ័ណ | - ដ - |
| ៥៥ | - | សោម | - កុមារ | អតីតបើកបរ |
| ៥៦ | - | ព្រហ្ម | - ឈុនលី | - |
| ៥៧ | - | សុខ | - អ៊ី | - |
| ៥៨ | - | ពៅ | - គៀន | - |
| ៥៩ | - | សុខ | - សុខា | - |
| ៦០ | - | ថោ | - សារិន | - |
| ៦១ | - | ហាស់ | - វុន | - |
| ៦២ | - | ឈិត | - ណាល់ | - |
| ៦៣ | - | ឃឹម | - យាត | - |
| ៦៤ | - | លុន | - សុផន | - |
| ៦៥ | - | ទឹម | - សុផុន | - |
| ៦៦ | - | រី | - ចើន | - |
| ៦៧ | - | ស៊ិន | - ស៊ិយ | - |
| ៦៨ | - | ភាព | - ផន | - |
| ៦៩ | - | ប៊ុន | - តឹក | បើកបររថយន្តមន្ត្រី |
| ៧០ | - | បាស | - សុផល | មធ្យម សិក្សាបត្រភាគ ១ |
| ៧១ | - | ហ៊ុយ | - ពេជ្រ | វិស្វករ ធារាសាស្ត្រ |
| ៧២ | - | ជិន | - សាមុត | វិស្វករ គ្រឿងយន្ត |
| ៧៣ | - | សួន | - សំណាង | ថ្នាក់ទី ១១ ថ្មី |

-CCL <u>នាយកដ្ឋានផែនការបរិដ្ឋាន និង គ្រប់គ្រងទឹក</u> :

| | | | | |
|---|---|---|---|---|
| ១ | លោក | អ៊ី | - ប៊ុណ្ណា | វិស្វករ បច្ចេកទេស |
| ២ | - | ហ៊ាន | - វីរៈ | វិស្វករ ធារាសាស្ត្រ |
| ៣ | - | ឡូន | - គង់ | វិស្វករ វារីសាស្ត្រ |
| ៤ | - | រ៉ុក | - សូរ្យច័ន្ទ | មធ្យម សំណង់ |
| ៥ | - | ផល | - សុភក្រ្ត | មធ្យម សំណង់ |
| ៦ | - | ជិន | - សម្បត្តិ | វិស្វករ គ្រឿងយន្ត |
| ៧ | - | ជៀប | - ព្រុំ | ឧត្តម សេដ្ឋកិច្ច ផែនការ |
| ៨ | - | ស៊ឹម | - សារឿន | មធ្យម ផែនការសេដ្ឋកិច្ច |

១៤៤. <u>នាយកដ្ឋាន ការពារ រុក្ខជាតិ</u> :

| | | | | | | |
|---|---|---|---|---|---|---|
| ១- | លោក | ចាយ | - | សាមិត | វិស្វករ | វរុក្ខកម្ម |
| ២- | - | រ៉េយ៉ម | - | សុខន | វិស្វករ | វរុក្ខកម្ម |
| ៣- | - | សី | - | និស័យ | វិស្វករ | បសុពេទ្យ |
| ៤- | លោកស្រី | អ៊ុក | - | សីហា | វិស្វករ | ជលផល |
| ៥- | លោក | ហាក់ | - | សុង | មធ្យម | ធារាសាស្ត្រ |
| ៦- | - | សិន | - | បិណ្ណាត | វិស្វករ | វរុក្ខកម្ម. |
| ៧- | - | ស៊ុ | - | វ៉ាមន្នី | វិស្វករ | តេក្នូតសាស្ត្រ |
| ៨- | - | រ៉េកន | - | នាង | មធ្យម | ធារាសាស្ត្រ |
| ៩- | - | ហ៊ាល | - | សុផារី | មធ្យម | បសុពេទ្យ |
| ១០- | - | អ៊ុ | - | ពិសី | វិស្វករ | បសុពេទ្យ |
| ១១- | - | ហ៊ុយ | - | ផលវឌ្ឍី | វិស្វករ | សំណង់ |
| ១២- | - | កៀល | - | ធន់ | វិស្វករ | វិទ្យាសាស្ត្រសេដ្ឋកិច្ច |
| ១៣- | - | ម៉ម | - | កុសល | វិស្វករ | ជលផល |
| ១៤- | - | ពេជ្រ | - | សំអាង | វិស្វករ | ធារាសាស្ត្រ |
| ១៥- | - | ពុង | - | សារុន | វិស្វករ | ធារាសាស្ត្រ |
| ១៦- | - | វ៉ាន់ | - | មុន្នីនាថ | វិស្វករ | ជលផល |
| ១៧- | - | ឌឹក | - | ផេង | វិស្វករ | ធារាសាស្ត្រ |
| ១៨- | - | ចាប | - | សារឿន | មធ្យម | ធារាសាស្ត្រ |
| ១៩- | - | លៀង | - | កេសរា | វិស្វករ | វរុក្ខកម្ម |
| ២០- | - | អ៊ុ | - | ចន្ទាវី | មធ្យម | សេដ្ឋកិច្ចកសិកម្ម |
| ២១- | - | ពៅ | - | សៀងលី | មធ្យម | ធារាសាស្ត្រ |
| ២២- | - | ញុប | - | ផារី | វិស្វករ | ផ្លូវថ្នល់ |
| ២៣- | - | សិន | - | ផាចាំ | វិស្វករ | តេក្នូតសាស្ត្រ |
| ២៤- | - | គឹម | - | លុង | វិស្វករ | គីមី |
| ២៥- | - | ម៉ុន | - | សាមុត | មធ្យម | គីមី |
| ២៦- | - | ឯក | - | សេរីសុភាព | មធ្យម | ធារាសាស្ត្រ ✓ |
| ២៧- | - | ពេជ្រ | - | សារ៉េត | វិស្វករ | ធារាសាស្ត្រ |
| ២៨- | - | មឿង | - | វិលច្ន | វិស្វករ | កសិកម្ម |
| ២៩- | - | លន់ | - | គឹមពុំ | វិស្វករ | វិទ្យាសាស្ត្រសេដ្ឋកិច្ច |
| ៣០- | - | យុន | - | សារ៉េន | មធ្យម | មីក្រូពក្សី |
| ៣១- | អ្នកស្រី | រី | - | ថាវី | មធ្យម | ធារាសាស្ត្រ ✓ |
| ៣២- | អ្នកស្រី | មាន | - | សុខអួន | មធ្យម | ធារាសាស្ត្រ |

៤. នាយកដ្ឋានកិច្ចកំណត់បទដ្ឋាន និង ត្រួតត្រាការប្រតិបត្តិ :

| | | | | | |
|---|---|---|---|---|---|
| ១- | លោក | ម៉ក់ | - | សុភី | សាស្ត្រាចារ្យមហាវិទ្យាល័យសូនរូប |
| ២- | - | ស្រេង | - | ផល្លា | ទស្សនវិជ្ជា |
| ៣- | - | អ៊ី | - | សេរីវឌ្ឍ | ឧត្ដម ធារាសាស្ត្រ |
| ៤- | - | ញ៉ក់ | - | សុខារ៉ាវុធ | ឧត្ដម គីមី |
| ៥- | - | តាំង | - | គ្រុយ | មធ្យម ធារាសាស្ត្រ |
| ៦- | - | ម៉េង | - | សាវុន | មធ្យម ធារាសាស្ត្រ |
| ៧- | - | ទង់ | - | គុណ | ឧត្ដម ផលផល |
| ៨- | - | ម៉េង | - | មន្នីរក្ស | ឧត្ដម រុក្ខកម្ម |
| ៩- | - | យ៉ា | - | ម៉ារិទ្ធ | មធ្យម រុក្ខសាស្ត្រ |
| ១០- | - | ហួយ | - | វិបុត្រ | ឧត្ដម ផលផល |
| ១១- | កញ្ញា | កាយ | - | វណ្ណធី | មធ្យម វារីសាស្ត្រ |
| ១២- | លោក | សោម | - | ប៊ុនថា | វិស្វករ រុក្ខា |
| ១៣- | - | សេង | - | ប៊ុនណាត | មធ្យម រុក្ខា |
| ១៤- | - | គឹម | - | សារិន | មធ្យម រុក្ខា |
| ១៥- | - | ហ៊ួ | - | សុផល | មធ្យម សំណង់ |
| ១៦- | - | ម៉ៅ | - | សុផាត | ជួសជុលឧបករណ៍ឧស្សាហកម្ម |
| ១៧- | - | យុន | - | យុវា | វិស្វករ សេដ្ឋកិច្ច |
| ១៨- | - | ម៉ៅ | - | វ៉ាត់ចាន់ | វិស្វករ គីមី |
| ១៩- | - | កើត | - | សារឿន | មធ្យម គីមី |
| ២០- | - | ញ៉ាន់ | - | បូរ៉ា | ឧត្ដម សេដ្ឋកិច្ចគ្រប់គ្រង |
| ២១- | - | ហេង | - | សាវេត | វិស្វករ សំណង់ |
| ២២- | - | អ៊ី | - | សម្បត្តិ | វិស្វករ សំណង់ |
| ២៣- | - | តន់ | - | វ៉ាន់ថារ៉ា | ឧត្ដម ធារាសាស្ត្រ |
| ២៤- | - | ផា | - | ស៊ីណុក | ឧត្ដម គីមី |
| ២៥- | - | ឌី | - | ណារ៉ា | ឧត្ដម វារីសាស្ត្រ |
| ២៦- | លោកស្រី | កៀម | - | សុផល | មធ្យម ធារាសាស្ត្រ |
| ២៧- | លោក | ស៊ិន | - | សូធី | មធ្យម អគ្គិសនី |
| ២៨- | - | ឌីផ | - | សុខហេង | វិស្វករ វារីសាស្ត្រ |
| ២៩- | - | ម៉េដ | - | សុវណ្ណ | វិស្វករ សេដ្ឋកិច្ច |
| ៣០- | - | ស៊ិន | - | ប៊ុនណា | វិស្វករ គីមី |
| ៣១- | - | ហ៊ី | - | បញ្ញារ៉ា | វិស្វករ សំណង់ |
| ៣២- | - | អ៊ី | - | វ៉ាស៊ី | វិស្វករបច្ចេកទេស គីមីផលិតកម្ម |
| ៣៣- | - | ឈឹម | - | សាវុទ្ធ | វិស្វករ អគ្គិសនី |

| | | | | | | |
|---|---|---|---|---|---|---|
| ៣៤- | លោក | ជៀក | - | អាង | បឋម | គណនេយ្យ |
| ៣៥- | - | អ៊ីវ | - | សុផល | វិស្សករ | ទេក្សសាស្ត្រ |
| ៣៦- | - | ធីវ | - | សុភារិទ្ធ | មធ្យម | គីមី |
| ៣៧- | - | ញ៉ូវ | - | ពណ្ណា | ឧត្តម | គ្រឿងយន្ត |
| ៣៨- | - | ទៀង | - | រិទ្ធិរក្ស | វិស្សករ | សំណង់ |
| ៣៩- | - | ទី | - | សុភាវុធ | មធ្យម | ធារាសាស្ត្រ |
| ៤០- | - | គឹម | - | ផល្លី | វិស្សករ | គ្រឿងយន្ត |
| ៤១- | - | នេក | - | រដ្ឋ | វិស្សករ | គីមី |
| ៤២- | - | សេង | - | ហុងហាង | វេជ្ជបណ្ឌិត | |
| ៤៣- | - | លី | - | បុប្ផា | វេជ្ជបណ្ឌិត | |
| ៤៤- | - | ជឹម | - | វុឌ្ឍា | ឧត្តម | សេដ្ឋកិច្ចកសិកម្ម |
| ៤៥- | - | ទេព | - | ផល្លា | | គីមី |
| ៤៦- | - | សោម | - | សារ៉ាត | ឧត្តម | ធារាសាស្ត្រ |
| ៤៧- | - | ឌីផ | - | ចាន់ធី | មធ្យម | គីមី |
| ៤៨- | - | ស៊ែម | - | សុខដារា | វិស្សករ | គីមី |
| ៤៩- | - | ជ្រឹន | - | សុខា | ឧត្តម | ធារាសាស្ត្រ |
| ៥០- | លោកស្រី | ទេព | - | ស៊ីថា | មធ្យម | ធារាសាស្ត្រ |
| ៥១- | លោក | ទា | - | គីវរា | ឧត្តម | គ្រឿងយន្ត |
| ៥២- | - | ទ៉េង | - | បុល | ឧត្តម | ទេក្សសាស្ត្រ |
| ៥៣- | - | ផា | - | សាន | វិស្សករ | គីមី |
| ៥៤ | - | ភោគ | - | សុបរឿន | មធ្យម | អគ្គិសនី |
| ៥៥ | - | ទ៉ែក | - | សារ៉ាត | វិស្សករ | អគ្គិសនី |
| ៥៦ | - | អ៊ុង | - | សម្បត្តិ | វិស្សករ | សំណង់ |
| ៥៧ | - | ផា | - | សុផល | មធ្យម | សេដ្ឋកិច្ច |
| ៥៨ | - | ទេព | - | វណ្ណារិទ្ធិ | វិស្សករ | គ្រឿងយន្ត |
| ៥៩ | - | អ៊ុច | - | ថន | មធ្យម | អគ្គិសនី |
| ៦០ | - | ជួ | - | សុភ័ក្រ | វេជ្ជបណ្ឌិត | |
| ៦១ | - | វ៉ែម | - | ពៅ | ឧត្តម | វិទ្យាសាស្ត្រសេដ្ឋកិច្ច |
| ៦២ | - | ចាប | - | ម៉ារិទ្ធិ | មធ្យម | ធារាសាស្ត្រ |
| ៦៣ | - | ភិន | - | រ៉ាធី | វិស្សករ | គីមី |

៦ ៖ ការិយាល័យរបស់រួចបញ្ចប់ និង កំពុងបញ្ចប់ ៖

| | | | | | |
|---|---|---|---|---|---|
| ១ | លោក | សំ | - | ចំរើន | ភូមិសាស្ត្រ |
| ២ | - | ឯក | - | ស៊ីថន | បឋម[illegible] |
| ៣ | - | វ៉ែម | - | ចាន់តារា | មធ្យម [illegible] |

| | | | | |
|---|---|---|---|---|
| ៤ | លោក | ឌី - | សុធី | វិស្វករ [illegible] |
| ៥ | - | ចាន់ - | តារា | វិស្វករ ផលផល |
| ៦ | - | រស់ - | ច័ន្ទតារា | វិស្វករ វីវ៉ |
| ៧ | - | ឡាយ - | ឃីម | វិស្វករ រុក្ខកម្ម |

ខ.៤- ការិយាល័យអប់រំ និង ព័ត៌មាន:

| | | | | |
|---|---|---|---|---|
| ១ | លោក | ស៊ូ - | សុវុធ | សាស្ត្រាចារ្យ បច្ចេកទេស |
| ២ | លោកស្រី | រេង - | លនគី | មធ្យម ជីវវិទ្យា |
| ៣ | លោក | ម៉ក់ - | សីវុធ | មធ្យម អាជីវកម្មភាពយន្ត |
| ៤ | - | គន - | សក្តិទ្ធិ | វិស្វករ គេហស្ថាបត្យ |
| ៥ | - | គេ - | រិទ្ធី | មធ្យម អាជីវកម្មភាពយន្ត |
| ៦ | កញ្ញា | ស - | បូរ៉ែន | ឧត្តម ចលនវិជ្ជា |
| ៧ | លោកស្រី | ឡុង - | សុទាបូរី | អង្គលិលេខ |

ប្រការ ២ : ប្រាក់បៀវត្ស និង របបគោលនយោបាយផ្សេងៗរបស់សាមីជន ក្រសួងបរិក្ខារ រក្សាទុកដដែល និង ធានាផ្គត់ផ្គង់បន្តបន្ទាប់ពីមាន វិញ្ញាបនប័ត្រផ្តាច់ពីអង្គភាពដើម ។

ប្រការ ៣ : មន្ទីរ ការិយាល័យបុគ្គលិក ការិយាល័យហិរញ្ញវត្ថុ គណនេយ្យ និង សាមីជន ត្រូវអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

[illegible]

# ឧបសម្ព័ន្ធទី៦

# របាយការណ៍បូកសរុបការងារបរិស្ថានប្រចាំឆ្នាំ២០២១ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ : ០១២ ១.ធ្យា ប.ស្ថ

ថ្ងៃ សុក្រ ១០កើត ខែ មាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០២២

# របាយការណ៍បូកសរុបការងារបរិស្ថាន
# ប្រចាំឆ្នាំ២០២១

## I. សេចក្តីផ្តើម

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** តាមរយៈកម្មវិធីនយោបាយរបស់គណបក្សប្រជាជនកម្ពុជា សម្រាប់ការកសាងនិងការពារមាតុភូមិ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ព្រមទាំងយុទ្ធសាស្ត្រនិងផែនការសកម្មភាពបរិស្ថានជាតិ ២០១៦-២០២៣ ក្រសួងបរិស្ថានបាននិងកំពុងអនុវត្តការងារកំណែទម្រង់ និងសម្រេចបានការងារជាច្រើនក្នុងដំណើរឆ្ពោះទៅកសាងឱ្យបាននូវរដ្ឋបាលទំនើបមួយ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនិងការវិវឌ្ឍរបស់សង្គម ក៏ដូចជាបរិការណ៍តំបន់និងពិភពលោក សំដៅជានាសម្រេចបាននូវបេសកកម្មរបស់ខ្លួនតាមសសរស្តម្ភទាំង៤ គឺ (១)ការធ្វើទំនើបកម្មស្ថាប័ន (២)កិច្ចគាំពារបរិស្ថាន (៣)ការគ្រប់គ្រងធនធានធម្មជាតិ និងការអភិរក្សជីវៈចម្រុះ និង(៤)ការរៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រ ដើម្បីធានាបានការអភិវឌ្ឍប្រកបដោយចីរភាព ដោយសំឡឹងឆ្ពោះទៅរកចក្ខុវិស័យកម្ពុជាឆ្នាំ ២០៣០ និង២០៥០។

ក្រសួងបរិស្ថានបានអនុវត្តនូវបណ្តាភារកិច្ចសំខាន់ៗដូចជា៖ ការងារគ្រប់គ្រងធនធានមនុស្ស ការងារគ្រប់គ្រងចំណូល-ចំណាយ ការចងក្រងឯកសារសិក្សាស្រាវជ្រាវទាក់ទងនឹងបច្ចេកវិទ្យា វិទ្យាសាស្ត្រសេដ្ឋកិច្ចបៃតង កិច្ចសហការប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ការតាមដានគុណភាពទឹកនិងខ្យល់សាធារណៈ ការពិនិត្យផ្តល់យោបល់និងឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការសិក្សាដីប្រើប្រាស់អាស្រ័យផលរបស់ប្រជាសហគមន៍ក្នុងតំបន់ការពារធម្មជាតិ ការទប់ស្កាត់និងបង្ក្រាបបទល្មើសធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ ការអប់រំផ្សព្វផ្សាយការងារបរិស្ថាន ការរៀបចំនិងចូលរួមកិច្ចប្រជុំ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលពីចំងាយតាមរយៈប្រព័ន្ធអនឡាញ (ZOOM) ដោយប្រកាន់ខ្ជាប់នូវវិធានសុខាភិបាលក្នុងការចូលរួមទប់ស្កាត់និងការពារការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩។

## II. លទ្ធផលការងារសម្រេចបានប្រចាំឆ្នាំ២០២១

### ១. ការងាររដ្ឋបាលនិងហិរញ្ញវត្ថុ

- មន្ត្រីក្របខណ្ឌក្រសួងបរិស្ថានសរុប ចំនួន២៧៥៥នាក់ (ស្រី៥២១នាក់)
- មន្ត្រីក្របខណ្ឌនៅទីស្តីការក្រសួងបរិស្ថានចំនួន១០១១នាក់
- មន្ត្រីរាជការនៅមន្ទីរបរិស្ថានរាជធានី-ខេត្ត ចំនួន១៧៤៤នាក់



អគារមរតកតេជោ ដីឡូលេខ503 ផ្លូវកោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: ០២៣ ២១៣ ៩០៨, ០២៣ ២២០ ៣៦៩ ទូរសារ: ០២៣ ២១២ ៥៤០

- មន្ត្រីជាប់កិច្ចសន្យានៅទីស្តីការក្រសួងបរិស្ថាន ចំនួន១០១នាក់
- បុគ្គលិកស្ម័គ្រចិត្តនៅទីស្តីការក្រសួងបរិស្ថាន ចំនួន១៦នាក់
- ចំណូលសរុបឆ្នាំ២០២១ បានចំនួន ១៧,៨៨៦,៦៧៦,៣២៥រៀល ស្មើនឹង ១៩៨.២៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១
- បានពិនិត្យ និងតាមដានការប្រើប្រាស់ប្រេងឥន្ធនៈសម្រាប់ ឆ្នាំ២០២១ ប្រេងសាំង EA (L) ចំនួន ១១៣.៨៧៥លីត្រ និងប្រេងម៉ាស៊ូត DO (L)ចំនួន ៥៧.៥៦៥ លីត្រ។

## ២.ការងាររៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រ

- បញ្ចប់ការបកប្រែឯកសារចំនួន០២ ជាភាសាជាតិ រួមមានៈ សេចក្តីព្រាងផែនទីបង្ហាញផ្លូវសម្រាប់ការវាយតម្លៃលទ្ធភាពរៀបចំគម្រោងសាងសង់មជ្ឈមណ្ឌលវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានុយក្លេអ៊ែរ និងកិច្ចព្រមព្រៀងរក្សាការសំងាត់ (Non-Disclosure Agreement)
- បញ្ចប់ការកែសម្រួលឯកសារលម្អិត ពីគម្រោងសាងសង់បង្គន់អនាម័យប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ និងដាក់ជូនស្ថានទូតឥណ្ឌាប្រចាំប្រទេសកម្ពុជា
- ដំឡើងថាមពលពន្លឺព្រះអាទិត្យ ៣២គីឡូវ៉ាត់ នៅមជ្ឈមណ្ឌលស្រាវជ្រាវនិងអភិរក្សកេសរកុលសុខ អាន ភ្នំគូលែន ខេត្តសៀមរាប និងសហគមន៍ស្រែអំពិល
- បោះពុម្ពរបាយការណ៍ការវាយតម្លៃសក្តានុពលពន្លឺព្រះអាទិត្យនៅកម្ពុជា សម្រាប់អ្នកធ្វើគោលនយោបាយរបស់រាជរដ្ឋាភិបាល ឆ្នាំ២០២២
- បញ្ចប់ប្រព័ន្ធតាមដានការចូលរួមរបស់កម្ពុជា ក្នុងការអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (NDC Tracking System) តាមដានសកម្មភាពបន្សុំា នៅក្នុង NDC និងទិន្នន័យសន្ទស្សន៍ភាពងាយរងគ្រោះ និងព័ត៌មានហិរញ្ញប្បទាន
- បញ្ចប់ការរៀបចំទិន្នន័យសម្រាប់ធ្វើការវិភាគសន្ទស្សន៍ភាពងាយរងគ្រោះ និងបានរៀបចំក្នុងគេហទំព័រសម្រាប់ទិន្នន័យឆ្នាំ២០២០
- បានបោះពុម្ពសៀវភៅរបាយការណ៍ជាតិលើកទី៦ សម្រាប់អនុសញ្ញាសហប្រជាជាតិ ស្តីពីជីវៈចម្រុះជាភាសាខ្មែរ ចំនួន១៥០ក្បាល សម្រាប់ការផ្សព្វផ្សាយ និងចែកជូនដល់ភាគីពាក់ព័ន្ធ
- បានរៀបចំផលិតវីដេអូ ដើម្បីអបអរសាទរ ទិវាជីវៈចម្រុះអន្តរជាតិ ២២ ឧសភា ឆ្នាំ២០២១
- បានរៀបចំប្រភេទកេសរកុលព្រៃ ចំនួន៣៤ប្រភេទ
- រៀបចំសំណើសុំថវិកាពីគម្រោងមូលនិធិពិសេសនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងនៃឆ្នាំ២០២២ ស្តីពី (១)ការកសាងសមត្ថភាព (២)ការរៀបចំនិងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និង(៣) ការប្រមូលនិងចងក្រងទិន្នន័យប្រភេទកេសរកុលព្រៃនៅកម្ពុជា។

## ៣. ការងារគាំពារបរិស្ថាន

- បានចុះពិនិត្យនិងយកទឹកសាធារណៈចំនួន ១១៧សំណាក
- បានតាមដានត្រួតពិនិត្យគុណភាពខ្យល់សាធារណៈជាប្រចាំនៅរាជធានីចំនួន ១២ទីតាំង និងតាមបណ្តាខេត្តទូទាំងប្រទេសចំនួន ២៩ទីតាំង

- បញ្ចប់ការដំឡើងស្ថានីយត្រួតពិនិត្យគុណភាពខ្យល់ចំនួន ១០ស្ថានីយ នៅរាជធានីភ្នំពេញចំនួន ២ស្ថានីយ និងខេត្តគោលដៅចំនួន ៨ស្ថានីយ (ស្វាយរៀង កំពង់ស្ពឺ កំពង់ធំ ក្រុងព្រះសីហនុ សៀមរាប បន្ទាយមានជ័យ ស្ទឹងត្រែង និងព្រះវិហារ)
- ធ្វើបច្ចុប្បន្នភាពទិន្នន័យប្រភពបំពុលសរុបចំនួន ១៤៥៥ទីតាំង
- ចុះពិនិត្យ និងអធិការកិច្ចប្រភពបំពុលសរុបចំនួន ៩២ទីតាំង
- ដោះស្រាយបណ្តឹងបំពុលសរុបចំនួន ១១ករណី
- ចេញបញ្ជាកែប្រែបញ្ហាបំពុលបរិស្ថានសរុបចំនួន ១៩ក្រុមហ៊ុន
- ធ្វើការពិន័យបទល្មើសបំពុលបរិស្ថានចំនួន ០៦ករណី
- ចងក្រងទិន្នន័យសេវាប្រមូលសំរាមបាន ២៧ក្រុង ទីប្រជុំជនបាន ៣០៤នៃរដ្ឋបាលស្រុក ១២៦
- ចងក្រងទិន្នន័យកន្លែងប្រមូលអេតចាយចំនួន ៦៩២ទីតាំង កន្លែងកែច្នៃសំណល់រឹង ៤០ទីតាំង និងកន្លែងផលិតប្លាស្ទិកនិងស្នោចំនួន ៤៩ទីតាំង
- ចុះពិនិត្យនិងវាយតម្លៃគម្រោងបង្កើតទីលានចាក់សំរាមចំនួន ១១កន្លែង និងស្នើសុំបំពាក់ឡដុតសំរាមចំនួន ៣៥កន្លែង
- ប្រមូលសំណល់ថ្មពិលនៅរាជធានីភ្នំពេញចំនួន ៥២ទីតាំង និងខេត្តចំនួន១២(១៦ទីតាំង) និងប្រមូលសំណល់ថ្មពិលបានចំនួន ២១៦គីឡូក្រាម
- តាមដានការអនុវត្តកិច្ចសន្យាការពារបរិស្ថានចំនួន ១៤៧គម្រោង
- ផ្តល់លិខិតឯកភាពកិច្ចសន្យាការពារបរិស្ថានចំនួន ១៥១គម្រោង
- ផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដំបូង ចំនួន៧៦គម្រោង
- ឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដំបូង បានចំនួន៧១គម្រោង
- ចេញលិខិតអនុញ្ញាតសេវាសាធារណៈ សរុបចំនួន ២០២៩ច្បាប់
- ប្រមូលមូលនិធិទាយជ្ជទានបរិស្ថានបានចំនួន ២.៨០៧.៣៩៦.៦៥០រៀល និងថ្លៃប្រមូលកម្រៃសេវាការងារចំនួន ៣.១៣៥.៣៩២.០០០រៀល
- អនុវត្តពិន័យអន្តរការណ៍ចំនួន ១៥៨ លានរៀល។

## ៤. ការងារការពារនិងអភិរក្សធនធានធម្មជាតិ

- បានដាំកូនឈើចំនួន ១៦០០១ដើម
- បានសាងសង់ និងបោះបង្គោលចំនួន ៦១៥ នៅតាមដែនជម្រកសត្វព្រៃ និងនៅតាមតំបន់ការពារធម្មជាតិនានាក្នុងព្រះរាជាណាចក្រកម្ពុជា
- បានរៀបចំទិវាសត្វស្លាបទេសន្តរប្រវេសន៍ឆ្នាំ២០២១ នៅតំបន់ប្រើប្រាស់ច្រើនយ៉ាងទូលំទូលាយ តាឡី-បឹងស្នេហ៍ ខេត្តព្រៃវែង
- បានប្រគល់ក្របីចំនួន ៥០ក្បាល សម្រាប់កម្មវិធីចញ្ចឹមក្របីប្រវាស់ ដើម្បីបង្កើនជីវភាពដល់សហគមន៍មូលដ្ឋាន នៅភូមិកំពង់រាំង ភូមិឈូក និងភូមិព្រៃខ្លា ស្រុកស្ទួង ខេត្តកំពង់ធំ

- បានរៀបចំបង្កើតតំបន់ប្រើប្រាសច្រើនយ៉ាងទួលព័ន្ធតាឡី-បឹងស្នេហ៍ ទំហំ ៣៥៥៧ហិកតា (អនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១)
- បានបង្កើតតំបន់ប្រើប្រាស់ច្រើនយ៉ាងបឹងកាដេរ ទំហំ ១៦៤៣ហិកតា (អនុក្រឹត្យលេខ ២២៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១)
- បាននិងកំពុងរៀបចំដាក់តំបន់វាលស្មៅ និងព្រៃលិចទឹក ក្នុងស្រុកបាកាន និងកណ្តៀង ខេត្តពោធិ៍សាត់ (បន្តនីតិវិធីរៀបចំសេចក្តីព្រាងអនុក្រឹត្យ)
- បាននិងកំពុងរៀបចំដាក់តំបន់ព្រៃលិចទឹក និងព្រៃឫស្សីមាត់ឃ្មុំ និងបឹងជុំវិញ ជាតំបន់ការពារធម្មជាតិ ស្ថិតក្នុងភូមិសាស្ត្រស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ
- បាននិងកំពុងចងក្រងទិន្នន័យធនធានធម្មជាតិក្នុងតំបន់ការពារ( Coastal PA Profile)និងចងក្រងទិន្នន័យធនធានធម្មជាតិតំបន់ឆ្នេរ សមុទ្រ ដូចជា ព្រៃកោងកាងបណ្តោយឆ្នេរ កោងកាង ស្មៅសមុទ្រ ផ្កាថ្ម កោះ ។ល។
- បានបង្ក្រាបបទល្មើសធនធានធម្មជាតិ និងដកហូតវត្ថុតាងបទល្មើសធនធានធម្មជាតិ និងធ្វើកិច្ចសន្យា ដូចខាងក្រោម៖
  - បានធ្វើការចាប់ឃាត់ឈើមូលចំនួន ១០១ម៣២៤៥ + ៥១កំណាត់
  - បានធ្វើការចាប់ឃាត់ឈើអារចំនួន ៤៣៨ម៣៧១០ + ២៨១កំណាត់
  - បានធ្វើការចាប់ឃាត់ឈើប្រណិតចំនួន ២៧៦ម៣៥៦៤ + ៣កំណាត់
  - ឡជ្រុងចំនួន ៣៩ឡ
  - ខ្ទមជ័យ/ជំរុំចំនួន ២៥៤ខ្ទម
  - ម៉ាស៊ីនត្រង់សូន័រចំនួន ៥១១គ្រឿង
  - ម៉ាស៊ីនគោយន្តចំនួន ១០៦គ្រឿង
  - រណារដៃចំនួន ៤២៦គ្រឿង
  - ចាប់បានម៉ូតូចំនួន ៧៩គ្រឿង រថយន្តចំនួន ៣០គ្រឿង
  - កាំភ្លើងចំនួន ២៩០ដើម
  - ប្រមូលអន្ទាក់ចាប់សត្វ ស្នាៈតះចំនួន ៦ ៦៧៨ខ្សែ
  - អប់រំណែនាំចំនួន ៣៦នាក់ និងធ្វើកិច្ចសន្យាចំនួន ២១១នាក់។

## ៥.ការងារអភិវឌ្ឍសហគមន៍មូលដ្ឋាន

- បានបោះបង្គោលកំណត់ព្រំប្រទល់តំបន់បេតិកភណ្ឌធម្មជាតិ ចំនួន២០បង្គោល
- បានបោះបង្គោលព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិ ចំនួន ៤០បង្គោល
- បានចុះបោះបង្គោលព្រំប្រទល់ដីទីតាំងជាក់ស្តែង លើករណីស្នើសុំវិនិយោគគម្រោងអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិ ចំនួន២៥គម្រោង
- ចុះពិនិត្យវឌ្ឍនភាពទីតាំងគម្រោងអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិខ្នាតតូច (ទំហំមិនលើសពី ១០ហិកតា)សរុប ចំនួន ២០៦គម្រោង ក្នុងនោះខេត្តកំពង់ស្ពឺ ២៩គម្រោង ខេត្តកោះកុង

៣២គម្រោង ខេត្តសៀមរាប បាត់ដំបង ប៉ៃលិន ០៣គម្រោង ខេត្តមណ្ឌលគិរី ៥៧គម្រោង ខេត្តព្រះសីហនុ ៤១គម្រោង ខេត្តកំពត ៣៧គម្រោង និងខេត្តកែប ០៧គម្រោង

- ចុះពិនិត្យទីតាំងជាក់ស្តែង លើសំណើសុំវិនិយោគអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិ (ទំហំដីមិនលើសពី ១០ហិកតា)សរុបចំនួន ៨១គម្រោង ក្នុងនោះខេត្តមណ្ឌលគិរីចំនួន ២០គម្រោង ខេត្តព្រះសីហនុ ១២គម្រោង ខេត្តកោះកុង ១៤គម្រោង ខេត្តកំពត ១៩គម្រោង ខេត្តកំពង់ស្ពឺ ០៨គម្រោង ខេត្តសៀមរាប ០៦គម្រោង និង ខេត្តកំពង់ឆ្នាំង ០២គម្រោង។

## ៦. ការគ្រប់គ្រងចំណេះដឹង និងព័ត៌មានបរិស្ថាន

- បោះពុម្ពសៀវភៅគោលការណ៍សាលាមេត្រីបរិស្ថានចំនួន ១០០០ក្បាល
- បានពិនិត្យ វាយតម្លៃ និងជ្រើសរើសសាលាចំនួន ៦សាលា ដើម្បីប្រគល់ជ័យលាភីជាសាលាមេត្រីបរិស្ថានថ្នាក់ជាតិលើកទី៣ ឆ្នាំ២០២១ ក្នុងនោះមានសាលាបឋមសិក្សាចំនួន ៣ និងមធ្យមសិក្សាចំនួន ៣
- បានផលិតវីដេអូអប់រំបរិស្ថានផ្សេងៗចំនួន ២៥វីដេអូ រួមមានៈ វីដេអូមេរៀនអប់រំបរិស្ថានស្តីពីការប្រែប្រួលអាកាសធាតុចំនួន ៣វីដេអូ ការប្រែប្រួលអាកាសធាតុចំនួន ៤វីដេអូ ការគ្រប់គ្រងសំណល់ប្លាស្ទិកចំនួន ៣វីដេអូ វីដេអូខ្លីស្តីពី សាលារៀនដែលបានប្រតិបត្តិមេត្រីភាពបរិស្ថានបានល្អប្រសើរចំនួន ១០វីដេអូ និងវីដេអូខ្លីស្តីពី វត្តអារាមដែលបានប្រតិបត្តិមេត្រីភាពបរិស្ថានបានល្អប្រសើរចំនួន ៥វីដេអូ
- បានរៀបចំបោះពុម្ព Posters Calendar ចំនួន ៤០០ច្បាប់ ស្តីពី ការគ្រប់គ្រងសំណល់ និងផលប៉ះពាល់របស់សំណល់ប្លាស្ទិក
- បានផ្តល់បណ្ណសរសើរមេត្រីភាពបរិស្ថានសរុប ចំនួន ៣៧៥បណ្ណ ក្នុងនោះមានបណ្ណសរសើរចំនួន ៣៤៧បណ្ណ និងលិខិតថ្លែងអំណរគុណ ចំនួន ២៨លិខិត ដោយបានផ្តល់ដល់នីតិបុគ្គលរូបវន្តបុគ្គល និងមន្ត្រីឧទ្យានុរក្ស
- បានផ្តល់បណ្ណក្នុងកម្មវិធីប្រឡងប្រណាំងនានាសរុប ចំនួន ៩៤បណ្ណ រួមមានៈ ១)អង្គភាពគំរូវិស័យបរិស្ថាន ចំនួន ៤០បណ្ណ ២)វេទិកាយុវជនជជែកពិភាក្សាបរិស្ថាន ចំនួន ៤៣បណ្ណ និង ៣)ការប្រកួតវីដេអូខ្លី «សម្រស់ស្រុកយើង» ចំនួន ១១បណ្ណ
- បញ្ចប់ការកសាង និងបោះពុម្ពរបាយការណ៍ស្ថានភាពបរិស្ថានលើកទី៤ ឆ្នាំ២០២១ ទាំងភាសាជាតិ និងភាសាអង់គ្លេស
- បញ្ចប់ការបកស្រាយផែនទី និងបោះពុម្ពសៀវភៅស្តីពី ការវាយតម្លៃធនធានគម្របព្រៃឈើកម្ពុជាឆ្នាំ២០១៨ ចំនួន ១៥០០ក្បាល និងបញ្ចប់របាយការណ៍កម្រិតបំភាយយោងកម្ពុជាលើកទី២ និងផ្ញើទៅ UNFCCC សម្រាប់ជាមូលដ្ឋានបច្ចេកទេស (Baseline map) ក្នុងការវាយតម្លៃបរិមាណកាបូនស្តុក សម្រាប់អនុវត្តគ្រប់គម្រោងរេដបូកនៅកម្ពុជា
- បានផលិតផែនទីគម្រោងវិនិយោគអេកូទេសចរណ៍ធម្មជាតិ (ទំហំមិនលើសពី ១០ហិកតា) ក្នុងតំបន់ការពារធម្មជាតិ ចំនួន ៣៥ទីតាំង
- បានផលិតផែនទីសហគមន៍តំបន់ការពារធម្មជាតិ ចំនួន ០២ ក្នុងភូមិសាស្ត្រខេត្តកោះកុង

- បានពិនិត្យ រៀបចំទិន្នន័យ និងស្រង់ព័ត៌មានភូមិសាស្ត្រតំបន់សហគមន៍ការពារធម្មជាតិទៅក្នុង Attribute table នៃ Shapefile សរុបចំនួន ១៣៨តំបន់សហគមន៍ការពារធម្មជាតិ
- រៀបចំទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ៥ មិថុនា ក្រោមប្រធានបទ «ជីវៈចម្រុះនិងសុខភាពមនុស្ស»
- បានផលិតបទចម្រៀងមេត្រីភាពបរិស្ថាន ចំនួន ៣បទ រួមមាន៖ ១)ស្រែពកចាំស្នេហ៍ ២)បឹងស្នេហ៍ភ្ជាប់និស្ស័យ និង៣)កំពង់សោមសំណព្វចិត្ត
- បានផលិតបទចម្រៀងបរិស្ថានចំនួន ២៩បទ និងបានសហការផលិតបទចម្រៀងរវាងក្រសួងបរិស្ថាន និង AMS ចំនួន ៥បទ
- បានផលិតវីដេអូនិងបទយកការណ៍ចំនួន ៩៨វីដេអូ ក្នុងនោះ៖ ១)វីដេអូឯកសារចំនួន ៨វីដេអូ ២)បទយកការណ៍ខ្លីចំនួន ៨វីដេអូ ៣)កិច្ចសម្ភាសអបអរសាទរទិវាឧទ្យានុរក្សពិភពលោក ៣១ កក្កដាចំនួន ៣វីដេអូ ៤)វីដេអូអប់រំបរិស្ថានចំនួន ៩វីដេអូ ៥)វីដេអូខ្លីអំពីបរិស្ថានចំនួន ១៦វីដេអូ ៦)វីដេអូព័ត៌មានប្រចាំសប្តាហ៍ចំនួន ៣៥វីដេអូ ៧)គម្រោងវេជបូក និងជីវភាពសហគមន៍នៅតាមតំបន់ការពារធម្មជាតិចំនួន ៨វីដេអូ និង៨)ប្រធានបទសាលាមេត្រីបរិស្ថានអារាមមេត្រី តំបន់ការពារធម្មជាតិ និងសហគមន៍តំបន់ការពារធម្មជាតិចំនួន ១៥វីដេអូ
- បានផ្សព្វផ្សាយព័ត៌មានតាមប្រព័ន្ធវេបសាយ និងបណ្តាញទំនាក់ទំនងសង្គមរបស់ក្រសួងបរិស្ថាន ដូចជា៖ ១.ហ្វេសប៊ុកបាន ៩៦១អត្ថបទ និង ៣២៨វីដេអូ ២.គេហទំព័រ www.moe.gov.kh ៣០៨អត្ថបទ ៣.ទំព័រយូធូប ៥៩វីដេអូ ៤. Tik Tok ៣១វីដេអូ និង៥.ផ្តិតយករូបភាពនិងផលិតព័ត៌មាន ឯកឧត្តមរដ្ឋមន្ត្រី និងថ្នាក់ដឹកនាំក្រសួង ចំនួន ១៩កម្មវិធី
- នៅលើទំព័រហ្វេសប៊ុក មានអ្នក Likeថ្មី ចំនួន ៤២.៩៦៤នាក់ អ្នក Follow ថ្មីមានចំនួន **៣៥៩.៤១៦នាក់ សរុបផេក Like ៣១៧.៩៥៣ នាក់**
- បានរៀបចំប្រារព្ធទិវាអនាម័យបរិស្ថានជាតិ ២៣ វិច្ឆិកា ឆ្នាំ២០២១ ក្រោមប្រធានបទ «ភូមិឋានស្អាត សុខភាពល្អ ជីវិតរីករាយ» នៅខេត្តកំពត
- បញ្ចប់ការចងក្រងទស្សនាវដ្តីផ្ទ ទីុ៧ លេខទី១ និងរៀបចំចងក្រងទស្សនាវដ្តីបរិស្ថានឆ្នាំទី៧ លេខទី២ ឆ្នាំ២០២១ សម្រេចបាន៩០% ចំនួន ១២០០ក្បាល ។

## ៧. ការងារស្ត្រី យុវជន យេនឌ័រ និងកុមារតូចក្រសួងបរិស្ថាន

- បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យបរិស្ថានឆ្នាំ២០២១-២០២៥
- បានរៀបចំសិក្សាសាលា និងទស្សនកិច្ចសិក្សារបស់យុវជនវិស័យបរិស្ថាន នៅតំបន់ប្រាសាទនគរបាជ័យ ក្នុងខេត្តកំពង់ចាម និងតំបន់ទួលព័ន្ធតាឡី-បឹងស្នេហ៍ នៅខេត្តព្រៃវែង
- បានទស្សនកិច្ចសិក្សាភូមិកុមារ SOS ប្រចាំនៅខេត្តសៀមរាប និងកម្មវិធីបណ្តាញកិច្ចការពារកុមារក្នុងគ្រួសារនៅតាមសាលារៀន អនុវត្តដោយអង្គការក្លែនអន្តរជាតិ
- បានរៀបចំផែនការសកម្មភាព សម្រាប់ឆ្នាំ២០២១ ដើម្បីអនុវត្តគោលនយោបាយកិច្ចគាំពារមន្ត្រីរាជការក្រសួងបរិស្ថាន ក្នុងនោះ៖ ១. បានចុះជួបសំណេះសំណាល និងសួរសុខទុក្ខមន្ត្រី

ឧទ្យានុរក្ស និងប្រជាសហគមន៍ ក្នុងខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់ ២. បានជួបសំណេះសំណាលជាមួយប៉ូលីស សន្តិសុខ និងអ្នកអនាម័យក្រសួងបរិស្ថាន និងបានឧបត្ថម្ភថវិកានិងសម្ភារៈមួយចំនួន ៣.បានចាត់ចែងឧបត្ថម្ភអាហារូបករណ៍ដល់កូនមន្ត្រីរាជការ និងកូនប្រជាសហគមន៍ដែលមានជីវភាពខ្វះខាតចំនួន ១៥នាក់ ៤. បានជួយសម្របសម្រួល និងដោះស្រាយបញ្ហាទុក្ខលំបាករបស់មន្ត្រីរាជការ និងផ្តល់ថវិកាឧបត្ថម្ភចំនួន ១០៧រូប រួមមាន៖ មន្ត្រីរាជការជានារីដែលបានសម្រាលបុត្រចំនួន ៣២រូប មន្ត្រីរាជការដែលរៀបអាពាហ៍ពិពាហ៍ចំនួន ៤៨រូប មន្ត្រីរាជការដែលមានជំងឺនិងគ្រោះថ្នាក់ផ្សេងៗចំនួន ២០រូប មន្ត្រីរាជការដែលទទួលមរណភាពចំនួន ០៧រូប មន្ត្រីរាជការឆ្លងជំងឺកូវីដ១៩ ចំនួន ១៤០រូប បែកចែកថវិកាឧបត្ថម្ភដល់ស្ត្រីចំនួន ៣២០រូប ក្នុងទិវាអន្តរជាតិនារី ០៨មិនា ឆ្នាំ២០២១ និងបែកចែកថវិកាឧបត្ថម្ភដល់មន្ត្រីរាជការ និងមន្ត្រីស្ម័គ្រចិត្ត ក្រសួងបរិស្ថានក្នុងពិធីបុណ្យចូលឆ្នាំខ្មែរ បុណ្យភ្ជុំបិណ្ឌ និងបុណ្យចូលឆ្នាំសកល

- បានរៀបចំពិធីដាក់ឱ្យប្រើប្រាសជាផ្លូវការនូវ ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យបរិស្ថានឆ្នាំ២០២១-២០២៥
- បានរៀបចំសិក្ខាសាលាបូកសរុបការងារស្ត្រី យុវជន យេនឌ័រ និងកុមារវិស័យបរិស្ថានឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ នៅទីរួមខេត្តកែប។

## ៨. កិច្ចប្រជុំ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធឌីជីថល(Zoom)

ក. កិច្ចប្រជុំ

**១- កិច្ចប្រជុំជាមួយអន្តរជាតិ ឬ ថ្នាក់តំបន់ បានចំនួន ១៩ លើក**

- បានចូលរួមកិច្ចប្រជុំថ្នាក់តំបន់អាស៊ី-ប៉ាស៊ីហ្វិក ពាក់ព័ន្ធនឹងការរៀបចំ Online Segment សម្រាប់សន្និសីទនៃភាគីអនុសញ្ញា Basel, Rotterdam, និង Stockholm
- បានចូលរួមប្រជុំចំនួន ០៣លើក រួមមាន៖ ១.កិច្ចប្រជុំស្តីពី សារធាតុបំផ្លាញស្រទាប់អូហ្សូននិងកិច្ចប្រជុំក្រុមការងារលើកទី៤៣ នៃភាគីពិធីសារម៉ុងរ៉េអាល់ ២.កិច្ចប្រជុំស្តីពីការអភិវឌ្ឍផែនការសីតកម្មជាតិនៅកម្ពុជា និង៣. កិច្ចប្រជុំស្តីពី ការបង្កើតប្រព័ន្ធកូតានាំចូលសារធាតុ HFC ក្រោមវិសោធនកម្មក្រុងគីហ្គាលីនៃពិធីសារម៉ុងរ៉េអាល់
- បានចូលរួមប្រជុំ ស្តីពី National Climate Change Experts and relevant Government entities especially from the Transport, Energy and AFOLU sectors
- រៀបចំកិច្ចប្រជុំចំនួន ០៣លើក រវាងក្រុមការងារថ្នាក់ជាតិដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការក្នុងការប្រើប្រាស់ថាមពលនុយក្លេអ៊ែរសម្រាប់បម្រើឱ្យគោលបំណងសន្តិភាព និងក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានចូលរួមកិច្ចប្រជុំ ស្តីពីកិច្ចប្រជុំលើកទី២នៃក្រុមការងារជាន់ខ្ពស់ ដើម្បីជំរុញគម្រោងវិនិយោគរួមរវាងកម្ពុជានិងរុស្ស៊ី
- បានចូលរួមកិច្ចប្រជុំកំពូលទីក្រុងសេអ៊ូលទី២ នៃភាពជាដៃគូសម្រាប់ការអភិវឌ្ឍន៍បៃតង និងគោលដៅសកលឆ្នាំ ២០៣០ (P4G)

- បានចូលរួមកិច្ចប្រជុំនិងពិភាក្សា អំពីសំណើគម្រោងរបស់ក្រសួងបរិស្ថានពាក់ព័ន្ធនឹងការស្នើសុំថវិកាគាំទ្រមូលនិធិពិសេសនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ឆ្នាំ២០២១
- បានចូលរួមកិច្ចប្រជុំក្រុមការងារកិច្ចសហប្រតិបត្តិការកម្ពុជា-រុស្ស៊ី លើវិស័យបរិស្ថាន និងធនធានធម្មជាតិ ដឹកនាំដោយ ឯកឧត្តម អ៊ាង សុផល្លែត រដ្ឋលេខាធិការក្រសួងបរិស្ថាន និងលោក Inamov Nuritdin ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងធនធានធម្មជាតិ និងបរិស្ថានសហព័ន្ធរុស្ស៊ី
- បានចូលរួមកិច្ចប្រជុំ ស្ដីពី"ដំណោះស្រាយផ្អែកលើធម្មជាតិ ដើម្បីកិច្ចការស្ដារសេដ្ឋកិច្ចជាតិឡើងវិញ" រៀបចំដោយអង្គការ IUCN ដែលមានសមាជិកទាំងអស់៩១ប្រទេស
- ចូលរួមកិច្ចប្រជុំកំពូលលើកទី៣ ស្តីពី «Sweden-Southeast Asia Business Reset Summit Singapore»
- ចូលរួមកិច្ចប្រជុំពិភាក្សា ស្តីពីការបញ្ចូលឥណទានកាបូននៅក្នុងទីផ្សារស្ម័គ្រចិត្ត(VCMI) ជាមួយទីភ្នាក់ងារអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)
- បានចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី នៅក្នុងកិច្ចប្រជុំជាន់ខ្ពស់ថ្នាក់រដ្ឋមន្ត្រី នៃក្រុមប្រទេសអភិវឌ្ឍន៍តិចតួច (LDCs) ស្តីពីការប្រែប្រួលអាកាសធាតុ និងបានរៀបចំជំហររបស់បណ្តាប្រទេស LDCs នៅក្នុងសន្និសីទកំពូលលើកទី២៦នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពី ការប្រែប្រួលអាកាសធាតុ (CoP26) នៅចក្រភពអង់គ្លេស
- បានចូលរួមកិច្ចប្រជុំ ស្តីពី "The fifteen meeting of the conference of the parties to the Conversation on Biological Diversity (COP15) and the concurrent meeting of the parties to the Parties to the Cartagena Protocol (CP-MOP-10) and Nagoya Protocol (NP-MOP4)
- ចូលរួមកិច្ចប្រជុំអនឡាញជាមួយ UNDP និង UNOP ពិភាក្សាអំពីរបៀបវារៈ និងការរៀបចំបទបង្ហាញសម្រាប់រៀបចំសិក្ខាសាលាពិគ្រោះយោបល់លើកទី២
- ចូលរួមកិច្ចប្រជុំក្រុមបច្ចេកទេស MRV/FRL ស្តីពីក្របខ័ណ្ឌពង្រឹងតម្លាភាពក្រោមកិច្ចព្រមព្រៀងប៉ារីស៍ស្តីពី អាកាសធាតុ (Enhanced Transparency Framework under the Paris Agreement) និងពិភាក្សាលើការពង្រឹងរចនាសម្ព័ន្ធ និងសកម្មភាពការងារសមាជិកក្រុមដើម្បីធ្វើរបាយការណ៍ស្តីពី ក្របខ័ណ្ឌពង្រឹងតម្លាភាព
- បានចូលរួមកិច្ចប្រជុំ ជាមួយភាគ ROSATOM លើការជ្រើសរើសនិស្សិតអាហារូបករណ៍ទៅសិក្សានៅប្រទេសរុស្ស៊ី ក្នុងឆ្នាំ២០២២ ដែលក្នុងនោះ ក៏មានបង្ហាញនៅកាលវិភាគដំណាក់កាល និងលក្ខន្តិកៈ ក្នុងការជ្រើសរើស សិស្សថ្នាក់បរិញ្ញាបត្រ និងអនុបណ្ឌិតជំនាញវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានុយក្លេអ៊ែរ។

## ២-កិច្ចប្រជុំផ្ទៃក្នុង បានចំនួន ៦២ លើក

- បានរៀបចំកិច្ចប្រជុំអន្តរអគ្គនាយកដ្ឋាន ដើម្បីពិនិត្យពិភាក្សាឆ្លងសេចក្តីព្រាងអនុក្រឹត្យស្តីពីកិច្ចគាំពារកាំរស្មីអ៊ីយ៉ុងកម្មចំនួន ៦លើក

- បានរៀបចំកិច្ចប្រជុំពិភាក្សាលើការរៀបចំអនុក្រឹត្យ ស្តីពីការគ្រប់គ្រងគុណភាពខ្យល់ សំឡេង និងរំញ័រ ចំនួន ៣លើក
- បានរៀបចំកិច្ចប្រជុំរបស់នាយកដ្ឋានចំនួន ១៣លើក ស្តីពី៖ ក)ការតាមដានវឌ្ឍនភាពការងារ ពិនិត្យ និងពិភាក្សាលើសកម្មភាពអាទិភាពសម្រាប់ឆ្នាំ២០២១ របស់ការិយាល័យជំនាញចំណុះនាយកដ្ឋាន ខ)ការរៀបចំទិវាជីវៈចម្រុះអន្តរជាតិ គ)ពិនិត្យលទ្ធភាពនៃការគ្រប់គ្រងធនធានជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ី និងឃ) ការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រមូលនិងការបែងចែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានពន្ធុ
- បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ខេត្ត ស្តីពី «ការកំណត់បែងចែកតំបន់គ្រប់គ្រង និងផែនការគ្រប់គ្រងដែនជម្រកសត្វព្រៃតាតៃ»
- បានចូលរួមកិច្ចប្រជុំ ស្តីពីការស្តារឡើងវិញតំបន់ភ្លើងឆេះព្រៃនៅតាមតំបន់ខេត្តដែលមានព្រំប្រទល់ជាប់នឹងប្រទេសថៃ
- រៀបចំកិច្ចប្រជុំ ស្តីពីវឌ្ឍនភាពការងារនិងទិសដៅបន្តរបស់អគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថានដើម្បី៖១)ពិនិត្យផែនការសកម្មភាពនិងគោលដៅរបស់នាយកដ្ឋាន ២)ពង្រឹងការងារផ្ទៃក្នុង ៣)រៀបចំរបាយការណ៍ពេញលេញរបស់នាយកដ្ឋាន និង៤) បញ្ហាផ្សេងៗក្នុងបរិបទនៃជំងឺកូវីដ-១៩
- ចូលរួមប្រជុំពិនិត្យលើសេចក្តីព្រាង ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន
- ចូលរួមកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន និងសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការកែសម្រួលមាត្រា១០នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤០៣ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- ចូលរួមកិច្ចប្រជុំ ស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយសម្រាប់ក្រសួងបរិស្ថាន
- ចូលរួមកិច្ចប្រជុំ ស្តីពីការពិនិត្យ និងកែសម្រួលសេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ (ក.វ.ស.) ៣ឆ្នាំរំកិល ២០២២-២០២៤
- ប្រជុំណែនាំពីការរៀបចំធាតុចូល សម្រាប់រៀបចំរបាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ ២០២១នៃការអនុត្តផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ
- រៀបចំកិច្ចប្រជុំ ស្តីពីការសម្រេចជ្រើសរើសជ័យលាភី សាលាមេត្រីបរិស្ថានថ្នាក់ជាតិ លើកទី៣ ឆ្នាំ២០២១
- បានចូលរួមកិច្ចប្រជុំ ស្តីពី «ការពិនិត្យវឌ្ឍនភាពគម្រោងនិរន្តរភាពតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិកម្ពុជា »
- បានចូលរួមក្នុងកម្មវិធីប្រកាសដាក់ឱ្យប្រើប្រាស់ និងផ្សព្វផ្សាយ «របាយការណ៍ស្ថានភាពបរិស្ថានលើកទី៤ និងសៀវភៅធនធានគម្របព្រៃឈើកម្ពុជា២០១៨»

- ចូលរួមកិច្ចប្រជុំអនឡាញ ស្តីពីផែនការសកម្មភាពការងារ និងផែនការថវិកាឆ្នាំ២០២២ នៃគណៈកម្មាធិការមូលនិធិបរិស្ថាននិងសង្គម ចំនួន ២លើក
- ចូលរួមប្រជុំពិភាក្សា ស្តីពី ារតែងតាំងសមាសភាពលេខាធិការដ្ឋាននៃគណៈកម្មាធិការមូលនិធិបរិស្ថាន និងសង្គម ចំនួន ៣លើក
- បានចូលរួមកិច្ចប្រជុំគម្រោង ស្តីពីការសាងសង់បង្គន់អនាម័យបំពាក់សូឡា នៅកោះរ៉ុង
- បានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសពិគ្រោះយោបល់លើការរៀបចំប្លង់ និងផែនការមេរបស់មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកូល សុខ អាន ភ្នំគូលែន ចំនួន ៤លើក
- បានរៀបចំកិច្ចប្រជុំជាមួយទីប្រឹក្សាបច្ចេកទេស ដើម្បីរៀបចំប្រព័ន្ធទិន្នន័យជីវៈចម្រុះជាតិ
- បានរៀបចំកិច្ចប្រជុំរៀបចំអនុក្រឹត្យ ស្តីពីការប្រមូលនិងការបែងចែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានជីវៈចម្រុះ ( ABS) ចំនួន ៥លើក
- បានចូលរួមកិច្ចប្រជុំស្តីពី «ការជំរុញការកំណត់ និងបោះបង្គោលព្រំ បែងចែកតំបន់គ្រប់គ្រង និងចុះបញ្ជីដីរដ្ឋ នៅតាមតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ»
- បានចូលរួមកិច្ចប្រជុំ ពិនិត្យលើវឌ្ឍនភាពនៃផែនការផលិតក្តារមឈូស សម្រាប់តម្កល់សពអ្នកជំងឺ កូវីដ១៩
- បានរៀបចំកិច្ចប្រជុំ ពិនិត្ ពិភាក្សាលើករណីស្នើសុំអនុម័តប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍ នៃគម្រោងអភិវឌ្ឍន៍ ទេសចរណ៍ធម្មជាតិខ្នាតតូច ចំនួន ៥គម្រោង ស្ថិតក្នុង ឧទ្យានជាតិព្រះមុនីវង្ស«បូកគោ» នៅទីស្តីការក្រសួងបរិស្ថាន
- បានចូលរួមកិច្ចប្រជុំ ផ្សព្វផ្សាយលើការជំរុញការងារចុះបញ្ជីទ្រព្យសម្បត្តិរដ្ឋ និងពង្រឹងប្រសិទ្ធភាពគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៅតាមបណ្តាអង្គភាពប្រើប្រាស់ប្រកបដោយការទទួលខុសត្រូវ
- បានចូលរួមកិច្ចប្រជុំ ស្តីពី "Informal session of the Subsidiary Body on Scientific, Technical and Technological Advice ( SBSTTA-24 )" និង "Informal session of the Subsidiary Body on Implementation ( SBI-3 )
- បានចូលរួមកិច្ចប្រជុំ និងធ្វើបទបង្ហាញអំពីគំនិតផ្តួចផ្តើមសម្រាប់ការរៀបចំគម្រោងសំណើដើម្បីបន្តការងារការរៀបចំការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី PES នៅឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម"ភ្នំគូលែន"
- បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ ចំនួន៤លើក ១)ការរៀបចំផែនការសកម្មភាពសម្រាប់ការអភិរក្ស និងការប្រើប្រាស់ធនធានជីវៈចម្រុះ និងប្រព័ន្ធ អេកូឡូស៊ីប្រកបដោយនិរន្តរភាពនៅតំបន់ភាគខាងជើងនៃប្រទេសកម្ពុជា ២)ជាមួយភាគីកូរ៉េ សម្រាប់ការរៀបចំគម្រោងសំណើស្តីពីការរៀបចំផែនទីប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះ នៅឧទ្យានជាតិព្រះជ័យវរ្ម័ននរោត្តម "ភ្នំគូលែន" និង ដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព ៣)ជាមួយអ្នកជំនាញខាងផែនទីទឹក និងតំណាងកម្មវិធីអភិវឌ្ឍន៍ សហប្រជាជាតិ (UNDP) ដើម្បីពិនិត្យនិងពិភាក្សា

អំពីការរៀបចំផែនការតាមដានគុណភាព និងបរិមាណទឹកសាប នៅតំបន់ប្រើប្រាស់ច្រើនយ៉ាងព្រែកទឹកសាបក្បាលឆាយ ក្នុងខេត្តព្រះសីហនុ នៅអំឡុងពេលអនុវត្តសាកល្បងការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី(PES) និង ៤)ជាមួយ GDANCP នៃគម្រោងនិរន្តរភាពតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិកម្ពុជា

- បានរៀបចំកិច្ចប្រជុំស្តីពី ការរៀបចំរបាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣
- ចូលរួមកិច្ចប្រជុំស្តីពី «ការត្រួតពិនិត្យការអនុវត្តកិច្ចលទ្ធកម្ម ៩ខែដើមឆ្នាំ២០២១ និងការណែនាំអំពីការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ២០២២»
- ចូលរួមប្រជុំពិនិត្យអំពីវឌ្ឍនភាពការងារក្នុងការរៀបចំមហាសន្និបាតសមុទ្រអាស៊ី-បូព៌ាឆ្នាំ២០២១ និងវេទិកាថ្នាក់រដ្ឋមន្ត្រីលើកទី៧ នៃភាពជាដៃគូក្នុងការគ្រប់គ្រងបរិស្ថានសមុទ្រអាស៊ីបូព៌ា ក្រោមអធិបតីភាព ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

**៣- កិច្ចប្រជុំជាមួយដៃគូពាក់ព័ន្ធក្នុងស្រុក បានចំនួន ៣៤ លើក**

- បានចូលរួមប្រជុំពិភាក្សា ស្តីពីបញ្ហាប្រឈមពាក់ព័ន្ធនឹងការរៀបចំការកំណត់កម្រៃសេវាប្រមូល សម្អាត និងដឹកជញ្ជូនសំរាម សំណល់រឹង និងកាលានុវត្តភាពក្នុងការកែសម្រួលប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ក្នុងខេត្តត្បូងឃ្មុំ ព្រៃវែង និងខេត្តព្រះសីហនុ
- បានរៀបចំកិច្ចប្រជុំលើកទី១របស់ក្រុមការងារសម្របសម្រួលបច្ចេកទេសគម្រោង ស្តីពីការវាយតម្លៃ តម្រូវការបច្ចេកវិទ្យា និងផែនការសកម្មភាព ដែលគាំទ្រដល់ការប្រើប្រាស់បច្ចេកវិទ្យាមេត្រីភាពបរិស្ថានក្នុងតំបន់សេដ្ឋកិច្ចពិសេស ក្នុងខេត្តព្រះសីហនុ
- បានចូលរួមកិច្ចប្រជុំជាមួយ GGGI ដើម្បីពិភាក្សាលើគំនិតក្នុងការរៀបចំយុទ្ធសាស្ត្រទំនាក់ទំនងទីក្រុងនិរន្តរភាព ផ្តោតលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍទីក្រុងនិរន្តរភាពឆ្នាំ២០២០-២០៣០ សម្រាប់ក្រុងគោលដៅទាំង៧
- បានចូលរួមកិច្ចប្រជុំជាមួយតំណាង Global Network of Local and Regional Governments Committed to Sustainable Urban Development: ICLEI
- បានចូលរួមកិច្ចប្រជុំពិភាក្សាលើផែនការអនុវត្តគម្រោង USAIDព្រៃឡង់បៃតងនៅឆ្នាំទី៤ និងទី៥ ដែលដឹកនាំដោយ ឯកឧត្តម សៅ សុភាព រដ្ឋលេខាធិការក្រសួងបរិស្ថាន ជាមួយលោក Matthew Edwardson ប្រធានគម្រោង USAID ព្រៃឡង់បៃតង និងសហការី
- បានចូលរួមកិច្ចប្រជុំវឌ្ឍនភាពនៃកិច្ចសហការជាមួយអង្គការ MJP និងអង្គការ FFI ក្នុងការចុះសិក្សាស្រាវជ្រាវជីវចម្រុះក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងសំឡូត ខេត្តបាត់ដំបង
- បានចូលរួមកិច្ចប្រជុំ ស្តីពី«ការពិនិត្យអនុវត្តគម្រោង និងការបង់ចំណូលពីគម្រោងវិនិយោគទុនរ៉ែមាស និងការបំពេញកាតព្វកិច្ចហិរញ្ញវត្ថុកិច្ចផ្សេងៗរបស់ក្រុមហ៊ុន XING YUAN KANNG YEAK Co.,LTD ដែលមានអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែមាស នៅក្នុងតំបន់អូរខ្និកខ្លក់ ស្រុកសំបូរ ខេត្តក្រចេះ

- បានចូលរួមប្រជុំពិគ្រោះយោបល់ថ្នាក់ខេត្តលើកទី២ ស្តីពីការរៀបចំកំណត់ និងបែងចែកតំបន់គ្រប់គ្រង និងផែនការគ្រប់គ្រងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់
- បានចូលរួមប្រជុំពិគ្រោះយោបល់ ស្តីពីការផ្ទៀងផ្ទាត់ដីត្រួតស៊ីគ្នារវាង ផ្ទៃដីរបៀងអភិរក្សជីវៈចម្រុះជាមួយដីក្រុមហ៊ុនសម្បទានសេដ្ឋកិច្ច ស្ថានីយសិក្សាស្រាវជ្រាវ សហគមន៍ព្រៃឈើ តំបន់សក្តានុពលសហគមន៍ព្រៃឈើ និងតំបន់ REDD+
- បានចូលរួមកិច្ចប្រជុំ ស្តីពីវឌ្ឍនភាពនៃការរៀបចំបញ្ជីត្រៀមបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ (UNESCO)
- បានចូលរួមកិច្ចប្រជុំ ពិនិត្យមើលឡើងវិញនូវផែនការឆ្លើយតបនឹងសេចក្តីសន្និដ្ឋាន ៥៧ ចំណុច របស់គណៈកម្មាធិការ CEDAW នៃអង្គការសហប្រជាជាតិលើរបាយការណ៍ជាតិលើកទី៦របស់កម្ពុជា
- បានចូលរួមប្រជុំប្រចាំខែ ជាមួយក្រុមការងារគម្រោង និងជំនាញការ JICA ពិភាក្សាលើវឌ្ឍនភាព និងបញ្ហាប្រឈមលើការអនុវត្តគម្រោងអភិវឌ្ឍន៍សមត្ថភាព ក្នុងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ចូលរួមកិច្ចប្រជុំ ពិនិត្យ និងពិភាក្សា អំពីទីតាំងដីដែលត្រូវបានកាត់ឆ្វៀលនៅក្នុងតំបន់ការពារធម្មជាតិ នៅភូមិសាស្ត្រខេត្តកោះកុង របស់គម្រោង និរន្តរភាពតំបន់ទេសភាពនិងទេសចរណ៍ធម្មជាតិកម្ពុជា
- បានចូលរួមប្រជុំ ស្តីពីវឌ្ឍនភាពនៃការពិនិត្យ សិក្សា និងចងក្រងឯកសារទីតាំងដី ដែលប្រជាពលរដ្ឋបានប្រើប្រាស់ និងអាស្រ័យផលជាក់ស្តែង ក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះភូមិសាស្ត្រខេត្តកំពត
- ចូលរួមកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ នៃគម្រោងការបញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិទៅក្នុងតំបន់ទេសភាពនៃព្រៃធម្មជាតិ និងផលិតភាពធម្មជាតិ នៅតំបន់ភាគខាងជើង នៃប្រទេសកម្ពុជា (INRM)
- ចូលរួមប្រជុំពិភាក្សាក្នុងការតម្រង់ទិសការអនុវត្តគម្រោងព្រៃបៃតង (GPL-USAID) ក្រោមកិច្ចសហប្រតិបត្តិការរវាងក្រសួងបរិស្ថាន និងគម្រោង GPL-USAID
- បានរៀបចំកិច្ចប្រជុំលើកទី២ របស់ក្រុមការងារសម្របសម្រួលបច្ចេកទេសគម្រោង ស្តីពីការវាយតម្លៃតម្រូវការបច្ចេកវិទ្យានិងផែនការសកម្មភាព ដែលគាំទ្រដល់ការប្រើប្រាស់បច្ចេកវិទ្យាមេត្រីភាពបរិស្ថានក្នុងតំបន់សេដ្ឋកិច្ចពិសេស ក្នុងខេត្តព្រះសីហនុ
- បានចូលរួមកិច្ចប្រជុំ ស្តីពី "The Development of Sustainable Financing Strategies for Srepok and Phnom Prich Wildlife Sanctuaries"
- បានចូលរួមកិច្ចប្រជុំពិភាក្សាទៅលើដំណើរការ និងលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសគម្រោងសាកល្បង និងប្រមូលគំនិតសម្រាប់គម្រោងសាកល្បងទៅលើប្រធានបទអាទិភាព (Priority Theme) ចំនួន៦ ដើម្បីជ្រើសរើសគម្រោងសាកល្បង

- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ខេត្តលើកទី១ ស្តីពីការកំណត់បែងចែកតំបន់គ្រប់គ្រង និងផែនការគ្រប់គ្រងដែនជម្រកសត្វព្រៃភ្នំសំកុស ដែលមានតំណាងខេត្តទាំង៣ពាក់ព័ន្ធ គឺខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង និងខេត្តកោះកុង
- បានចូលរួមកិច្ចប្រជុំក្រុមការងារនៃកម្មវិធីតាមដានសុខភាពសត្វព្រៃកម្ពុជាដែលរៀបចំ និងសម្របសម្រួលដោយអង្គការសមាគមអភិរក្សសត្វព្រៃ(WCS)
- បានចូលរួមស្តាប់បាឋកថាស្តីពី «Cambodia & ASEAN and Cambodia as ASEAN Chairmanship 2022»
- ចូលរួមកិច្ចប្រជុំជាមួយក្រុមការងារ CEMIS ដើម្បីពិភាក្សាលើការបញ្ចូលទិន្នន័យសម្រាប់កសាងមូលដ្ឋានទិន្នន័យ (Database)
- ចូលរួមកិច្ចប្រជុំអនឡាញ ជាមួយក្រុមការងារបច្ចេកទេសនៃវិទ្យាស្ថានស្រាវជ្រាវព្រៃឈើ និងផលិតផល ព្រៃឈើ (FFPRI, Japan) អំពីវិធីសាស្ត្រ FRL Allocation
- ចូលរួមកិច្ចប្រជុំអនឡាញ ជាមួយកម្មវិធី Silvar Carbon ពិភាក្សាអំពីវឌ្ឍនភាពការងារកសាងផែនទីដីកសិកម្ម និងកំណត់ការងារបច្ចេកទេសដែលត្រូវអនុវត្តបន្ត
- ចូលរួមកិច្ចប្រជុំជាមួយក្រុមការងារវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់(MRV/REL) ស្តីពីក្របខ័ណ្ឌពង្រឹងតម្លាភាពក្រោមកិច្ចព្រមព្រៀងប៉ារីស៍ស្តីពី អាកាសធាតុ
- បានចូលរួមកិច្ចប្រជុំស្តីពីការអនុវត្តការងារ ការពង្រឹងសមត្ថភាពក្នុងការរៀបចំផែនការ និងការគ្រប់គ្រងតំបន់ទេសភាពក្នុងតំបន់ការពារធម្មជាតិ «និរន្តរភាពតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិកម្ពុជា»
- បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ខេត្ត ស្តីពី ការដាក់តំបន់ការពារទេសភាពបឹងព្រែកល្ពៅ ជាតំបន់រ៉ាមសារ
- ចូលរួមកិច្ចប្រជុំពិភាក្សាស្តីពីការបញ្ចូលឥណទានកាបូននៅក្នុងទីផ្សារស្ម័គ្រចិត្តជាមួយទីភ្នាក់ងារអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)
- ចូលរួមប្រជុំស្តីពី វឌ្ឍនភាពនៃការពិនិត្យ សិក្សា និងចងក្រងឯកសារទីតាំងដី ដែលប្រជាពលរដ្ឋបានប្រើប្រាស់ និងអាស្រ័យផលជាក់ស្តែង ក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ ភូមិសាស្ត្រខេត្តកំពត
- ចូលរួមកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធនៃគម្រោង "ការបញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិទៅក្នុងតំបន់ទេសភាពនៃព្រៃធម្មជាតិ និងផលិតភាពធម្មជាតិ នៅតំបន់ភាគខាងជើង នៃប្រទេសកម្ពុជា (INRM)"
- ចូលរួមកិច្ចប្រជុំស្តីពី ការបង្កើត DATA CENTER របស់គម្រោងកែលម្អវិស័យធារាសាស្ត្រកសិកម្ម IAIP
- ចូលរួមកិច្ចប្រជុំស្តីពី ការផ្ទេរការងារនៃការប្រមូលទិន្នន័យមូលដ្ឋានតំបន់ការពារធម្មជាតិដោយប្រើប្រាស់ឧបករណ៍ METT របស់គម្រោង «និរន្តភាពតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិកម្ពុជា»

- ចូលរួមកិច្ចប្រជុំស្តីពី ការណែនាំគម្រោង «និរន្តភាពតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិកម្ពុជា» ដល់ទីប្រឹក្សាដែលទើបចូលថ្មី។

## ៤- កិច្ចប្រជុំជាមួយអន្តរក្រសួង បានចំនួន ១៨ លើក

- បានប្រជុំអន្តរក្រសួង ដើម្បីពិនិត្យលើរបាយការណ៍សិក្សាសមិទ្ធិលទ្ធភាព របស់គម្រោងវិនិយោគប្រមូល និងប្រព្រឹត្តកម្មសំណល់វេជ្ជសាស្ត្រ ក្នុងព្រះរាជាណាចក្រកម្ពុជា
- រៀបចំកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីសម្រេចរបស់ក្រសួងបរិស្ថានលេខ ០២២ សសរ ប.ស្ត ស្តីពីការបង្កើតក្រុមការងារចំពោះកិច្ចសម្របសម្រួល និងគ្រប់គ្រងគម្រោងលេខាធិការដ្ឋាន និងអនុក្រុមការងារបច្ចេកទេស សម្រាប់ការអនុវត្តគម្រោង Vegetation Survey
- បានរៀបចំកិច្ចប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងសេចក្តីសម្រេចអន្តរក្រសួង ស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលអន្តរក្រសួង សម្រាប់ភាពស៊ាំនៃឱសថប្រឆាំងមេរោគ (ចំនួន២លើក)
- រៀបចំកិច្ចប្រជុំអន្តរក្រសួង ស្តីពីសំណើសុំពន្យារពេលអនុគ្រោះចំពោះការអនុវត្តស្តង់ដារ EURO IV ចំពោះរថយន្តម៉ាក FORD XLT របស់ក្រុមហ៊ុន RMA CAMBODIA PLC. ដឹកនាំដោយឯកឧត្តម សៅ សុភាព រដ្ឋលេខាធិការក្រសួងបរិស្ថាន
- បានចូលរួមប្រជុំជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំនួន០២លើក៖
  - កម្មវិធីការបញ្ជ្រាបការយល់ដឹងអំពីមុខងារលទ្ធកម្មពេញលេញនិងមុខងាររៀបចំផែនការថវិកា
  - ការត្រួតពិនិត្យការអនុវត្តកិច្ចលទ្ធកម្ម ៩ខែដើមឆ្នាំ២០២១ និងការណែនាំអំពីការរៀបចំផែនការលទ្ធកម្មប្រចាំ ឆ្នាំ២០២២
- បានចូលរួមកិច្ចប្រជុំ ស្តីពីកម្មវិធីបញ្ជ្រាបការយល់ដឹងស្តីពីនីតិវិធីអនុវត្តការងារថ្មីសម្រាប់ចំណាយទូទាត់ត្រង់ដែលមានហានិភ័យទាបតាមប្រព័ន្ធ FMIS
- ចូលរួមប្រជុំសម្រាប់ត្រៀមប្រជុំជាមួយក្រុមប្រឹក្សាអ្នកច្បាប់ ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើតនិងដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញាអគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិ និងតំបន់ការពារធម្មជាតិនីមួយៗ
- បានប្រជុំអន្តរក្រសួងរវាងក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទាំងពីរកម្រិត (បច្ចេកទេសនិងថ្នាក់ដឹកនាំ) ដើម្បីចរចារកញ្ចប់ថវិកាឆ្នាំ២០២២ របស់ក្រសួងបរិស្ថាន
- ចូលរួមប្រជុំ ស្តីពី CAM Irrigated Agriculture Improvement Project-Request for Mission Concurrence ដឹកនាំដោយ ឯកឧត្តម ចាន់ ស៊ីណាត អនុរដ្ឋលេខាធិការ នៃក្រសួងធនធានទឹក និងឧតុនិយម និងជានាយកគម្រោង PUM-ADB and WB Mowram នៅសាលប្រជុំរង្វង់ទីស្តីការក្រសួងធនធានទឹកនិងឧតុនិយម
- ប្រជុំអន្តរក្រសួង ស្តីពីការពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមចំនួន ២គម្រោង។

- បានចូលរួមកិច្ចប្រជុំលើកដំបូងរបស់គណៈកម្មាធិការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន ដឹកនាំដោយឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន
- បានចូលរួមកិច្ចប្រជុំជាមួយគណៈកម្មាធិការដឹកនាំការងារ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (របាយការណ៍ត្រីមាសទី១និងទី២ ឆ្នាំ២០២១ នៃការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ បូក២)។
- បានប្រជុំពិនិត្យ និងផ្ដល់យោបល់តាមOnline លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដំបូងបានចំនួន១៣គម្រោង
- បានចូលរួមកិច្ចប្រជុំតាមរយៈប្រព័ន្ធ Zoom ជាមួយក្រុមប្រឹក្សាស្ដារអភិវឌ្ឍវិស័យ កសិកម្ម និងជនបទរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី ស្ដីពីអាហារូបត្ថម្ភដើម្បីការលូតលាស់និងកំណើន ក្នុងគោលបំណង ដើម្បីរៀបចំផែនការនិងការប្ដេជ្ញាចិត្តរបស់កម្ពុជា ស្ដីពីអាហារូបត្ថម្ភ សម្រាប់គណៈប្រតិភូកម្ពុជា ចូលរួមកិច្ចប្រជុំកំពូល ស្ដីពីអាហារូបត្ថម្ភដើម្បីការលូតលាស់ និងកំណើន នៅទីក្រុងតូក្យូ ប្រទេសជប៉ុន
- បានចូលរួមកិច្ចប្រជុំពិភាក្សាតាមរយៈប្រព័ន្ធ Zoom ជាមួយគណៈកម្មាធិការដឹកនាំការងារ កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីដំណើរការការរៀបចំសិក្ខាសាលាចែករំលែកបទពិសោធន៍ និងការអនុវត្តថវិកាកម្មវិធី ដែលនៅក្នុងសិក្ខាសាលានេះ ក្រសួងបរិស្ថានមានបទបង្ហាញ ស្ដីពីការបង្កើតអង្គភាពថវិកា និងបង្កើនសិទ្ធិអំណាចដល់អង្គភាពថវិកា។
- ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃស្ដីពី ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព តាមរយៈអនឡាញ Zoom Meeting ដែលដឹកនាំដោយ សម្ដេចក្រឡាហោម ស ខេង។

ខ. សិក្ខាសាលា

**១- សិក្ខាសាលាជាមួយអន្តរជាតិ ឬថ្នាក់តំបន់ បានចំនួន ០៧ លើក**

- ចូលរួមសិក្ខាសាលាលើកទី២ ពីការរៀបចំ និងកសាងរបៀបវារៈស្រាវជ្រាវជាតិតាមរយៈប្រព័ន្ធវីដេអូពីចំងាយ
- ចូលរួមសិក្ខាសាលាស្ដីពី Sustainable Forest Trade in the Lower Mekong Region
- ចូលរួមសិក្ខាសាលាលើសេចក្ដីព្រាងផែនទីបង្ហាញផ្លូវការប្រើប្រាស់ និងផលិតកម្មដោយនិរន្តភាព។ អង្គសិក្ខាសាលាបានទទួលយកមតិយោបល់ពីភាគីពាក់ព័ន្ធដើម្បីឱ្យមានតម្លៃជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចដោយចីរភាព
- បានចូលរួមសិក្ខាសាលាស្ដីពី « Ecological Protection and Management for Developing Countries» នៃ Economic and Commercial Counselor's Office Embassy of the People's Republic of China ។

- បានចាត់បញ្ជូនមន្ត្រី ចំនួន១រូប ចូលរួមសិក្ខាសាលាថ្នាក់អន្តរជាតិតាមប្រព័ន្ធ (Online) ស្តីពី National Water Resources Management Data Center របស់គម្រោងកែលម្អវិស័យធារាសាស្ត្រកសិកម្ម IAIP នៅរាជធានីភ្នំពេញ
- សិក្ខាសាលាថ្នាក់តំបន់ ស្តីពីរបាយការណ៍តាមដានគុណភាពទឹក ២០១៩ និង វគ្គបណ្តុះបណ្តាលអំពីការវិភាគ
- បានចូលរួមសិក្ខាសាលា ' ROSATOM-Russian –ASEAN Business Council Energy Corporation Development Between Russian and ASEAN" ។

## ២- សិក្ខាសាលាផ្ទៃក្នុង បានចំនួន ០៣ លើក

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានក្នុងនោះរួមមាន៖ ១).សៀវភៅណែនាំ ស្តីពីការងារដោះស្រាយផលប៉ះពាល់លើការតាំងទីលំនៅដ្ឋាន ដោយមិនស្ម័គ្រចិត្តសម្រាប់គម្រោងអភិវឌ្ឍន៍ឯកជន ២).ប្រកាស ស្តីពីចំណាត់ថ្នាក់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងអភិវឌ្ឍន៍ និង ៣).ប្រកាស ស្តីពីនីតិវិធីនិងការអនុវត្តគោលការណ៍ណែនាំសម្រាប់តារាងផ្ទៀងផ្ទាត់ ក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងចំនួន៥វិស័យ
- ចូលរួមសិក្ខាសាលា ស្តីពីការធ្វើបច្ចុប្បន្នភាពទិន្នន័យ GIS រវាងក្រុមហ៊ុន DVIP ក្រសួងបរិស្ថាន និងក្រសួងអភិវឌ្ឍន៍ជនបទនៃគម្រោងនិរន្តភាពតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិកម្ពុជា។
- បានចូលរួមសិក្ខាសាលា ស្តីពីការរៀបចំសិក្សារយៈពេលបំពេញបែបបទបញ្ចេញទំនិញ ឆ្នាំ២០២១ (Time Release Study 2021) ។

## ៣- សិក្ខាសាលាជាមួយដៃគូពាក់ព័ន្ធក្នុងស្រុក បានចំនួន ០៦ លើក

- ចូលរួមក្នុងសិក្ខាសាលាស្តីពី «ឥណ្ឌូ-ប៉ាស៊ីហ្វិកនិងបើកចំហ និងកិច្ចសហប្រតិបត្តិការនាពេលអនាគត»
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីការកាត់បន្ថយការប្រើប្រាស់ផលិតផលនិងសម្ភារប្លាស្ទិក ក្រោមកិច្ចសហការជាមួយគម្រោងជំរុញបរិយាកាសអំណោយផល សម្រាប់ការអភិវឌ្ឍដោយចីរភាព
- ចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ខេត្ត ស្តីពី «ការរៀបចំគម្រោងការលើកកម្ពស់ការគ្រប់គ្រងទឹកក្រោមដីឆ្លងដែនប្រកបដោយចីរភាព រវាងតំបន់ទំនាបទន្លេមេគង្គនៃប្រទេសកម្ពុជា និងដែនដីសណ្តរនៃតំបន់មេគង្គវៀតណាម»
- បានរៀបចំសិក្ខាសាលា ស្តីពីការកំណត់អនុវិស័យអាទិភាព នៃគម្រោងវាយតម្លៃតម្រូវការបច្ចេកវិទ្យានិងផែនការសកម្មភាព គាំទ្រដល់ការប្រើប្រាស់បច្ចេកវិទ្យាមេត្រីភាពបរិស្ថានក្នុងតំបន់សេដ្ឋកិច្ចពិសេស នៅខេត្តព្រះសីហនុ

- សិក្ខាសាលា Closing Workshop of the South East Asian Network for Enhancing Climate Transparency Confirmation ដែលរៀបចំដោយ UNEP DTU Partnership
- សិក្ខាសាលារួមគ្នា ដើម្បីប្រកាសដាក់ដំណើរការគម្រោង Blue Action Fund (BAF)។

៤. សិក្ខាសាលាជាមួយអន្តរក្រសួង ចំនួន៧ លើក

- ចូលរួមសិក្ខាសាលា ស្តីពីសំបបទ និងនីតិវិធីនៃការវាយតម្លៃទទួលស្គាល់ មន្ទីរពិសោធន៍ អនុលោម តាមស្តង់ដារអន្តរជាតិ ISO/IEC 1705:2017 រៀបចំដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ និងនវានុវត្តន៍
- បានចូលរួមសិក្ខាសាលា ស្តីពីការរៀបចំការសិក្សារយៈពេលបំពេញបែបបទបញ្ចេញទំនិញ ពីគយ ឆ្នាំ២០២១ ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត គុណ ញឹម រដ្ឋមន្ត្រីប្រតិភូអម នាយករដ្ឋមន្ត្រី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- បានចូលរួមសិក្ខាសាលា ស្តីពីក្រមសីលធម៌ស្រាវជ្រាវ រៀបចំដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានចូលរួមសិក្ខាសាលា ស្តីពីការរៀបចំកម្មវិធីស្រាវជ្រាវជាតិ ដែលរៀបចំដោយក្រសួង ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ចូលរួមកិច្ចប្រជុំសិក្ខាសាលាផ្សព្វផ្សាយអនុក្រឹត្យលេខ១៦៨អនក្រ.បក ជាមួយក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមកិច្ចសិក្ខាសាលា ស្តីពីការត្រួតពិនិត្យនិងវាយតម្លៃ រៀបចំដោយក្រសួងផែនការ
- បានចូលសិក្ខាសាលា ពិគ្រោះយោបល់អន្តរក្រសួងនិងដៃគូពាក់ព័ន្ធ ដើម្បីប្រមូលធាតុចូល លើសេចក្តីព្រាងច្បាប់ ស្តីពីកិច្ចការពារកុមារនៃព្រះរាជាណាចក្រកម្ពុជាដែលរៀបចំដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

គ. វគ្គបណ្តុះបណ្តាល ចំនួន ៣១លើក

- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់កម្មវិធី (Software) សម្រាប់ការពិនិត្យនិង ផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ចំនួន ១វគ្គ
- បានចូលរួមវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ ស្តីពីការចែករំលែកព័ត៌មានប្រព័ន្ធ អង្កេតតាមដានហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ទន្លេមេគង្គ ក្នុងគោលបំណង ប្រើប្រាស់ ឧបករណ៍ MIT ដើម្បីទទួលបានទិន្នន័យក្នុងតំបន់មេគង្គ ក្នុងការចែករំលែកទៅក្រសួង ស្ថាប័ននៅកម្ពុជា
- បានចូលរួមវគ្គបណ្តុះបណ្តាលបច្ចេកទេស ក្នុងប្រទេសចំនួន៤វគ្គ៖ Forest Inventory ២វគ្គ Law Enforcement ១វគ្គ និងការបកស្រាយគម្របព្រៃឈើ (Google Earth Engine) ១វគ្គ និងបានបញ្ជូនមន្ត្រីទៅសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅក្រៅប្រទេស ចំនួន ០១រូប (AIT, Thailand)
- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការបង្ហាញពីគោលការណ៍ និងដំណើរការឧបករណ៍ Compact IC Flex 930 ជាមួយក្រុមហ៊ុន Dynamic ក្រុមហ៊ុន Metrohm នៅប្រទេសថៃ

- ចូលរួមវគ្គបណ្តុះបណ្តាលបំប៉នបន្ថែម ស្តីពី គន្លឹះថ្មីៗនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានមូលដ្ឋាន និងការប្រើប្រាស់ប្រព័ន្ធ FMIS
- ចូលរួមវគ្គបណ្តុះបណ្តាលបច្ចេកទេស ស្តីពីការជំរុញ ការប្រមូលចំណូល និងការប្រើប្រាស់មូលនិធិបរិស្ថាន និងសង្គម
- វគ្គបណ្តុះបណ្តាល ស្តីពី "Climate related Loss and Damage with Climate Risk Management " ដែលរៀបចំឡើងដោយ GIZ និង ADPC (មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី ប្រទេសថៃ)
- វគ្គបណ្តុះបណ្តាល ស្តីពី "ការកំណត់អត្តសញ្ញាណសត្វស្លាប ច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងបទល្មើសសត្វស្លាបក្នុងតំបន់ការពារធម្មជាតិ"
- វគ្គបណ្តុះបណ្តាល ស្តីពីសវនកម្មលើគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងតាមប្រព័ន្ធគណនេយ្យកុំព្យូទ័រ លើគម្រោងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ចំនួន ២វគ្គ
- រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការពង្រឹងសមត្ថភាពអប់រំបរិស្ថាននៅថ្នាក់ក្រោមជាតិ ដឹកនាំដោយ ឯកឧត្តម ជួប ប៉ារីស៍ អគ្គនាយកចំណេះដឹង និងព័ត៌មានបរិស្ថាន ចំនួន ០៣លើក
- រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការបំពុលបរិស្ថាន និងការប្រែប្រួលអាកាសធាតុរយៈពេល ០២ថ្ងៃ ចាប់ពីថ្ងៃទី២០-២១ ខែសីហា ឆ្នាំ២០២១ នៅវិទ្យាល័យពេជ្រចិន្តា ខេត្តបាត់ដំបង
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី Waste Management and Countermeasures Against Marine Litter
- ចូលបានចូលរួមសិក្ខាសាលា ស្តីពីការរៀបចំសិក្សារយៈពេលបំពេញបែបបទបញ្ចេញទំនិញឆ្នាំ២០២១ (Time Release Study 2021)
- បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីប្រសិទ្ធភាពនៃការរៀបចំផែនការថវិកា និងការអនុវត្តថវិកា បទពិសោធន៍ប្រទេសសិង្ហបុរី បង្រៀនដោយសកលវិទ្យាល័យលីក្វាន់យូ
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី «ការអប់រំបរិស្ថាន» ចំនួន ២វគ្គ តាមរយៈការអនុវត្តគម្រោង «ការសម្រេចឱ្យបាននូវបរិស្ថានរស់នៅប្រកបដោយចីរភាពរបស់ប្រជាពលរដ្ឋ តាមរយៈការលើកកម្ពស់និងការអប់រំការយល់ដឹងអំពីបរិស្ថាន» របស់អង្គការ អិន ស៊ី អ (NCR) ជប៉ុន
- បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការពង្រឹងសមត្ថភាពអប់រំបរិស្ថាន នៅថ្នាក់ក្រោមជាតិ
- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការរៀបចំនិងកែលម្អបរិស្ថានអង្គភាព ដែលជាលក្ខណៈវិនិច្ឆ័យគោលទី៥ ក្នុងចំណោមលក្ខណៈវិនិច្ឆ័យគោលទាំង៨ នៃឯកសារគោលការណ៍ការវាយតម្លៃ និងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ
- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីស្ថិតិ ដែលរៀបចំដោយវិទ្យាស្ថានស្ថិតិនៃក្រសួងផែនការ
- បានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពីភាពជាអ្នកដឹកនាំសម្រាប់សមភាពយេនឌ័រក្នុងការគ្រប់គ្រងធនធានធម្មជាតិ រៀបចំដោយក្រុមការងារយេនឌ័រក្រសួងបរិស្ថាន

- បានចូលរួមវគ្គបណ្តុះបណ្តាល តាមរយៈប្រព័ន្ធ Zoom ស្តីពីស្ថិតិ ដែលរៀបចំដោយវិទ្យាស្ថានស្ថិតិ នៃក្រសួងផែនការ
- បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពី«ការលើកកម្ពស់សមភាពយេនឌ័រនិងបរិយាបន្នពិការភាព» ដែលរៀបចំដោយក្រសួងកិច្ចការនារី តាមរយៈប្រព័ន្ធបញ្ជូនរូបភាព និងសម្លេង
- ចូលរួមវគ្គបណ្តុះបណ្តាលតាមរយៈប្រព័ន្ធអនឡាញ ស្តីពីការធ្វើបច្ចុប្បន្នភាពទិន្នន័យមន្ត្រីរាជការក្រសួងបរិស្ថានចំនួន១វគ្គ
- បានចូលរួមវគ្គបណ្តុះបណ្តាលបច្ចេកទេស ចំនួន៤វគ្គ៖ Forest Inventory ចំនួន២វគ្គ Law Enforcement ១វគ្គ និងការបកស្រាយគម្របព្រៃឈើ (Google Earth Engine) ១វគ្គ
- ចូលរួមក្នុងវគ្គបណ្តុះបណ្តាល ស្តីពី «ការរៀបចំ និងកែលម្អបរិស្ថានអង្គភាព» ដែលជាលក្ខណៈវិនិច្ឆ័យគោលទី៥ ក្នុងចំណោមលក្ខណៈវិនិច្ឆ័យគោលទាំង៨ នៃឯកសារគោលការណ៍ការវាយតម្លៃ និងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ
- បានបញ្ជូនសវនករចូលរួមវគ្គបណ្តុះបណ្តាលនៅសាលាភូមិន្ទរដ្ឋបាលចំនួន២វគ្គ (វគ្គវិក្រឹត្យការមន្ត្រីគ្រប់គ្រងរដ្ឋបាលនិងវគ្គបណ្តុះបណ្តាលលើជំនាញរដ្ឋបាលទូទៅរីមជ្ឈការវិសហមជ្ឈការភាពជាអ្នកដឹកនាំអង្គភាព ការងារគ្រប់គ្រងបុគ្គលិក ហិរញ្ញវត្ថុ កំណែទម្រង់រដ្ឋបាលសាធារណៈទំនាក់ទំនងសាធារណៈ ប្រព័ន្ធគ្រប់គ្រងនយោបាយ)
- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី សវនកម្មលើគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ រៀបចំដោយអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន១វគ្គ
- ចាត់បញ្ជូនមន្ត្រីចំនួន២រូប ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំសន្តិសុខស្បៀង (Building Food security) នៅមជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការកម្ពុជាសិង្ហបុរី
- ចាត់បញ្ជូនមន្ត្រីរាជការចំនួន៣រូប ដើម្បីចូលរួមសិក្សាវគ្គបណ្តុះបណ្តាលបន្តក្នុងឆ្នាំ២០២១ សម្រាប់វគ្គវិក្រឹតការ មន្ត្រីគ្រប់គ្រងរដ្ឋបាលនៅសាលាភូមិន្ទរដ្ឋបាល
- ចាត់បញ្ជូនមន្ត្រីចំនួន១៣រូប ដើម្បីចូលរួមវគ្គបណ្តុះបណ្តាល រៀបចំដោយភាគីថៃ
- ចាត់បញ្ជូនលិខិតស្នើសុំកំណត់ទុតជូនមន្ត្រីរាជការចំនួន០១នាក់ ដើម្បីដាក់ពាក្យចូលរួមវគ្គបណ្តុះបណ្តាលស្តីពី Solid waste management
- មន្ត្រីចំនួន២៥រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីជំនាញការទូតនិងទំនាក់ទំនងអន្តរជាតិ
- មន្ត្រីចំនួន២រូប ចូលរួមវគ្គបណ្តុះបណ្តាល ភាសាអង់គ្លេស និងទំនាក់ទំនងកម្រិតមធ្យម។

## III. បញ្ហាប្រឈម

- ការរៀបចំសូចនាករ និងគោលដៅសូចនាករនៃផែនការយុទ្ធសាស្ត្រ និងផែនការថវិកាឆ្នាំមិនស៊ីចង្វាក់គ្នា
- សង្គតិភាពនៃការរៀបចំថវិកា និងការអនុវត្តថវិកានៅមានកម្រិត ដែលនាំឱ្យអង្គភាពថវិកាជួបការលំបាកក្នុងការទូទាត់ចំណាយ៖ ប្រព័ន្ធ យន្តការ ក្របខណ្ឌគតិយុត្ត និងក្រុមការងារថវិកានៃអង្គភាពថវិកាជាកត្តាត្រូវពង្រឹងបន្ថែម

- សកម្មភាពមួយចំនួនមិនអាចអនុវត្តបានទៅតាមផែនការ ដែលបានគ្រោងទុកដោយសារបញ្ហាការរីករាលដាលនៃជំងឺកូវីដ-១៩
- សមត្ថភាពជំនាញរបស់មន្ត្រីនៅមានកម្រិត ជាពិសេសផ្នែកស្រាវជ្រាវ វិភាគទិន្នន័យ រៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការ និងសំណើគម្រោង
- កិច្ចសហប្រតិបត្តិការ និងការគាំទ្រធនធានពីដៃគូអភិវឌ្ឍន៍នៅមានកម្រិត និងមិនអាចព្យាករបានច្បាស់លាស់
- មិនទាន់មានឧបករណ៍ផ្ទុកទិន្នន័យឱ្យមានសុវត្ថិភាព (Data Storage)
- បញ្ហាថវិកាកម្មវិធី ឆ្នាំ២០២១ ត្រូវបានធ្វើវិចារណកម្មថវិកាលើអនុគណនីមួយចំនួន
- កិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិនៅមានកម្រិត
- សមត្ថភាពមន្ត្រី និងស្វ័យអភិវឌ្ឍន៍សមត្ថភាពជំនាញនៅមានកម្រិត
- ខ្វះមធ្យោបាយធ្វើដំណើរ និងស្ថានភាពផ្លូវទៅតាមសហគមន៍តំបន់ការពារធម្មជាតិមួយចំនួនមានការលំបាក ពិសេសនៅរដូវវស្សា ដែលធ្វើឱ្យមានការយឺតយ៉ាវដល់ការងារអភិវឌ្ឍន៍សហគមន៍
- សហគមន៍តំបន់ការពារធម្មជាតិមួយចំនួនបាត់បង់ភាពជាម្ចាស់ ឬអសកម្មដោយខ្វះខាតថវិកាសម្រាប់ទ្រទ្រង់សកម្មភាព
- មានការលួចកាប់ឈើពីអ្នកខាងក្រៅ និងខាងក្នុង ជាពិសេសការកាប់ដើមជ័រទឹកនិងប្រភេទឈើសំណង់ ការបរបាញ់សត្វនៅក្នុងតំបន់ការពារធម្មជាតិ និងក្បែរតំបន់ព្រៃសហគមន៍តំបន់ការពារធម្មជាតិ
- សហគមន៍តំបន់ការពារធម្មជាតិភាគច្រើន មិនទាន់បានអនុវត្តលក្ខន្តិកៈពេញលេញ
- គម្រោងអភិវឌ្ឍទេសចរណ៍ធម្មជាតិក្រោម១០ហិកតាមួយចំនួនធំ ដែលបានទទួលលិខិតអនុញ្ញាតជាគោលការណ៍ពីក្រសួងបរិស្ថាន មានដំណើរការល្អ តែនីតិវិធីមួយចំនួនដូចជា កិច្ចសន្យា សិទ្ធិប្រទាន និងការធ្វើអនុប្រយោគ មានការលំបាកដែលរាំងស្ទះដល់ការអនុវត្តគម្រោងទេសចរណ៍ធម្មជាតិខ្នាតតូចនេះឱ្យទទួលបានជោគជ័យ
- ធនធានមនុស្សនៅមានកម្រិត ទាំងចំនួននិងចំណេះដឹងក្នុងការរៀបចំវិភាគទិន្នន័យព័ត៌មានឱ្យបានទូលំទូលាយនិងស៊ីជម្រៅ បច្ចេកទេសផ្នែករចនានិងបរិយាយលើការរចនាប្រភេទរង្វាន់មេត្រីភាពបរិស្ថាន ជំនាញសម្រាប់ការងារផ្នែករដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ ព្រមទាំងជំនាញច្បាប់
- ឧបករណ៍បច្ចេកទេសសម្រាប់ថត និងផលិតព័ត៌មានជាវីដេអូឯកសារ នៅខ្វះខាតមិនទាន់បម្រើការផលិតព័ត៌មានឱ្យទាន់ពេលវេលា និងសមស្របតាមបច្ចេកទេសថ្មី
- ឧបករណ៍បច្ចេកទេស និងសម្ភារបរិក្ខារផ្សេងៗ នៅពុំទាន់គ្រប់គ្រាន់ទៅតាមតម្រូវការ និងការបំពេញការងារនៅតាមនាយកដ្ឋានជំនាញនៅឡើយ
- មន្ត្រីឧទ្យានុរក្សមានចំនួនតិចបើប្រៀបធៀបទៅនឹងទំហំផ្ទៃដីតំបន់ការពារធម្មជាតិដែលត្រូវការពារ អភិរក្ស និងល្បាតជាប្រចាំ
- បទល្មើសធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិនៅតែបន្តកើតមាន
- សកម្មភាពទន្ទ្រានដីព្រៃ និងការទិញលក់ដីតំបន់ការពារធម្មជាតិនៅតែបន្តកើតមាន

- បញ្ហាស្មុគស្មាញ អំពីការប្រើប្រាស់ដី ដែលទាមទារឱ្យមានការចុះប្រមូលនិងសិក្សាពីដីអាស្រ័យផលយូរឆ្នាំ និងដីទន្រ្ទានថ្មី ដើម្បីធ្វើបច្ចុប្បន្នទិន្នន័យការប្រើប្រាស់ដីក្នុងតំបន់ការពារធម្មជាតិ
- តំបន់ការពារធម្មជាតិភាគច្រើន ពុំទាន់បានបោះបង្គោលព្រំប្រទល់តំបន់ការពារធម្មជាតិដែលត្រូវជំរុញឱ្យមានការបោះបង្គោលព្រំប្រទល់តំបន់ការពារធម្មជាតិជាចាំបាច់
- ការគ្រប់គ្រងទិន្នន័យធនធានធម្មជាតិ និងទិន្នន័យព័ត៌មានភូមិសាស្ត្រតំបន់ការពារធម្មជាតិនៅពុំទាន់ធ្វើលក្ខណៈទំនើបស្របតាមបរិបទ និងការវិវឌ្ឍនៃបច្ចេកវិទ្យា។

## IV. ទិសដៅការងារឆ្នាំ២០២២

- បន្តសម្របសម្រួលការងារផ្តល់សេវាសាធារណៈច្រកចេញ-ចូលតែមួយ ឱ្យមានតម្លាភាព និងគណនេយ្យភាព
- រៀបចំវគ្គបណ្តុះបណ្តាលជូនមន្ត្រីរាជការ នៅសាលាភូមិន្ទរដ្ឋបាល វិទ្យាស្ថានការទូតនិងទំនាក់ទំនងអន្តរជាតិ និងសាលានាយទាហានសកម្ម
- បន្តរៀបចំផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំរំកិល ២០២៣-២០២៥ និងផែនការថវិកាឆ្នាំ២០២៣
- បន្តពង្រឹងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(NRMIS) ដល់មន្ត្រី
- បន្តកៀរគរការគាំទ្រពីប្រទេសម្ចាស់ជំនួយដៃគូអភិវឌ្ឍន៍ និងស្ថាប័នពាក់ព័ន្ធនានា ដើម្បីជំរុញការអនុវត្តការងារស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- បន្តអនុវត្តអនុស្សរណៈនៃការយោគយល់ លើកិច្ចសហប្រតិបត្តិការក្នុងការប្រើប្រាស់ថាមពលនុយក្លេអ៊ែរសម្រាប់បម្រើឱ្យគោលបំណងសន្តិភាពជាមួយភាគីរុស្ស៊ី និងភាគីចិន
- រៀបចំការសិក្សាគំរូអាជីវកម្ម សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកែច្នៃសំណល់ទៅជាថាមពល (Refuse-derived fuel: RDF) សម្រាប់ឡដុតឥដ្ឋ នៅរាជធានីភ្នំពេញ
- រៀបចំគោលនយោបាយដើម្បីជំរុញវិស័យឯកជនវិនិយោគ លើថាមពលនិរន្តរភាពនៅក្នុងវិស័យវាយនភ័ណ្ឌនៅកម្ពុជា
- រៀបចំវគ្គបណ្តុះបណ្តាលទាក់ទងនឹង វិធាននិងវិធីសាស្ត្រវិភាគផលចំណេញ ថ្លៃខូចខាតបរិស្ថានចេញពីគម្រោងអភិវឌ្ឍន៍ថាមពល
- ធ្វើបច្ចុប្បន្នភាពទិន្នន័យជីវៈចម្រុះ និងដាក់ឱ្យដំណើរការប្រព័ន្ធទិន្នន័យជីវៈចម្រុះថ្នាក់ជាតិ
- បន្តសម្របសម្រួលក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូននៅកម្ពុជា
- បន្តរៀបចំលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេស ពាក់ព័ន្ធនឹងគុណភាពទឹក ខ្យល់ សំឡេងនិងរំញ័រ
- គ្រប់គ្រងទិន្នន័យគុណភាពទឹក គុណភាពខ្យល់ និងធ្វើបច្ចុប្បន្នភាពសំរាម សំណល់រឹងទីប្រជុំជន សំណល់ប្លាស្ទិក និងការកែច្នៃសំណល់ (រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)
- បន្តពង្រឹងការងារចុះអធិការកិច្ច ដោះស្រាយបណ្តឹងការបំពុលបរិស្ថាន និងចុះតាមដានការអនុវត្តផែនការគ្រប់គ្រងបរិស្ថានដែលកំណត់ក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- បន្តសិក្សាវិភាគរកសារធាតុគ្រោះថ្នាក់លោហៈធ្ងន់ នៅក្នុងផលិតផលគ្រឿងសម្អាងថ្មីៗ ដែលដាក់លក់តាមប្រព័ន្ធ online

- ជំរុញប្រភពដែលមានសក្តានុពលបំពុលបរិស្ថានខ្លាំង អនុវត្តវិធានការស្វ័យត្រួតពិនិត្យ និងស្វ័យរាយការណ៍ ពីការបំពុលបរិស្ថានស្របតាមលិខិតបទដ្ឋានគតិយុត្ត
- បង្កើនចំនួនឧទ្យានុរក្ស សម្រាប់ពង្រឹងការល្បាតក្នុងតំបន់ការពារធម្មជាតិ
- បង្កើនវគ្គបណ្តុះបណ្តាលដល់ឧទ្យានុរក្ស ដើម្បីពង្រឹងសមត្ថភាពក្នុងការល្បាត និងឆ្លើយតបនឹងបទល្មើសធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ
- បន្តធ្វើបច្ចុប្បន្នភាពទិន្នន័យ ពីការប្រើប្រាស់ដីក្នុងតំបន់ការពារធម្មជាតិជាប្រចាំ ដើម្បីផ្តល់ភាពងាយស្រួលក្នុងការគ្រប់គ្រង និងការចុះបញ្ជីដីសាធារណៈរបស់រដ្ឋ
- ស្នើសុំថវិកាមូលនិធិបរិស្ថានបន្ថែមទៀត ក្នុងការជំរុញការងារបោះបង្គោលព្រំតំបន់ការពារធម្មជាតិ និងការកំណត់តំបន់ការពារធម្មជាតិថ្មីៗទៀត
- ជំរុញ និងបន្តការចុះបញ្ជីដីសាធារណៈរបស់រដ្ឋ ការកំណត់បែងចែកតំបន់គ្រប់គ្រង និងបោះបង្គោលព្រំឱ្យបានគ្រប់តំបន់ការពារធម្មជាតិ
- ធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យធនធានធម្មជាតិ និងទិន្នន័យព័ត៌មានភូមិសាស្ត្រតំបន់ការពារធម្មជាតិ តាមបែបប្រព័ន្ធឌីជីថល
- សិក្សាពីលទ្ធភាពក្នុងការទាក់ទាញដៃគូវិនិយោគ លើការអភិវឌ្ឍទេសចរណ៍ធម្មជាតិក្នុងតំបន់ការពារធម្មជាតិ ដែលអាចលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋាន និងការងារអភិរក្ស
- ជំរុញ និងសិក្សាពីលទ្ធភាពក្នុងការរៀបចំបញ្ជី ឬចំណាត់ថ្នាក់ប្រភេទសត្វព្រៃសម្រាប់ការអភិរក្សថ្នាក់ជាតិ ដើម្បីឱ្យស្របតាមស្ថានភាព និងរបាយជីវចម្រុះជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា
- បន្តពិនិត្យ និងធ្វើបច្ចុប្បន្នភាពទៅលើបញ្ជីសហគមន៍តំបន់ការពារធម្មជាតិ និងផែនការគ្រប់គ្រងសហគមន៍ និងបន្តធ្វើការសិក្សារៀបចំសហគមន៍ថ្មីៗ នៅក្នុងតំបន់ការពារធម្មជាតិទើបបង្កើតថ្មីៗ និងរបៀងអភិរក្សជីវចម្រុះ ឱ្យទៅជាសហគមន៍តំបន់ការពារធម្មជាតិ
- រៀបចំទីផ្សារសហគមន៍មូលដ្ឋាន ដើម្បីផ្តល់លទ្ធភាពជូនសហគមន៍លក់និងចែកចាយផលិតផលដល់ទីប្រជុំជន និងជំរុញការធ្វើសមាហរណកម្មផែនការសកម្មភាពនៅក្នុងផែនការគ្រប់គ្រងសហគមន៍ ទៅក្នុងផែនការវិនិយោគឃុំ/សង្កាត់ដែលពាក់ព័ន្ធ
- បន្តផ្តល់ពូជគោ ជ្រូក មាន់ ដល់សហគមន៍តំបន់ការពារធម្មជាតិ និងបន្តរៀបចំស្ថានីយបន្សុទ្ធពូជសត្វក្នុងស្រុកនៅខេត្តពោធិ៍សាត់
- បន្តសិក្សាពីប្រពៃណីទំនៀមទម្លាប់ សហគមន៍មូលដ្ឋាន(ជនជាតិដើមភាគតិច) និងរៀបចំចងក្រងឯកសារអត្តសញ្ញាណ អភិរក្សវប្បធម៌សហគមន៍ជនជាតិដើមភាគតិច ដែលរស់នៅក្នុង និងក្បែរតំបន់ការពារធម្មជាតិ
- បន្តកិច្ចសហការជាមួយអង្គការយូណេស្កូ(UNESCO)ប្រចាំនៅកម្ពុជា ក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ និងជំនាញ ដើម្បីជំរុញដំណើរការ និងនីតិវិធីបំពេញឯកសារស្នើសុំដាក់បញ្ចូលតំបន់បេតិកភណ្ឌធម្មជាតិ«ភ្នំត្បែង» ខេត្តព្រះវិហារ ក្នុងបញ្ជីត្រៀមបេតិកភណ្ឌពិភពលោករបស់អង្គការ UNESCO (World Heritage Tentative List)
- បន្តជំរុញ សហការ និងសម្របសម្រួលជាមួយមន្ទីរជំនាញ-អង្គភាពពាក់ព័ន្ធ និងអង្គការដៃគូ ដើម្បីកសាងសមត្ថភាព តាមរយៈវគ្គបណ្តុះបណ្តាល ស្តីពី«ការគ្រប់គ្រងបេតិកភណ្ឌធម្មជាតិ-វប្បធម៌» ដល់អាជ្ញាធរមូលដ្ឋាន មន្ត្រីឧទ្យានុរក្ស និងអ្នកពាក់ព័ន្ធ

- បោះពុម្ព និងផ្សព្វផ្សាយសៀវភៅវាយតម្លៃធនធានគម្របព្រៃឈើកម្ពុជា ឆ្នាំ២០២០ រៀបចំផលិតផែនទីបច្ចុប្បន្នភាពគម្របព្រៃឈើឆ្នាំ២០២២
- កសាងសមត្ថភាពមន្ត្រី ដោយរៀបចំវគ្គបណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ និងវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសធ្វើសារពើភ័ណ្ឌព្រៃឈើសម្រាប់រេដបូក
- ជ្រើសរើស និងផ្តល់ជ័យលាភីសាលាមេត្រីបរិស្ថានថ្នាក់ជាតិ និងបន្តទៅចូលរួមប្រឡងប្រណាំងសាលាមេត្រីបរិស្ថានអាស៊ាន
- រៀបចំវេទិកាយុវជនជជែកពិភាក្សាអំពីបរិស្ថានសម្រាប់យុវសិស្សកម្រិតវិទ្យាល័យលើ ៥ខេត្តនៅតំបន់ជុំវិញតំបន់ព្រៃឡង់ និងរាជធានីភ្នំពេញ
- ផលិត និងបោះពុម្ពសម្ភារអប់រំបរិស្ថានផ្សេងៗ ដូចជា posters, sticker, signboard,t-shirt, story book ស្តីពី ការគ្រប់គ្រងសំណល់ និងផលប៉ះពាល់របស់សំណល់ប្លាស្ទិក
- បន្តផ្សព្វផ្សាយព័ត៌មានតាមប្រព័ន្ធវេបសាយ និងបណ្តាញទំនាក់ទំនងសង្គមរបស់ក្រសួង
- បន្តរៀបចំទិវាបរិស្ថានពិភពលោក ៥មិថុនា និងទិវាអនាម័យបរិស្ថានជាតិ ២៣វិច្ឆិកា
- ផលិតវីដេអូឯកសារ វីដេអូអប់រំបរិស្ថាន និងបទចម្រៀងបរិស្ថាន ព្រមទាំងបកប្រែអត្ថបទ និងវីដេអូអប់រំបរិស្ថានសម្រាប់ផ្សព្វផ្សាយក្នុងបណ្តាញសង្គម។

## V. សន្និដ្ឋាន

ក្នុងឆ្នាំ២០២១នេះ បើទោះបីជាមានបញ្ហាប្រឈមមួយចំនួន ជាពិសេសស្ថិតក្នុងកាលៈទេសៈនៃការរីករាលដាលខ្លាំងក្លានៃជំងឺកូវីដ-១៩ក៏ដោយ ក៏ក្រសួងបរិស្ថានបានខិតខំបំពេញការងារ និងសម្រេចបាននូវបណ្តាភារកិច្ចស្នូលដូចជា៖ ការងារគ្រប់គ្រងធនធានមនុស្ស ការរៀបចំគោលនយោបាយបរិស្ថាននិងផែនការយុទ្ធសាស្ត្រនានា ការសិក្សាស្រាវជ្រាវ ការពង្រឹងកិច្ចសហការប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ការតាមដានគុណភាពទឹកនិងខ្យល់សាធារណៈ ការពង្រឹងការគ្រប់គ្រងសំណល់រឹងទីប្រជុំជន ការទប់ស្កាត់និងបង្ក្រាបបទល្មើសធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ ការអប់រំផ្សព្វផ្សាយការងារបរិស្ថាន និងការរៀបចំកិច្ចប្រជុំ សិក្ខាសាលានិងវគ្គបណ្តុះបណ្តាលនានា តាមរយៈប្រព័ន្ធអនឡាញ ។ លទ្ធផលទាំងនេះ បានឆ្លុះបញ្ចាំងនិងសម្រេចបាននូវទិសដៅការងារចម្បងៗដែលបានដាក់ចេញនាឆ្នាំ២០២១កន្លងមកស្របតាមស្មារតីនៃ «**សន្និបាតបូកសរុបលទ្ធផលការងារបរិស្ថានឆ្នាំ២០២០និងលើកទិសដៅការងារឆ្នាំ២០២១**» ៕

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

# ឧបសម្ព័ន្ធទី៧

# ឯកសារពាក់ព័ន្ធ នឹងលិខិតអនុញ្ញាត

# ការចុះស្រាវជ្រាវ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

នាយកដ្ឋានធនធានមនុស្ស
លេខ ១៦០
ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០២២
ម៉ោង ១០:៣០

**ក្រសួងបរិស្ថាន**
**អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ**
**នាយកដ្ឋានធនធានមនុស្ស**

លិខិតលេខ ៖ ៦១៦ សាគភ.វគរ ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០២២
របស់ ៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
ខ្លឹមសារ ៖ សំណើសុំអនុញ្ញាតឱ្យនិស្សិតចំនួន ០២ រូប ចុះស្រាវជ្រាវឯកសារ

| មតិយោបល់ | ជ្រាប | ឯកភាព | អនុញ្ញាត | ចាត់ការ | ស្នើសុំគោលការណ៍ | ស្នើសុំមតិយោបល់ | ពិនិត្យ និងសម្រេច | យល់ព្រម | ហត្ថលេខា |
|---|---|---|---|---|---|---|---|---|---|
| ១. ការិយាល័យរដ្ឋបាល | | | | ✓ | | | | | 23.5.22 [illegible] |
| ២. ការិយាល័យក្របខណ្ឌ | | | | | | | | | |
| ៣. ការិយាល័យបៀវត្ស | | | | | | | | | |
| ៤. ការិយាល័យគ្រឿងឥស្សរិយយស | | | | | | | | | |
| ៥. ការិយាល័យសង្គមកិច្ច និងគាំពារមន្ត្រីរាជការ | | | | | | | | | |
| ៦. ការិយាល័យបណ្តុះបណ្តាល | | | | ✓ | | | | | |
| **អនុប្រធាននាយកដ្ឋានទទួលបន្ទុក** | | | | | | | | | [illegible] 23.5.22 |
| **ប្រធាននាយកដ្ឋាន** | | | | | | | | | [illegible] |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

លិខិតលេខ ៖ ៦១៦ សកនវស ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០២២

ក្រសួងបរិស្ថាន
ចូល
លេខ 3525
ថ្ងៃ 1 ខែ 05 ឆ្នាំ 22
ម៉ោង 4:30

៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

ខ្លឹមសារ ៖ សំណើសុំអនុញ្ញាតឱ្យនិស្សិតចំនួន ០២រូប ចុះស្រាវជ្រាវឯកសារ។

Chenda

## មតិនាយកដ្ឋានរដ្ឋបាល

សូមគោរពជូន

ឯកឧត្តមអគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ មេត្តាពិនិត្យ និងសម្រេច

16.05.22

## មតិអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ

## មតិរដ្ឋ-អនុរដ្ឋលេខាធិការទទួលបន្ទុក

18/5/22

## យោបល់សម្រេចឯកឧត្តមរដ្ឋមន្ត្រី

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

លេខ..៦២៦......ស.ភ.ន.វ.ស

ក្រសួងបរិស្ថាន
ចូល លេខ 3525
ថ្ងៃទី 16 ខែ 05 ឆ្នាំ២០22
ម៉ោង 4 : 30

**សូមគោរពជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**កម្មវត្ថុ៖** សំណើសុំអនុញ្ញាតឱ្យនិស្សិតចំនួន០២រូប ចុះស្រាវជ្រាវឯកសារ។

**យោង៖** សំណើរបស់សាមីនិស្សិតចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២២។

តបតាមកម្មវត្ថុ និងយោងខាងលើខ្ញុំសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចបាន និងកំពុងបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ។ អំឡុងពេលសិក្សាឆ្នាំបញ្ចប់និស្សិតយើងខ្ញុំចំនួន០២រូប ដូចមានបញ្ជីរាយនាមជូនភ្ជាប់មកជាមួយនេះ ត្រូវចុះស្រាវជ្រាវឯកសារ និងស្វែងយល់ពីការងារមួយចំនួនដែលទាក់ទងនឹងប្រធានបទស្តីពី «**ការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងបរិស្ថាន**» នៅក្រសួងបរិស្ថាន ចាប់ពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២ ដើម្បីសរសេរសារណា និងការពារបញ្ចប់ការសិក្សារបស់ខ្លួន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យលទ្ធភាពអនុញ្ញាតឱ្យនិស្សិតយើងខ្ញុំបានចុះស្រាវជ្រាវឯកសារដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវគារវកិច្ចដ៏ស្មោះពីខ្ញុំ

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២

**សាកលវិទ្យាធិការ**

**បណ្ឌិត លុយ ចណ្ណា**

Monivong Blvd, Sangkat Tonle Bassac, Khan Chamkamon, Phnom Penh, Cambodia.
P.O. Box 842, Tel: (855) 23 214 703, Fax: (855) 23 214 953, E-mail: rector@rule.edu.kh, website: www.rule.edu.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## បញ្ជីរាយនាម
## និស្សិតថ្នាក់បរិញ្ញាបត្រ រដ្ឋបាលសាធារណៈ
## ឆ្នាំទី៤ ជំនាន់ទី១៥ ក្រុមP4C5 ឆ្នាំសិក្សា២០២១-២០២២
## ដែលត្រូវចុះស្រាវជ្រាវឯកសារ នៅក្រសួងបរិស្ថាន

| ល.រ | គោត្តនាម-នាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | លេខទូរស័ព្ទ | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | ជ័រ ស្រីណយ | ស្រី | ២៣-កុម្ភៈ-២០០០ | ០១៥ ៧៩ ៧៤ ៧៦ | |
| ២ | ភាព បូផា | ស្រី | ១៩-សីហា-១៩៩៩ | ០៩៦ ៧៨ ០៧ ១៣៩ | |

ថ្ងៃចន្ទ ៩កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២២
**ប្រធានការិយាល័យស្រាវជ្រាវ**

ញឹក_ឧុត្តី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យសុំអនុញ្ញាតចុះស្រាវជ្រាវឯកសារ

យើងខ្ញុំឈ្មោះ **ជ័រ ស្រីណយ** និងឈ្មោះ **ភាព បូផា** ជានិស្សិតថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ ឆ្នាំទី៤ ជំនាន់១៥ ក្រុមP4C5 ឆ្នាំសិក្សា២០២១-២០២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមគោរពជូន**

**ឯកឧត្តមសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**

**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**កម្មវត្ថុ៖** សំណើសុំអនុញ្ញាតចុះស្រាវជ្រាវឯកសារ។

តាមកម្មវត្ថុខាងលើ យើងខ្ញុំមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តម** មេត្តាជ្រាបថា បន្ទាប់ពីបានធ្វើការសិក្សាផ្នែកទ្រឹស្តី យើងខ្ញុំត្រូវសរសេរសារណា និងការពារបញ្ចប់ការសិក្សាដែលទាក់ទងនឹងប្រធានបទស្តីពី « **ការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងបរិស្ថាន** » ដោយត្រូវចុះស្រាវជ្រាវឯកសារ នៅក្រសួងបរិស្ថាន ចាប់ពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២។

អាស្រ័យហេតុនេះ សូម ឯកឧត្តម មេត្តាអនុញ្ញាតឱ្យយើងខ្ញុំបានចុះស្រាវជ្រាវឯកសារដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ថ្ងៃចន្ទ ៩កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២២

ហត្ថលេខា

ភាព បូផា    ជ័រ ស្រីណយ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
លេខ:......៦៦៧.............អរហ.ប.ស្ថ

# លិខិតបញ្ជាក់កម្មសិក្សា

សូមបញ្ជាក់ថា កញ្ញា **ភាព មុនា** និង កញ្ញា **ជ័រ ស្រីណាយ** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែករដ្ឋបាលសាធារណៈ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ពិតជាបានចុះបំពេញកម្មសិក្សានៅនាយកដ្ឋានធនធានមនុស្ស នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងបរិស្ថាន ចាប់ពីថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០២២ ដើម្បីដកស្រង់បទពិសោធន៍ ស្វែងយល់ ពីដំណើរការប្រព្រឹត្តទៅរបស់ក្រសួង និងសកម្មភាពអនុវត្តការងារជាក់ស្តែងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ឧស្សាហ៍ព្យាយាម និងគោរពវិន័យ បទបញ្ជាផ្ទៃក្នុងរបស់ក្រសួងបរិស្ថាន។

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ចេញលិខិតបញ្ជាក់នេះ ដើម្បីឱ្យសាមីខ្លួនយកទៅប្រើប្រាស់តាមការដែលអាចប្រើបាន។

ថ្ងៃពុធ ១៣កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២

**អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ**

**ជ្រិន_សុខា**

ចម្លងជូន៖
-ប្រធានកម្មសិក្សា«ដើម្បីជូនជ្រាប»
-សាមីខ្លួន
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
នាយកដ្ឋានធនធានមនុស្ស
លេខ:...១៥៩.........ធម.ប.ស្ក

## លិខិតបញ្ជាក់កម្មសិក្សា

សូមបញ្ជាក់ថា កញ្ញា **គាត មុផា** និង កញ្ញា **ជ័រ ស្រីណាយ** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែករដ្ឋបាលសាធារណៈ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានចុះកម្មសិក្សា នៅនាយកដ្ឋានធនធានមនុស្ស នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងបរិស្ថាន ចាប់ពីថ្ងៃទី១៦ ខែឧសភា រហូតដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២ ពិតប្រាកដមែន។

កម្មសិក្សារបស់កញ្ញា **គាត មុផា** និងកញ្ញា **ជ័រ ស្រីណាយ** ពិតជាមានភាពត្រឹមត្រូវដោយបានឆ្លុះបញ្ចាំងអំពីទិដ្ឋភាពជាក់ស្តែងស្តីពី «ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងបរិស្ថាន»។ កម្មសិក្សានេះត្រូវបានចងក្រងឡើងដោយមានរចនាបថល្អៗ ខ្លឹមសារច្បាស់លាស់ និងអត្ថន័យគ្រប់គ្រាន់ដែលអាចរួមចំណែកជាធាតុចូលថ្មីៗសមជាប្រយោជន៍សម្រាប់ការស្រាវជ្រាវ និងគំនិតយោបល់បន្ថែមសម្រាប់អ្នកសិក្សាក្រោយៗទៀត។

លិខិតបញ្ជាក់នេះ ចេញជូនសាមីខ្លួនយកទៅប្រើប្រាស់តាមការដែលអាចប្រើបាន៕

ថ្ងៃអង្គារ ១២ កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែសីហា ឆ្នាំ២០២២
**អនុប្រធាននាយកដ្ឋានធនធានមនុស្ស**
**និងជាប្រធានកម្មសិក្សា**

**រស់_សុវណ្ណ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
នាយកដ្ឋានធនធានមនុស្ស
លេខៈ...១៥៨.........ធម.ប.ស្ក

# កម្មសិក្សា

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងបរិស្ថាន

ចាប់ពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ ២០២២

ថ្ងៃ ចន្ទ ១១ កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ២០២២
**សិស្សកម្មសិក្សា**

ភាព បូរ៉ា    ងឹន ស្រីណាល

បានពិនិត្យ និងត្រឹមត្រូវ
ថ្ងៃអង្គារ ១២ កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែសីហា ឆ្នាំ២០២២
**អនុប្រធាននាយកដ្ឋានធនធានមនុស្ស**
**និងជាប្រធានកម្មសិក្សា**

**រស់_សុវណ្ណ**

បានពិនិត្យ និងឯកភាព
ថ្ងៃពុធ ១៣ កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០២២
**ប្រធាននាយកដ្ឋានធនធានមនុស្ស**

**ខឹម_សុវណ្ណា**



សាស្ត្រាចារ្យណែនាំ៖ បណ្ឌិត ឈុន ណារ៉េត



ប្រធានកម្មសិក្សា៖ លោក រស់ សុវណ្ណា អនុប្រធាននាយកដ្ឋានធនធានមនុស្ស

